# ខុទ្ទកនិកាយគាថាធម្មបទ

## យមកវគ្គវណ្ណនា

ប្រែ និងរៀបរៀងដោយ ព្រះសុវណ្ណថេរោ ភិក្ខុ **ឈឹម ឆន់**

ព.ស ២៥៤៩

**ខេត្តបាត់ដំបង**

# ខុទ្ទកនិកាយគាថាធម្មបទ

## យមកវគ្គវណ្ណនា

ប្រែ និងរៀបរៀងដោយ ព្រះសុវណ្ណថេរោ ភិក្ខុ **លឹម ធន់**

**ព.ស ២៥៤៩**

**ខេត្តបាត់ដំបង**

# បុព្វកថា

ព្រះសុគតសាស្តា ទ្រង់មានព្រះបន្ទូលដូច្នេះថា ៖

ពួកជនណា ៗ ទោះបីក្មេងក្តី ចាស់ក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅខាងមុខ ។ ភាជនៈដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជនៈទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ ។

ម្នាកភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ ចូររក្សាចិត្តរបស់ខ្លួនឲ្យរឿយ ៗ ចុះ ។

ភិក្ខុណាមិនប្រមាទ ហើយក្នុងធម្មវិន័យនេះ ភិក្ខុនោះនឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបានពុំខានឡើយ... ។

បាត់ដំបង ថ្ងៃទី ១៥ កើត ខែភទ្របទ ព.ស ២៥៤៩

ដោយព្រះសុវណ្ណថេរោ ភិក្ខុ **លឹម ឆន់**

# អ្នកមានឧបការៈក្នុងការងារធម្មទាន

ដោយ សង្ឃបទីបោ ភិក្ខុ ម៉ី សាលួន

ឯកធម្មោ ភិក្ខុ ម៉ែន សឿន

ធម្មធីរោ ភិក្ខុ ឃុន សុខ

វិរិយធម្មោ ភិក្ខុ ម៉ៅ អៀប

មណីជោតោ ភិក្ខុ វ៉ាត់ ចំណាប់

សាមណេរ អគ្គធីរោ ស សត្ថា

សាមណេរ បដិភាណោ អឿង សំអួន

ធម្មចារ្យ ហាយ ចំរើន

ឧបាសក សន ម៉ារឌី

ឧបាសក ហុក សឹងហួត

# អ្នកឧបត្ថម្ភក្នុងការងារធម្មទាន

ឧបាសក ប៉េង តាំងហៃ + ឧបាសិកា ហ៊ុំ គឹមហៀក និងបុត្រ

ឧបាសក ស្ងួន សៀប + ឧបាសិកា ញ៉ឹក ស៊ីថន និងបុត្រ

# ព្រះពុទ្ធសាសនាមានអង្គ ៩

ព្រះពុទ្ធវចនៈ គឺព្រះធម្មវិន័យ ដែលព្រះមានព្រះភាគទ្រង់សម្តែង ប្រកបដោយអង្គ ៩ គឺ ៖

**សុត្តៈ** បានដល់ ព្រះសូត្រទាំងឡាយ មានមង្គលសូត្រជាដើម រួមទាំងព្រះវិន័យបិដក និងនិទ្ទេស ។

**វេយ្យាករណៈ** គឺ ព្រះអភិធម្មបិដក មានព្រះសូត្រដែលមិនមានគាថាលាយ និងព្រះពុទ្ធវចនៈដែលមិនចាត់ចូលក្នុងអង្គ ៨ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះថា សូត្រ ក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះមានព្រះភាគទ្រង់បន្លឺដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តកៈ** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្តើមដោយពាក្យ

ថា *វុត្តំ ហេតំ ភគវា* ( សេចក្ដីនេះសមដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកហើយ ) ។

***ជាតក*** គឺ រឿងអតីតជាតិ របស់ព្រះមានព្រះភាគ និងសាវក មានអបណ្ណកជាតកជាដើម រួម ៥៥០ ជាតក ។

***អព្ភូតធម៌*** គឺ ព្រះសូត្រដែលប្រកបដោយអច្ឆរិយអព្ភូតធម៌ ( ធម៌ដ៏ក្រៃលែងដោយគុណវិសេសដែលគួរអស្ចារ្យ ) ។

***វេទល្ល:*** គឺ ព្រះសូត្រដែលសួរហើយៗបានការត្រាស់ដឹង និងសេចក្ដីត្រេកអរក្រៃលែងឡើងៗ មានចូឡវេទល្លសូត្រជាដើម ។

# សារបណ្ណ

## ព្រះសុត្តន្តបិដក

## ខុទ្ទកនិកាយគាថាធម្មបទ

### គាថាធម្មបទ យមកវគ្គវណ្ណនា ទី ១ មាន ១៤ រឿង

### ១. រឿងព្រះចក្ខុបាលត្ថេរ

កុដុម្ពិកធ្វើពិធីសុំបុត្រ ............................................................ ២
កុដុម្ពិកបានបុត្រពីរនាក់ ............................................................ ២
ព្រះសាស្ដាទ្រង់គង់នៅក្នុងក្រុងសាវត្ថី ២៥ វស្សា ............................................ ៣
អ្នកទំនុកបម្រុងភិក្ខុសាមណេរ ............................................................ ៤
សេដ្ឋីមិនធ្លាប់ទូលសួរបញ្ហា ............................................................ ៥
អ្នកក្រុងសាវត្ថីទៅស្ដាប់ធម៌ ............................................................ ៦
អនុបុព្វីកថា ៥ យ៉ាង ............................................................ ៨
មហាបាលសុំបួស ............................................................ ៨
មហាបាលប្រគល់សម្បត្តិឲ្យប្អូនប្រុស ............................................................ ៩
មហាបាលបព្វជ្ជាឧបសម្បទា ............................................................ ១១
ធុរៈ ២ យ៉ាងក្នុងព្រះសាសនា ............................................................ ១១
ព្រះមហាបាលធ្វើដំណើរទៅកាន់ស្រុកជាយដែន ............................................ ១២
អ្នកស្រុកជ្រះថ្លាអារាធនាឲ្យនៅចាំវស្សា ............................................ ១៣
ព្រះមហាបាលសមាទាននេសជ្ជិកធុតង្គ ............................................ ១៤
ចក្ខុរបស់មហាបាលពិការ ............................................................ ១៦
ពេទ្យផ្សំថ្នាំឲ្យបន្តក់ ............................................................ ១៧

ព្រះមហាបាលអង្គុយបន្តក់ថ្នាំ ........................................ ១៨
ព្រះចក្ខុបាលប្រឹក្សានឹងករជ្ជកាយ ........................................ ១៩
ពេទ្យឈប់ព្យាបាលព្រះមហាបាល ........................................ ២១
ព្រះថេរៈបែកធ្លាយចក្ខុព្រមនឹងការសំរេចព្រះអរហត្ត ........................................ ២២
ពួកភិក្ខុ និង អ្នកស្រុកធានាទំនុកបម្រុងព្រះថេរៈ ........................................ ២៣
ពួកភិក្ខុទៅគាល់ព្រះសាស្តា ........................................ ២៥
ពួកភិក្ខុប្រាប់ដំណឹងដល់ប្អូនប្រុសរបស់ព្រះថេរៈ ........................................ ២៧
បញ្ជូនសាមណេរជាក្មួយប្រុសទៅទទួលព្រះថេរៈ ........................................ ២៨
សាមណេរបបួលព្រះមហាថេរៈត្រឡប់ទៅវិញ ........................................ ៣០
សាមណេរដល់ការវិបត្តិសីលព្រោះសំឡេងស្រ្តី ........................................ ៣១
ព្រះថេរៈមិនព្រមឲ្យសាមណេរគប់រក ........................................ ៣៣
អាសនៈសក្កទេវរាជក្តៅ ........................................ ៣៥
សក្កទេវរាជនាំព្រះថេរៈទៅដល់វត្តជេតពន ........................................ ៣៨
បុព្វកម្មរបស់ព្រះចក្ខុបាល ........................................ ៤៣
អធិប្បាយគាថា ........................................ ៤៦

## ២. រឿងមដ្ឋកុណ្ឌលី

ព្រាហ្មណ៍ធ្វើគ្រឿងប្រដាប់ឲ្យបុត្រ ........................................ ៥៤
ព្យាបាលបុត្រខ្លួនឯងព្រោះខ្លាចអស់ថ្លៃឈ្នួល ........................................ ៥៥
ឲ្យបុត្រដេកក្រៅផ្ទះព្រោះខ្លាចគេឃើញសម្បត្តិ ........................................ ៥៦
ព្រះពុទ្ធពិចារណាឃើញឧបនិស្ស័យរបស់មដ្ឋកុណ្ឌលី ........................................ ៥៧
មដ្ឋកុណ្ឌលីញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ ........................................ ៦០
ព្រោះចិត្តជ្រះថ្លាធ្វើកាលកិរិយាទៅកើតក្នុងទេវលោក ........................................ ៦០
ព្រាហ្មណ៍ខ្សឹកខ្សួលដល់បុត្រ ........................................ ៦១
ទេវបុត្រនិម្មិតកាយទៅរកព្រាហ្មណ៍ ........................................ ៦១
ទេវបុត្រ និង ព្រាហ្មណ៍បានឆ្លងឆ្លើយគ្នា ........................................ ៦២

ព្រាហ្មណ៍យល់ព្រមចុះចាញ់ហើយសរសើរទេវបុត្រ ........................................ ៦៥
ព្រាហ្មណ៍សាកសួរទេវបុត្រ ........................................ ៦៧
ព្រាហ្មណ៍ដល់ព្រះពុទ្ធជាសរណៈ ........................................ ៦៨
ទេវបុត្រឱ្យឱវាទព្រាហ្មណ៍ហើយក៏បាត់ខ្លួនទៅ ........................................ ៦៩
ព្រាហ្មណ៍ថ្វាយទានដល់ព្រះពុទ្ធ ........................................ ៧១
ចិត្តជាធំក្នុងកម្មគ្រប់យ៉ាង ........................................ ៧៥
អធិប្បាយគាថា ........................................ ៧៦

## ៣. រឿងព្រះតិស្សៈ

ព្រះតិស្សត្រូវជាអ្នកទូន្មានលំបាក និង ប្រកាន់ខ្លួន ........................................ ៨២
ព្រះតិស្សៈទូលរឿងដល់ព្រះសាស្ដា ........................................ ៨៤
ព្រះតិស្សៈមិនព្រមខមាទោសភិក្ខុសង្ឃ ........................................ ៨៥
បុព្វកម្មរបស់ព្រះតិស្សៈ ........................................ ៨៧
ទោសនៃការដេកខុសកន្លែង ........................................ ៨៨
តាបសទាំងពីរនាក់ដាក់ផ្ដាសារគ្នា ........................................ ៩០
ប្រជាជនក្ដៅក្រហាយរហូតដល់ព្រះរាជា ........................................ ៩២
អធិប្បាយគាថា ........................................ ៩៧

## ៤. រឿងការកើតឡើងនៃនាងយក្ខិណី

មាតារកភរិយាឱ្យបុត្រ ........................................ ១០០
ប្រពន្ធដើមផ្សំថ្នាំទម្លាយគភ៌ប្រពន្ធចុង ........................................ ១០៣
ផ្លាស់ប្ដូរគ្នាប្រហារគ្នាម្នាក់មួយជាតិដោយអំណាចនៃការចងពៀរ ........................................ ១០៥
ពៀរមិនរម្ងាប់ដោយការចងពៀរ ពៀរតែងរម្ងាប់បានដោយការមិនចងពៀរ ........................................ ១០៨
អធិប្បាយគាថា ........................................ ១១០
នាងយក្ខិណីដឹងភ្លៀងច្រើនភ្លៀងតិច ........................................ ១១២
នាងយក្ខិណីចាប់ផ្ដើមតាំងសលាកភត្ត ........................................ ១១៥

## ៥. រឿងភិក្ខុកោសម្ពី


ព្រះវិន័យធម៌ និង ព្រះធម្មកថិកប្រកែកគ្នារឿងវិន័យ ........................................ ១១៧
ព្រះសាស្ដាត្រាស់ប្រៀនប្រដៅឲ្យសាមគ្គីគ្នា ........................................ ១១៩
ត្រាស់ប្រៀនប្រដៅប៉ុន្មានក៏មិនជឿ ........................................ ១២២
ព្រះសាស្ដាទ្រង់អផ្សុកទើបស្ដេចគេចទៅចាំវស្សានៅក្នុងព្រៃរក្ខិតវ័ន ........................................ ១២៤
ពួកឧបាសកទូន្មានភិក្ខុ ........................................ ១២៥
ដំរីបាលិលេយ្យកៈឧបដ្ឋាកព្រះសាស្ដា ........................................ ១២៧
ស្វាថ្វាយសំបុកឃ្មុំ ........................................ ១៣០
ស្ដេចដំរីសង្កេតមើលវត្តរបស់ព្រះអានន្ទ ........................................ ១៣១
មិនបានសម្លាញ់ដែលមានបញ្ញាត្រាច់ទៅតែម្នាក់ឯងប្រសើរជាង ........................................ ១៣៣
ដំរីស្លាប់ទៅកើតជាទេវបុត្រ ........................................ ១៣៨
ភិក្ខុក្រុងកោសម្ពីទូលសូមខមាទោសព្រះសាស្ដា ........................................ ១៣៩
អធិប្បាយគាថា ........................................ ១៤២


## ៦. រឿងចុល្លកាល និង មហាកាល


មហាកាលស្ដាប់ធម៌ហើយលាប្អូនប្រុសទៅបួស ........................................ ១៤៥
ព្រះមហាកាលបំពេញសោសានិកធុតង្គ ........................................ ១៤៧
របៀបអ្នកនៅក្នុងព្រៃស្មសាន ........................................ ១៤៨
ព្រះចុល្លកាលអផ្សុក ........................................ ១៥២
ព្រះមហាកាលពិចារណាសាកសពកុលធីតា ........................................ ១៥២
ព្រះមហាកាលសម្រេចព្រះអរហត្ត ........................................ ១៥៤
របៀបក្រាលអាសនៈសម័យពុទ្ធកាល ........................................ ១៥៥
ព្រះចុល្លកាលត្រូវស្ត្រីចាប់ផ្សឹក ........................................ ១៥៦
ព្រះមហាកាលក៏ត្រូវភរិយាចាប់ផ្សឹក ........................................ ១៥៧
ព្រះមហាកាលជាអ្នកមិនញាប់ញ័រ ........................................ ១៥៩

អធិប្បាយគាថា ........................................ ១៦១
មហាកាលហោះគេចភរិយា ........................................ ១៦៥

## ៧. រឿងព្រះទេវទត្ត

ព្រះសារីបុត្រសម្ដែងធម៌ដល់អ្នកក្រុងរាជគ្រឹះ ........................................ ១៦៧
និមន្តភិក្ខុ ១០០០ រូបទទួលភត្តាហារ ........................................ ១៦៨
ឱបាសកបបួលអ្នកស្រុកថ្វាយភត្តាហារ ........................................ ១៦៩
ប្រគេនសំពត់តម្លៃមួយសែនដល់ទេវទត្ត ........................................ ១៧១
ព្រះទេវទត្តស្លៀកដណ្ដប់សំពត់កាសាវៈមិនសមគួរដល់ខ្លួន ........................................ ១៧១
កាលមុនទេវទត្តជានាយព្រានដំរី ........................................ ១៧២
របស់ល្អរមែងសមគួរដល់មនុស្សល្អ មិនសមគួរដល់មនុស្សអាក្រក់ទេ ........................................ ១៧៧
អធិប្បាយគាថា ........................................ ១៧៨

## ៨. រឿងសញ្ជ័យ

ព្រះសាស្ដាបានទទួលការព្យាករណ៍អំពីព្រះពុទ្ធ ២៣ ព្រះអង្គ ........................................ ១៨១
ទ្រង់ឃើញទេវទូតហើយស្ដេចបព្វជ្ជា ........................................ ១៨៤
ទ្រង់សម្រេចសព្វញ្ញុតញ្ញាណហើយទ្រង់សម្ដែងធម៌ ........................................ ១៨៦
ព្រះសាស្ដាទ្រង់បញ្ជូនសាវកទៅប្រកាសព្រះសាសនា ........................................ ១៨៩
អនុបុព្វីកថាក្នុងរឿងព្រះសារីបុត្រ និង ព្រះមោគ្គល្លាននោះមានដូចតទៅនេះ ........................................ ១៩១
សម្លាញ់ពីរនាក់ដាក់កតិកាគ្នា ........................................ ១៩៤
ព្រះអស្សជិសម្ដែងបេះដូងព្រះសាសនា ........................................ ១៩៨
ឧបតិស្សៈ និង កោលិតៈសម្រេចព្រះសោតាបន្ន ........................................ ២០០
ឧបតិស្សៈ និង កោលិតៈបបួលសញ្ជ័យទៅគាល់ព្រះសាស្ដា ........................................ ២០២
សិស្សសម្រេចអរហត្តផលមុនអាចារ្យ ........................................ ២០៥
ពួកភិក្ខុតិះដៀលព្រះសាស្ដា ........................................ ២០៧
បុព្វកម្មរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ ........................................ ២០៨

បុព្វកម្មរបស់ជន ៥៥ នាក់ មានយសកុលបុត្រជាដើម ........................... ២១៣
បុព្វកម្មរបស់ភទ្ទវគ្គីយ៍ ៣០ នាក់ ........................................... ២១៥
បុព្វកម្មរបស់ជដិល ៣ នាក់បងប្អូន ........................................... ២១៥
បរិភោគអាហារដែលគេឧទ្ទិសចំពោះភិក្ខុសង្ឃ ស្លាប់ទៅកើតជាប្រេត ................. ២២០
ពួកប្រេតសួរវេលាបានអាហារនឹងព្រះពុទ្ធ ៣ ព្រះអង្គ ............................. ២២២
ពួកប្រេតរួចផុតទុក្ខព្រោះផលទាន ............................................. ២២៤
បុព្វកម្មរបស់ព្រះអគ្គសាវកទាំងពីរ ............................................. ២២៦
អគ្គសាវកទាំង ២ ទូលរឿងបច្ចុប្បន្នដល់ព្រះសាស្តា ............................... ២៤៤
អ្នកឃើញខុស និង អ្នកឃើញត្រូវបានទទួលផលផ្សេងគ្នា ............................. ២៤៥
អធិប្បាយគាថា .......................................................... ២៤៦

## ៩. រឿងព្រះនន្ទត្ថេរ

ព្រះសាស្តាស្តេចយាងទៅកាន់ក្រុងកបិលពស្តុ ....................................... ២៤៩
រាហុលកុមារទូលសូមកំណប់ទ្រព្យអំពីព្រះសាស្តា ................................. ២៥២
រាហុលកុមារបព្វជ្ជា ....................................................... ២៥៥
ព្រះនន្ទចង់សឹក .......................................................... ២៥៧
ព្រះសាស្តាទ្រង់ទូន្មានព្រះនន្ទ ................................................. ២៥៨
ព្រះនន្ទសម្រេចអរហត្តផល .................................................. ២៦១
ព្រះនន្ទត្រូវចោទប្រកាន់ ..................................................... ២៦៤
អធិប្បាយគាថា .......................................................... ២៦៦
ព្រះនន្ទត្រូវល្បួងលួងលោមអំពីមាតុគ្រាម ....................................... ២៦៧
បុព្វកម្មរបស់ព្រះនន្ទ ....................................................... ២៦៨

## ១០. រឿងនាយចុន្ទសូករិក

នាយចុន្ទចិញ្ចឹមជីវិតដោយការចិញ្ចឹមជ្រូកលក់ ..................................... ២៧៤
អវីចិមហានរកក្តៅជាងភ្លើងធម្មតា ............................................. ២៧៦

នាយចុន្ទៈ សោយផលកម្មទាន់ហន់ .............................................. ២៧៧
សោយផលកម្មក្នុងសម្បរាយភព .............................................. ២៧៨
ពួកភិក្ខុយល់ថាគាត់សម្លាប់ជ្រូកធ្វើពិធីមង្គល .............................................. ២៧៨
អធិប្បាយគាថា .............................................. ២៨០

## ១១. រឿងធម្មិកឧបាសក

ឧបាសក និង ក្រុមគ្រួសារបំពេញកុសលជានិច្ច .............................................. ២៨២
ឧបាសកឈឺដេកស្ដាប់ធម៌ .............................................. ២៨៣
ទេវតានាំរថមកទទួលឧបាសកទៅទេវលោក .............................................. ២៨៤
ពួកភិក្ខុ និង បុត្រធីតារបស់ឧបាសកយល់ខុស .............................................. ២៨៥
អធិប្បាយគាថា .............................................. ២៩០

## ១២. រឿងទេវទត្ត

សក្យៈទាំង ៦ អង្គទ្រង់ព្រះផ្នួស .............................................. ២៩២
សក្យៈទាំងពីរសន្ទនាគ្នាអំពីរឿងបួស និង ការងារ .............................................. ២៩៧
សក្យៈទាំង ៣ សន្ទនាគ្នាអំពីទីកើតនៃភត្ត .............................................. ២៩៨
ឧបាលិចេញបួសជាមួយនឹងសក្យៈទាំង ៦ អង្គ .............................................. ៣០០
សក្យៈទាំង ៦ អង្គសម្រេច .............................................. ៣០២
ព្រះទេវទត្តសម្ដែងឫទ្ធិដល់អជាតសត្តុរាជកុមារ .............................................. ៣០៣
ទេវទត្តព្យាយាមសម្លាប់ព្រះសម្មាសម្ពុទ្ធ .............................................. ៣០៥
កម្មអាក្រក់របស់ព្រះទេវទត្តប្រាកដដល់មហាជន .............................................. ៣០៩
ព្រះទេវទត្តទូលសូមវត្ថុ ៥ ប្រការ .............................................. ៣១០
ព្រះទេវទត្តបំបែកសង្ឃ .............................................. ៣១១
អគ្គសាវកទាំងពីរនាំភិក្ខុត្រឡប់ចូលកាន់ពួកបាន .............................................. ៣១៣
បុព្វកម្មរបស់ព្រះទេវទត្ត .............................................. ៣១៥
ព្រះទេវទត្តឲ្យសាវកនាំទៅគាល់ព្រះសាស្ដា .............................................. ៣១៩

ព្រះទេវទត្តត្រូវធរណីស្រូប ........................................ ៣២១
ព្រះទេវទត្តកើតក្នុងអវីចិត្រូវឆ្កាងដោយលំពែងដែក ........................................ ៣២៣
អ្នកធ្វើបាបរមែងក្តៅក្រហាយក្នុងលោកទាំងពីរ ........................................ ៣២៧
អធិប្បាយគាថា ........................................ ៣២៨

## ១៣. រឿងនាងសុមនាទេវី

អប់រំកូនចៅឱ្យទទួលនាទីរបស់ខ្លួន ........................................ ៣៣០
នាងសុមានាឈឺហៅបិតាថាប្អូនប្រុស ........................................ ៣៣២
លោកសេដ្ឋីជាបិតាយំទៅទូលព្រះសាស្តា ........................................ ៣៣៣
អ្នកធ្វើបុណ្យរមែងរីករាយក្នុងលោកទាំងពីរ ........................................ ៣៣៦
អធិប្បាយគាថា ........................................ ៣៣៧

## ១៤. រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីររូប

សម្លាញ់ពីរនាក់ចេញបួស ........................................ ៣៣៩
ព្រះថេរៈទាំងពីរជួបគ្នា ........................................ ៣៤២
ព្រះសាស្តាសួរបញ្ហាព្រះថេរៈទាំងពីររូប ........................................ ៣៤២
ព្រះវិបស្សកភិក្ខុបានទទួលសាធុកា ........................................ ៣៤៤
និយាយច្រើនតែមិនបដិបត្តិក៏ឥតប្រយោជន៍ ........................................ ៣៤៥
អធិប្បាយគាថា ........................................ ៣៤៧

# សុត្តន្តបិដក
# ខុទ្ទកនិកាយ ខុទ្ទកបាឋ

## ភាគទី ១

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

១ មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោស[១] ប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខ រមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះរិល

---

[១] *ធម៌ជាទោស ឬជាឧបក្កិលេសនៃចិត្តមានអភិជ្ឈាដើម ដែលចូលមកធ្វើចិត្តឲ្យវិកាវរ។*

តាមដានជើងគោដែលកំពុងអូសទៅ ។

**២ មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**
**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លា[1]ហើយ ពោលក្តី ធ្វើក្តី នូវសុចរិត ព្រោះសុចរិតទាំងនោះ សុខ រមែងជាប់ តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមទៅប្រាណ ។

**៣ អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**
**យេ ចតំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។**

អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណា ចងសេចក្តីក្រោធ

ដ

[1] ជ្រះថ្លាដោយគុណ មានអនកិជ្ឈាជាដើម

បែបនោះទុក ( ដូច្នេះ ) ពៀររបស់អ្នកនោះ មិនស្ងប់ឡើយ ។

**អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**

**យេ ចតំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ** ។

អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណា មិនចងសេចក្តីក្រោធនោះទុក ( ដូច្នេះ ) ពៀររបស់អ្នកនោះ ទើបរម្ងាប់បាន ។

**៥ ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ**

**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ** ។

ពិតមែន តាំងពីកាលណាមក ក្នុងលោកនេះ ពៀរទាំងឡាយ មិនរម្ងាប់ដោយពៀរឡើយ ពៀរទាំងឡាយ តែងរម្ងាប់ដោយមិនចងពៀរ នេះជាបវេណីធម៌ ។

**៦ បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ**

**យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា** ។

ជនទាំងឡាយដទៃ ( ក្រៅអំពីបណ្ឌិត ) តែងមិនដឹងខ្លួនថា

យើងទាំងឡាយ នឹងវិនាសក្នុងកណ្ដាលនៃពួកនេះ ដូច្នេះ ឡើយ ចំណែកជនទាំងឡាយណា ក្នុងលោកនេះ ដឹងខ្លួនថា យើងទាំងឡាយ នឹងវិនាសក្នុងកណ្ដាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់អំពីជនទាំងនោះ ។

**សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ**
**ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ**
**តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្វលំ ។**

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រីយ៍ ទាំងឡាយ មិនប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាម ធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ ។

**អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ**
**ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ**
**តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ ។**

ឯបុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុង

ឥន្ទ្រិយ៍ទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យា-
យាម កិលេសមារតែងគ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់
គ្របសង្កត់ភ្នំថ្មតាន់មិនបានដូច្នោះ ។

**៧ អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហេស្សតិ**

**អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។**

អ្នកណា នៅមានទឹកចត់គឺរាគាទិក្កិលេស ( ក្នុងសន្តាន ) ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយ៍ និងសច្ចៈ ហើយស្លៀកដណ្តប់សំពត់កាសាវៈ អ្នកនោះមិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈឡើយ ។

**យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ**

**ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។**

លុះតែអ្នកណា មានទឹកចត់គឺរាគាទិក្កិលេស ខ្ជាកចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ ក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ៍ និងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់កាសាវៈបាន ។

៨ អសារេ សារមតិនោ      សារេ បាសារទស្សិនោ

តេ សារំ នាធិគច្ឆន្តិ      មិច្ឆាសង្កប្បគោចរា ។

ជនទាំងឡាយ ដែលយល់ឃើញ ក្នុងធម៌មានខ្លឹម ថាជាធម៌មិនមានខ្លឹមផង ជាអ្នកតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ ។

សារញ្ច សារតោ ញត្វា      អសារញ្ច អសារតោ

តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

ជនទាំងឡាយ ដែលយល់ឃើញ នូវធម៌មានខ្លឹម ថាជាធម៌មានខ្លឹមផង យល់ឃើញនូវធម៌គ្មានខ្លឹម ថាជាធម៌គ្មានខ្លឹមផង ជាអ្នកមានតម្រិះត្រូវ ជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្លឹម ។

៩ យថា អគារំ ទុច្ឆន្នំ      វុដ្ឋី សមតិវិជ្ឈតិ

ឯវំ អភាវិតំ ចិត្តំ      រាគោ សមតិវិជ្ឈតិ ។

ផ្ទះដែលប្រក់ខ្ជីខ្ជាហើយ ដំណក់ទឹកភ្លៀង រមែងលេចរហូតយ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ដោត យ៉ាងនោះឯង ។

**យថា អគារំ សុច្ឆន្នំ　　វុដ្ឋី ន សមតិវិជ្ឈតិ**

**ឯវំ សុភាវិតំ ចិត្តំ　　រាគោ ន សមតិវិជ្ឈតិ ។**

ផ្ទះដែលបុគ្គលប្រក់ល្អហើយ ដំណក់ទឹកភ្លៀង រមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតបាន យ៉ាងនោះឯង ។

**១០ ឥធ សោចតិ បេច្ច សោចតិ បាបការី ឧភយត្ថ**

**សោ សោចតិ សោ វិហញ្ញតិ ទិស្វា កម្មកិលិដ្ឋមត្តនោ ។**

បុគ្គលអ្នកធ្វើបាប រមែងសោកស្តាយក្នុងលោកទាំងពីរ គឺសោកស្តាយក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះរមែងសោយស្តាយ ក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

**១១ ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ**

**សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។**

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីក

រាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធិរបស់ខ្លួន ។

**១២ ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ**

**បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។**

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាបអញធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិក៏រឹងរឹតក្តៅក្រហាយដ៏ក្រៃលែង ។

**១៣ ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ**

**បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ ។**

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរក្នុងលោកទាំងពីរ គឺត្រេកអរក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងត្រេកអរដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះមរណកាលទៅកាន់សុគតិ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

**៣ពហុម្បិ ចេ សហិតំ ភាសមានោ**

ន តក្ករោ ហោតិ នរោ បមត្តោ
គោបោវ គាវោ គណយំ បរេសំ
ន ភាគវា សាមញ្ញស្ស ហោតិ ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍សូម្បីច្រើន តែជាអ្នកប្រមាទមិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដទៃហើយ ( ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស ) ដូច្នោះឯង ។

១៩ អប្បម្បិ ចេ សហិតំ ភាសមានោ
ធម្មស្ស ហោតិ អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ
សម្មប្បជានោ សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា
ស ភាគវា សាមញ្ញស្ស ហោតិ ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ

និងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ មានចិត្ត ផុតស្រឡះអំពិសេចក្តីសៅហ្មង មិនមានសេចក្តីប្រកាន់មាំ ក្នុងលោកនេះ និងលោកខាងមុខ នរជននោះ រមែងជាអ្នកបានចំណែកសាមញ្ញផល ។

*( យមកវគ្គោ បឋមោ )*

*( យមកវគ្គទី ១ ចប់ )*

# ១ យមកវគ្គវណ្ណនា

❈❈❈ 📖 ❈❈❈

## ១ រឿងព្រះចក្ខុបាលត្ថេរ

### សេចក្ដីខាងដើម

មានបុច្ឆាថា "ព្រះធម្មទេសនានេះថា ៖

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត មានចិត្តជាធំ សម្រេចពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្ដី ធ្វើក្ដី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសនឹមទៅ ។

ដូច្នេះ ព្រះសាស្ដាទ្រង់សម្ដែងហើយ នៅក្នុងទីណា ?

វិសជ្ជនាថា ព្រះអង្គទ្រង់ត្រាស់សម្ដែងហើយ នៅក្នុងក្រុងសាវត្ថី ។

មានបុច្ឆា (ជាលំដាប់តទៅ) ថា "ព្រះអង្គទ្រង់ប្រារព្ធចំពោះ

នវណា” ?

មានវិសជ្ជនាថា “ព្រះអង្គទ្រង់ប្រារព្ធព្រះចក្ខុបាលត្ថេរ” ។

## កុដុម្ពិកធ្វើពិធីសុំបុត្រ

ដូចបានស្ដាប់មក នៅក្នុងក្រុងសាវត្ថី មានកុដុម្ពិកម្នាក់ឈ្មោះមហាសុវណ្ណ ជាអ្នកស្ដុកស្ដម្ភ មានទ្រព្យ មានសម្បត្តិច្រើន (តែ) មិនមានបុត្រ ។ ថ្ងៃមួយគាត់បានធ្វើដំណើរទៅកំពង់ទឹក ងូតស្រេចហើយត្រឡប់មកឃើញដើមឈើធំដែលជាម្ចាស់ព្រៃមួយដើម មានមែកសម្បូណ៌នៅក្នុងចន្លោះផ្លូវ គិតថា “ដើមឈើនេះនឹងមានទេវតាដែលមានសក្ដិធំបិតនៅ” ដូច្នេះហើយ ទើបឲ្យគេជម្រះចំណែកខាងក្រោមនៃដើមឈើនោះឲ្យស្អាតហើយ ឲ្យធ្វើជារបងពទ្ធជុំវិញ កៀរខ្សាច់លើកទង់ជ័យ និងទង់បដាឡើង តុបតែងដើមឈើម្ចាស់ព្រៃហើយធ្វើសេចក្ដីប្រាថ្នា ( គឺបន់ស្រន់ ) ថា “ខ្ញុំម្ចាស់បានបុត្រ ឬធីតាហើយនឹងធ្វើសក្ការៈធំថ្វាយដល់លោក” ដូច្នេះហើយ ចៀសចេញទៅ ។

## កុដុម្ពិកបានបុត្រពីរនាក់

ក្នុងកាលជាលំដាប់មក ភរិយារបស់សេដ្ឋីបុត្រក៏តាំងគភ៌ ។

លោកក៏ឲ្យពិធីគភ៌បរិហារដល់នាង ។ លុះកន្លង ១០ ខែ នាងប្រសូត បុត្រម្នាក់ សេដ្ឋីដាក់ឈ្មោះបុត្រនោះថា "បាលៈ" ព្រោះកូននោះដែលខ្លួនបានមកហើយព្រោះអាស្រ័យដើមឈើធំ ជាម្ចាស់នៃព្រៃដែលខ្លួនរក្សា ។

ក្នុងកាលជាចំណែកដទៃ លោកសេដ្ឋីបានបុត្រម្នាក់ទៀតដាក់ឈ្មោះថា "ចុល្លបាល " ដាក់ឈ្មោះបុត្រច្បងថា "មហាបាល" លុះកុមារពីរនាក់ចម្រើនវ័យហើយ មាតាបិតាក៏គិតចងដោយចំណង គឺការគ្រប់គ្រងផ្ទះ ។ ក្នុងកាលជាចំណែកដទៃ មាតាបិតាបានធ្វើកាលកិរិយាទៅ ។ ពួកញាតិក៏បើកសម្បត្តិទាំងអស់ប្រគល់ឲ្យដល់សេដ្ឋីបុត្រទាំងពីរនាក់ ។

## ព្រះសាស្ដាទ្រង់គង់នៅក្នុងក្រុងសាវត្ថី ២៥ វស្សា

ក៏ក្នុងសម័យនោះ ព្រះសាស្ដា ទ្រង់ប្រកាសព្រះធម្មចក្កដ៏បវរឲ្យប្រព្រឹត្តទៅហើយ ស្ដេចយាងទៅកាន់ចារិកដោយលំដាប់ ទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ដែលអនាថបិណ្ឌិកសេដ្ឋីបរិច្ចាគទ្រព្យ

រាប់បាន ៥៤ កោដិ សាងថ្វាយ ទ្រង់ទូន្មានមហាជនឲ្យតាំងនៅក្នុងផ្លូវសួគ៌ និងផ្លូវនិព្វាន ។

ពិតណាស់ ព្រះតថាគត ទ្រង់នៅចាំវស្សាតែមួយវស្សាតែប៉ុណ្ណោះ ក្នុងនិគ្រោធមហាវិហារ ដែលព្រះញាតិវង្សខាងព្រះមាតា ៨ ម៉ឺនត្រកូល, ខាងបិតា ៨ ម៉ឺនត្រកូល រួមគ្នាជា ១៦ ម៉ឺនត្រកូលសាងថ្វាយ, ស្ដេចគង់ចាំវស្សានៅក្នុងជេតវនមហាវិហារ ដែលអនាថ-បិណ្ឌិកសេដ្ឋីសាងថ្វាយ ១៩ វស្សា, ស្ដេចគង់ចាំវស្សានៅក្នុងបុព្វា-រាម ដែលនាងវិសាខាមហាឧបាសិកាបរិច្ចាគទ្រព្យរាប់បាន ២៧ កោដិ សាងថ្វាយ ៦ វស្សា, ទ្រង់អាស្រ័យត្រកូលទាំងពីរដែលជាធំដោយគុណធម៌ ស្ដេចទ្រង់ចាំវស្សាអាស្រ័យក្រុងសាវត្ថីជាគោចរគ្រាមដល់ ២៥ វស្សា ដោយប្រការដូច្នេះ ។

## អ្នកទំនុកបម្រុងភិក្ខុសាមណេរ

ទាំងអនាថបិណ្ឌិកសេដ្ឋី ទាំងវិសាខាមហាឧបាសិកា រមែងទៅកាន់ទីបម្រើព្រះតថាគតមួយថ្ងៃពីរដងជាប្រចាំ ។ ហើយកាលនឹង

ទៅមិនធ្លាប់មានដៃទទេទៅ ដោយគិតក្រែងថា “ភិក្ខុកម្លោះ និងសាមណេរនឹងក្រឡេកមើលនូវដៃរបស់ខ្លួន ។ កាលទៅមុនពេលឆាន់អាហារ រមែងប្រើបម្រើឲ្យកាន់យកបរស់ទំពាស៊ីជាដើមទៅ, កាលទៅខាងក្រោយពីវេលាឆាន់អាហារ ប្រើឲ្យបម្រើកាន់យកបញ្ចភេសជ្ជៈ និងអដ្ឋបានទៅ ។ ហើយក្នុងគេហដ្ឋាននៃលោកទាំងពីរនោះ គាត់តាក់តែងអាសនៈទុកដើម្បីភិក្ខុ ២ ពាន់រូបក្នុងគេហដ្ឋានទីមួយៗ ជានិច្ច ។ ព្រះភិក្ខុរូបណាប្រាថ្នារបស់ណា ទោះបីជាបាយ ទឹក ឬភេសជ្ជៈ របស់នោះក៏សម្រេចដល់ភិក្ខុរូបនោះសមដូចប្រាថ្នា ។

## សេដ្ឋីមិនធ្លាប់ទូលសួរបញ្ហា

ក្នុងបណ្ដាលោកទាំងពីរ លោកអនាថបិណ្ឌិកសេដ្ឋីមិនធ្លាប់ទូលសួរបញ្ហាចំពោះព្រះសាស្ដាម្ដងណាឡើយ ។ បានឮថា លោកគិតថា “ព្រះតថាគតជាព្រះពុទ្ធ, ដែលជាសុខុមាលជាតិ ជាក្សត្រសុខុមាលជាតិ កាលទ្រង់សម្ដែងធម៌ដល់យើង ដោយទ្រង់ព្រះតម្រិះថា “គហបតីមានឧបការៈដល់យើងច្រើន ដូច្នេះនឹងទ្រង់លំបាក” ហើយ

មិនទូលសួរបញ្ហា ដោយសេចក្ដីស្រឡាញ់ក្នុងព្រះសាស្ដាជាយ៉ាងក្រៃលែង ។ ចំណែកព្រះសាស្ដា លុះលោកសេដ្ឋីអង្គុយហើយ ទ្រង់មានព្រះពុទ្ធតម្រិះថា "សេដ្ឋីនេះរក្សាយើងក្នុងទីដែលមិនគួររក្សា ព្រោះហេតុថា យើងកាត់សិរសារបស់យើងដែលប្រដាប់ហើយ, ខ្វេះដួងព្រះនេត្ររបស់យើងចេញ ហើយកាត់សាច់បេះដូងរបស់យើង លះបង់កូនប្រពន្ធ ដែលជាទីស្រឡាញ់ស្មើដោយជីវិតរបស់យើង ហើយបំពេញបារមី ៤ អសង្ខេយ្យ និងមួយសែនកប្បក៏បំពេញហើយ ដើម្បីសម្ដែងធម៌ដល់អ្នកដទៃប៉ុណ្ណោះ សេដ្ឋីនេះរក្សាយើងក្នុងទីដែលមិនគួររក្សា" ( លុះទ្រង់ពុទ្ធតម្រិះ ) ដូច្នេះហើយ ក៏ទ្រង់ត្រាស់ព្រះ-ធម្មទេសនា ១ កណ្ឌ ជានិច្ច ។

## អ្នកក្រុងសាវត្ថីទៅស្ដាប់ធម៌

គ្រានោះ នៅក្នុងក្រុងសាវត្ថីមានមនុស្ស ៧ កោដិ ក្នុងបណ្ដាមនុស្សទាំងនោះ អ្នកបានស្ដាប់ធម្មកថារបស់ព្រះសាស្ដាហើយ បានទៅជាអរិយសាវកប្រមាណ ៥ កោដិ នៅជាបុថុជ្ជនប្រមាណ ២

កោដិ ។ ក្នុងបណ្ដាមនុស្សទាំងនោះ កិច្ចរបស់អរិយសាវកមានត្រឹមតែពីរយ៉ាងប៉ុណ្ណោះ គឺមុនកត្ត លោកថ្វាយទាន, ក្រោយកត្ត លោកមានដៃកាន់គ្រឿងសក្ការបូជា មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ប្រើមនុស្សឲ្យកាន់ទេយ្យធម៌ មានសំពត់ ភេសជ្ជៈ និងទឹកបានៈជាដើម ទៅដើម្បីត្រូវការស្ដាប់ធម៌ ។

ថ្ងៃមួយ កុដុម្ពិក៍មហាបាលឃើញពួកអរិយសាវកមានដៃកាន់គ្រឿងសក្ការបូជា មានរបស់ក្រអូប និងកម្រងផ្កាជាដើម ទៅកាន់វិហារ ទើបសួរថា "មហាជនទាំងនេះទៅណាហ្នឹង ?" លុះបានឮថា "ទៅស្ដាប់ធម៌" ក៏គិតថា "យើងក៏នឹងទៅដែរ" លុះទៅដល់ថ្វាយបង្គំព្រះសាស្ដាហើយ អង្គុយនៅខាងចុងប្រជុំជន ។ ធម្មតាព្រះពុទ្ធទាំងឡាយ កាលនឹងទ្រង់សម្ដែងធម៌ ទ្រង់ត្រួតមើលឧបនិស្ស័យនៃគុណមានសរណៈ សីល និងបព្វជ្ជា ជាដើម (សិន) ហើយទើបទ្រង់សម្ដែងធម៌តាមអំណាចអធ្យាស្រ័យ ។

## អនុបុព្វីកថា ៥ យ៉ាង

ហេតុនោះ ថ្ងៃនោះ ព្រះសាស្ដាទតឃើញឧបនិស្ស័យរបស់កុដុម្ពិក៍មហាបាលហើយ កាលទ្រង់សម្ដែងធម៌ បានត្រាស់អនុព្វីកថា គឺទ្រង់ប្រកាសទានកថា ( ពណ៌នាទាន ) សីលកថា ( ពណ៌នាសីល ) សគ្គកថា ( ពណ៌នាឋានសួគ៌ ) អាទីនវកថា ( ពណ៌នាអំពីទោសរបស់កាមទាំងឡាយ ) នេក្ខម្មកថា ( គឺពណ៌នាអំពីអានិសង្សនៃការចេញចាកកាមទាំងឡាយ ) ។

## មហាបាលសុំបួស

កុដុម្ពិក៍មហាបាលបានស្ដាប់ធម៌នោះហើយ គិតថា "បុត្រ និងធីតាក្ដី ភោគសម្បត្តិក្ដី រមែងទៅតាមអ្នកទៅកាន់បរលោកមិនបាន សូម្បីសរីរៈក៏ទៅជាមួយនឹងខ្លួនមិនបាន ប្រយោជន៍អ្វីដល់យើងក្នុងការនៅគ្រប់គ្រងផ្ទះ យើងនឹងបួស, លុះទេសនាចប់ គេក៏ចូលទៅគាល់ព្រះសាស្ដាទូលសុំបួស" ។ ខណៈនោះ ព្រះសាស្ដាត្រាស់សួរគេថា "ញាតិណាៗរបស់អ្នក ដែលនឹងលា មិនមានខ្លះទេឬ" ? គេ

ទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ប្អូនប្រុសរបស់ខ្ញុំព្រះអង្គ មាន" ។

ព្រះសាស្តា ទ្រង់ត្រាស់ប្រាប់ថា បើដូច្នោះ អ្នកចូរលាគេ ( សិន ) ។

## មហាបាលប្រគល់សម្បត្តិឲ្យប្អូនប្រុស

គេទទួលថា "ល្អហើយ ព្រះអង្គ" ថ្វាយបង្គំព្រះសាស្តាហើយ ទៅដល់ផ្ទះហើយ ឲ្យហៅប្អូនប្រុសមក ប្រគល់ទ្រព្យសម្បត្តិឲ្យថា "នែប្អូនសម្លាញ់ សវិញ្ញាណកទ្រព្យក្តី អវិញ្ញាណកទ្រព្យក្តី ឯណានីមួយមាននៅក្នុងត្រកូលនេះ ចូរជាភារៈរបស់ឯងទាំងអស់ ឯងចូរគ្រប់គ្រងទ្រព្យនោះចុះ" ។

ប្អូនប្រុសសួរថា "បងសម្លាញ់ ក៏បងឯងយ៉ាងម៉េច" ?

បងប្រុសឆ្លើយថា "បងនឹងបួសក្នុងសំណាក់ព្រះសាស្តា" ។

ប្អូ. បងនិយាយអ្វី កាលមាតារបស់ខ្ញុំស្លាប់ហើយ ខ្ញុំបានបងឯងដូចជាមាតា កាលបិតាស្លាប់ហើយ បានបងឯងដូចជាបិតា ។ សម្បត្តិជាច្រើនមាននៅក្នុងផ្ទះរបស់បង, បងឯងនៅគ្រប់គ្រងផ្ទះ ក៏

អាចធ្វើបុណ្យបានដែរ, សូមបងកុំធ្វើយ៉ាងនោះឡើយ ។

បង. ប្អូនសម្លាញ់បងបានស្តាប់ធម្មទេសនារបស់ព្រះសាស្តា, ព្រោះ(ហេតុដែល) ព្រះសាស្តាទ្រង់សម្តែងធម៌មានលម្អបទដើម បទកណ្តាល និងបទខាងចុង លើកឡើងកាន់ត្រៃលក្ខណ៍ ដ៏ល្អិតសុខុមធម៌នោះដែលនរណាៗមិនអាចនឹងបំពេញឲ្យបរិបូណ៌ ក្នុងភាពជាឃរាវាសបាន, បងនឹងបួសហើយ ប្អូនសម្លាញ់ ។

ប្អូន. អើ បងសម្លាញ់ ក៏បងនៅក្មេងដោយពិត, ចាំបងចាស់សិន សឹមបួសចុះ ។

បង. ប្អូនសម្លាញ់ ក៏ដៃ និងជើងរបស់មនុស្សចាស់ ( សូម្បីតែ) ខ្លួន ក៏នៅថាមិនស្តាប់ ប្រាប់មិនតាម មិនប្រព្រឹត្តទៅក្នុងអំណាចខ្លួន, ក៏នឹងពោលទៅថ្វីដល់ញាតិទាំងឡាយ បងនឹងមិនធ្វើ (តាម) ពាក្យរបស់ឯងទេ, បងនឹងបំពេញសមណធម៌ឲ្យបរិបូណ៌ ។

ដៃ និងជើងរបស់អ្នកណា ទ្រុឌទ្រោមទៅព្រោះជរា
ថាមិនស្តាប់ ប្រាប់មិនតាម អ្នកនោះ មានកម្លាំងដែល

ជរាកម្មាត់ហើយ នឹងប្រព្រឹត្តធម៌ដូចម្តេចបាន ។
បងនឹងបួសឲ្យទាល់តែបាន ណាប្អូនសម្លាញ់ ។

## មហាបាលបព្វជ្ជាឧបសម្បទា

កាលប្អូនប្រុសកំពុងស្រែកយំនោះឯង, គេទៅកាន់សំណាក់ព្រះសាស្តាហើយទូលសុំបួស បានបព្វជ្ជាឧបសម្បទាហើយនៅក្នុងសំណាក់របស់អាចារ្យ និងព្រះឧបជ្ឈាយ៍គ្រប់ ៥ វស្សាហើយ ចេញវស្សាបវារណាហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ក្នុងព្រះសាសនានេះមានធុរៈប៉ុន្មានយ៉ាង ?"

## ធុរៈ ២ យ៉ាងក្នុងព្រះសាសនា

ព្រះសាស្តាទ្រង់ត្រាស់ឆ្លើយថា "ម្នាលភិក្ខុ ធុរៈមាន ២ យ៉ាង គឺ គន្ថធុរៈ និង វិបស្សនាធុរៈប៉ុណ្ណោះ" ។

ព្រះមហាបាលទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ក៏គន្ថធុរៈតើដូចម្តេច ? វិបស្សនាធុរៈដូចម្តេចដែរ ?

ស. ធុរៈនេះ គឺការរៀននិកាយមួយក្តី ពីរនិកាយក្តី ចប់ពុទ្ធ-វចនៈ គឺព្រះត្រៃបិដកក្តី តាមសមគួរដល់បញ្ញារបស់ខ្លួន ហើយទ្រទ្រង់ទុក ពោល សម្តែង ប្រាប់ បើកបង្ហាញនូវពុទ្ធវចនៈនោះ ឈ្មោះថា គន្ថធុរៈ, ចំណែកការផ្តើម ទាំងការអស់ទៅ និងសូន្យទៅក្នុងអត្តភាព ញុំាងវិបស្សនាឲ្យចម្រើន ដោយអំណាចនៃការជាប់តគ្នាហើយ កាន់យកព្រះអរហត្តរបស់ភិក្ខុអ្នកមានការប្រព្រឹត្តិស្រាល ហើយត្រេកអរក្រៃលែងហើយក្នុងសេនាសនៈដ៏ស្ងាត់ ឈ្មោះថា វិបស្សនាធុរៈ ។

ម. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបួសហើយ ក្នុងកាលដែលខ្លួនជាមនុស្សចាស់ មិនអាចនឹងបំពេញគន្ថធុរៈឲ្យបរិបូណ៌បាន, តែនឹងបំពេញវិបស្សនាធុរៈឲ្យបរិបូណ៌, សូមព្រះអង្គត្រាស់ប្រាប់ព្រះកម្មដ្ឋានដល់ខ្ញុំព្រះអង្គចុះ ។

## ព្រះមហាបាលធ្វើដំណើរទៅកាន់ស្រុកជាយដែន

លំដាប់នោះ ព្រះសាស្តាបានត្រាស់ប្រាប់ព្រះកម្មដ្ឋានរហូតដល់ព្រះអរហត្ត ដល់ព្រះមហាបាល ។ លោកថ្វាយបង្គំព្រះសាស្តា

ហើយ ស្វែងរកភិក្ខុដែលជាអ្នកនឹងទៅជាមួយខ្លួន បានភិក្ខុ ៦០ រូប ហើយចេញព្រមជាមួយនឹងភិក្ខុទាំងឡាយ ទៅរហូតអស់ផ្លូវ ១២០ យោជន៍ ដល់ស្រុកជាយដែនមួយតំបន់ ក៏ចូលទៅបិណ្ឌបាតក្នុងស្រុកនោះព្រមជាមួយនឹងបរិវាររបស់ខ្លួន ។

## អ្នកស្រុកជ្រះថ្លាអារាធនាឲ្យនៅចាំវស្សា

ពួកមនុស្សឃើញភិក្ខុទាំងឡាយ អ្នកដល់ព្រមដោយវត្ត មានចិត្តជ្រះថ្លា រៀបចំអាសនៈ ហើយនិមន្តឲ្យគង់, អង្គាសដោយអាហារដ៏ប្រណីត ហើយសួរថា "បពិត្រលោកម្ចាស់ លោកម្ចាស់នឹងទៅទីណា" ? កាលភិក្ខុទាំងឡាយឆ្លើយថា "ឧបាសក និងឧបាសិកាទាំងឡាយ "ពួកអាត្មានឹងទៅកាន់ទីដែលជាទីសប្បាយ" ដូច្នេះហើយ មនុស្សទាំងឡាយដែលបណ្ឌិតដឹងថា លោកម្ចាស់ដ៏ចម្រើនទាំងឡាយស្វែងរកសេនាសនៈដើម្បីចាំវស្សា" ទើបអារាធនាថា "លោកម្ចាស់ដ៏ចម្រើនទាំងឡាយ បើលោកម្ចាស់ទាំងឡាយគប្បីនៅក្នុងទីនេះ រហូតអស់ត្រៃមាសនេះ ខ្ញុំម្ចាស់ទាំងឡាយនឹងគប្បីតាំងនៅក្នុងសរណៈ

ហើយកាន់សីល ” ។ សូម្បីភិក្ខុទាំងឡាយ ក៏គិតឃើញថា “យើងបាន អាស្រ័យត្រកូលទាំងនេះនឹងធ្វើទីបំផុតទុក្ខបាន” ដូច្នេះ ទើបទទួល និមន្ត ។ ពួកមនុស្សទទួលប្តេជ្ញារបស់ភិក្ខុទាំងឡាយហើយបាន ( ជួយគ្នា ) បោសសំអាតវិហារ រៀបចំទីសម្រាប់សម្រាកពេលថ្ងៃ និងពេលយប់ហើយប្រគល់ថ្វាយ ។ ភិក្ខុទាំងឡាយចូលទៅបិណ្ឌបាតក្នុងស្រុកនោះតែមួយតំបន់ជាប្រចាំ ។ គ្រានោះ ពេទ្យម្នាក់ចូលទៅរកភិក្ខុទាំងឡាយបវារណាថា “លោកម្ចាស់ដ៏ចម្រើនទាំងឡាយ ក៏ធម្មតាក្នុងលំនៅនៃមនុស្សច្រើននាក់ រមែងមានការមិនផាសុកខ្លះ កាលមិនផាសុកនោះកើតឡើងហើយ លោកម្ចាស់ទាំងឡាយគប្បីប្រាប់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់នឹងធ្វើភេសជ្ជៈថ្វាយ ” ។

## ព្រះមហាបាលសមាទាននេសជ្ជិកធុតង្គ

ក្នុងថ្ងៃចូលវស្សា ព្រះថេរៈហៅភិក្ខុទាំងនោះមក ( ព្រមគ្នា ) ហើយសួរថា “អ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយនឹងឲ្យត្រៃមាសនេះកន្លងទៅ ដោយឥរិយាបថប៉ុន្មាន ” ?

ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំទាំងឡាយ នឹងឲ្យកន្លងទៅដោយឥរិយាបថគ្រប់ទាំង ៤” ។

ថ. អ្នកមានអាយុទាំងឡាយ ក៏ការនោះសមគួរឬ ? យើងទាំងឡាយមិនគួរជាអ្នកប្រមាទមិនមែនឬ ? ព្រោះយើងទាំងឡាយរៀនព្រះកម្មដ្ឋានមកអំពីសំណាក់ព្រះពុទ្ធ ដែលទ្រង់នៅមានព្រះជន្ម ។ ធម្មតាថា ព្រះពុទ្ធទាំងឡាយ បុគ្គលអ្នកច្រើនដោយការអួតអាងមិនអាចញុំាងព្រះអង្គឲ្យត្រេកអរបានទេ, ព្រោះថា ព្រះពុទ្ធទាំងឡាយនោះ មនុស្សមានអធ្យាស្រ័យល្អ ( តែមួយចំពូក ) រមែងឲ្យទ្រង់ត្រេកអរបាន, ហើយដែលឈ្មោះថាអបាយទាំង ៤ ដូចជាផ្ទះរបស់ខ្លួនឯងនៃបុគ្គលអ្នកប្រមាទហើយ, អ្នកមានអាយុទាំងឡាយ សូមអ្នកទាំងឡាយចូរជាអ្នកមិនប្រមាទចុះ ។

ក. លោកម្ចាស់ដូចម្ដេចដែរ ទាន !

ថ. អ្នកមានអាយុទាំងឡាយខ្ញុំនឹងឲ្យ (ត្រៃមាសនេះ) (បង្ហើន) កន្លងទៅដោយឥរិយាបថ ៣ នឹងមិនទម្រេតខ្នង ។

ក. សាធុ សូមលោកម្ចាស់ចូរជាអ្នកមិនប្រមាទចុះ ។

## ចក្ខុរបស់មហាបាលពិការ

កាលព្រះថេរៈមិនឈានចុះកាន់និទ្រា,នាកាលខែជាដំបូងកន្លងទៅហើយ, រោគក្នុងចក្ខុក៏កើតឡើង ។ ទឹកភ្នែកហូរចេញអំពីភ្នែកទាំងពីរខាង ដូចជាទ.នៃទឹកទាំងឡាយដែលហូរចេញអំពីធ្នាំងផ្ទះ ។ លោកបំពេញសមណធម៌រហូតអស់រាត្រីហើយ កាលអារុណរះឡើងចូលទៅកាន់បន្ទប់ក៏អង្គុយ ។ ក្នុងវេលាភិក្ខចារ ភិក្ខុទាំងឡាយទៅកាន់សំណាក់ព្រះថេរៈ ប្រាប់ថា "បពិត្រលោកដ៏ចម្រើន នេះជាវេលាភិក្ខាចារ" ព្រះថេរៈពោលថា "ម្នាលអាវុសោទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរកាន់បាត្រ និងចីវរទៅចុះ" ដូច្នេះហើយ ឲ្យភិក្ខុទាំង-ឡាយកាន់បាត្រ និងចីវររបស់ខ្លួនចេញទៅ ។

ភិក្ខុទាំងឡាយ ឃើញភ្នែកទាំងពីររបស់ព្រះថេរៈមានទឹកហូរចេញ ទើបសួរថា " បពិត្រលោកដ៏ចម្រើន រោគនោះដូចម្តេច " ?

ថ. ម្នាលអាវុសោទាំងឡាយ ខ្យល់ចាក់ដោតភ្នែករបស់ខ្ញុំ ។

ភ. បពិត្រលោកដ៏ចម្រើន យើងទាំងឡាយជាអ្នកដែលពេទ្យបាន បវារណាទុកហើយមិនមែនឬ ? យើងគប្បីប្រាប់ដល់ពេទ្យនោះ ។

ថ. ប្រពៃហើយ អ្នកមានអាយុទាំងឡាយ ។

## ពេទ្យផ្សំថ្នាំឲ្យបន្តក់

ភិក្ខុទាំងឡាយក៏បានប្រាប់រឿងនោះដល់ពេទ្យ ។ ពេទ្យស្ងួប្រេងបញ្ជូនទៅថ្វាយហើយ ។ ព្រះថេរៈកាលបន្តក់ប្រេងក្នុងច្រមុះ អង្គុយបន្តក់ រួចហើយចូលទៅកាន់ស្រុក ។ ពេទ្យឃើញហើយសួរថា "បពិត្រលោកដ៏ចម្រើន បានឮថា ខ្យល់ចាក់ដោតភ្នែករបស់លោកម្ចាស់ឬ ?

ថ. ចម្រើនពរ ឧបាសក ។

ពេ. លោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ស្ងួប្រេងហើយបញ្ជូនទៅ ( ថ្វាយ ) លោកម្ចាស់បន្តក់តាមច្រមុះហើយឬ ?

ថ. ចម្រើនពរ ឧបាសក ។

ពេ. ឥឡូវនេះ យ៉ាងណាហើយ លោកម្ចាស់ ?

ថ. នៅតែចាក់ដោយដដែល ឧបាសក ។

## ព្រះមហាបាលអង្គុយបន្តក់ថ្នាំ

ពេទ្យគិតឆ្ងល់ក្នុងចិត្តថា "យើងបញ្ជូនប្រេងទៅដើម្បីនឹងញ៉ាំង រោគឲ្យស្ងប់បានដោយការបន្តក់ត្រឹមតែម្តងប៉ុណ្ណោះ ទៅថ្វាយហើយ ហេតុដូចម្តេចហ្ន៎ ទើបរោគនៅមិនទាន់ស្ងប់" ? ទើបសួរថា "លោកម្ចាស់ដ៏ចម្រើន ប្រេងនោះ លោកម្ចាស់អង្គុយបន្តក់ ឬក៏ដេកបន្តក់" ?

ព្រះថេរៈបាននៅស្ងៀម, សូម្បីពេទ្យសួរទៀតក៏មិននិយាយ ។

ពេទ្យគិតថា "យើងនឹងទៅកាន់វិហារមើលលំនៅរបស់លោកដោយខ្លួនឯង" ដូច្នោះហើយ ពោលថា "បើដូច្នោះ សូមលោកម្ចាស់ដ៏ចម្រើននិមន្តទៅចុះ" លះបង់ព្រះថេរៈហើយទៅកាន់វិហារ មើលលំនៅរបស់ព្រះថេរៈ ឃើញតែទីចង្ក្រម និងទីអង្គុយ មិនឃើញទីដេក ទើបសួរថា "លោកម្ចាស់ដ៏ចម្រើន ប្រេងនោះលោកម្ចាស់អង្គុយបន្តក់ ឬដេកបន្តក់" ? ព្រះថេរៈបាននៅស្ងៀម ។ ពេទ្យអង្វរដដែលៗ ថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំធ្វើយ៉ាងនោះ, ធម្មតា

សមណធម៌កាលរាងកាយនៅប្រព្រឹត្តទៅ ក៏អាចធ្វើបាន, សូមលោកម្ចាស់ដេកបន្តក់ចុះ” ។

## ព្រះចក្ខុបាលប្រឹក្សានឹងករជកាយ

ព្រះថេរៈឆ្លើយថា “ទៅចុះ អ្នកមានអាយុ អាត្មានឹងប្រឹក្សាមើលសិន ហើយទើបនឹងដឹង ។ ក៏ក្នុងទីនោះមិនមានញាតិសាលោហិតរបស់ព្រះថេរៈទេ លោកនឹងគប្បីប្រឹក្សាជាមួយនឹងនរណាទៅ ? សូម្បីយ៉ាងនោះក៏ដោយ លោកក៏ប្រឹក្សានឹងករជកាយថា “នែ បាលិតៈដ៏មានអាយុ អ្នកចូរថាមកមើល អ្នកនឹងឃើញដល់ចក្ខុ ឬនឹងឃើញដល់ព្រះពុទ្ធសាសនា ក៏ក្នុងសង្សារវដ្តដែលមានទីបំផុត ដែលនរណាតាមទៅដឹងមិនបាន កាលគណនារាប់ខ្លួនឯងដែលជាអ្នកមានភ្នែកខ្វាក់មិនបាន, ហើយព្រះពុទ្ធទាំងឡាយក៏កន្លងទៅច្រើនរយ ច្រើនពាន់ៗអង្គហើយ ក្នុងព្រះពុទ្ធទាំងនោះ ព្រះពុទ្ធសូម្បីតែមួយព្រះអង្គក៏កំណាត់ដឹងមិនបាន, អ្នកបានចងចិត្តទុកក្នុងកាលឥឡូវនេះឯងថានឹងមិនដេករហូតអស់កាល ៣ ខែ ខាងក្នុងវជ្សាភៀងនេះ, ហេតុដូច្នោះ

ចក្ខុរបស់អ្នកវិនាស ឬក៏បែកធ្លាយក៏ដោយចុះ អ្នកចូរទ្រទ្រង់តែព្រះពុទ្ធសាសនាទុកចុះ កុំឃើញដល់ចក្ខុឡើយ” ។ កាលពោលទូន្មានកូតកាយ បានភាសិតគាថាទាំងនេះថា ៖

ចក្ខុទាំងឡាយ ដែលលោករាប់ហើយថាជារបស់ខ្លួន
ចូរសាបសូន្យទៅចុះ ត្រចៀកទាំងឡាយដែលលោក
រាប់ហើយថាជារបស់ខ្លួន ចូរសាបសូន្យចុះ, រាង
កាយក៏ដូចគ្នាដែរ ដែលលោករាប់ហើយថាជារបស់
ខ្លួនចូរសាបសូន្យទៅចុះ, សូម្បីអវយវៈតូច និងអវ-
យវៈធំ ( អវយវៈអាស្រ័យនឹងអវយវៈ ) សូម្បីទាំង
អស់ដែលអាស្រ័យហើយនូវកាយនេះ ចូរសាបសូន្យ
ទៅចុះ, ម្នាលបាលិតៈ ព្រោះហេតុអ្វី ទើបអ្នកប្រមាទ ។
ចក្ខុទាំងឡាយ ដែលលោករាប់ហើយថា ជារបស់ខ្លួន
ចូរគ្រាំគ្រាចុះ ត្រចៀកទាំងឡាយ ដែលលោករាប់
ហើយថាជារបស់ខ្លួន ចូរគ្រាំគ្រាចុះ កាយក៏ដូចគ្នាដែរ

ដែលលោកកាប់ហើយថា ជារបស់ខ្លួន ចូរគ្រាំគ្រាចុះ អវយវៈតូចធំទាំងអស់ ដែលអាស្រ័យនូវកាយនេះ ចូរគ្រាំគ្រាទៅចុះ ម្នាលបាលិតៈ ព្រោះហេតុម្ដេច ទើបបានប្រមាទ ។ ចក្ខុទាំងឡាយ ដែលលោកកាប់ ហើយថាជារបស់ខ្លួន ចូរបែកធ្លាយទៅចុះ ត្រចៀក ទាំងឡាយ ដែលលោកកាប់ហើយថាជារបស់ខ្លួន ចូរ បែកធ្លាយទៅចុះ រូបក៏ដូចគ្នាយ៉ាងនោះទៅចុះ, សូម្បី អវយវៈតូចធំទាំងអស់ដែលអាស្រ័យកាយនេះ ក៏ចូរ បែកធ្លាយទៅចុះ, ម្នាលបាលិតៈ ព្រោះហេតុអ្វី ទើបលោកប្រមាទ ។

## ពេទ្យឈប់ព្យាបាលព្រះមហាបាល

ព្រះថេរៈឲ្យឱវាទដល់ខ្លួនឯង ដោយគាថា ៣ គាថាយ៉ាងនេះ ហើយ បានអង្គុយធ្វើនត្ថុកម្ម ( បន្តក់ភ្នែក ) ហើយទើបចូលទៅកាន់ ស្រុកដើម្បីបិណ្ឌបាត ពេទ្យឃើញហើយសួរថា “លោកម្ចាស់ដ៏ចំរើន

លោកម្ចាស់ធ្វើនត្ថុកម្មហើយឬ" ?

ថ. អើ ឧបាសក ។

ពេទ្យ. យ៉ាងណាដែរ លោកម្ចាស់ ?

ថ. នៅតែចាក់ដោតដដែល ឧបាសក ។

ពេទ្យ. លោកម្ចាស់អង្គុយបន្តក់ ឬសឹងបន្តក់ ?

ព្រះថេរៈបាននៅស្ងៀម, សូម្បីពេទ្យសួរទៀតក៏មិននិយាយអ្វីទាំងអស់ ។

ខណៈនោះ ពេទ្យពោលនឹងលោកថា លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មិនធ្វើនូវសេចក្តីសប្បាយ ចាប់ផ្តើមអំពីថ្ងៃនេះទៅ សូមលោកម្ចាស់កុំពោលឡើយថា ពេទ្យឈ្មោះឯណោះស្ងួប្រេងហើយឲ្យដល់អាត្មា, សូម្បីខ្ញុំម្ចាស់ក៏នឹងមិនពោលថា "អាត្មាអញស្ងួប្រេងប្រគេនលោក" ។

## ព្រះថេរៈបែកធ្លាយចក្ខុព្រមនឹងការសំរេចព្រះអរហត្ត

ព្រះថេរៈត្រូវពេទ្យប្រាប់ថា ឈប់ព្យាបាលហើយ ត្រឡប់ទៅ

កាន់វិហារ ត្រិះរិះថា "សមណៈសូម្បីពេទ្យគេប្រាប់ថាឈប់ព្យាបាលហើយ អ្នកឯងកុំបានលះបង់ឥរិយាបថចោលណាំសមណៈ" ហើយទូន្មានខ្លួនដោយគាថានេះថា ៖

"ម្នាលបាលិតៈ អ្នកត្រូវពេទ្យគេប្រកែកហើយថា ឈប់ព្យាបាលអ្នកទៀតហើយ អ្នកទៀងចំពោះមច្ចុរាជ ព្រោះហេតុអ្វី ទើបនៅប្រមាទទៀត ។

ដូច្នោះហើយ បំពេញសមណធម៌ ។

លំដាប់នោះ លុះមជ្ឈិមយាមកន្លងទៅហើយ ទាំងចក្ខុទាំងកិលេសរបស់លោកក៏បែក ( ព្រមគ្នា ) មិនមុន មិនក្រោយជាងគ្នា លោកជាព្រះអរហន្តសុក្ខវិបស្សកៈ ហើយក៏ចូលទៅគង់ក្នុងបន្ទប់ ។

## ពួកភិក្ខុ និង អ្នកស្រុកជានាទំនុកបម្រុងព្រះថេរៈ

ក្នុងវេលាភិក្ខាចារ ភិក្ខុទាំងឡាយទៅប្រាប់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន វេលានេះ ជាវេលាភិក្ខាចារ ។

ថ. អ្នកមានអាយុទាំងឡាយ ដល់វេលាហើយឬ ?

ភ. ករុណា លោកម្ចាស់ដ៏ចម្រើន ។

ថ. បើដូច្នោះ លោកទាំងឡាយចូរទៅចុះ ។

ភ. បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះលោកម្ចាស់ ?

ថ. ម្នាលអាវុសោទាំងឡាយ ភ្នែករបស់ខ្ញុំបែកធ្លាយហើយ ។

ភិក្ខុទាំងឡាយក្រឡេកមើលភ្នែករបស់លោកហើយ ជាអ្នកមានភ្នែកពេញហើយដោយទឹកភ្នែក លួងលោមព្រះថេរៈថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកកុំព្រួយបារម្ភឡើយ, យើងខ្ញុំទាំងឡាយនឹងបដិបត្តិលោក" ដូច្នោះហើយ ធ្វើវត្តតូច និងវត្តធំដែលខ្លួនគួរធ្វើស្រេចហើយចូលទៅកាន់ស្រុក ។ ពួកមនុស្សមិនឃើញព្រះថេរៈសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់របស់ខ្ញុំព្រះករុណាទាំងឡាយទៅខាងណា" ដឹងដំណឹងនុ៎ះហើយ បញ្ជូនបបរទៅមុន ហើយកាន់យកបិណ្ឌបាតទៅខ្លួនឯង ថ្វាយបង្គំព្រះថេរៈហើយ ស្រែកយំបម្រះនទៀលទៀបទីជិតនៃព្រះបាទ ( របស់ព្រះថេរៈ ) លួងលោមថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំព្រួយបារម្ភឡើយ

ខ្ញុំម្ចាស់ទាំងឡាយនឹងជានាបម្រើលោកម្ចាស់” ហើយត្រឡប់ទៅកាន់ផ្ទះវិញ ។ តាំងពីនោះមក គេក៏បញ្ជូនបបរ និងកត្តទៅថ្វាយឯវិហារជានិច្ច ។

ចំណែកព្រះថេរៈ ក៏ឲ្យឱវាទភិក្ខុ ៦០ រូបក្រៅពីនេះជានិច្ច ។

ភិក្ខុទាំងឡាយតាំងនៅក្នុងឱវាទរបស់លោក ។ លុះជិតថ្ងៃបវារណាក៏សម្រេចអរហត្តព្រមទាំងបដិសម្ភិទាគ្រប់រូប ។

## ពួកភិក្ខុទៅគាល់ព្រះសាស្តា

ក៏ឯភិក្ខុទាំងឡាយចេញវស្សាហើយ ប្រាថ្នានឹងគាល់ព្រះ-សាស្តា ទើបប្រាប់ព្រះថេរៈថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំករុណាទាំងឡាយ ប្រាថ្នានឹងគាល់ព្រះសាស្តា” ។

ព្រះថេរៈបានស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយហើយ គិតថា “យើងជាមនុស្សទុព្វលភាពហើយ ក្នុងចន្លោះនៃផ្លូវមានព្រៃ ដែលអមនុស្សកាន់កាប់ កាលបើអញទៅជាមួយនឹងភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយនឹងលំបាក និងមិនអាចដើម្បីបាននូវភិក្ខា អញនឹងបញ្ជូន

ភិក្ខុទាំងនេះទៅមុន” ។ លំដាប់នោះ ព្រះថេរៈក៏ពោលនឹងភិក្ខុទាំងនោះថា “ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយទៅមុនចុះ” ។

ភ. បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះលោកម្ចាស់ ។

ថ. ខ្ញុំករុណាជាអ្នកទុព្វលភាពហើយ មិនត្រឹមតែប៉ុណ្ណោះ ដងព្រៃក្នុងចន្លោះផ្លូវជាប្រទេស គឺអមនុស្សគ្រាន់កាប់ហើយ កាលបើខ្ញុំទៅជាមួយនឹងលោកទាំងឡាយ លោកទាំងឡាយនឹងលំបាកទាំងអស់អង្គ លោកទាំងឡាយ ចូរទៅមុនចុះ ។

កុំធ្វើយ៉ាងនេះឡើយ លោកម្ចាស់ ពួកខ្ញុំករុណាទាំងឡាយនឹងទៅព្រមជាមួយនឹងលោកម្ចាស់ ។

ថ. “ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយកុំពេញចិត្តយ៉ាងនេះឡើយ, កាលបើដូច្នោះ ការមិនសប្បាយនឹងមានដល់ខ្ញុំ, ប្អូនប្រុសរបស់ខ្ញុំឃើញលោកទាំងឡាយហើយគង់នឹងសួរ កាលបើដូច្នោះ លោកទាំងឡាយគប្បីប្រាប់ការដែលចក្ខុរបស់ខ្ញុំសាបសូន្យហើយដល់គេ គេគង់នឹងបញ្ជូននរណាៗមកកាន់សំណាក់របស់ខ្ញុំៗ

នឹងទៅជាមួយគេ លោកទាំងឡាយចូរថ្វាយបង្គំព្រះទសពល និង អសីតិមហាថេរៈតាមពាក្យរបស់ខ្ញុំ” ដូច្នេះហើយ ក៏បញ្ជូនភិក្ខុទាំង នោះទៅ ។

## ពួកភិក្ខុប្រាប់ដំណឹងដល់ប្អូនប្រុសរបស់ព្រះថេរៈ

ភិក្ខុទាំងឡាយ ខមាទោសព្រះថេរៈហើយ ចូលទៅកាន់ខាង ក្នុងស្រុក ។ ពួកមនុស្សនិមន្តឲ្យគង់ថ្វាយភិក្ខា ហើយសួរថា “បពិត្រ លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយនឹងនិមន្តទៅណាឬ”?

ភិក្ខុទាំងឡាយឆ្លើយថា “អើ ឧបាសក ឧបាសិកាទាំងឡាយ ពួកអាត្មា ចង់គាល់ព្រះសាស្ដា” ។

ពួកឧបាសកឧបាសិកាអង្វរច្រើនដងហើយ ដឹងការពេញចិត្ត ក្នុងការដែលភិក្ខុទាំងឡាយនឹងទៅឲ្យទាល់តែបាន ទើបតាមទៅហើយ ខ្សឹកខ្សួលត្រឡប់មកវិញ ។

ចំណែកភិក្ខុទាំងឡាយទៅដល់វត្តជេតពនដោយលំដាប់ ថ្វាយ បង្គំព្រះសាស្ដា និងមហាថេរៈទាំងឡាយតាមពាក្យរបស់ព្រះថេរៈ

ហើយ, លុះព្រឹកឡើង ចូលទៅកាន់ផ្ទះដែលប្អូនប្រុសរបស់ព្រះថេរៈអាស្រ័យនៅដើម្បីបិណ្ឌបាត ។ កុដុម្ពិកចាំភិក្ខុទាំងឡាយបាននិមន្តឲ្យគង់ ធ្វើបដិសណ្ឋារៈ ហើយសួរថា “ព្រះថេរៈជាបងរបស់ខ្ញុំម្ចាស់នៅទីណា” ?

លំដាប់នោះ ភិក្ខុទាំងឡាយ ប្រាប់ដំណឹងនោះដល់កុដុម្ពិក ។

កុដុម្ពិកស្រែកយំបម្រះននៀល នៅទៀបទីជិតបាទមូលរបស់ភិក្ខុទាំងឡាយ សួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ គួរធ្វើយ៉ាងណាទើបល្អ ?

## បញ្ជូនសាមណេរជាក្មួយប្រុសទៅទទួលព្រះថេរៈ

ក. ព្រះថេរៈត្រូវការឲ្យនរណាមួយទៅអំពីទីនេះ, ក្នុងកាលនៃបុរសនោះទៅដល់ហើយ លោកនឹងមកជាមួយគេ ។

ក. បពិត្រលោកម្ចាស់ដ៏ចម្រើន បុរសនេះជាក្មួយរបស់ខ្ញុំឈ្មោះបាលិតៈ សូមលោកទាំងឡាយចូរបញ្ជូនបុរសឈ្មោះបាលិតៈនេះទៅចុះ ។

ក. បញ្ជូនទៅយ៉ាងនេះមិនបាន ( ព្រោះ ) អន្តរាយក្នុងចន្លោះនៃផ្លូវមាន, ត្រូវឲ្យបួសហើយសឹមទៅ ទើបនឹងគួរ ។

ក. បពិត្រលោកដ៏ចម្រើន សូមលោកទាំងឡាយចូរធ្វើយ៉ាងនោះហើយ បញ្ជូនទៅចុះ ។

គ្រានោះ ភិក្ខុទាំងឡាយឲ្យគេបួសហើយ បង្ហាត់ឲ្យសិក្សានូវវត្តបដិបត្តិ មានទទួលចីវរជាដើមអស់កន្លះខែហើយ ប្រាប់ផ្លូវឲ្យហើយ បញ្ជូនទៅ ។

សាមណេរទៅដល់ស្រុកនោះដោយលំដាប់ ឃើញបុរសចាស់ម្នាក់ទៀបទ្វារនៃស្រុក ទើបសួរថា “វិហារដែលតាំងនៅក្នុងព្រៃ អាស្រ័យស្រុកនេះមានឬទេ” ?

ប. បពិត្រលោកម្ចាស់ដ៏ចម្រើន មាន ។

ស. លោកម្ចាស់អង្គណាគង់ក្នុងវិហារនោះ ?

ប. ព្រះថេរៈឈ្មោះ បាលៈ លោកម្ចាស់ ។

ស. សូមញោមប្រាប់ផ្លូវដល់អាត្មាភាពបន្តិច ។

ប. លោកម្ចាស់ជានរណា ?

ស. អាត្មាភាពជាក្មួយរបស់ព្រះថេរៈ ។

## សាមណេរបបួលព្រះមហាថេរៈត្រឡប់ទៅវិញ

ខណៈនោះ បុរសចាស់នោះ នាំសាមណេរទៅកាន់វិហារ សាមណេរក៏ថ្វាយបង្គំព្រះថេរៈ ហើយធ្វើវត្តបដិបត្តិ បម្រើព្រះថេរៈ ដោយល្អអស់កន្លះខែ ហើយប្រាប់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន កុដុម្ពិក៏ជាអ៊ុំរបស់ខ្ញុំត្រូវការឲ្យលោកម្ចាស់ត្រឡប់ទៅវិញ សូមលោកម្ចាស់ទៅជាមួយខ្ញុំចុះ" ។

ព្រះថេរៈពោលថា "បើដូច្នោះ លោកចូរចាប់ចុងឈើច្រត់របស់យើងចុះ" ។ សាមណេរចាប់ចុងឈើច្រត់ចូលទៅកាន់ស្រុកជាមួយនឹងព្រះថេរៈ ។ ពួកមនុស្សនិមន្តឲ្យគង់ ហើយសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់នឹងនិមន្តទៅណា" ? ព្រះថេរៈឆ្លើយថា "អើ ឧបាសកឧបាសិកាទាំងឡាយ អាត្មានឹងនិមន្តទៅថ្វាយបង្គំព្រះសាស្តា" ។ ពួកមនុស្សទាំងនោះអង្វរ ដោយប្រការផ្សេងៗ

( កាលមិនបានសមដូចបំណង ) ក៏ជូនព្រះថេរៈទៅបានពាក់កណ្តាលផ្លូវហើយ នាំគ្នាវិ្រកវ្រលត្រឡប់មកវិញ ។

## សាមណេរដល់ការវិបត្តិសីលព្រោះសំឡេងស្ត្រី

សាមណេរនាំព្រះថេរៈដោយចុងឈើច្រត់ទៅដល់ស្រុក ដែលព្រះថេរៈធ្លាប់អាស្រ័យនៅឈ្មោះ សក្កដ្ឋៈ នៅហើយក្នុងព្រៃចន្លោះផ្លូវ ។

លោកបានឮសំឡេងច្រៀងរបស់ស្ត្រីម្នាក់ ដែលជាអ្នកចេញអំពីស្រុកនោះហើយ ច្រៀងបណ្តើររើសឧសបណ្តើរនៅក្នុងព្រៃ កាន់យកនិមិត្តក្នុងសំឡេងនោះ ។

ពិតណាស់ មិនមានសំឡេងដទៃ ដែលអាចផ្សាយទៅពាសពេញសរីរៈរបស់បុរសទាំងឡាយ តាំងនៅដូចជាសំឡេងស្ត្រីឡើយ, ហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយតថាគតមិនឃើញសំឡេងដទៃសូម្បីតែមួយ ដែលនឹងញាំងចិត្តរបស់បុរសទាំងឡាយ ឲ្យតាំងនៅដូចជាសំឡេងស្ត្រីឡើយ” ។

សាមណេរកាន់យកនិមិត្តក្នុងសំឡេងនោះហើយ ព្រលែងចុង ឈើប្រត់ ហើយពោលថា "បពិត្រលោកដ៏ចម្រើន សូមលោករង់ចាំ បន្តិចសិន, កិច្ចរបស់ខ្ញុំមាន" ដូច្នេះហើយទៅកាន់សំណាក់របស់ស្ត្រី នោះ ។ នាងឃើញសាមណេរហើយបានឈប់ស្ងៀម ។ សាមណេរ បានដល់ការវិបត្តិសីលជាមួយនឹងនាង ។ ព្រះថេរៈគិតថា "យើងបាន ឮសំឡេងច្រៀងក្នុងកាលអម្បាញ់មិញនេះឯង, ក៏សំឡេងនោះសោត ជាសំឡេងស្ត្រី សូម្បីសាមណេរក៏ទៅបាត់យូរ, លោកនឹងដល់ការ វិនាសសីលពិតប្រាកដហើយ" ចំណែកសាមណេរនោះ ធ្វើកិច្ចរបស់ ខ្លួនស្រេចហើយ មកនិយាយថា បពិត្រលោកម្ចាស់ យើងទាំង-ឡាយបន្តដំណើរទៅមុខទៀតចុះ ។

ខណៈនោះ ព្រះថេរៈសួរលោកថា "សាមណេរអ្នកក្លាយជា មនុស្សអាក្រក់ហើយឬ" ? លោកនៅស្ងៀម សូម្បីព្រះថេរៈសួរទៀត ក៏មិននិយាយអ្វីៗ ទាំងអស់ ។

## ព្រះថេរៈមិនព្រមឲ្យសាមណេរគប់រក

លំដាប់នោះ ព្រះថេរៈពោលនឹងលោកថា "កិច្ចដោយការដែលមនុស្សអាក្រក់ដូចអ្នកចាប់ឈើប្រត់របស់យើងមិនចាំបាច់" ។ សាមណេរដល់នូវការសង្វេគ ហើយដោះសំពត់កាសាយៈចេញ ហើយស្លៀកដណ្ដប់ដូចគ្រហស្ថនិយាយថា "បពិត្រលោកដ៏ចម្រើន កាលមុនខ្ញុំជាសាមណេរ តែឥឡូវនេះ ខ្ញុំត្រឡប់ជាគ្រហស្ថហើយ, ម្យ៉ាងទៀត កាលខ្ញុំបួសក៏មិនបានបួសដោយសទ្ធា បួសព្រោះខ្លាចអន្តរាយក្នុងចន្លោះផ្លូវ សូមលោកម្ចាស់មក ទៅជាមួយខ្ញុំចុះ ។

ព្រះថេរៈនិយាយថា "អ្នកមានអាយុ គ្រហស្ថអាក្រក់ក្ដី សមណៈអាក្រក់ក្ដី ក៏អាក្រក់ដូចតែគ្នា, អ្នកសូម្បីតាំងនៅក្នុងភាពជាសាមណេរហើយ ក៏មិនអាចដើម្បីធ្វើគុណត្រឹមតែសីលឲ្យបរិបូណ៌បាន ជាគ្រហស្ថនឹងធ្វើសេចក្ដីល្អអ្វីបាន, កិច្ចដោយការដែលមនុស្សអាក្រក់ដូចអ្នកចាប់ចុងឈើប្រត់របស់យើង មិនចាំបាច់មាន" ។

នាយបាលិតៈឆ្លើយថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ផ្លូវមាន

អមនុស្សច្រើន ហើយចក្ខុរបស់លោកម្ចាស់ក៏បែក នឹងនៅក្នុងទីនេះយ៉ាងណាបាន" ។

លំដាប់នោះ ព្រះថេរៈពោលនឹងគេថា "អ្នកមានអាយុ អ្នកកុំអាលគិតយ៉ាងនោះឡើយ, យើងនឹងដេកស្លាប់ក្នុងទីនេះក្តី នឹងដេកនទៀលទៅមកនៅក្នុងទីនេះក្តី ដែលឈ្មោះថា ការទៅជាមួយនឹងអ្នករមែងមិនមាន" ( លុះពោលយ៉ាងនេះហើយ ) បានពោលគាថាទាំងនេះថា ៖

ណ្ហើយចុះ យើងជាអ្នកមានចក្ខុខូចហើយ មកកាន់
ផ្លូវឆ្ងាយកន្តារៈ ដេកនៅ ( ក៏ដោយចុះនឹងមិនទៅ )
ព្រោះភាពជាសម្លាញ់ក្នុងជនពាលរមែងមិនមាន ។
ណ្ហើយចុះ យើងជាអ្នកមានចក្ខុខូចហើយ មកកាន់
ផ្លូវឆ្ងាយកន្តារៈ នឹងស្លាប់ក៏ដោយចុះនឹងមិនទៅ,
ព្រោះភាពជាសម្លាញ់នឹងជនពាល រមែងមិនមាន ។

នាយបាលិតៈ បានឮពាក្យនោះហើយ កើតសេចក្តីសង្វេគ

នឹកថា "យើងធ្វើកម្មធ្ងន់ ប្រព្រឹត្តទៅដោយរហ័សមិនសមគួរហ្ន៎" ដូច្នេះ ហើយ ខ្សឹកខ្សួលស្អុះចូលទៅកាន់ព្រៃ បានគេចចេញទៅដោយប្រការ ដូច្នេះឯង ។

## អាសនៈសក្កទេវរាជក្តៅ

ដោយតេជៈនៃសីលរបស់ព្រះថេរៈ ( ខណៈនោះ ) បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កទេវរាជបណ្តោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ មានពណ៌ដូចផ្កាជ័យព្រឹក្ស មានប្រក្រតីស្រុតចុះក្នុងវេលាប្រថាប់គង់ និងប៉ោងឡើងក្នុងវេលាស្តេចក្រោកឡើង សម្តែងអាការក្តៅ ។ សក្កទេវរាជទ្រង់ត្រិះរិះថា "នរណាហ្ន៎ ប្រាថ្នានឹងញុំាងយើងឲ្យឃ្លាតចាកឋាន" ? ដូច្នេះហើយ ទ្រង់ក្រឡេកចុះមក បានឃើញព្រះថេរៈដោយទិព្វចក្ខុ ។

ហេតុនោះព្រះបូរាណាចារ្យទាំងឡាយ ទើបពោលថា ៖

សហស្សនេត្រ ដែលជាស្តេចនៃពួកទេវតា មើលដោយ
ទិព្វចក្ខុ ( ទ្រង់ជ្រាបថា ) ព្រះបាលត្ថេរអង្គនេះ តិះដៀល

បុគ្គលបាប ជម្រះគ្រឿងចិញ្ចឹមជីវិតឲ្យបរិសុទ្ធហើយ, សហស្សនេត្រដែលជាស្តេចនៃទេវតា, ទ្រង់ក្រឡេក មើលដោយទិព្វចក្ខុហើយ ( ទ្រង់ជ្រាបថា ) ព្រះបាលត្ថេរ អង្គនេះជូន់ក្នុងធម៌ គ្រេកអរក្នុងសាសនា អង្គុយនៅ ហើយក្នុងព្រៃ ។

ខណៈនោះ សក្កទេវរាជបានទ្រង់ត្រិះរិះថា“បើយើងនឹងមិនទៅ កាន់សំណាក់របស់លោក ដែលជាអ្នកតិះដៀលបុគ្គលបាប ជូន់ក្នុង ធម៌បែបនោះ ក្បាលរបស់យើងគប្បីបែកជា ៧ ចំណែក, យើងនឹង ទៅកាន់សំណាក់របស់លោក” ( លុះទ្រង់ព្រះតម្រិះដូច្នោះហើយ ក៏ ស្តេចយាងទៅ ) ។

ហេតុនោះ ( បូរាណាចារ្យទាំងឡាយទើបពោលថា ) “លំដាប់ នោះ ទេវរាជឈ្មោះសក្កសហស្សនេត្រមានព្រះនេត្រជ្រាបនូវហេតុ កំណត់ដោយពាន់ ជាធំជាងទេវតា ទ្រទ្រង់សិរីរបស់ទេវរាជ ស្តេច មកហើយដោយមួយរំពេច ចូលទៅជិតព្រះចក្ខុបាលត្ថេរ” ។

លុះស្តេចចូលទៅជិតហើយ បានទ្រង់ធ្វើសំឡេងនៃជើងក្នុងទីជិតព្រះថេរៈ ។

ខណៈនោះ ព្រះថេរៈសួរសក្កទេវរាជថា "នរណាហ្នឹង" ?

សក្កទេវរាជឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើនខ្ញុំជាអ្នកដើរផ្លូវឆ្ងាយ ( ជាអ្នកដំណើរ ) ។

ថ. ឧបាសក អ្នកនឹងទៅទីណា ?

ស. បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំនឹងទៅកាន់ក្រុងសាវត្ថី ។

ថ. ទៅចុះ អ្នកមានអាយុ ។

ស. ក៏លោកម្ចាស់ដ៏ចម្រើន នឹងទៅកាន់ទីណា ?

ថ. សូម្បីអាត្មាភាពក៏នឹងទៅកាន់ទីនោះដែរ ។

ស. បើដូច្នោះ យើងទាំងឡាយទៅជាមួយគ្នាចុះ លោកម្ចាស់ ។

ថ. យើងជាមនុស្សទុព្វលភាព, ការយឺតយូរនឹងមានដល់អ្នកដែលទៅជាមួយនឹងយើង ។

ស. កិច្ចប្រញាប់របស់ខ្ញុំមិនមាន សូម្បីខ្ញុំម្ចាស់នឹងទៅជាមួយ

លោកម្ចាស់ នឹងបានបុញ្ញកិរិយាវត្ថុ ១០ ប្រការ ប្រការណានីមួយ, យើងទាំងឡាយទៅជាមួយគ្នាចុះ លោកម្ចាស់ ។

ព្រះថេរៈគិតថា "នុ៎ះនឹងជាសប្បុរស" ទើបពោលថា "បើយ៉ាងនោះ ចាប់ចុងឈើច្រត់របស់អាត្មាភាពចុះ ឧបាសក" ។

## សក្កទេវរាជនាំព្រះថេរៈទៅដល់វត្តជេតពន

សក្កទេវរាជ ទ្រង់ធ្វើយ៉ាងនោះហើយ បំព្រួញផែនដីឲ្យដល់វត្តជេតពន ក្នុងវេលាសៀល ។

ព្រះថេរៈបានឮសូរសំឡេងតន្ត្រី មានស័ង្ខ និងរនាត ជាដើម ហើយសួរថា "សំឡេងហ្នឹងនៅទីណា" ?

ស. ក្រុងសាវត្ថី លោកម្ចាស់ ។

ថ. ក្នុងវេលាទៅ អាត្មាទៅដោយកាលយូរណាស់ ។

ស. ខ្ញុំដឹងផ្លូវត្រង់ លោកម្ចាស់ ។

ក្នុងខណៈនោះ ព្រះថេរៈដឹងបានថា "អ្នកនេះមិនមែនមនុស្សប្រាកដជាទេវតា" ។

( ហេតុនោះព្រះបូរាណាចារ្យទាំងឡាយ ទើបពោលថា )

"សក្កទេវរាជ ដែលជាស្តេចនៃទេវតា ទ្រទ្រង់សិរីរបស់ទេវរាជ ស្តេចបំប្រួញផ្លូវនោះស្តេចមកដល់ក្រុងសាវត្ថីយ៉ាងឆាប់រហ័ស"។

សក្កទេវរាជនាំព្រះថេរៈទៅកាន់បណ្ណសាលា ដែលកុដុម្ពិកជាប្អូនប្រុសធ្វើដើម្បីប្រយោជន៍ដល់ព្រះថេរៈនោះឯង និមន្តឲ្យគង់លើបន្ទះក្តារ ហើយនិម្មិតខ្លួនជាសម្លាញ់ ជាទីស្រឡាញ់ទៅកាន់សំណាក់នៃកុដុម្ពិកចុល្លបាល ត្រាស់ស្រែកហៅថា "នែ៎ បាលៈសម្លាញ់" ។

កុដុម្ពិកចុល្លបាលស្រែកសួរថា ( ស្អី ? សម្លាញ់ )

សក្ក. លោកដឹងកាលដែលព្រះថេរៈមកហើយឬ ?

ខ្ញុំមិនទាន់ដឹង, ក៏ព្រះថេរៈមកហើយឬ ?

សក្កទេវរាជត្រាស់ថា "អើ សម្លាញ់ ខ្ញុំទៅកាន់វិហារឃើញព្រះថេរៈគង់នៅក្នុងបណ្ណសាលា ដែលលោកធ្វើអម្បាញមិញនេះឯង" ដូច្នោះហើយ ស្តេចក៏គេចចេញទៅ ។

ចំណែកកុដុម្ពិកទៅដល់វិហារ ឃើញព្រះថេរៈហើយ ស្រែក

យំបម្រះនទៀលនៅទៀបហ្នឹងបាទមូល ពោលថា “លោកម្ចាស់ដ៏ចម្រើន ខ្ញុំឃើញហេតុនេះហើយ ទើបមិនព្រមឲ្យលោកបួស” ដូច្នោះជាដើម ហើយធ្វើក្មេងទាសៈពីរនាក់ឲ្យជាអ្នកជា ឲ្យបួសក្នុងសំណាក់របស់ព្រះថេរៈ ហើយផ្តាំថា “លោកទាំងឡាយ ចូរនាំយករបស់ឆាន់មានបបរ និងបាយជាដើម មកអំពីខាងក្នុងស្រុកឧបដ្ឋាកព្រះថេរៈ” ដូច្នេះហើយប្រគល់កិច្ចនោះឲ្យធ្វើ ។ សាមណេរទាំងឡាយក៏ធ្វើវត្តបម្រើព្រះថេរៈ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយអ្នកនៅក្នុងទិស ( អ្នកនៅក្នុងទីដទៃ ) មកកាន់វត្តជេតពនដោយសង្ឃឹមថា “នឹងគាល់ព្រះសាស្តា” ថ្វាយបង្គំព្រះសាស្តា សួរសុខទុក្ខព្រះអសិតីមហាសាវក ហើយត្រាច់ចារិកទៅក្នុងវិហារ ដល់លំនៅព្រះចក្ខុបាលត្ថេរហើយ មានមុខឆ្ពោះទៅទីនោះនៅវេលារសៀល ដោយសង្ឃឹមថា “នឹងមើលសូម្បីទីនេះ”។

ក្នុងខណៈនោះ មហាមេឃតាំងឡើងហើយ ។ ពួកលោកគិតថា “ឥឡូវនេះរសៀលហើយ, ហើយមេឃក៏តាំងឡើងហើយ” យើងនឹងមកមើលពេលព្រឹក ដូច្នេះហើយ ក៏ត្រឡប់ទៅវិញ ។ ភ្លៀងធ្លាក់

ក្នុងបឋមយាម ឈប់ក្នុងមជ្ឈិមយាម ។ ព្រះថេរៈជាអ្នក ( ធ្លាប់ ) ប្រារព្ធសេចក្ដីព្យាយាមដើរចង្រ្កមជានិច្ច, ហេតុដូច្នេះ ទើបចុះកាន់ទីចង្រ្កម ហើយក្នុងបច្ឆិមយាម ។ ក៏ក្នុងកាលនោះ មេភ្លៀងជាច្រើនកើតឡើង ហើយលើផ្ទៃដីដែលមានភ្លៀងធ្លាក់ថ្មីៗ ។ មេភ្លៀងទាំងនោះ កាលព្រះថេរៈចង្រ្កមបានវិបត្តិ ( ស្លាប់ ) ដោយច្រើន ។

ពួកអន្តេវាសិក នៅបានមិនទាន់បោសទីចង្រ្កមរបស់ព្រះថេរៈពីព្រលឹម រីឯពួកភិក្ខុក្រៅពីនេះមកដោយសង្ឃឹមថា "នឹងមើលលំនៅរបស់ព្រះថេរៈ" ឃើញសត្វទាំងឡាយក្នុងទីចង្រ្កមហើយ សួរថា "នរណាចង្រ្កមក្នុងទីនេះ" ពួកសិស្សរបស់ព្រះថេរៈឆ្លើយថា "ឧបជ្ឈាយ៍របស់ពួកខ្ញុំករុណា លោកម្ចាស់" ។ ភិក្ខុទាំងឡាយតិះដៀលថា "អ្នកទាំងឡាយចូរមើលកម្មរបស់សមណៈចុះ ក្នុងកាលដែលមានចក្ខុលោកដេកមិនធ្វើអ្វី ក្នុងកាលមានចក្ខុវិកល ឥឡូវនេះទុកខ្លួនថា ចង្រ្កមធ្វើសត្វមានប្រមាណប៉ុណ្ណេះឲ្យស្លាប់ ហើយលោកគិតថា "នឹងធ្វើប្រយោជន៍" ត្រឡប់ជាការធ្វើមិនជាប្រយោជន៍" ហើយពួកភិក្ខុទៅក្រាប

ទូលព្រះតថាគតក្នុងខណៈនោះថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះចក្ខុ-បាលត្ថេរទុកខ្លួនថា ( ចង្រ្កម ) ធ្វើសត្វមានជីវិតជាច្រើនឲ្យស្លាប់ហើយ" ។

ព្រះសាស្តាទ្រង់ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយឃើញ លោកកំពុងធ្វើសត្វមានជីវិតជាច្រើនឲ្យស្លាប់ហើយឬ" ។

ភិក្ខុទាំងនោះ ក្រាបទូលថា "មិនឃើញទេព្រះអង្គ" ។

ស. អ្នកទាំងឡាយមិនឃើញលោក ( ធ្វើដូច្នោះ ) យ៉ាងណា សូម្បីលោកក៏មិនឃើញសត្វមានជីវិតទាំងនោះដូច្នោះដែរ ម្នាលភិក្ខុទាំង-ឡាយដែលឈ្មោះថា ចេតនាជាហេតុឲ្យស្លាប់របស់ព្រះខីណាស្រពទាំងឡាយ ( គឺបុគ្គលអ្នកមានអាសវៈអស់ហើយ ) រមែងមិនមាន ។

ភ. បពិត្រព្រះអង្គដ៏ចម្រើន កាលឧបនិស្ស័យនៃព្រះអរហត្តមានហេតុដូចម្តេច ទើបលោកក្លាយជាអ្នកមានចក្ខុងងឹត ។

ស. ម្នាលភិក្ខុទាំងឡាយ ដោយអំណាចកម្មដែលខ្លួនធ្វើទុកហើយ ។

ភ. បពិត្រព្រះអង្គដ៏ចំរើន ក៏លោកបានធ្វើកម្មអ្វីទុក ។

## បុព្វកម្មរបស់ព្រះចក្ខុបាល

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះអ្នកទាំងឡាយចូរស្តាប់" ដូច្នេះហើយ ( ត្រាស់និទានរឿងថា ) ៖

ក្នុងអតីតកាល កាលព្រះបាទពារាណសី គ្រប់គ្រងរាជ-សម្បត្តិនៅក្នុងក្រុងពារាណសី ពេទ្យម្នាក់ត្រាច់ធ្វើវេជ្ជកម្មនៅក្នុងស្រុក និងនិគម ឃើញស្ត្រីអ្នកទុព្វលដោយចក្ខុម្នាក់ទើបសួរថា "ការមិនសប្បាយរបស់នាងតើដូចម្តេច " ?

ស្ត្រីនោះឆ្លើយថា "ខ្ញុំមើលមិនឃើញដោយភ្នែកទាំងឡាយ" ។

ពេទ្យពោលថា "ខ្ញុំនឹងធ្វើថ្នាំឲ្យដល់នាង" ។

ស. បពិត្រលោកម្ចាស់ លោកចូរធ្វើចុះ ។

ព. នាងនឹងឲ្យអ្វីដល់ខ្ញុំ ?

ស. ប្រសិនបើលោកអាចនឹងធ្វើនូវភ្នែកទាំងឡាយរបស់ខ្ញុំឲ្យត្រឡប់ជាប្រក្រតីបាន, ខ្ញុំ និងបុត្រធីតានឹងព្រមធ្វើជាទាសាទាសី

របស់លោក ។

៣. ទទួលថា "ល្អហើយ" ដូច្នេះហើយ ផ្សំថ្នាំឲ្យហើយ, ភ្នែកទាំងឡាយត្រឡប់ជាប្រក្រតី ដោយថ្នាំតែមួយមុខប៉ុណ្ណោះ ។

ស្ត្រីនោះគិតហើយថា "យើងបានប្តេជ្ញាចំពោះពេទ្យនោះថា "យើង និងបុត្រធីតាព្រមជាទាសាទាសីរបស់គេ" ក៏ប៉ុន្តែគេមុខជានឹងមិនហៅរកយើងដោយវាចាដែលទន់ភ្លន់ទេ យើងនឹងបញ្ឆោតគេ" ។ នាងដែលពេទ្យមកហើយសួរថា "ម្នាលនាងដ៏ចម្រើន រោគក្នុងភ្នែករបស់នាងដូចម្តេចទៅហើយ" ? ឆ្លើយថា "ក្នុងកាលមុន ភ្នែកទាំងឡាយរបស់ខ្ញុំ ចាក់ដោតបន្តិចបន្តួច ក្នុងកាលឥឡូវនេះចាក់ដោតលើសលប់" ។ ពេទ្យគិតថា ស្ត្រីនេះជាអ្នកចង់ដើម្បីនឹងបញ្ឆោតនូវយើង ហើយមិនឲ្យនូវវត្ថុតិចតួច សេចក្តីត្រូវការរបស់យើងដោយថ្លៃឈ្នួល ដែលស្ត្រីនេះឲ្យដល់យើងមិនមាន, យើងនឹងធ្វើស្ត្រីនេះឲ្យខ្វាក់ក្នុងកាលឥឡូវនេះ" ហើយទៅដល់ផ្ទះប្រាប់សេចក្តីនេះដល់ភរិយា ។ នាងបាននៅស្ងៀម ។ ពេទ្យនោះផ្សំថ្នាំមួយមុខ ហើយក៏ទៅ

កាន់សំណាក់ស្ត្រីនោះ ដោយប្រាប់ឲ្យបន្តក់ថ្នាំថា "ម្នាលនាងដ៏ចម្រើន ចូរនាងបន្តក់ថ្នាំនេះ" ។ ភ្នែកទាំងពីរខាងបានរលត់ហើយ ដូចអណ្តាតប្រទីប ។ ពេទ្យនោះបាន ( មកកើត ) ជាចក្ខុបាលភិក្ខុ ក្នុងកាលឥឡូវនេះ ។

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កម្មដែលបុត្រតថាគតធ្វើហើយក្នុងកាលនោះជាប់តាមគេអំពីក្រោយៗ ។ពិតណាស់ ដែលឈ្មោះថាបាបកម្មនេះ រមែងជាប់តាមអ្នកធ្វើ ដូចកង់រិលតាមស្នាមជើងគោ ( គឺគោដែលគេទឹមរទេះផ្ទុកទំនិញ ) គោនាំទៅនូវធុរៈ" លុះទ្រង់ត្រាស់រឿងនេះហើយ ព្រះអង្គជាធម្មរាជា ទ្រង់បានត្រាស់ព្រះគាថានេះបន្តអនុសន្ធិ ដូចប្រថាប់ព្រះរាជសាសន៍ ដែលមានដីប្រថាំទុកហើយដោយព្រះរាជលញ្ចក្ក ( ត្រារបស់ព្រះរាជា ) ថា ៖

១ មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត ( មានចិត្តជាធំ ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី ( នូវទុច្ចរិត ) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមជានជើងគោដែលកំពុងអូសនឹមទៅ ។

## អធិប្បាយគាថា

ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ សូម្បីទាំងអស់ មានកាមាវចរកុសលចិត្តជាដើម ឈ្មោះថា “មនោ” ក្នុងព្រះគាថានោះ ។ ប៉ុន្តែក្នុងបទនេះ កាលពោលដោយចិត្តដែលកើតឡើងដល់ពេទ្យនោះក្នុងកាលនោះ រមែងបានចំពោះចិត្តដែលប្រព្រឹត្តដោយទោមនស្សប្រកបដោយបដិឃៈ ( តែម្យ៉ាង ) ។

បទថា **បុព្វង្គមា** គឺប្រកបព្រមហើយដោយចិត្តនោះ ដែលជាធម្មជាតិ មានប្រក្រតីប្រព្រឹត្តទៅមុន ។

បទថា **ធម្មា** គឺ ឈ្មោះថាធម៌មាន ៤ យ៉ាង ដោយអំណាច

គុណធម៌ ទេសនាធម៌ បរិយត្តិធម៌ និងនិស្សត្តនិជ្ជីវធម៌ ។ ក្នុងបណ្តាធម៌ ៤ ប្រការនោះ ធម្មស័ព្ទនេះក្នុងពាក្យថា “ធម៌ និងអធម៌ពីរប្រការឲ្យផលមិនដូចគ្នា អធម៌រមែងនាំទៅកាន់នរក ធម៌រមែងឲ្យដល់សុគតិ” ។

ដូច្នេះឈ្មោះថា គុណធម៌ (ប្រែថា ធម៌ គឺគុណ)។ ធម្មស័ព្ទក្នុងពាក្យថា “ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌មានលម្អបទដើមដល់អ្នកទាំងឡាយ” ដូច្នេះជាដើម ឈ្មោះថាទេសនាធម៌ (ប្រែថា ធម៌ គឺទេសនា) ។ ធម្មស័ព្ទក្នុងពាក្យថា “ម្នាលភិក្ខុទាំងឡាយ កុលបុត្រពួកខ្លះក្នុងលោកនេះ រមែងរៀនធម៌ គឺ សុត្តៈ, គេយ្យៈ ដូច្នេះជាដើម ឈ្មោះថា បរិយត្តិធម៌ ( ប្រែថា ធម៌ គឺបរិយត្តិ ) ។ ធម្មស័ព្ទក្នុងពាក្យនេះថា សម័យនោះឯងធម៌ទាំងឡាយ គឺខន្ធរមែងមាន” ដូច្នេះជាដើម ឈ្មោះថា និស្សត្តធម៌ ( ប្រែថា ធម៌ គឺសភាវៈដែលមិនមែនសត្វ ) សូម្បីន័យក្នុងបទថា “និជ្ជីវធម៌” ដែលប្រែថា ( ធម៌ គឺសភាវៈមិនមែនជីវៈ ) ក៏ដូចគ្នា ។ ក្នុងបណ្តាធម៌ ៤ ប្រការ

នោះ និស្សត្តធម៌ ឬ និជ្ជីវធម៌ ព្រះសាស្តាទ្រង់ប្រាប់ថាយកហើយក្នុងទីនេះ ។ និស្សត្តធម៌ ឬ និជ្ជីវធម៌នោះ ដោយអត្ថក៏បានដល់ អរូបក្ខន្ធ ៣ ប្រការគឺ “វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ” ។ ព្រោះហេតុថា អរូបក្ខន្ធ ៣ ប្រការនោះ ឈ្មោះថា មានចិត្តជាប្រធាន ។

មានពាក្យសួរថា “ក៏ចិត្តមានវត្ថុ ១ មានអារម្មណ៍ ១ កើតក្នុងខណៈ ១ រលត់ក្នុងខណៈ ១ ជាមួយនឹងធម៌ទាំងនោះ មិនមុន មិនក្រោយ ឈ្មោះថា ជាប្រធាននៃធម៌ទាំងនោះដូចម្ដេច” ?

មានពាក្យឆ្លើយថា “ចិត្តបានឈ្មោះថា ជាប្រធាននៃធម៌ទាំងនោះ ដោយអត្ថថា ជាបច្ច័យញុំាងធម៌ទាំងនោះឲ្យកើតឡើង ។ ដូចយ៉ាងថា កាលពួកចោរជាច្រើនធ្វើចោរកម្ម មានប្លន់អ្នកស្រុកជាដើមជាមួយគ្នា កាលមានគេសួរថា “នរណាជាប្រធាននៃពួកវានរណាជាបច្ច័យរបស់ពួកវា គឺអាស្រ័យអ្នកណា ទើបធ្វើកម្មនោះបាន អ្នកនោះទោះបីជាឈ្មោះទត្តៈក៏ដោយ ឈ្មោះមត្តៈក៏ដោយ គេហៅថាប្រធានរបស់វា យ៉ាងណាមិញ ពាក្យឧបមេយ្យដែលជាគ្រឿងញុំាងអត្ថឲ្យ

ដល់ព្រមនេះ បណ្ឌិតគប្បីដឹងច្បាស់ ដូច្នោះ។ ចិត្តឈ្មោះថាជាប្រធាន នៃធម៌ទាំងឡាយនោះ ដោយអត្ថថា ជាបច្ច័យញុំាងធម៌ទាំងនោះឲ្យ កើតឡើងដូច្នេះ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា មានចិត្តជាប្រធាន, ព្រោះកាលចិត្តមិនកើតឡើង ធម៌ទាំងនោះរមែង មិនអាចនឹងកើតឡើងបាន ចំណែកចិត្តសូម្បីចេតសិកធម៌ពួកខ្លះមិន កើតឡើង ក៏រមែងកើតឡើងបានដោយពិត ។ ម្យ៉ាងទៀត ចិត្តឈ្មោះ ថាជាធំនៃធម៌ទាំងឡាយនោះ ដោយអំណាចជាអធិបតី ព្រោះហេតុ នោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថាមានចិត្តជាធំ ។ ដូចយ៉ាងថា ជនទាំងឡាយមានចោរដែលជាប្រធានជាដើម ដែលជាអធិបតី បាន ឈ្មោះថា ជាធំនៃជនទាំងឡាយមានចោរជាដើម យ៉ាងណាមិញ ចិត្ត ដែលជាអធិបតីបានឈ្មោះថា ជាធំនៃធម៌ទាំងនោះដូច្នោះដែរ ព្រោះ ហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា មានចិត្តជាធំ ។ ម្យ៉ាងទៀត កណ្ឌៈទាំងឡាយនោះៗ សម្រេចហើយអំពីវត្ថុមានឈើ ជាដើម ក៏ ឈ្មោះថា ជារបស់សម្រេចហើយអំពីឈើជាដើម យ៉ាងណា សូម្បី

ធម៌ទាំងឡាយនោះ បានឈ្មោះថាសម្រេចហើយអំពីចិត្ត ព្រោះសម្រេចមកអំពីចិត្ត ដូច្នោះ ។

បទថា **បទុដ្ឋេន** គឺដែលទោសមានអភិជ្ឈាជាដើម ដែលទើបចរមកថ្មីប្រទូស្តហើយ ។ ពិតណាស់ ចិត្តប្រក្រតីឈ្មោះថាភវង្គចិត្ត, ភវង្គចិត្តនោះមិនត្រូវទោសប្រទូស្តហើយទេ ។ ដូចយ៉ាងថា ទឹកថ្លាសៅហ្មងហើយ ព្រោះពណ៌ទាំងឡាយ មានពណ៌ខៀវជាដើមដែលទើបមកថ្មីចូលទៅធ្វើឲ្យសៅហ្មង ជាទឹកផ្សេងមានពណ៌ខៀវជាដើម និងឈ្មោះថាទឹកថ្មីក៏មិនមែន និងឈ្មោះថាទឹកថ្លា ដូចដើមនោះឯង ក៏មិនមែន យ៉ាងណាមិញ ភវង្គចិត្តសូម្បីនោះដែលទោស មានអភិជ្ឈាជាដើមដែលទើបមកថ្មីប្រទូស្តហើយ នឹងឈ្មោះថាចិត្តថ្មីក៏មិនមែន នឹងឈ្មោះថាភវង្គចិត្តដដែលនោះឯងក៏មិនមែន, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចិត្តនេះជាធម្មជាតិផូរផង់ តែវាសៅហ្មងហើយព្រោះឧបក្កិលេសទាំងឡាយ ដែលទើបមកថ្មីនុ៎ះឯង" ដូច្នេះ ។ បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយយ៉ាងនេះ ។

បាទព្រះគាថាថា **ភាសតិ វា ករោតិ វា** គឺកាលបុគ្គលនោះនិយាយរមែងនិយាយតែវចីទុច្ចរិត ៤ យ៉ាង កាលធ្វើរមែងធ្វើតែកាយទុច្ចរិត ៣ យ៉ាង កាលមិននិយាយ កាលមិនធ្វើ ព្រោះកាលដែលខ្លួនជាអ្នកមានចិត្តដែលទោស មាន អភិជ្ឈា ជាដើម ប្រទូស្តរ៉ាយហើយនោះ រមែងញុំាងមនោទុច្ចរិត ៣ យ៉ាងឲ្យពេញ ។ អកុសលកម្មបថ ១០ យ៉ាង របស់បុគ្គលនោះ រមែងដល់ការពេញពោរដោយប្រការយ៉ាងនេះ ។ បាទព្រះគាថាថា **តតោ នំ ទុក្ខមន្វេតិ** សេចក្ដីថា ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ព្រោះទុច្ចរិត ៣ យ៉ាងនោះ គឺទុក្ខដែលជាផល ទាំងប្រព្រឹត្តទៅក្នុងកាយ និងប្រព្រឹត្តទៅក្នុងចិត្ត ដោយបរិយាយយ៉ាងនេះថា ទុក្ខមានកាយជាទីតាំងខ្លះ ទុក្ខមានចិត្តក្រៅនេះជាទីតាំងខ្លះ រមែងទៅតាមអត្តភាពនោះ ដែលជាអ្នកទៅនៅក្នុងអបាយភូមិ ៤ ក្ដី ក្នុងពួកមនុស្សក្ដី ដោយអានុភាពនៃទុច្ចរិតនោះ ។

មានពាក្យសួរថា “ទុក្ខរមែងជាប់តាមបុគ្គលនោះដូចជាអ្វី” ?

មានពាក្យឆ្លើយថា ដូចជាកង់រទេះវិលទៅតាមស្នាមជើងគោ

ដែលនាំទៅនូវធុរៈ, អធិប្បាយថា "ដូចជាកង់រទេះដែលវិលទៅតាមស្នាមជើងគោដែលគេទឹមទុកហ្នឹងនឹមនាំនឹមទៅ ។ ដូចយ៉ាងថា វាអូសទៅអស់មួយថ្ងៃក្ដី ពីរថ្ងៃក្ដី ១០ ថ្ងៃក្ដី កន្លះខែក្ដី រមែងមិនអាចឲ្យកង់ត្រឡប់វិញបាន គឺមិនអាចដើម្បីលះបង់នូវកង់ទៅបាន, ក្នុងន័យថាកាលវាឈានទៅខាងមុខ នឹមក៏បៀតបៀន ( សង្កត់ ) នូវក ( របស់វា ) កាលវាថយក្រោយកង់ក៏ទន្ទិច ( កកិត ) នូវសាច់ភ្លៅរបស់វា, កង់បៀតបៀនដោយហេតុ ២ ប្រការនេះ ជាវត្ថុដែលប្រព្រឹត្តទៅតាមស្នាមជើងរបស់វា យ៉ាងណា, ទុក្ខទាំងដែលប្រព្រឹត្តទៅក្នុងកាយខ្លះទាំងដែលប្រព្រឹត្តក្នុងចិត្តខ្លះ ដែលមានទុច្ចរិតជាមូល រមែងជាប់តាមបុគ្គលអ្នកមានចិត្តដែលត្រូវទោសប្រទូស្តហើយ ញុំាងទុច្ចរិត ៣ ប្រការឲ្យពេញបរិបូណ៌ហើយឋិតនៅក្នុងទីដែលគេទៅហើយៗ មាននរកជាដើមយ៉ាងនោះឯង ។

ក្នុងកាលចប់គាថា ភិក្ខុ ៣០០០ រូប បានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ។ ទេសនាបានជាកថាមានប្រ-

យោជន៍ មានផលសូម្បីដល់បរិស័ទអ្នកប្រជុំគ្នាហើយ ដូច្នេះឯង ។

( រឿងព្រះចក្ខុបាលត្ថេរ ចប់ )

# ២ រឿងមដ្ឋកុណ្ឌលី

## សេចក្តីខាងដើម

ចំណែកព្រះគាថាទីពីរថា "**មនោបុព្វង្គមា**" ជាដើម ព្រះមានព្រះភាគ ទ្រង់ប្រារព្ធមដ្ឋកុណ្ឌលីមាណព សម្តែងហើយនៅក្នុងក្រុងសាវត្ថីនោះឯង ។

## ព្រាហ្មណ៍ធ្វើគ្រឿងប្រដាប់ឲ្យបុត្រ

មានសេចក្តីដំណាលមកថា នៅក្រុងសាវត្ថី មានព្រាហ្មណ៍ម្នាក់ឈ្មោះ អទិន្នបុព្វកៈ ។ គាត់មិនធ្លាប់ឲ្យវត្ថុអ្វី ៗ ដល់នរណា ៗ ។ ព្រោះហេតុនោះ មហាជនក៏បានដាក់ឈ្មោះគាត់ថា "អទិន្នបុព្វកៈ" គាត់មានបុត្រម្នាក់ជាទីស្រឡាញ់ពេញចិត្ត ។ ក្រោយមក គាត់ចង់ដើម្បីនឹងធ្វើគ្រឿងប្រដាប់ឲ្យដល់បុត្រនោះ ក៏គិតថា "ប្រសិនបើយើងជួលជាងមាសឲ្យធ្វើក៏នឹងត្រូវឲ្យកត្ត និងថ្លៃឈ្នួលដល់ជាង" ដូច្នោះហើយក៏ដំមាសដោយខ្លួនឯង ហើយធ្វើជាទំហ៊ូរលោងៗ ស្រេចហើយឲ្យ (ដល់បុត្ររបស់ខ្លួន) ព្រោះហេតុនោះ ទើបបុត្ររបស់គាត់បានប្រាកដឈ្មោះថា មដ្ឋកុណ្ឌលី" ។

## ព្យាបាលបុត្រខ្លួនឯងព្រោះខ្លាចអស់ថ្លៃឈ្នួល

ក្នុងកាលបុត្រនោះមានអាយុបាន ១៦ ឆ្នាំ កើតរោគស្គមលឿង ។ មាតាក្រឡេកឃើញបុត្រហើយក៏និយាយនឹងព្រាហ្មណ៍ "ដែលជាស្វាមី" ថា "បពិត្រព្រាហ្មណ៍ រោគកើតឡើងហើយដល់បុត្ររបស់លោក សូមលោករកពេទ្យមកព្យាបាលឲ្យវាចុះ" ។

ព្រាហ្មណ៍ឆ្លើយថា "នែ នាងដ៏ចម្រើន ប្រសិនបើអញនឹងរកពេទ្យមក, អញនឹងគប្បីឲ្យថ្លៃឈ្នួល និងរង្វាន់ដល់គេ នាងមិនរមិលមើលនូវការខាតបង់ទ្រព្យរបស់យើង ( ខ្លះ )" ។

នាងព្រាហ្មណីសួរថា "បពិត្រព្រាហ្មណ៍ កាលបើយ៉ាងនេះលោកនឹងធ្វើដូចម្តេចទៅ" ?

ព្រាហ្មណ៍ឆ្លើយថា "ទ្រព្យរបស់យើងនឹងមិនខាតបង់ទៅដោយប្រការណាយ៉ាងណា យើងនឹងធ្វើយ៉ាងនោះ" ។

ព្រាហ្មណ៍នោះទៅកាន់សំណាក់ពួកពេទ្យហើយ សួរថា "ពួកលោកផ្សំថ្នាំដូចម្តេចដល់អ្នកជម្ងឺដែលកើតរោគឈ្មោះឯណោះ" ។

គ្រានោះ ពួកពេទ្យក៏ប្រាប់នូវវុក្ខាអវយវៈ មានសំបកឈើជាដើមដល់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍ ( ទៅ ) យកឫសឈើជាដើម ដែលពួកទេព្យប្រាប់នោះមក ហើយធ្វើថ្នាំឲ្យដល់បុត្ររបស់ខ្លួន ។ កាលព្រាហ្មណ៍ធ្វើថ្នាំដូច្នោះ, រោគបាន ( កម្រើកឡើង ) យ៉ាងខ្លាំងក្លា ហើយ ( រហូត ) ចូលដល់ការដែលមិនមាននរណានឹងព្យាបាលបាន ។ ព្រាហ្មណ៍ដឹងថាបុត្រទុព្វលភាពហើយ ក៏អញ្ជើញពេទ្យម្នាក់មក ពេទ្យនោះ ( មក ) ពិនិត្យមើលហើយ ក៏និយាយ ( គេចកែ ) ថា "ខ្ញុំមានកិច្ចរវល់ សូមលោកអញ្ជើញពេទ្យដទៃមកឲ្យព្យាបាលចុះ" ដូច្នោះ ហើយ ប្រកែកនឹងព្រាហ្មណ៍នោះហើយ ក៏លាទៅ ។

## ឲ្យបុត្រដេកក្រៅផ្ទះព្រោះខ្លាចគេឃើញសម្បត្តិ

ព្រាហ្មណ៍ដឹងនូវសម័យជិតស្លាប់នៃបុត្រនោះហើយ គិតថា "ពួកជនដែលមកហើយៗ ដើម្បីនឹងសួរសុខទុក្ខបុត្រនេះ នឹងឃើញទ្រព្យសម្បត្តិខាងក្នុងផ្ទះ យើងនឹងនាំគេចេញទៅខាងក្រៅ" ដូច្នេះ ហើយ ទើបនាំយកបុត្រចេញមកឲ្យដេកឰដ៏ខាងក្រៅនៃផ្ទះ ។

# ព្រះពុទ្ធពិចារណាឃើញឧបនិស្ស័យរបស់មដ្ឋកុណ្ឌលី

ក្នុងវេលាបច្ចូសម័យ “គឺវេលាជិតភ្លឺ” ថ្ងៃនោះ ព្រះមានព្រះភាគ ស្តេចចេញអំពីព្រះមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ដើម្បីកិរិយាឃើញពួកសត្វអ្នកជាផៅពង្សដែលព្រះអង្គគប្បីណែនាំបាន ដែលមានកុសលមូលកើតឡើង ហើយមានអធិការដែលបានធ្វើទុកហើយក្នុងព្រះពុទ្ធជាន់មុនទាំងឡាយ បានទ្រង់ផ្សាយសំណាញ់ គឺព្រះញាណទៅក្នុងមុីនចក្រវាឡ ។

មដ្ឋកុណ្ឌលីមាណពប្រាកដហើយពួដ៏ខាងក្នុងនៃសំណាញ់ គឺព្រះញាណនោះ ដោយអាការ គឺភាវៈនៃខ្លួនជាអ្នកដេកហើយពួដ៏ខាងក្រៅនៃផ្ទះយ៉ាងនោះ ។

ព្រះសាស្តាទតឃើញមដ្ឋកុណ្ឌលីហើយ ទ្រង់ជ្រាបថា ព្រាហ្មណ៍ដែលជាបិតានាំគេចេញអំពីខាងក្នុងផ្ទះ ហើយឲ្យដេកពួដ៏ខាងក្រៅនៃផ្ទះនោះ ទ្រង់ពិចារណាថា កាលដែលតថាគតយាងទៅកាន់ទីនោះ “នឹងមានប្រយោជន៍ខ្លះដែរឬទេហ្ន៎” កំពុងទ្រង់ពិចារណានោះឯង ក៏

បានឃើញហេតុនេះថា “មាណពនេះនឹងញុំាងចិត្តឲ្យជ្រះថ្លាក្នុងតថាគត ធ្វើកាលកិរិយាហើយនឹងកើតក្នុងវិមាន មាសកំពស់ ៣០ យោជន៍ ក្នុងតាវត្តិង្សទេវលោក មាននាងទេពអប្សរជាបរិវារ ១០០០ ។ ចំណែកព្រាហ្មណ៍ប្រើមនុស្សឲ្យដុតសាកសពកូននោះហើយ យំដើរទៅកាន់ទីដុតនោះ ។ ទេវបុត្រនឹងរមិលមើលនូវអត្តភាពកំពស់ ៣ គាវុត ប្រ-ដាប់ដោយគ្រឿងអលង្ការទម្ងន់ ៦០ រទេះ មាននាងទេពអប្សរជាបរិវារ ១០០០ គិតថា “សិរីសម្បត្តិនេះយើងបានដោយកម្មអ្វីហ្ន៎” ? ដូច្នេះហើយ សម្លឹងមើល, ក៏បានដឹងថា បានដោយចិត្តជ្រះថ្លាចំពោះតថាគត គិតថា “បិតាមិនអញ្ជើញពេទ្យមកផ្សំថ្នាំឲ្យដល់យើង ព្រោះខ្លាចក្រែងទ្រព្យនឹងអស់ទៅ ឥឡូវនេះទៅកាន់ប៉ាឆាស្រែកយំ, យើងនឹងធ្វើគាត់ឲ្យដល់ប្រការដែលប្លែក” ដូច្នេះ ដោយការថ្នាំងថ្នាក់ចំពោះបិតា ហើយនិម្មិតខ្លួនដូចមដ្ឋកុណ្ឌលីមាណព មកធ្វើដូចជាដេកស្រែកយំក្នុងទីជិតប៉ាឆា ។ ពេលនោះ ព្រាហ្មណ៍នឹងសួរមាណពនោះថា “ឯងជានរ-ណា” ក៏ប្រាប់ថា ខ្ញុំជាមដ្ឋកុណ្ឌលីមាណព បុត្ររបស់លោក ។

ព្រាហ្មណ៍. ឯងទៅកើតក្នុងភពណា ?

ទេវបុត្រ. ក្នុងភពតាវត្តិង្ស ។

កាលព្រាហ្មណ៍សួរថា "ព្រោះធ្វើកម្មអ្វី" ? គេនឹងប្រាប់ថា គេញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះតថាគត ។ ព្រាហ្មណ៍នឹងសួរតថាគតថា "ដែលឈ្មោះថា ការញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ (ប៉ុណ្ណោះ) ហើយទៅកើតក្នុងទេវលោកមានដែរឬ" ? ពេលនោះ តថាគតនឹងឆ្លើយប្រាប់ព្រាហ្មណ៍ថា "មិនមាននរណាអាចនឹងកំណត់ដោយការរាប់បានថា មានប្រមាណប៉ុណ្ណោះរយ ឬប៉ុណ្ណោះពាន់ ឬក៏ប៉ុណ្ណោះសែន" ដូច្នេះហើយ នឹងសម្ដែងគាថាក្នុងធម្មបទ ។ ក្នុងកាលចប់គាថា ការត្រាស់ដឹងធម៌នឹងមានដល់សត្វ ៨៤០០០ មដ្ឋកុណ្ឌលីទេវបុត្រនឹងបានជាសោតាបន្ន, សូម្បីអទិន្នបុព្វកព្រាហ្មណ៍ក៏ដូចគ្នាដែរ ។ អាស្រ័យកុលបុត្រនេះ ការបូជាធម៌ជាច្រើននឹងមានដោយប្រការដូច្នេះ, ក្នុងថ្ងៃស្អែកឡើងទ្រង់ធ្វើការបដិបត្តិ (ជម្រះ) ព្រះសរីរៈស្រេចហើយ ដែលមានភិក្ខុសង្ឃមួយពួកធំហែហមហើយ ស្ដេចចូលទៅកាន់ក្រុងសាវត្ថី

ដើម្បីបិណ្ឌបាតស្តេច យាងដល់ទ្វារផ្ទះរបស់ព្រាហ្មណ៍ដោយលំដាប់ ។

## មដ្ឋកុណ្ឌលីញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់

ក្នុងខណៈនោះ មដ្ឋកុណ្ឌលីមាណព កំពុងដេកបែរមុខទៅខាងក្នុងផ្ទះ ។ ព្រះសាស្តាទ្រង់ជ្រាបថា មិនឃើញព្រះអង្គ, ទើបបានផ្សាយព្រះរស្មីទៅមួយព្យាម ។ មាណពគិតថា "ពន្លឺនេះជាពន្លឺអ្វី" ? ទើបដេកប្រែត្រឡប់មក ឃើញព្រះសាស្តាហើយ គិតថា "យើងអាស្រ័យបិតាដែលជាមនុស្សអន្ធពាល ទើបមិនបានចូលទៅគាល់ព្រះពុទ្ធជាម្ចាស់បែបនេះ ហើយធ្វើសេចក្តីខ្វល់ខ្វាយដោយកាយ ឬថ្វាយទាន ឬស្តាប់ធម៌, ឥឡូវនេះសូម្បីតែដៃទាំងពីរខាងរបស់យើងក៏លើកមិនរួច ។ កិច្ចដែលអញគួរធ្វើយ៉ាងដទៃមិនមាន " ដូច្នេះហើយ បានញុំាងចិត្តប៉ុណ្ណោះឲ្យជ្រះថ្លា ។

## ព្រោះចិត្តជ្រះថ្លាធ្វើកាលកិរិយាទៅកើតក្នុងទេវលោក

ព្រះសាស្តាទ្រង់ព្រះតម្រិះថា "ល្មមហើយដោយការដែលមាណពនេះ ធ្វើចិត្តឲ្យជ្រះថ្លាមានប្រមាណប៉ុណ្ណោះ" ក៏ស្តេចទ្រង់ចៀស

ចេញទៅហើយ កាលព្រះតថាគតលះបង់នូវគន្ធនៃចក្ខុប៉ុណ្ណោះ,មា-ណពនោះមានចិត្តជ្រះថ្លាធ្វើកាលកិរិយាហើយ ហាក់ដូចជាលក់ហើយត្រឡប់ភ្ញាក់ឡើង ទៅកើតក្នុងវិមានមាសកំពស់ប្រមាណ ៣០យោជន៍ក្នុងទេវលោក ។

## ព្រាហ្មណ៍ខ្សឹកខ្សួលដល់បុត្រ

ចំណែកព្រាហ្មណ៍ប្រើឲ្យគេដុតសាកសពកូននោះហើយ ជាអ្នកមានតែការស្រែកយំប្រព្រឹត្តទៅខាងមុខ, គាត់ទៅកាន់ប៉ាឆារាល់ថ្ងៃយំបណ្តើរ រៀបរាប់បណ្តើរថា "កូនសម្លាញ់របស់ពុកនៅទីណា ? កូនសម្លាញ់របស់ពុកនៅទីណា " ?

## ទេវបុត្រនិម្មិតកាយទៅរកព្រាហ្មណ៍

(សូម្បី) ទេវបុត្រក្រឡេកមើលសម្បត្តិរបស់ខ្លួនហើយ គិតថា "សម្បត្តិនេះយើងបានដោយកម្មអ្វី " ? កាលពិចារណាទៅក៏ដឹងថា "បានដោយចិត្តដែលជ្រះថ្លាក្នុងព្រះសាស្តា ដូច្នេះហើយ ទើបគិតតទៅថា "ព្រាហ្មណ៍នេះក្នុងកាលដែលយើងមិនសប្បាយ មិនបាន

អញ្ជើញពេទ្យមកព្យាបាលទេ, ឥឡូវទៅកាន់ប៉ាឆាស្រែកយំ, គួរដែលយើងនឹងធ្វើគាត់ឲ្យដល់ប្រការដែលប្លែក" ដូច្នេះហើយ ក៏និម្មិតខ្លួនដូចមដ្ឋកុណ្ឌលីមាណព មកហើយបានឈរឱបដៃយំក្នុងទីមិនឆ្ងាយអំពីប៉ាឆា ។

## ទេវបុត្រ និង ព្រាហ្មណ៍បានឆ្លងឆ្លើយគ្នា

ព្រាហ្មណ៍ឃើញអាការនោះហើយ ក៏គិតថា "យើងយំព្រោះសោកស្តាយអាល័យដល់បុត្រ, ក៏មាណពនោះយំត្រូវការអ្វីទៅ ? យើងនឹងសួរគេមើល" ដូច្នេះហើយ កាលនឹងសួរ បានពោលគាថានេះថា ៖

"អ្នកប្រដាប់តុបតែងហើយ ដូចមដ្ឋកុណ្ឌលី មានភារៈ គឺ
កម្រងផ្កាមានខ្លួនដ៏ខ្ពស់ឡើង ដោយការប្រោះព្រំដោយ
ខ្លឹមចន្ទន៍មានពណ៌ក្រហម, ឈរឱបដៃទាំងពីរកន្ទក់កន្ទេញ
នៅកណ្តាលព្រៃ ជាអ្នកមាននូវសេចក្តីទុក្ខដូចម្តេច" ?

មាណពឆ្លើយថា ៖

“រាជរថធ្វើដោយមាសដ៏ភ្លឺផ្លេក ( ជាដែនផ្សាយចេញនៃរស្មី ) កើតឡើងហើយដល់ខ្ញុំ, ខ្ញុំមិនបាននូវគូនៃកង់ដើម្បីរាជរថនោះ ខ្ញុំនឹងលះបង់ជីវិត ព្រោះសេចក្ដីទុក្ខនោះ” ។

គ្រានោះព្រាហ្មណ៍បាននិយាយនឹងមាណពនោះថា ៖

“ម្នាលមាណពដ៏ចម្រើន គូនៃកង់នោះ ទោះបីសម្រេចដោយមាសក្ដី សម្រេចដោយកែវមណីក្ដី សម្រេចដោយលោហៈក្ដី សម្រេចដោយប្រាក់ក្ដី អ្នកចូរប្រាប់ដល់ខ្ញុំចុះ, ខ្ញុំនឹងញ៉ាំងអ្នកឲ្យបានគូនៃកង់នោះ” ។

មាណពបានស្ដាប់នូវពាក្យនោះហើយ គិតថា ៖

“ព្រាហ្មណ៍នេះមិនធ្វើថ្នាំឲ្យដល់បុត្រហើយ លុះមកឃើញយើងមានរូបរាងដូចបុត្ររបស់ខ្លួនកំពុងយំ និយាយថា យើងនឹងធ្វើកង់នៃរថ ដែលសម្រេចដោយមាសជាដើមឲ្យណ្ហើយចុះ យើងនឹងផ្ចាញ់ផ្ចាលគាត់” ដូច្នេះហើយទើបពោលថា “លោកនឹងធ្វើគូនៃកង់ឲ្យដល់ខ្ញុំធំប៉ុណ្ណា ?” កាល

ព្រាហ្មណ៍នោះពោលថា អ្នកនឹងត្រូវការទំហំប៉ុណ្ណាទៅ” ទើបប្រាប់ថា ៖

“ខ្ញុំត្រូវការព្រះច័ន្ទ និងព្រះអាទិត្យទាំងពីរដួង លោកដែលខ្ញុំសូមហើយ មេត្តាឲ្យនូវព្រះអាទិត្យ និងព្រះច័ន្ទទាំងពីរនោះឲ្យដល់ខ្ញុំចុះ” ។

មាណពនោះពោលតទៅទៀតថា ៖

“ព្រះច័ន្ទ និងព្រះអាទិត្យរុងរឿងក្នុងវិថីទាំងពីរ រថរបស់ខ្ញុំសម្រេចហើយដោយមាស រមែងល្អសមនឹងគូនៃកង់នោះ” ។

លំដាប់នោះព្រាហ្មណ៍និយាយនឹងមាណពថា ៖

“ម្នាលមាណព អ្នកប្រាថ្នារបស់ដែលមិនគួរប្រាថ្នា ជាមនុស្សល្ងង់ខ្លៅពិតៗ ខ្ញុំយល់ថា អ្នកប្រាថ្នាហួតស្លាប់ក៏នឹងមិនបានព្រះច័ន្ទ និងព្រះអាទិត្យទាំងពីរនោះឡើយ” ។

ខណៈនោះ មាណពក៏បាននិយាយនឹងព្រាហ្មណ៍នោះថា “ក៏បុគ្គលអ្នកយំ ដើម្បីត្រូវការវត្ថុដែលប្រាកដជាមនុស្សល្ងង់ខ្លៅ ឬថា

បុគ្គលអ្នកយំ ដើម្បីត្រូវការវត្ថុដែលមិនប្រាកដជាមនុស្សល្ងង់ខ្លៅ" ? ដូច្នេះហើយ ទើបពោលគាថាថា ៖

"សូម្បីការទៅ និងការមករបស់ព្រះច័ន្ទ និងព្រះអាទិត្យក៏ប្រាកដ វណ្ណធាតុគឺរស្មីនៃព្រះច័ន្ទ និងព្រះអាទិត្យក៏ប្រាកដនៅក្នុងវិថីទាំងពីរ ( ចំណែក ) ជនដែលធ្វើកាលកិរិយាទៅហើយ នរណាក៏មិនឃើញ, បណ្ដាយើងទាំងពីរដែលជាអ្នកទួញកន្ទេញនៅក្នុងទីនេះ នរណានឹងជាមនុស្សល្ងង់ខ្លៅជាងនរណា" ។

## ព្រាហ្មណ៍យល់ព្រមចុះចាញ់ហើយសរសើរទេវបុត្រ

ព្រាហ្មណ៍ស្ដាប់ពាក្យនោះហើយ កំណត់បានថា "មាណពនេះនិយាយត្រូវ" ទើបពោលថា ៖

"ម្នាលមាណពដ៏ចម្រើន អ្នកនិយាយពាក្យនេះ ពិតមែនហើយ បណ្ដាយើងទាំងពីរដែលជាអ្នកកន្ទួញកន្ទេញ ( ក្នុងទីនេះ ខ្ញុំខ្លួនឯងជាអ្នកល្ងង់ខ្លៅជាង ខ្ញុំចង់បានបុត្រដែល

ធ្វើកាលកិរិយាហើយមកវិញ ដូចទារកយំចង់បានព្រះច័ន្ទ" ។

ដូច្នេះហើយ ជាអ្នកអស់សេចក្តីសោកព្រោះពាក្យរបស់មាណពនោះ, កាលនឹងធ្វើសេចក្តីសរសើរមាណពបានពោលគាថាទាំងនេះថា ៖

"អ្នកមកស្រោចរំលត់នូវខ្ញុំ ដែលជាអ្នកត្រូវភ្លើងគឺសេចក្តីសោកដុតរោលរាលហើយ ដូចបុគ្គលរំលត់ភ្លើងដែលឆេះឆ្នាំងប្រេងដោយទឹក, ខ្ញុំរមែងញ៉ាំងសេចក្តីក្រវល់ក្រវាយទាំងពួងឲ្យរលត់បាន លោកបន្ទោបង់សេចក្តីសោកដល់បុត្តរបស់ខ្ញុំដែលសេចក្តីសោកគ្របសង្កត់ហើយ បានដកកូនសរ គឺសេចក្តីសោកដែលចាក់ដោតហឫទ័យរបស់ខ្ញុំចេញបាន ខ្ញុំនោះជាអ្នកមានកូនសរ ដែលលោកដកចេញហើយ ជាអ្នកត្រជាក់ស្ងប់រម្ងាប់ហើយ, ម្នាលមាណព ខ្ញុំខ្ញុំសោកសៅ មិនយំព្រោះបានស្តាប់ពាក្យរបស់អ្នក" ។

## ព្រាហ្មណ៍សាកសួរទេវបុត្រ

ខណៈនោះ ព្រាហ្មណ៍កាលនឹងសួរទេវបុត្រថា "អ្នកឈ្មោះអ្វី ?" ទើបពោលថា ៖

"អ្នកជាទេវតា ឬក៏ជាគន្ធព ឬថាជាបុរិន្ទទសក្កទេវរាជ, អ្នកឈ្មោះអ្វី ? ជាបុត្ររបស់អ្នកណា ? ធ្វើដូចម្ដេចទៅ ខ្ញុំគប្បីបានស្គាល់អ្នក" ?

គ្រានោះ មាណពប្រាប់ដល់ព្រាហ្មណ៍នោះថា ៖

"អ្នកដុតបុត្រណា ក្នុងព្រៃស្មសានខ្លួនឯង ហើយរមែងកន្ទក់កន្ទេញ និងយំរកបុត្រណា បុត្រនោះ គឺខ្ញុំធ្វើកុសលកម្មហើយដល់នូវភាពជាសម្លាញ់របស់ទេវតាជាន់តាវត្តិង្ស ។

ព្រាហ្មណ៍បានពោលថា ៖

"កាលអ្នកឲ្យទានតិច ឬច្រើនក្នុងផ្ទះរបស់ខ្លួន ឬរក្សាឧបោសថកម្មដូច្នោះខ្ញុំមិនដែលឃើញ, អ្នកទៅកាន់ទេវលោកបានព្រោះកម្មអ្វី" ?

មាណពបានពោលថា ៖

"ខ្ញុំមានរោគឈឺលំបាក មានកាយសោប់សេល់ នៅក្នុងផ្ទះរបស់ខ្លួន, ខ្ញុំបានឃើញព្រះពុទ្ធដែលជាអ្នកប្រាសធូលី គឺកិលេស, ព្រះអង្គចូងផុតសេចក្តីសង្ស័យហើយ ស្តេចយាងទៅដោយល្អ មានព្រះប្រាជ្ញាមិនថោកថយ,ខ្ញុំនោះជាអ្នកមានចិត្តរីករាយហើយ មានចិត្តជ្រះថ្លាហើយ បានថ្វាយនូវអញ្ជលីដល់ព្រះតថាគត ។

ខ្ញុំបានធ្វើកុសលកម្មនោះហើយ ក៏ដល់នូវភាពជាសម្លាញ់របស់ពួកទេវតាជាន់តាវត្តិង្ស" ។

## ព្រាហ្មណ៍ដល់ព្រះពុទ្ធជាសរណៈ

កាលមាណពនោះ កំពុងនិយាយរៀបរាប់នោះឯង សរីរៈទាំងអស់របស់ព្រាហ្មណ៍ក៏ពោរពេញហើយដោយបីតិ ។ ព្រាហ្មណ៍នោះកាលនឹងប្រកាសបីតិនោះ ទើបពោលថា ៖

"គួរអស្ចារ្យណាស់ហ្ន៎ គួរឲ្យចម្លែកណាស់ហ្ន៎ វិបាកនៃការ

ធ្វើនូវអញ្ជលីកម្មនេះ ប្រព្រឹត្តទៅបានដូច្នេះ សូម្បីខ្ញុំមានចិត្តរីករាយហើយ មានចិត្តជ្រះថ្លាហើយ ដល់ព្រះពុទ្ធជាសរណៈក្នុងថ្ងៃនេះឯង" ។

## ទេវបុត្រឲ្យឪវាទព្រាហ្មណ៍ហើយក៏បាត់ខ្លួនទៅ

ខណៈនោះ មាណពបានពោលនឹងព្រាហ្មណ៍ថា ៖

"លោកចូរជាអ្នកមានចិត្តជ្រះថ្លាហើយ ដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ថាជាសរណៈក្នុងថ្ងៃនេះឯងចុះ លោកចូរជាអ្នកមានចិត្តជ្រះថ្លាយ៉ាងនោះ ហើយសមាទានសិក្ខាបទ ៥ កុំឲ្យដាច់ធ្លុះធ្លាយ, ចូរប្រញាប់វៀរចាកបាណាតិបាត (ការសម្លាប់សត្វ) ចូរវៀរចាករបស់ដែលម្ចាស់គេមិនទាន់ឲ្យក្នុងលោក, ចូរកុំផឹកទឹកស្រវឹង, ចូរកុំនិយាយកុហក, និងចូរជាអ្នកពេញចិត្តចំពោះតែភរិយារបស់ខ្លួន" ។

ព្រាហ្មណ៍ទទួលថា "ល្អហើយ" បានភាសិតគាថាទាំងនេះថា ៖

"ម្នាលយក្ស អ្នកជាអ្នកប្រាថ្នាប្រយោជន៍ដល់ខ្ញុំ, ម្នាល

ទេវតាអ្នកជាអ្នកប្រាថ្នាវត្ថុដែលជាឧបការៈដល់ខ្ញុំ, ខ្ញុំនឹងធ្វើ ( តាម ) ពាក្យរបស់អ្នក, អ្នកជាអាចារ្យរបស់ខ្ញុំ, ខ្ញុំសូមដល់ព្រះពុទ្ធជាសរណៈផង, ខ្ញុំសូមដល់សូម្បីព្រះធម៌ដែលមិនមានវត្ថុដទៃក្រៃលែងជាង ថាជាសរណៈផង, ខ្ញុំសូមដល់ព្រះសង្ឃរបស់ព្រះពុទ្ធ ដែលជាមនុស្សល្អពិសេសដូចពិសេសដូចទេវតាថាជាសរណៈផង, ខ្ញុំម្ចាស់នឹងប្រញាប់វៀរចាកបាណាតិបាត, វៀរចាកការកាន់យកទ្រព្យសម្បត្តិដែលម្ចាស់គេមិនទាន់ឲ្យក្នុងលោក, មិនផឹកទឹកស្រវឹង, មិននិយាយកុហក, និងជាអ្នកពេញចិត្តចំពោះភរិយារបស់ខ្លួន" ។

ខណៈនោះ ទេវបុត្រពោលនឹងព្រាហ្មណ៍ថា "ម្នាលព្រាហ្មណ៍ ទ្រព្យក្នុងផ្ទះរបស់លោកមានច្រើន, សូមលោកចូលទៅគាល់ព្រះ-សាស្តា ហើយថ្វាយទាន ចូរស្តាប់ធម៌ ចូរសួរបញ្ហា" ដូច្នេះហើយក៏បាត់អំពីទីនោះទៅ ។

# ព្រាហ្មណ៍ថ្វាយទានដល់ព្រះពុទ្ធ

ចំណែកព្រាហ្មណ៍ ទៅផ្ទះហើយ ហៅនាងព្រាហ្មណីមកនិយាយថា "ម្នាលនាងដ៏ចម្រើន ខ្ញុំនឹងនិមន្តព្រះសមណគោតម ហើយទូលសួរបញ្ហា, នាងចូរធ្វើសក្ការៈ" ដូច្នេះហើយ ទៅកាន់វិហារ មិនថ្វាយបង្គំព្រះសាស្តា មិនធ្វើបដិសណ្ឋារៈ ឈរនៅក្នុងទីដ៏សមគួរមួយ ហើយក្រាបទូលថា "បពិត្រព្រះគោតមដ៏ចម្រើន សូមព្រះអង្គព្រមទាំងព្រះភិក្ខុសង្ឃ មេត្តាទ្រង់អនុគ្រោះទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីសោយក្នុងថ្ងៃនេះ" ។

ព្រះសាស្តាទ្រង់ទទួលហើយ ។ ព្រាហ្មណ៍បានដឹងថា ព្រះ-សាស្តាទ្រង់ទទួលហើយ ទើបមកកាន់ផ្ទះដោយរហ័ស ប្រើមនុស្សឲ្យចាត់ចែងខាទនីយភោជនីយាហារទុកក្នុងផ្ទះរបស់ខ្លួន ។ ព្រះសាស្តាដែលពួកភិក្ខុសង្ឃហែហមហើយ ស្តេចយាងទៅកាន់ផ្ទះព្រាហ្មណ៍នោះ ទ្រង់គង់លើអាសនៈដែលគេក្រាលទុក ។ ព្រាហ្មណ៍អង្គាសព្រះសាស្តាព្រមទាំងភិក្ខុសង្ឃហើយដោយគោរព ។ មហាជនប្រជុំ

គ្នា ។ បានឮថា កាលព្រះតថាគតដែលព្រាហ្មណ៍មិច្ឆាទិដ្ឋិនិមន្តហើយ ពួកជនពីរពួកតែងមកប្រជុំគ្នា គឺពួកជនដែលជាមិច្ឆាទិដ្ឋិប្រជុំគ្នាដោយតាំងចិត្តថា "ថ្ងៃនេះពួកយើងនឹងរង់ចាំមើលព្រះសមណគោតម ដែលត្រូវព្រាហ្មណ៍បៀតបៀនដោយការសួរបញ្ហា" ពួកជនដែលជាសម្មាទិដ្ឋិប្រជុំគ្នាដោយតាំងចិត្តថា "ថ្ងៃនេះពួកយើងនឹងរង់ចាំមើលពុទ្ធវិស័យ ពុទ្ធលីលា" ។

ខណៈនោះ ព្រាហ្មណ៍ចូលទៅគាល់ព្រះតថាគតដែលទ្រង់ធ្វើភត្តកិច្ចស្រេចហើយ អង្គុយលើអាសនៈទាប បានទូលសួរបញ្ហាថា "បពិត្រព្រះគោតមដ៏ចម្រើន មានដែរឬទេចំពោះពួកជនដែលមិនបានថ្វាយទានដល់ព្រះអង្គ មិនបានបូជាព្រះអង្គ មិនបានស្តាប់ធម៌ មិនបានរក្សាឧបោសថសោះ បានទៅកើតក្នុងឋានសួគ៌ដោយត្រឹមតែចិត្តជ្រះថ្លាតែម្យ៉ាងប៉ុណ្ណោះ" ?

ស. ម្នាលព្រាហ្មណ៍ ហេតុដូចម្តេចអ្នកមកសួរតថាគត ការដែលអ្នកញ៉ាំងចិត្តជ្រះថ្លាក្នុងតថាគតហើយកើតក្នុងឋានសួគ៌ ដែល

មដ្ឋកុណ្ឌលីជាបុត្ររបស់អ្នកបានប្រាប់ដល់អ្នកហើយ មិនមែនឬ ?

ព. បពិត្រព្រះគោតមដ៏ចម្រើន កាលណា ?

ស. ថ្ងៃដែលអ្នកខ្សឹកខ្សួលទៅកាន់ព្រៃស្មសាន ។ ឃើញមាណពម្នាក់ឱបដៃកន្ទក់កន្ទេញនៅក្នុងទីមិនឆ្ងាយហើយសួរថា ៖

"អ្នកប្រដាប់តុបតែងហើយដូចមដ្ឋកុណ្ឌលី មានភារៈគឺកម្រងផ្កា មានខ្លួនរុងរឿងដោយខ្លឹមចន្ទន៍ក្រហម" ។

ដូច្នេះជាដើម មិនមែនឬ ? កាលទឹងទ្រង់ប្រកាសពាក្យដែលជនទាំងពីរនាក់ពោលហើយ បានត្រាស់រឿងមដ្ឋកុណ្ឌលីទាំងអស់ ។ ព្រោះដូច្នោះ រឿងមដ្ឋកុណ្ឌលីនោះ ទើបបានឈ្មោះថាជាពុទ្ធភាសិត ។ កាលព្រះសាស្តាត្រាស់រឿងមដ្ឋកុណ្ឌលីនោះហើយ ទើបត្រាស់ថា "ម្នាលព្រាហ្មណ៍ មិនមែនមានតែមួយរយ និងពីររយទេ ដោយពិតកាលដែលទឹងរាប់ពួកសត្វ ដែលញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងតថាគតហើយកើតក្នុងឋានសួគ៌រមែងមិនមាន" ។ មហាជនបានជាអ្នកកើតសេចក្តីសង្ស័យឡើង ខណៈនោះ ព្រះសាស្តាទ្រង់ជ្រាបការដែលមហាជន

នោះមិនទាន់អស់សេចក្ដីសង្ស័យ បានទ្រង់អធិដ្ឋានថា "សូមមដ្ឋ-កុណ្ឌលីទេវបុត្តចូរមកព្រមជាមួយនឹងវិមាន" ។ អ្នកមានអត្តភាពដែលប្រដាប់ហើយដោយគ្រឿងអាភរណទិព្វ កំពស់ប្រមាណ ៣ គាវុតមកហើយ ចុះមកអំពីវិមានថ្វាយបង្គំព្រះសាស្ដាហើយ បានឈរនៅក្នុងទីដ៏សមគួរមួយ ។

ខណៈនោះ ព្រះសាស្ដាកាលនឹងត្រាស់សួរទេវបុត្រថា "អ្នកធ្វើកម្មអ្វី ទើបបានសម្បត្តិនេះ" បានត្រាស់ព្រះគាថាថា ៖

"ទេវតា អ្នកមានកាយល្អក្រៃលែងណាស់ ឈរញុំាងទិសទាំងអស់ឲ្យភ្លឺស្វាង ដូចផ្កាយព្រឹក, ទេវតាអ្នកមានអានុភាពច្រើន តថាគតសុំសួរអ្នក ( កាល ) អ្នកជាមនុស្សបានធ្វើបុណ្យអ្វីទុក" ។

ទេវបុត្រក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សម្បត្តិនេះខ្ញុំព្រះអង្គ បានហើយ ព្រោះញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ" ។

ស. សម្បត្តិនេះអ្នកបានហើយ ព្រោះញុំាងចិត្តឲ្យជ្រះថ្លាក្នុងតថា-

គតឬ ?

ទ. ព្រះករុណា ព្រះអង្គ ។

មហាជនក្រឡេកមើលទេវបុត្រហើយ បានប្រកាសសេចក្តីត្រេកអរថា "នែ៎ អ្នកដ៏ចម្រើនទាំងឡាយ ពុទ្ធគុណគួរឲ្យអស្ចារ្យមែនហ្ន៎ បុត្ររបស់ព្រាហ្មណ៍ឈ្មោះ អទិន្នបុព្វកៈ មិនបានធ្វើបុណ្យអ្វី ៗ យ៉ាងដទៃ ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះសាស្តា ហើយបានសម្បត្តិបែបនេះ" ។

## ចិត្តជាធំក្នុងកម្មគ្រប់យ៉ាង

ខណៈនោះ ព្រះសាស្តាត្រាស់នឹងពួកជនទាំងនោះថា "ក្នុងការធ្វើកម្មដែលជាកុសល និងអកុសល ចិត្តជាប្រធាន ចិត្តជាធំ, ព្រោះថា កម្មដែលធ្វើដោយចិត្តដែលជ្រះថ្លាហើយ រមែងមិនលះបង់បុគ្គលអ្នកទៅកាន់ទេវលោក មនុស្សលោកដូចស្រមោលដូច្នោះ" លុះត្រាស់រឿងនេះហើយ ព្រះអង្គដែលជាធម្មរាជា បានត្រាស់ព្រះគាថានេះបន្តអនុសន្ធិ ដូចប្រថាប់ព្រះរាជសាសន៍ ដែលមានដីស្អិតប្រថាំទុកហើយ

ដោយព្រះគាថាថា ៖

២ មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយា វ អនុបាយិនី ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរ បំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី ( នូវសុចរិត ) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោល អន្ទោលតាមប្រាណ ។

## អធិប្បាយគាថា

ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ សូម្បីទាំងអស់ ព្រះមានព្រះ-ភាគត្រាស់ហៅថា "មនោ" ក្នុងព្រះគាថានោះ ដោយមិនប្លែកគ្នាក៏ពិត មែនហើយ, តែកាលកំណត់យកចិត្តក្នុងបទនេះ រមែងបានដល់ចិត្ត ជាកាមាវចរកុសល ៨ ដួង, ក៏កាលពោលដោយអំណាចវត្ថុ រមែង

បានដល់ចិត្តដែលប្រកបដោយញាណ ប្រព្រឹត្តទៅព្រមនឹងសោមនស្សអំពីកាមាវចរកុសលចិត្ត ៤ ដួង ប៉ុណ្ណោះ ។

បទថា **បុព្វង្គមា** សេចក្តីថា ប្រកបជាមួយនឹងចិត្តដែលជាសភាវៈ ប្រព្រឹត្តទៅមុននោះ ខន្ធ ៣ មានវេទនាខន្ធជាដើម ឈ្មោះថាធម៌ ។ ពិតណាស់ ចិត្តជាប្រធានរបស់អរូបក្ខន្ធទាំង ៣ មានវេទនាខន្ធជាដើមនោះ ពោលដោយអត្ថ គឺជាបច្ច័យញុំាងធម៌ទាំងនោះឲ្យកើតឡើង ព្រោះហេតុនោះ ខន្ធទាំង ៣ ប្រការនោះ ទើបឈ្មោះថាមានចិត្តជាប្រធាន ។ ដូចឧទាហរណ៍ថា កាលទាយកជាច្រើនកំពុងធ្វើបុណ្យមានប្រគេនបាត្រ និងចីវរជាដើម ដល់ភិក្ខុសង្ឃមួយពួកធំក្តី មានបូជាដ៏ក្រៃលែង និងស្តាប់ធម៌ ហើយដុតប្រទីបធ្វើសក្ការៈដោយកំរងផ្កាជាដើមក្តី កាលមានអ្នកសួរថា "នរណាជាប្រធាននៃទាយកទាំងនោះ" ទាយកណាជាបច្ច័យរបស់ពួកគេ, គឺពួកគេអាស្រ័យទាយកណាទើបធ្វើបុណ្យទាំងនោះបាន, ទាយកនោះ ឈ្មោះតិស្សៈក៏ដោយ ឈ្មោះបុស្សៈក៏ដោយ ជំនុំជន រមែងហៅថា ជាប្រធានរបស់ពួកគេ"

យ៉ាងណាមិញ ពាក្យឧបមេយ្យដែលជាគ្រឿងញ៉ាំងសេចក្ដីឲ្យដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបដូច្នេះ ។ ចិត្តឈ្មោះថាជាប្រធានរបស់ធម៌ទាំងនោះ ដោយអត្ថថា ជាបច្ច័យដែលជាគ្រឿងញ៉ាំងធម៌ទាំងនោះឲ្យកើតឡើងដោយប្រការដូច្នេះ, ព្រោះហេតុនោះ ទើបធម៌ទាំងនេះឯងឈ្មោះថាមានចិត្តជាប្រធាន, ពិតណាស់ ធម៌ទាំងនោះកាលចិត្តមិនកើតឡើង រមែងមិនអាចនឹងកើតឡើងបាន ចំណែកចិត្ត កាលចេតសិកពួកខ្លះសូម្បីមិនកើតឡើង ក៏កើតឡើងបានដោយពិត ។ ហើយចិត្តឈ្មោះថាជាធំជាងធម៌ទាំងនោះ ដោយអំណាចជាអធិបតី ព្រោះដូច្នោះ ទើបធម៌ទាំងនេះឈ្មោះថាមានចិត្តជាធំ ។ មួយវិញទៀត វត្ថុទាំងឡាយនោះៗ សម្រេចហើយអំពីវត្ថុមានមាស ជាដើម ក៏ឈ្មោះថាសម្រេចហើយអំពីមាសជាដើម យ៉ាងណាមិញ, សូម្បីធម៌ទាំងនោះក៏បានឈ្មោះថា សម្រេចហើយអំពីចិត្ត ព្រោះជារបស់ដែលសម្រេចមកអំពីចិត្ត ដូច្នោះ ។

បទថា **បសន្នេន** សេចក្ដីថា ជ្រះថ្លាហើយដោយគុណទាំង-

ឡាយ មានការមិនសម្ងំនូវពៀរជាដើម ។

ពីរបទថា **ភាសតិ វា ករោតិ វា** សេចក្ដីថា បុគ្គលមានចិត្តបែបនេះ កាលនឹងនិយាយ រមែងនិយាយតែសុចរិត ៤ យ៉ាង កាលនឹងធ្វើ រមែងធ្វើតែសុចរិត ៣ យ៉ាង កាលមិននិយាយ កាលមិនធ្វើ រមែងធ្វើតែមនោសុចរិត ៣ យ៉ាង ឲ្យពេញបរិបូណ៌ ព្រោះការដែលខ្លួនជាអ្នកមានចិត្តជ្រះថ្លាផូរផង់ហើយ ដោយគុណទាំងឡាយមានអនភិជ្ឈាជាដើមនោះ ។ កុសលកម្មបថ ១០ របស់គេរមែងដល់ការពេញបរិបូណ៌ដោយប្រការយ៉ាងនេះ ។

បាទព្រះគាថាថា **តតោ នំ សុខមន្វេតិ** សេចក្ដីថា សេចក្ដីសុខរមែងជាប់តាមបុគ្គលនោះទៅ ព្រោះសុចរិត ៣ យ៉ាងនោះ ។ កុសលទាំង ៣ ភូមិ ព្រះមានព្រះភាគប្រាថ្នាយកហើយក្នុងទីនេះ, ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបការអធិប្បាយថា "សេចក្ដីសុខដែលជាផល ដែលប្រព្រឹត្តទៅក្នុងកាយ និងប្រព្រឹត្តទៅក្នុងចិត្ត ( ដោយបរិយាយនេះ ) ថា សេចក្ដីសុខមានកាយជាទីតាំងខ្លះ សេចក្ដីសុខមាន

ចិត្តជាទីតាំងខូះរមែងជាប់តាមទៅ គឺថា រមែងមិនលះបង់បុគ្គលនោះ ដែលកើតហើយក្នុងសុគតិភពក្តី តាំងនៅហើយក្នុងទីដែលសោយសុខក្នុងសុគតិក្តី ព្រោះអានុភាពនៃសុចរិតដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មានពាក្យសួរសើកចូលមកថា "ដូចអ្វី" ឆ្លើយថា "ដូចស្រមោលមានប្រក្រតីអន្ទោលទៅតាមប្រាណ" អធិប្បាយដូចយ៉ាងថា ធម្មតាស្រមោលជារបស់ជាប់នឹងសរីរៈ កាលសរីរៈដើរទៅ វាក៏ដើរទៅ, កាលសរីរៈឈប់ វាក៏ឈប់, កាលសរីរៈអង្គុយ វាក៏អង្គុយ, មិនមាននរណាអាចនឹងស្តីថាវាដោយពាក្យទន់ភ្លន់ក្តី ដោយពាក្យគ្រោតគ្រាតក្តី ថា "ឯងចូរត្រឡប់ទៅវិញ ឬវៃហើយឲ្យត្រឡប់ទៅវិញបាន" សួរថា "ព្រោះហេតុអ្វី" ឆ្លើយថា ព្រោះវាជារបស់ជាប់នឹងសរីរៈ យ៉ាងណាមិញ សេចក្តីសុខដែលប្រព្រឹត្តទៅក្នុងកាយ និងប្រព្រឹត្តទៅក្នុងចិត្តផ្សេងដោយសុខមានកាមាវចរសុខជាដើម មានកុសលនៃកុសល-កម្មបថ ១០ ប្រការនេះ ដែលបុគ្គលប្រព្រឹត្តមកហើយ និងប្រព្រឹត្តល្អហើយ ជាមូល ជាឫសគល់ រមែងមិនលះបង់ ( បុគ្គលនោះ ) ក្នុង

ទីដែលបុគ្គលនោះទៅហើយៗ ដូចស្រមោលអន្ទោលទៅតាមប្រាណ យ៉ាងនោះឯង ។

ក្នុងកាលចប់គាថា ការត្រាស់ដឹងធម៌ បានមានហើយដល់ពួកសត្វ ៨៤០០០ មដ្ឋកុណ្ឌលីទេវបុត្រតាំងនៅហើយក្នុងព្រះសោតាបត្តិផល, អទិន្នបុព្វកព្រាហ្មណ៍ក៏ដូចគ្នាដែរ ។ គាត់បានសាបព្រោះទ្រព្យសម្បត្តិដ៏ច្រើនដល់ម្ល៉េះ ក្នុងព្រះពុទ្ធសាសនា ដោយប្រការដូច្នេះឯង ។

( រឿងមដ្ឋកុណ្ឌលី ចប់ )

## ៣ រឿងព្រះតិស្សៈ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះ-ថេរៈឈ្មោះ តិស្សៈ បានត្រាស់នូវព្រះធម្មទេសនានេះថា "**អក្កោច្ឆិ មំ អវធិ មំ**" ជាដើម ។

### ព្រះតិស្សត្ថេរជាអ្នកទូន្មានលំបាក និង ប្រកាន់ខ្លួន

បានឮមកថា ព្រះតិស្សត្ថេរនោះ ជាឱរសនៃព្រះមាតុច្ឆារបស់ព្រះមានព្រះភាគ ( ព្រះអង្គម្ចាស់មីងខាងមាតា ) បួសក្នុងកាលនៃខ្លួនជាមនុស្សចាស់ បរិភោគលាភសក្ការៈដែលកើតឡើងហើយក្នុងព្រះ-ពុទ្ធសាសនា មានរាងកាយធំធាត់ មានចីវរដែលបុគ្គលជំទូទៅ និងជំត្រឡប់ហើយ ដោយច្រើនអង្គុយក្នុងឧបដ្ឋានសាលាក្នុងវត្ត ។ ភិក្ខុអាគន្តុកៈទាំងឡាយមកហើយ ដើម្បីប្រយោជន៍នឹងគាល់ព្រះតថាគតទៅកាន់សំណាក់របស់លោកដោយសម្គាល់ថា "នេះនឹងជាព្រះមហាថេរៈ" ដូច្នេះហើយ សួរដល់វត្ត សួរដល់កិច្ចគួរធ្វើ មានប្របាច់ជើងជាដើម ។ លោកអង្គុយស្ងៀម ។

គ្រានោះ ភិក្ខុកំលោះមួយអង្គសួរលោកថា “លោកមានវស្សាប៉ុន្មាន” ? លោកឆ្លើយថា “មិនទាន់មានវស្សា ខ្ញុំព្រះករុណាបួសហើយក្នុងកាលនៃខ្លួនជាមនុស្សចាស់” ទើបពោលថា ម្នាលអាវុសោ អ្នកជាមនុស្សដែលគេប្រដៅបានដោយក្រ អ្នកមិនស្គាល់ប្រមាណរបស់ខ្លួន, អ្នកឃើញព្រះមហាថេរៈមានប្រមាណប៉ុណ្ណេះហើយ មិនធ្វើវត្តសូម្បីតែសាមីចិកម្ម កាលវត្តដែលព្រះថេរៈទាំងនោះសួរដោយអើពើ លោកអង្គុយស្ងៀម, សូម្បីត្រឹមតែការវៀស ក៏មិនមានដល់លោក” ដូច្នេះ ទើបប្រហារនូវម្រាមដៃ ។ លោកញ៉ាំងខត្តិយមានះឲ្យកើតឡើងហើយ សួរថា “ពួកលោកមកកាន់សំណាក់អ្នកណា” ?កាលអាគន្តុកភិក្ខុទាំងនោះ ឆ្លើយថា “មកកាន់សំណាក់របស់ព្រះសាស្តា” ទើបពោលថា “ក៏ពួកលោកស្មានខ្ញុំថា នេះនរណា ខ្ញុំនឹងកាត់ភាពជាសមណៈរបស់ពួកលោកចេញឲ្យទាល់តែបាន” ដូច្នេះហើយ យំកើតទុក្ខ ខូចចិត្ត បានទៅកាន់សំណាក់របស់ព្រះសាស្តា ។

# ព្រះតិស្សៈទូលរឿងដល់ព្រះសាស្តា

គ្រានោះ ព្រះសាស្តាត្រាស់សួរលោកថា “ម្នាលតិស្សៈ ព្រោះហេតុអ្វី ទើបអ្នកកើតទុក្ខ អាក់អន់ចិត្ត មានមុខទទឹកដោយទឹកភ្នែក ស្រែកយំ មកហើយកាន់សំណាក់របស់តថាគត” ។ ចំណែកភិក្ខុទាំងនោះ ( គឺភិក្ខុអាគន្តុកៈ ) គិតថា “ភិក្ខុនោះគប្បីទៅធ្វើកម្មអ្វីមួយ” ដូច្នេះទើបទៅជាមួយនឹងព្រះតិស្សៈនោះដែរ ថ្វាយបង្គំព្រះសាស្តាហើយ បានអង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះតិស្សៈនោះ ដែលព្រះសាស្តាត្រាស់សួរហើយ បានក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុទាំងនេះជេរខ្ញុំព្រះអង្គ” ។

ស. ក៏អ្នកអង្គុយហើយក្នុងទីណា ?

ត. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគង់ក្នុងឧបដ្ឋានសាលា ។

ស. ភិក្ខុទាំងនេះមក អ្នកបានឃើញឬ ?

ត. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។

ស. អ្នកបានក្រោកឡើងធ្វើការទទួលឬ ?

គ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានធ្វើទេ ។

ស. អ្នកបានសួរដោយអើពើដល់ការទទួលបរិក្ខាររបស់ភិក្ខុទាំងនោះឬ ?

គ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានសួរដោយអើពើទេ ។

ស. អ្នកបានសួរដោយអើពើ ដល់ធម្មទំនៀម ឬទឹកផាន់ឬ ?

គ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានសួរដោយអើពើទេ ។

ស. អ្នកនាំអាសនៈមកហើយ ធ្វើការប្រេបាច់ជើងឲ្យឬ ?

គ. បពិត្រព្រះដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានធ្វើទេ ។

## ព្រះតិស្សៈមិនព្រមខមាទោសភិក្ខុសង្ឃ

ស. ម្នាលតិស្សៈ វត្តទាំងពួងនោះ អ្នកគួរធ្វើដល់ភិក្ខុចាស់ ។ កាលដែលអ្នកមិនធ្វើវត្តទាំងពួងនោះហើយ អង្គុយនៅក្នុងវិហារមិនសមគួរឡើយ, ទោសរបស់អ្នកឯងមាន ។ អ្នកឯងចូរសូមទោសភិក្ខុទាំងឡាយនោះទៅ ។

គ. បពិត្រព្រអង្គដ៏ចម្រើន ភិក្ខុទាំងនេះបានជេរខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ

មិនព្រមសូមខមាទោសទេ ។

ស. ម្នាលតិស្សៈ អ្នកុំបានធ្វើយ៉ាងនេះ ទោសរបស់អ្នកមាន អ្នកចូរសូម ទោសភិក្ខុទាំងនោះចុះ ។

ត. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនព្រមសូមទោសភិក្ខុទាំងនេះ ។

គ្រានោះ ព្រះសាស្តា កាលភិក្ខុទាំងឡាយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះតិស្សៈនេះជាអ្នកទូន្មានបានដោយកម្រ" ដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តិស្សៈនេះមិនមែនជាអ្នកដែលគេទូន្មានបានដោយកម្រតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងកាលមុន តិស្សៈនេះក៏ជាអ្នកទូន្មានបានដោយកម្រដូចគ្នា" កាលភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយជ្រាបការដែលលោកជាអ្នកទូន្មានបានដោយកម្រ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ, លោកបានធ្វើអ្វីទុកក្នុងអតីតកាល" ដូច្នេះហើយ ក៏ទ្រង់នាំរឿងអតីតៈមក ។

# បុព្វកម្មរបស់ព្រះតិស្សៈ

ក្នុងអតីតកាល កាលព្រះបាទពារាណសី សោយរាជសម្បត្តិនៅក្នុងក្រុងពារាណសី, មានតាបសឈ្មោះ ទេវិល នៅក្នុងហិមវន្តប្រទេស ៨ ខែ ប្រាថ្នានឹងចូលទៅអាស្រ័យព្រះនគរ ៤ ខែ ដើម្បីត្រូវការនឹងសេពរសប្រៃ និងរសជូរ ទើបចេញពីហិមវន្តប្រទេស ជួបអ្នកយាមទ្វារព្រះនគរ ទើបសួរថា "ពួកបព្វជិត អ្នកមកដល់ព្រះនគរនេះហើយ រមែងសម្រាកនៅទីណា" ? អ្នកយាមទ្វារព្រះនគរ ប្រាប់ថា "ក្នុងរោងនាយស្មូនឆ្នាំង លោកម្ចាស់" ។ លោកទៅកាន់រោងនៃស្មូនឆ្នាំងហើយ ឈរទៀបទ្វារពោលថា "បើលោកមិនធុញទ្រាន់ចិត្ត (សេចក្តីមិនចង្អៀតចង្អល់) អាត្មាសូមសម្រាកនៅក្នុងរោងមួយយប់" ស្មូនឆ្នាំងពោលថា "ពេលយប់កិច្ចរបស់ខ្ញុំក្នុងរោងមិនមាន, រោងធំ, និមន្តលោកនៅតាមសប្បាយចុះ" ដូច្នេះហើយ ក៏ថ្វាយរោងដល់លោក ។

កាលលោកចូលទៅអង្គុយហើយ ។ មានតាបសមួយអង្គទៀតឈ្មោះ នារទៈ មកអំពីហិមវន្តប្រទេស បានសុំស្មូនឆ្នាំងសំរាក

មួយរាត្រី ។ ស្ងួនផ្ទាំងគិតថា "តាបសអង្គដែលនិមន្តមកមុន គប្បីជាអ្នកលំបាកនៅជាមួយនឹងតាបសអង្គនេះឬទេ "ក៏មិនជ្រាប, យើងនឹងដោះខ្លួនចេញ" ដូច្នេះហើយ ទើបពោលថា "បើលោកអង្គចូលទៅមុននឹងពេញចិត្តសោត, សូមលោកសម្រាកនៅតាមការពេញចិត្តនៃតាបសអង្គមុនចុះ" ។ នារទតាបសនោះចូលទៅរកទេវិលតាបសហើយពោលថា "បពិត្រលោកអាចារ្យ បើលោកមិនជូនចិត្តទេ, ខ្ញុំសូមសម្រាកនៅក្នុងរោងនេះមួយរាត្រីផង" កាលតាវិលតាបសពោលថា "រោងធំ សូមលោកចូលទៅនៅក្នុងទីចំណែកមួយចុះ" ដូច្នេះហើយ ទើបចូលទៅអង្គុយក្នុងទីចំណែកមួយទៀត នៃទេវិលតាបសដែលជាអ្នកចូលទៅមុន ។

## ទោសនៃការដេកខុសកន្លែង

តាបសសូម្បីទាំងពីររូប និយាយប្រាស្រ័យឲ្យដល់ការរព្រកដល់គ្នានិងគ្នាហើយ, ក្នុងវេលាដេក ។ នារទតាបសកំណត់ទីដេកនៃតាបស និងទ្វារហើយ ទើបដេក ។ ចំណែកទេវិលតាបសនោះ

កាលនឹងដេក មិនបានដេកក្នុងទីកន្លែងរបស់ខ្លួនទេ ( ត្រឡប់ ) ដេកទទឹងត្រង់កណ្ដាលទ្វារ ។ នារទតាបសកាលចេញទៅក្នុងរាត្រី បានជាន់ត្រង់ជដារបស់លោក ។ កាលលោកពោលថា នរណាជាន់យើង" ? នារទតាបសពោលថា "បពិត្រលោកអាចារ្យ ខ្ញុំ " ។

ទ. នែ ជដិលកោង លោកមកអំពីព្រៃហើយ ជាន់ត្រង់ជដារបស់យើង ។

ន. បពិត្រលោកអាចារ្យ ខ្ញុំមិនដឹងថា លោកដេកទីនេះ សូមលោកអត់ទោសឲ្យខ្ញុំផងចុះ ។ កាលលោកកំពុងរអ៊ូរទាំនោះឯងនារទតាបសក៏បានចេញទៅខាងក្រៅ ទេវិលតាបសក្រៅនេះគិតថា "តាបសរូបនេះ សូម្បីចូលមកនឹងគប្បីជាន់យើង" ដូច្នេះហើយ ទើបបានសឹងបែរក្បាលត្រឡប់ទៅទីនៃជើងវិញ ។

ចំណែកនារទតាបស កាលនឹងចូលទៅគិតថា "សូម្បីកាលដំបូងយើងបានខុសហើយក្នុងលោកអាចារ្យ, ឥឡូវនេះ យើងនឹងចូលទៅតាមចំណែកនៃជើងរបស់លោក" ដូច្នេះហើយ កាលមកបានជាន់

ត្រង់ករបស់លោក, កាលលោកពោលថា “ នរណាហ្នឹង ” ? ទើប ពោលថា “បពិត្រលោកអាចារ្យ ខ្ញុំ” កាលលោកពោលថា “ជដិល កោង កាលពីដំបូងលោកជាន់ត្រង់ជដារបស់យើងហើយ ឥឡូវនេះ ជាន់ត្រង់ករបស់យើងទៀត យើងនឹងដាក់ផ្តាសារលោក” ទើបពោល ថា “បពិត្រលោកអាចារ្យ ទោសរបស់មិនមាន, ខ្ញុំមិនដឹងថាលោក ដេកហើយយ៉ាងនេះ, ខ្ញុំគិតថា សូម្បីពីដំបូងកំហុសរបស់យើងមាន, ឥឡូវនេះ យើងនឹងចូលទៅតាមចំណែកនៃជើងរបស់លោក ដូច្នេះ សូមលោកចូរអត់ទោសដល់ខ្ញុំផងចុះ” ។

## តាបសទាំងពីរនាក់ដាក់ផ្តាសារគ្នា

ទ. នែ ជដិលកោង យើងនឹងដាក់ផ្តាសារលោក ។

ន. បពិត្រលោកអាចារ្យ លោកកុំធ្វើយ៉ាងនេះឡើយ ។

លោកមិនអើពើនឹងពាក្យសម្តីរបស់នារទតាបសនោះ

នៅតែបចេសដាក់ ផ្តាសារនារទតាបសនោះ ( ដោយគាថាថា ) ៖

“ព្រះអាទិត្យមានរស្មីទាំងពាន់ មានតេជៈទាំងរយ មាន

ប្រក្រតីកម្ចាត់ងងឹត, លុះព្រះអាទិត្យរះឡើងមកក្នុងវេលា

ព្រឹក សូមក្បាលរបស់លោកចូរបែកចេញជា ៧ ចំរៀក" ។

នារទតាបសពោលថា "បពិត្រលោកអាចារ្យ ទោសរបស់ខ្ញុំមិនមាន កាលខ្ញុំកំពុងតែពោល លោកបានផ្ដាសារហើយ ។ ទោសរបស់អ្នកណាមាន សូមក្បាលរបស់អ្នកនោះចូរបែក, របស់អ្នកណាមិនមានចូរកុំបែក" ដូច្នេះហើយ បានផ្ដាសារ ( ដោយគាថា ) ថា ៖

"ព្រះអាទិត្យមានរស្មីទាំងពាន់ មានតេជៈទាំងរយ មាន

ប្រក្រតីកម្ចាត់ងងឹត, លុះព្រះអាទិត្យរះឡើងមកក្នុងវេលា

ព្រឹក សូមក្បាលរបស់លោកចូរបែកចេញជា ៧ ចំណែក" ។

ក៏នារទតាបសនោះ មានអានុភាពច្រើន តាមរឭកជាតិបាន ៨០ កប្ប គឺក្នុងអតីតកាល ៤០ កប្ប, ក្នុងអនាគតកាល ៤០ កប្ប ។ ព្រោះហេតុនោះ លោកគិតថា "បន្ដាសារនឹងធ្លាក់ទៅលើនរណាហ្ន៎" ? ដូច្នេះ កាលពិចារណាទៅក៏ដឹងថា នឹងធ្លាក់ទៅលើលោកអាចារ្យ, អាស្រ័យសេចក្ដីករុណាចំពោះលោក ទើបហាមអារុណកុំឲ្យរះឡើង

ដោយកម្លាំងឫទ្ធិ" ។

## ប្រជាជនក្តៅក្រហាយរហូតដល់ព្រះរាជា

អ្នកព្រះនគរ កាលអរុណមិនរះឡើង ក៏នាំគ្នាទៅកាន់ទ្វារព្រះរាជវាំង ហើយក្រាបទូលកន្ទក់កន្ទេញ (លំអុក) ថា "បពិត្រព្រះសម្មតិទេព កាលព្រះអង្គគ្រប់គ្រងរាជសម្បត្តិ, អារុណមិនរះឡើង សូមទ្រង់ព្រះករុណា មេត្តាឲ្យអារុណរះឡើង ដើម្បីខ្ញុំព្រះអង្គទាំងឡាយចុះ" ។

ព្រះរាជាទ្រង់ពិចារណាចរិយាអនុវត្ត មានកាយកម្មជាដើមរបស់ព្រះអង្គ មិនឃើញនូវកម្មដែលមិនសមគួរតិចតួចណាៗ ឡើយ ទើបទ្រង់ព្រះតម្រិះថា "មានហេតុអ្វីហ្ន៎" ដូច្នេះ ទ្រង់រង្កៀសថា "នឹងជាការវិវាទរបស់ពួកបព្វជិត" ដូច្នេះហើយ ទើបត្រាស់សួរថា "ពួកបព្វជិតក្នុងព្រះនគរនេះមានខ្លះដែរឬ" ? កាលមានអ្នកក្រាបទូលថា "ក្នាលពីល្ងាចថ្ងៃម្សិលមិញនេះ មានពួកបព្វជិតមកកាន់រោងស្មូនឆ្នាំងព្រះអង្គ" ព្រះរាជាមានរាជបុរសកាន់គប់ភ្លើង ស្តេចទៅកាន់ទីនោះ ក្នុងខណៈនោះឯង ទ្រង់ថ្វាយបង្គំព្រះនារទតាបសហើយ ទ្រង់ប្រថាប់នៅត្រង់ទី

ម្នាងហើយត្រាស់សួរថា ៖

“បពិត្រព្រះនារទតាបស ការងារទាំងឡាយនៃអ្នកជម្ពូទ្វីប រមែងប្រព្រឹត្តទៅមិនបាន, លោកកើតងងឹតហើយ ព្រោះហេតុអ្វី លោកដែលខ្ញុំសួរហើយ ចូរប្រាប់នូវហេតុនោះដល់ខ្ញុំ” ។

នារទតាបស ដំណាលរឿងទាំងអស់ថ្វាយស្រេចហើយ ថ្វាយព្រះពរថា “អាត្មាភាព ដែលតាបសរូបនេះផ្តាសារហើយដោយហេតុនេះ កាលបើដូច្នេះ ទើបបានផ្តាសារខ្វះថា “ទោសរបស់ខ្ញុំមិនមាន, ពាក្យផ្តាសារចូរមានដល់បុគ្គលនោះចុះ” ក៏លុះផ្តាសារហើយ ទើបគិតថា “តើទោសនៃការផ្តាសារនេះនឹងមានដល់នរណាហ្ន៎” ? កាលពិចារណាទៅក៏ឃើញថា “ក្នុងវេលាព្រះអាទិត្យរះឡើង ក្បាលរបស់អាចារ្យនឹងបែកជា ៧ ចំណែក ដូច្នេះហើយ អាស្រ័យសេចក្តីអនុគ្រោះចំពោះលោក ទើបមិនឲ្យអារុណរះឡើង ។

ព្រះរាជាត្រាស់សួរថា បពិត្រលោកដ៏ចម្រើន ក៏អន្តរាយមិន

គប្បីមាន ដល់លោកដោយប្រការដូចម្តេច ?

ន. បើលោកសូមទោសអាត្មាហើយ អន្តរាយក៏នឹងមិនគប្បីមានដល់លោកឡើយ ។

រ. បើដូច្នោះ លោកចូរសូមទោសចុះ ។

ទ. ជដិលនោះជាន់អាត្មាភាពត្រង់ជដា និងត្រង់ក អាត្មាភាពមិនព្រមសូមទោសជដិលកោងនោះទេ ។

រ. បពិត្រលោកដ៏ចម្រើន សូមលោកចូរសូមទោសលោកចុះ លោកកុំធ្វើយ៉ាងនេះ ។

ទេវិលតាបសពោលថា "អាត្មាភាព មិនព្រមសូមទោស" សូម្បីកាលព្រះរាជាត្រាស់ថា "ក្បាលរបស់លោកនឹងបែកជា ៧ ចំរៀក" ដូច្នេះ ក៏នៅតែមិនព្រមសូមទោសទៀត ។

ខណៈនោះ ព្រះរាជាត្រាស់នឹងលោកថា "លោកមិនព្រមសូមទោសតាមការពេញចិត្តរបស់ខ្លួនឬ" ? ដូច្នេះហើយ ទើបបញ្ជាឲ្យរាជបុរសចាប់ទេវិលតាបសនោះត្រង់ដៃ, ត្រង់ជើង, ត្រង់ពោះ, ត្រង់កឲ្យ

ឱនចុះទៀបបាទមូល របស់នារទតាបស ។

នារទតាបសពោលថា "អាចារ្យ អញ្ជើញលោកក្រោកឡើងចុះ ខ្ញុំព្រមអត់ទោសឲ្យដល់លោក" ដូច្នេះហើយ ថ្វាយព្រះពរថា "មហាបពិត្រតាបសរូបនេះ មិនបានសូមទោសអាត្មាភាពតាមការពេញចិត្តឡើយ, មានស្រះនៅមិនឆ្ងាយអំពីទីនេះមួយ សូមព្រះអង្គបញ្ជាឲ្យលោកឈរទូលដុំដីស្អិតលើក្បាល ត្រាំទឹកនៅក្នុងស្រះនោះត្រឹមក ។ ព្រះរាជាបញ្ជាឲ្យធ្វើយ៉ាងនោះហើយ ។ នារទតាបសហៅទេវិលតាបសមក "បពិត្រលោកអាចារ្យ លុះឫទ្ធិដែលខ្ញុំព្រលែងហើយ កាលពន្លឺព្រះអាទិត្យតាំងឡើង, លោកគប្បីមុជចុះក្នុងទឹក ហើយទៅងើបឡើងទីដទៃចុះ" ដុំដីស្អិតលើក្បាលរបស់ទេវិលតាបសនោះ លុះរស្មីនៃព្រះអាទិត្យពាល់ត្រូវហើយប៉ុណ្ណោះក៏បែកជា ៧ ចំរៀក, ទេវិលតាបសនោះមុជចុះទៅកាន់ទីដទៃ ។

## ពៀរមិនស្ងប់ដោយការចងពៀរ

ព្រះសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ បាន

ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាល ឥឡូវនេះ, ទេវិលតាបសបានមកជាតិស្សៈ, នារទតាបសបានមកជាយើងតថាគតនេះឯង, សូម្បីក្នុងកាលនោះ តិស្សៈនេះក៏ជាអ្នកទូន្មានបានដោយកម្រយ៉ាងនេះដែរ" ដូច្នេះហើយ បញ្ជាឲ្យហៅតិស្សត្ថេរមកហើយ ត្រាស់ថា "ម្នាលតិស្សៈ ក៏កាលភិក្ខុគិតថា យើងទើងត្រូវអ្នកឯណោះជេរហើយ ត្រូវអ្នកឯណោះប្រហារហើយ ត្រូវអ្នកឯណោះឈ្នះហើយ, អ្នកឯណោះបានលួចទ្រព្យរបស់យើងទៅហើយ, ដូច្នេះឈ្មោះថាពៀរមិនស្ងប់ទៅបានទេ, តែកាលភិក្ខុមិនចូលទៅចងពៀរយ៉ាងនោះឯង ពៀររមែងស្ងប់ទៅបាន, ដូច្នេះហើយ បានទ្រង់ភាសិត ព្រះគាថាទាំងនេះថា ៖

៣ អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ
អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

បើអ្នកណាចូលទៅចងសេចក្តីក្រោធនោះទុកថា អ្នកឯណោះបានជេរអញ អ្នកឯណោះបានប្រហារអញ អ្នកឯណោះបានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញទៅហើយ ( ដូច្នេះ ) ពៀររបស់អ្នកនោះ មិនរម្ងាប់ឡើយ ។

អ្នកឯណោះបានជេរអញ អ្នកឯណោះបានប្រហារអញ អ្នកឯណោះបានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណាមិនចូលទៅចងសេចក្តីក្រោធបែបនោះទុក ( ដូច្នេះ ) ពៀររបស់អ្នកនោះ ទើបស្ងប់បាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អក្កោច្ឆិ** គឺជេរហើយ ។ បទថា **អវធិ** គឺប្រហារហើយ ។ បទថា **អជិនិ** គឺបានឈ្នះយើងដោយការអាងសាក្សីកោងខ្លះ ដោយការពោលប្រកែកខ្លះ ដោយការធ្វើឲ្យក្រៃលែងជាងការធ្វើខ្លះ ។

បទថា **អហាសិ** គឺអ្នកឯណោះបានលួចយកទ្រព្យ គឺបណ្តា

វត្ថុទាំងឡាយមានសំពត់ជាដើម វត្ថុណាមួយរបស់យើង ។

ពីរបទថា **យេ ច តំ** ជាដើម សេចក្ដីថា ជនពួកណាមួយ គឺទេវតា ឬមនុស្ស គ្រហស្ថ ឬបព្វជិត ចូលទៅចងសេចក្ដីក្រោធនោះ គឺមានវត្ថុជាដើម ថា "អ្នកឯណោះបានជេរយើង" ដូចពួកអ្នកបររទេះ ចងនូវនឹមនៃរទេះដោយមេកំព្រា និងដូចពួកអ្នកប្រមាញ់ចងវត្ថុមានត្រីស្អុយជាដើម ដោយវត្ថុទាំងឡាយ មានស្បូវក្លាំងជាដើមរឿយៗ ។ ពៀររបស់ពួកជនទាំងនោះកើតឡើងហើយ អស់វារៈម្ដងរមែងមិនស្ងប់ គឺថារមែងមិនស្ងប់រម្ងាប់ទៅបាន ។

បាទនៃព្រះគាថាថា **យេ ច តំ នូបនយ្ហន្តិ** សេចក្ដីថា ជនទាំងឡាយឯណាមិនចូលទៅចងសេចក្ដីក្រោធនោះ គឺមានពាក្យជេរជាដើមជាទីតាំង ដោយការមិនរឭកដល់ និងការមិនធ្វើទុកក្នុងចិត្ដខ្លះ ដោយអំណាចការពិចារណាឃើញកម្មយ៉ាងនេះថា "អ្នកណាមួយដែលថាជាអ្នកមិនមានទោសមិនមាន សូម្បីលោកក៏គង់នឹងជេរគេហើយក្នុងភពមុន គង់នឹងធ្លាប់ប្រហារគេហើយក្នុងភពមុន គង់នឹង

ធ្លាប់អាងសាក្សីកោងឈ្នះគេហើយក្នុងកពមុន លោកគង់នឹងលួចយកព្រទ្យរបស់អ្នកដទៃហើយក្នុងកពមុន, ព្រោះដូច្នោះ លោកសូម្បីជាអ្នកមិនមានទោស ទើបបានទទួលផលដែលមិនគួរប្រាថ្នា មានពាក្យជេរជាដើម" ដូច្នេះខ្លះ, ពៀររបស់ជនទាំងនោះ សូម្បីកើតហើយព្រោះសេចក្ដីប្រមាទ រមែងស្ងប់បានដោយការមិនចង ( ក្រោធ ) នេះ ដូចភ្លើងព្រៃមានរំកាច់អស់ហើយ ដូច្នោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុមួយសែន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ព្រះធម្មទេសនាបានជាកថាមានប្រយោជន៍ដល់មហាជនហើយ ។ ព្រះតិស្សត្ថេរ សូម្បីជាមនុស្សប្រដៅក្រ ក៏ក្លាយជាមនុស្សប្រដៅងាយហើយ ដូច្នេះឯង ៕

( រឿងព្រះតិស្សៈ ចប់ )

# ៤ រឿងការកើតឡើងនៃនាងយក្ខិណី

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្ត្រីអារម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា “**ន ហិ វេរេន វេរានិ**” ជាដើម ។

## មាតារកភរិយាឲ្យបុត្រ

ដូចបានស្ដាប់មក បុត្រកុដុម្ពីក៍ម្នាក់ កាលបិតាធ្វើមរណកាលទៅហើយ ធ្វើការងារទាំងពួង ទាំងការងារក្នុងស្រែផ្សេងៗ ទាំងការងារក្នុងផ្ទះផងដោយខ្លួនឯង បដិបត្តិមាតាបិតា ។ តមក មាតាបានប្រាប់ដល់គេថា “នែកូន ម៉ែ នឹងនាំនាងកុមារិកាមកឲ្យឯង” ។

បុ. ម៉ែ កុំនិយាយយ៉ាងនេះឡើយ, ខ្ញុំនឹងប្រណិបត្តន៍ម៉ែរហូតអស់មួយជីវិត ។

ម. ហៃបា កូនឯងតែម្នាក់ធ្វើការងារទាំងក្នុងស្រែផងទាំងក្នុងផ្ទះផង, ព្រោះហេតុនោះ ម៉ែមិនមានការសប្បាយចិត្តឡើយ, ម៉ែនឹងនាំនាងកុមារិកាមកឲ្យឯង ។

គេសូម្បីហាម (មាតា) ច្រើនដងហើយបានជាអ្នកស្ងៀម មាតានោះចេញអំពីផ្ទះដើម្បីនឹងទៅកាន់ត្រកូលមួយ ។

លំដាប់នោះ បុត្រសួរមាតាថា "ម៉ែនឹងទៅកាន់ត្រកូលណា" ? កាលមាតាប្រាប់ថា "នឹងទៅកាន់ត្រកូលឈ្មោះឯណោះ" ដូច្នេះហើយ ហាមការដែលនឹងទៅកាន់ត្រកូលនោះ ហើយប្រាប់ត្រកូលដែលខ្លួនពេញចិត្តឲ្យ ។ មាតាបានទៅកាន់ត្រកូលនោះ ដណ្តឹងនាងកុមារិកាទៅហើយ កំណត់ថ្ងៃ ( អាវាហ៍វិវាហ៍ ) នាំនាងកុមារិកានោះមក បានធ្វើទុកក្នុងផ្ទះរបស់ខ្លួន ។ នាងកុមារិកានោះបានជាស្រ្តីមានពូជ គឺកម្មសម្លាប់ហើយ ( ជាស្រ្តីអារ ) ។

ពេលនោះទើបមាតានិយាយនឹងបុត្រថា "ហៃបា កូនឯងឲ្យម៉ែនាំនាងកុមារិកាមកតាមការពេញចិត្តរបស់កូនឯងហើយ ឥឡូវនេះនាងកុមារិកានោះ ជាស្រ្តីអារ, ក៏ធម្មតាត្រកូលដែលមិនមានបុត្ររមែងវិនាស ប្រពៃណីរមែងមិនជាប់តទៅ ព្រោះហេតុនោះ ម៉ែនឹងនាំនាងកុមារិកាដទៃមក ( ឲ្យកូនឯង )" សូម្បីបុត្រនោះពោលហាមថា "កុំ

ឡើយម៉ែ” ដូច្នេះហើយ ក៏បានពោល ( យ៉ាងនោះ ) រឿយៗ ។ ស្ត្រីអារបានឮពាក្យនោះ ទើបគិតថា “ធម្មតាបុត្ររមែងមិនអាចហាមឃាត់ពាក្យមាតាបិតាបាន, ឥឡូវនេះម្ដាយក្មេកគិតនឹងនាំស្ត្រីដទៃ អ្នកមិនជាស្ត្រីអារមកហើយ ក៏នឹងប្រើយើងដូចជាទាសី, បើដូច្នោះយើងគប្បីនាំនាងកុមារិកាម្នាក់មកដោយខ្លួនឯង” ដូច្នេះហើយ ទើបទៅកាន់ត្រកូលមួយ សុំនាងកុមារិកាដើម្បីប្រយោជន៍ដល់បុរសជាស្វាមី, ត្រូវពួកជនក្នុងត្រកូលនោះហាមថា នាងកុំនិយាយដូច្នោះ” ដូច្នេះហើយ ទើបអង្វរថា ខ្ញុំជាស្ត្រីអារ ត្រកូលដែលមិនមានបុត្ររមែងវិនាស បុត្រីរបស់លោកបានបុត្រហើយនឹងបានជាម្ចាស់នៃសម្បត្តិ, សូមលោកមេត្តាលើកបុត្រីនោះឲ្យដល់ស្វាមីរបស់ខ្ញុំចុះ” ដូច្នេះហើយ ញ៉ាំងត្រកូលនោះឲ្យយល់ព្រមហើយ ទើបនាំមកទុកក្នុងផ្ទះរបស់ស្វាមី ។

ក្រោយមក ស្ត្រីអារនោះបានមានការត្រិះរិះថា “បើនាងនឹងមានបុត្រ ឬបុត្រីសោត នឹងបានជាម្ចាស់នៃសម្បត្តិតែម្នាក់ឯង, គួរយើងនឹងធ្វើនាងកុំឲ្យមានទារក” ។

## ប្រពន្ធដើមផ្សំថ្នាំទម្លាយគភ៌ប្រពន្ធចុង

ខណៈនោះ ស្ត្រីអារទើបនិយាយទឹងនាងនោះថា “គភ៌តាំងឡើងក្នុងផ្ទៃរបស់នាងកាលណា សូមឲ្យនាងប្រាប់ដល់ខ្ញុំក្នុងកាលនោះ” ។ នាងនោះទទួលថា “ចា៎” កាលគភ៌តាំងឡើងហើយ បានប្រាប់ដល់ស្ត្រីអារនោះ ។ ចំណែកស្ត្រីអារនោះឲ្យបបរ និងបាយដល់នាងនោះជានិច្ច ។ ខាងក្រោយមក នាងបានឲ្យថ្នាំសម្រាប់ធ្វើគភ៌ឲ្យធ្លាក់លាយទឹងអាហារដល់នាងនោះ ។ គភ៌ក៏ធ្លាក់ ( រលូតកូន ) ។ កាលគភ៌តាំងឡើងហើយជាគ្រាទីពីរ នាងក៏បានប្រាប់ដល់ស្ត្រីអារនោះ ។ សូម្បីស្ត្រីអារនោះក៏បានធ្វើគភ៌ឲ្យធ្លាក់ដោយឧបាយយ៉ាងនោះឯង ជាលើកទីពីរ ។

ខណៈនោះ ពួកស្ត្រីដែលស្និទ្ធស្នាលទឹងគ្នាបានសួរនាងនោះថា “ស្ត្រីរួមស្វាមីធ្វើអន្តរាយដល់នាងខ្លះឬទេ ? នាងប្រាប់សេចក្តីនោះហើយ ត្រូវស្ត្រីទាំងនោះពោលថា “ស្ត្រីអន្ធពាល ហេតុដូចម្តេចទើបបាននាងធ្វើយ៉ាងនោះទៅ ? ស្ត្រីអារនេះបានផ្សំថ្នាំសម្រាប់ធ្វើគភ៌ឲ្យ

ធ្លាក់ឲ្យដល់នាង ព្រោះខ្លាចនាងនឹងបានជាធំ ព្រោះដូច្នោះ ទើបគភ៌របស់នាងធ្លាក់, នាងបានធ្វើយ៉ាងនេះទៀត" ។ ក្នុងគ្រាទីបីនាងទើបមិនបានប្រាប់ ។ ខាងក្រោយមក ( ចំណែក ) ស្ត្រីអារឃើញផ្ទៃរបស់នាងនោះហើយទើបពោលថា "ហេតុដូចម្តេច ទើបនាងមិនប្រាប់ការដែលនាងតាំងគភ៌ដល់ខ្ញុំ" នាងនោះពោលថា "នាងនាំខ្ញុំមកហើយធ្វើគភ៌ឲ្យធ្លាក់ដល់ទៅពីរដងហើយ ខ្ញុំនឹងប្រាប់ដល់នាងធ្វើអ្វី ? ទើបគិតថា "ឥឡូវនេះ យើងវិនាសហើយ" រង់ចាំមើលការធ្វេសប្រហែសរបស់នាងកុមារិកានោះ, កាលគភ៌ចាស់ពេញលេញហើយ ទើបបានឱកាស បានផ្សំថ្នាំឲ្យហើយ គភ៌មិនអាចធ្លាក់ ព្រោះគភ៌ចាស់ ទើបដេកទទឹង ( ទ្វារ ) វេទនាខ្លាំងក្លាក៏កើតឡើង ។ នាងដល់ការអស់ជីវិត ។

នាងតាំងសេចក្តីប្រាថ្នាថា យើងត្រូវវាឲ្យវិនាសហើយ វាខ្លួនឯងនាំយើងមក ធ្វើទារកឲ្យវិនាសដល់ ៣ នាក់ហើយ ឥឡូវនេះយើងខ្លួនឯងក៏វិនាស ឥឡូវនេះ យើងចុតិចាកអត្តភាពនេះ គប្បីកើតជានាងយក្ខិណីអាចទំពាស៊ីទារករបស់វាចុះ" ដូច្នេះហើយ ស្លាប់ទៅ

កើត ជាឆ្មាក្នុងផ្ទះនោះឯង ។ ចំណែកស្វាមីចាប់ស្ត្រីអារនោះហើយ ពោលថា "នាងឯង បានធ្វើការកាត់ផ្តាច់ត្រកូល របស់យើងឲ្យដាច់សូន្យ" ដូច្នេះហើយ វាយដោយអវយវៈទាំងឡាយមានដុំដៃ និងជង្គង់ជាដើមឲ្យធ្ងន់ធ្ងរហើយ ។ ស្ត្រីអារនោះស្លាប់ព្រោះការឈឺចាប់នោះឯង ហើយបានកើតជាមេមាន់ក្នុងផ្ទះនោះដែរ ។

## ផ្លាស់ប្តូរគ្នាប្រហារគ្នាម្នាក់មួយជាតិដោយអំណាចនៃការចងពៀរ

ចំណេរកាលមិនយូរប៉ុន្មាន មេមាន់បានធ្លាក់ពងច្រើនៗពង មេឆ្មាមកស៊ីពងមាន់ទាំងនោះអស់ ។ សូម្បីលើកទីពីរ លើកទីបី វាក៏ស៊ីអស់ដែរ ។ សូម្បីមេមាន់ធ្វើសេចក្តីប្រាថ្នាថា "វាស៊ីពងរបស់យើងអស់បីដងហើយ ឥឡូវនេះ វាក៏ចង់ស៊ីខ្លួនយើងផង ។ ឥឡូវនេះ យើងចុតិចាកអត្តភាពនេះហើយ គប្បីបានទំពាស៊ីវា និងកូនរបស់វា" ដូច្នេះហើយ ចុតិចាកអត្តភាពនោះ បានកើតជាមេខ្លាដំបង ។ ចំណែកមេឆ្មាបានមកកើតជាមេម្រឹគ ។ ក្នុងវេលាមេម្រឹគនោះកើតកូនហើយៗ

មេខ្លាជំបងក៏បានមកស៊ីកូនម្រឹគទាំងឡាយអស់ដល់បីដង។ កាលជិតនឹងស្លាប់មេម្រឹគធ្វើសេចក្ដីប្រាថ្នាថា "ពួកកូនរបស់យើង មេខ្លាជំបងនេះស៊ីអស់ដល់បីដងហើយ ឥឡូវនេះវានឹងស៊ីខ្លួនយើងផង ។ ឥឡូវនេះយើងចុតិចាកអត្តភាពនេះហើយ គប្បីបានស៊ីវា និងកូនរបស់វាចុះ" ដូច្នេះហើយ បានស្លាប់ទៅកើតជានាងយក្ខិណី ចំណែកមេខ្លាជំ-បងចុតិចាកអត្តភាពនោះហើយ បានកើតជាកុលធីតាក្នុងក្រុងសាវត្ថី។ នាងមានវ័យចម្រើនហើយ បានទៅកាន់ត្រកូលនៃស្វាមីក្នុងស្រុកក្បែរទ្វារ ( ក្រុង ) ក្នុងកាលខាងក្រោយមក នាងបានប្រសូតបុត្រម្នាក់ ។ នាងយក្ខិណី ក្លែងខ្លួនជាស្ត្រីសម្លាញ់ដែលជាទីស្រឡាញ់នៃនាងកុលធីតានោះមកហើយ សួរថា "ស្ត្រីជាសម្លាញ់របស់ខ្ញុំនៅទីណា" ? ពួកអ្នកស្រុកបានប្រាប់ថា "នាងប្រសូតបុត្តនៅខាងក្នុងបន្ទប់ នាងយក្ខិណីស្ដាប់ពាក្យនោះហើយ ពោលថា "សម្លាញ់របស់ខ្ញុំ ប្រសូតបុត្តប្រុសឬស្រីហ្ន៎, ខ្ញុំនឹងមើលក្មេងនោះ" ពោលដូច្នេះហើយ ចូលទៅធ្វើអាការហាក់ដូចជាមើល ចាប់ទារកស៊ីហើយក៏ចេញទៅ ។ សូម្បីក្នុងគ្រា

ទីពីរក៏ស៊ីហើយដែរ ។ សូម្បីក្នុងគ្រាទីបីនាងកុលធីតាមានគភ៌ចាស់ក៏ហៅស្វាមីមកហើយ ប្រាប់ថា "នាយ នាងយក្ខិណីម្នាក់ស៊ីបុត្ររបស់ខ្ញុំក្នុងទីនេះពីរនាក់ហើយ, ឥឡូវនេះខ្ញុំនឹងទៅកាន់ផ្ទះនៃត្រកូលរបស់ខ្ញុំប្រសូតបុត្រ" ដូច្នេះហើយ ទៅកាន់ផ្ទះនៃត្រកូលប្រសូត ( បុត្រក្នុងទីនោះ ) ។ ក្នុងកាលនោះ យក្ខិណី នោះដល់វេនជញ្ជូនទឹក ។ ព្រោះថានាងយក្ខិណីទាំងឡាយ ត្រូវដងទឹកអំពីស្រះឈ្មោះអនោតត្តទូលលើក្បាលដើរមកដើម្បីស្តេចវេស្សវណតាមវេន ដោយកន្លងទៅ ៤ ខែខ្លះ ៥ ខែខ្លះទើបផុត (អំពីវេន) បាន ។ នាងយក្ខិណីដទៃមានការលំបាកហើយដល់ការអស់ជីវិតខ្លះក៏មាន ។ ចំណែកនាងយក្ខិណីនោះ លុះផុតអំពីវេនជញ្ជូនទឹកហើយប៉ុណ្ណោះ ក៏ប្រញាប់ទៅកាន់ផ្ទះនោះ សួរថា "ស្ត្រីដែលជាសម្មាញ់របស់ខ្ញុំនៅទីណា" ? ពួកអ្នកស្រុកប្រាប់ថា "នាងនឹងជួបស្ត្រីនោះអំពីទីណាបាន? នាងយក្ខិណីម្នាក់ស៊ីទារករបស់នាងដែលប្រសូតក្នុងទីនេះ, ព្រោះដូច្នោះ ទើបនាងទៅកាន់ផ្ទះនៃត្រកូល" នាងយក្ខិណីនោះ គិតថា "នាងទៅកាន់ទីណាៗក៏ដោយចុះ នឹង

មិនរួចផុតអំពីយើងបានទេ” ដូច្នេះហើយ ដោយកម្លាំងនៃពៀរធ្វើឲ្យឧស្សាហ៍ហើយ រត់សម្តៅទៅកាន់ក្រុង ។ ចំណែកនាងកុលធីតា ក្នុងថ្ងៃដែលជាទីដាក់ឈ្មោះឲ្យទារកនោះ នាងក៏បានងូតទឹកឲ្យបុត្រហើយដាក់ឈ្មោះ ពោលនឹងស្វាមីថា “នាយ ឥឡូវនេះ យើងនាំគ្នាទៅកាន់ផ្ទះរបស់យើងចុះ” បីបុត្រទៅជាមួយស្វាមី តាមផ្លូវដែលគាត់ទៅតាមកណ្តាលនៃវត្តប្រគល់បុត្រឲ្យដល់បុរសដែលជាស្វាមីហើយ ចុះងូតទឹកក្នុងស្រះបោក្ខរណីក្បែរវត្ត ហើយឡើងមកទទួលយកបុត្រ កាលស្វាមីកំពុងងូតទឹក ឈរឲ្យបុត្របៅ ក្រឡេកឃើញនាងយក្ខិណីមកចាំបាន ហើយស្រែកដោយសំឡេងដ៏ខ្លាំងថា “នាយ មកប្រញាប់ៗចុះនេះនាងយក្ខិណីនោះ”ដូច្នេះហើយ មិនអាចឈររង់ចាំរហូតដល់ស្វាមីនោះមកបាន រត់ត្រឡប់សម្តៅទៅកាន់វិហារ ។

## ពៀរមិនរម្ងាប់ដោយការចងពៀរ
## ពៀរតែងរម្ងាប់បានដោយការមិនចងពៀរ

ក្នុងសម័យនោះ ព្រះសាស្តាកំពុងសម្តែងធម៌នៅក្នុងកណ្តាល

បរិស័ទ នាងកុលធីតានោះ ឲ្យបុត្រដេកលើខ្នងព្រះបាទរបស់ព្រះ-តថាគតហើយ ក្រាបទូលថា "បុត្រនេះ ខ្ញុំព្រះអង្គថ្វាយដល់ព្រះអង្គហើយ សូមព្រះអង្គប្រទានជីវិតដល់បុត្ររបស់ខ្ញុំព្រះអង្គចុះ សុមន-ទេពដែលជាអ្នកអាស្រ័យនៅដំបូលខ្លោងទ្វារមិនព្រមឲ្យ យក្ខិណីចូលទៅខាងក្នុង ។ ព្រះសាស្តាត្រាស់ហៅព្រះអានន្ទមកហើយ ត្រាស់ថា "ម្នាលអានន្ទ អ្នកចូរទៅហៅយក្ខិណីនោះមក" ។ ព្រះថេរៈហៅនាងយក្ខិណីនោះមកហើយ ។ នាងកុលធីតាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នាងយក្ខិណីនេះមកហើយ ។ ព្រះសាស្តាត្រាស់ថា "នាងយក្ខិណីចូរមកចុះ, នាងកុំស្រែកឡើយ" ។ ដូច្នេះហើយ បានត្រាស់នឹងនាងយក្ខិណីដែលមកឈរនៅហើយថា "ព្រោះហេតុអ្វី ទើបនាងធ្វើយ៉ាងនេះ ? ប្រសិនបើពួកនាងមិនមកកាន់សំណាក់ព្រះពុទ្ធប្រាកដដូចជាតថាគតទេ ពៀររបស់ពួកនាងនឹងបានជាកម្ម តាំងនៅអស់កប្ប ដូចពៀររបស់ពស់ និងស្គារ, ខ្លាឃ្មុំ និងដើមពជ្រ ក្អែក និងមៀម, ព្រោះហេតុអ្វី ទើបពួកនាងធ្វើពៀរដាក់គ្នាអ៊ីចឹង ? ព្រោះពៀរ

រម្ងាប់បានដោយការមិនចងពៀរ មិនមែនរម្ងាប់បានដោយពៀរទេ”
ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា ៖

**៤ ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ**

**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។**

ពិតមែន តាំងពីកាលណាមក ក្នុងលោកនេះ ពៀរទាំង-
ឡាយ រមែងមិនស្ងប់រម្ងាប់ដោយការចងពៀរឡើយ
ពៀរទាំងឡាយ តែងស្ងប់រម្ងាប់ដោយការមិនចងពៀរ
ធម៌នេះមានយូរយោណាស់មកហើយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ន ហិ វេរេន** ជាដើម សេចក្ដីថា ឧបមាថា បុគ្គលសូម្បីកាលលាងនូវទីដែលប្រឡាក់ដោយរបស់មិនស្អាត មានទឹកមាត់ និងសំបោរជាដើមដោយរបស់មិនស្អាតទាំងនោះឯង រមែងមិនអាចធ្វើឲ្យជាទីបរិសុទ្ធបាត់ក្លិនស្អុយបាន, ដោយពិត ទីនោះត្រឡប់ជាទីមិនស្អាត និងមានក្លិនស្អុយក្រៃលែងជាងដើម យ៉ាង

ណាមិញ បុគ្គលកាលជេរតបនូវបុគ្គលដែលជេរ ប្រហារតបនូវបុគ្គលដែលប្រហារ រមែងមិនអាចញុំាងពៀរឲ្យស្ងប់ដោយពៀរបាន, ដោយពិត គេឈ្មោះថាធ្វើពៀរនោះឯងឲ្យក្រៃលែងឡើងៗ ដូច្នោះ សូម្បីក្នុងកាលណាៗ ដែលឈ្មោះថាពៀរទាំងឡាយ រមែងមិនស្ងប់រម្ងាប់បានដោយការចងពៀរ, ដោយពិត ឈ្មោះថារមែងចម្រើនតែម្យ៉ាង ដោយប្រការដូច្នេះ ។

ពីរបទថា **អវេរេន ច សម្មន្តិ** សេចក្តីថា ឧបមាថា របស់មិនស្អាត មានទឹកមាត់ជាដើមនោះ ដែលបុគ្គលលាងដោយទឹកថ្លារមែងស្អាតបរិសុទ្ធបាន, ទីនោះរមែងជាទីស្អាត មិនមានក្លិនស្អុយយ៉ាងណាមិញ ពៀរទាំងឡាយរមែងរម្ងាប់ គឺរមែងស្ងប់ បានដល់រមែងដល់ការមិនមានដោយការមិនមានពៀរ គឺដោយទឹក គឺខន្តី និងមេត្តា ដោយការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និងដោយការពិចារណាដូច្នោះ ។

បាទព្រះគាថាថា **ឯស ធម្មោ សនន្តនោ** សេចក្តីថា ធម៌នេះ

ដែលរាប់ថា ការស្ងប់រម្ងាប់ពៀរដោយការមិនចងពៀរ ជារបស់ចាស់ គឺជាមគ្គានៃព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ គ្រប់ៗព្រះអង្គ ធ្វើដំណើរទៅហើយ ។

ក្នុងកាលចប់ព្រះគាថា នាងយក្ខិណីនោះ តាំងនៅក្នុងសោតាបត្តិផល ។ ទេសនាបានជាកថា មានប្រយោជន៍សូម្បីដល់បរិស័ទអ្នកប្រជុំគ្នាហើយ ។

## នាងយក្ខិណីដឹងភ្លៀងច្រើនភ្លៀងតិច

ព្រះសាស្តា បានត្រាស់នឹងស្ត្រីនោះថា "នាងចូរឲ្យបុត្ររបស់នាងឲ្យដល់នាងយក្ខិណីចុះ" ។

ស. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គខ្លាច ។

ត. នាងកុំខ្លាចឡើយ, អន្តរាយរមែងមិនមានដល់នាងព្រោះអាស្រ័យនាងយក្ខិណីនេះ ។

នាងបានឲ្យបុត្រដល់យក្ខិណីនោះហើយ នាងយក្ខិណីនោះទទួលទារកនោះឱបថើបហើយឲ្យដល់មាតាវិញ ក៏ផ្ដើមយំ គ្រានោះ ព្រះ-

សាស្តាត្រាស់សួរនាងយក្ខិណីនោះថា ហេតុដូចម្តេចបានជានាងយំ ។

នាងយក្ខិណីនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពីមុនខ្ញុំព្រះអង្គ សូម្បីសម្រេចការចិញ្ចឹមជីវិតដោយមិនជ្រើសរើសផ្លូវ មិនបានអាហារពេញផ្ទៃ, ឥឡូវនេះ ខ្ញុំព្រះអង្គនឹងចិញ្ចឹមជីវិតបានយ៉ាងដូចម្តេច" ។

គ្រានោះ ព្រះសាស្តា ទ្រង់លួងលោមនាងយក្ខិណីនោះថា "នាងកុំព្រួយឡើយ" ដូច្នេះហើយ ត្រាស់នឹងស្ត្រីនោះថា "នាងចូរនាំនាងយក្ខិណី ទៅឲ្យនៅក្នុងផ្ទះរបស់ខ្លួន ហើយចូរផ្គត់ផ្គង់ដោយបបរ និងបាយដ៏ថ្មីថ្មោងទាំងឡាយ" ស្ត្រីនោះនាំនាងយក្ខិណីទៅហើយ ឲ្យសម្រាកនៅក្នុងរោងត្បាល់ បានផ្គត់ផ្គង់ដោយបបរ និងបាយថ្មីថ្មោងទាំងឡាយហើយ។ ក្នុងវេលាបុកស្រូវ អង្រែប្រាកដដល់នាងយក្ខិណីនោះដូចប្រហារសិរសា ទើបនាងហៅនាងកុលធីតាដែលជាសម្លាញ់មកហើយ និយាយថា "ខ្ញុំនឹងមិនអាចនៅក្នុងទីនេះបាន សូមនាងចូរឲ្យខ្ញុំស្នាក់នៅក្នុងទីដទៃចុះ" សូម្បីដែលស្ត្រីសម្លាញ់នោះឲ្យស្នាក់នៅក្នុង

ទីទាំងនេះ គឺក្នុងរោងអង្រែ ក្បែរពាងទឹក ក្បែរចង្ក្រាន ក្រោមសំយាបផ្ទះ លើគំនរសម្រាម ក្បែរទ្វារស្រុក, ( នាង ) ក៏ពោលថា "ក្នុងរោងអង្រែនេះ អង្រែរមែងប្រាកដដូចជាប្រហារសិរសាខ្ញុំ, ត្រង់ក្បែរពាងទឹកនេះ ពួកក្មេងរមែងចាក់ទឹកដែលសល់ទៅក្បែរពាងទឹក, ក្បែរចង្ក្រាននេះហ្វូងសុនខរមែងមកដេក, ក្រោមសំយាបផ្ទះនេះ, ពួកក្មេងរមែងធ្វើនូវវត្ថុមិនស្អាត, ក្បែរគំនរសម្រាមនេះ ជនទាំងឡាយរមែងចាក់សម្រាម, ក្បែរក្លោងទ្វារនេះ ក្មេងអ្នកស្រុករមែងលេងល្បែងខ្នាច់ "ដូច្នេះហើយ បានហាមទីទាំងពួងនោះ" ។

គ្រានោះ ស្ត្រីជាសម្លាញ់ ទើបឲ្យយក្ខិណីនោះសម្រាកនៅក្នុងទីដ៏ស្ងាត់ខាងក្រៅស្រុក ហើយនាំភោជន មានបបរ និងបាយជាដើមដ៏ថ្មីថ្មោងទៅដើម្បីនាងយក្ខិណីនោះ ហើយផ្គត់ផ្គង់ក្នុងទីនោះ នាងយក្ខិណីនោះគិតយ៉ាងនេះថា "ឥឡូវនេះ ស្ត្រីជាសម្លាញ់របស់យើងមានឧបការៈដល់យើងច្រើន ណ្ហើយចុះ យើងនឹងធ្វើការតបស្នងសងគុណអ្វីមួយ" ដូច្នេះហើយ បានប្រាប់ដល់ស្ត្រីជាសម្លាញ់ថា "ក្នុងឆ្នាំ

នេះនឹងមានភ្លៀងធ្លាក់ល្អ, នាងចូរធ្វើនូវសន្ទូងក្នុងទីទួលចុះ, ក្នុងឆ្នាំនេះភ្លៀងពុំល្អ នាងចូរធ្វើនូវសន្ទូងក្នុងទីទំនាបតែម្យ៉ាងចុះ ។ស្រូវសន្ទូងដែលពួកជនដ៏សេសធ្វើហើយ រមែងវិនាសទៅដោយទឹកក្រៃពេកខ្លះ ដោយមិនមានទឹកខ្លះ ។ ចំណែកសន្ទូងរបស់នាងកុលធីតានោះរមែងបរិបូណ៌ក្រៃលែង ។

## នាងយក្ខិណីចាប់ផ្ដើមតាំងសលាកភត្ត

គ្រានោះ ពួកជនទាំងឡាយដ៏សេសនាំគ្នាសួរនាងថា "នែ៎នាងសន្ទូងដែលនាងធ្វើហើយ រមែងមិនវិនាសដោយទឹកក្រៃពេក រមែងមិនវិនាសដោយទឹកតិច, នាងដឹងនូវការៈនៃឆ្នាំ មានភ្លៀងល្អ និងឆ្នាំមានភ្លៀងមិនល្អហើយទើបធ្វើនូវការងារឬ ? ហេតុហ្នឹងដូចម្ដេចហ្ន៎" ? នាងប្រាប់ថា "នាងយក្ខិណីជាសម្លាញ់របស់ខ្ញុំប្រាប់នូវការៈនៃឆ្នាំមានភ្លៀងល្អ និងឆ្នាំមានភ្លៀងមិនល្អដល់ខ្ញុំ, ខ្ញុំធ្វើសន្ទូងទាំងឡាយក្នុងទីទួល និងទីទំនាបតាមពាក្យរបស់យក្ខិណីនោះ, ព្រោះហេតុនោះ ទើបសន្ទូងរបស់ខ្ញុំសម្រេចបានបរិបូណ៌, ពួកអ្នកទាំងឡាយមិនឃើញនូវ

កោជនទាំងឡាយមានបបរ និងបាយជាដើមដែលបុគ្គលកាលនាំទៅអំពីផ្ទះរបស់ខ្ញុំអស់កាលជានិច្ចឬ ? វត្ថុទាំងឡាយមានបបរ និងបាយជាដើមនោះ គឺខ្ញុំនាំទៅដើម្បីនាងយក្ខិណីនោះ សូម្បីអ្នកទាំងពួងក៏ចូរនាំកោជនទាំងឡាយមានបបរ និងបាយដ៏ថ្មីថ្មោងជាដើមទៅដើម្បីនាងយក្ខិណីនោះខ្ចះចុះ នាងយក្ខិណីនោះក៏នឹងត្រួតមើលនូវការងារទាំង-ឡាយរបស់អ្នកទាំងឡាយ" ។

គ្រានោះ ពួកជនដែលនៅក្នុងក្រុងទាំងមូល នាំគ្នាធ្វើសក្ការបូជាដល់នាងយក្ខិណីនោះ, ចាប់ផ្ដើមអំពីនោះមក នាងយក្ខិណីនោះត្រួតមើលនូវការងារទាំងឡាយរបស់ជនទាំងពួង ជាស្ត្រីដល់ហើយនូវការៈជាអ្នកថ្កើងដោយលាភ ជាស្ត្រីមានបរិវារច្រើន ។

ក្នុងកាលតមក នាងយក្ខិណីនោះ តាំងផ្ដើមនូវសលាកភត្ត ៨ កន្លែង ។ សលាកភត្តនោះ ជនទាំងឡាយនឹងថ្វាយរហូតអស់កាលដល់សព្វថ្ងៃនេះ ។

( រឿងការកើតនៃនាងកាឡីយក្ខិណី ចប់ )

## ៥ រឿងភិក្ខុកោសម្ពី

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកភិក្ខុកោសម្ពី ត្រាស់ព្រះធម្មទេសនានេះថា “**បរេ ច ន វិជានន្តិ**” ជាដើម ។

### ព្រះវិន័យធរ និង ព្រះធម្មកថិកប្រកែកគ្នារឿងវិន័យ

សេចក្តីពិស្តារថា ភិក្ខុពីររូប គឺព្រះវិន័យធរមួយរូប ព្រះធម្មកថិកមួយរូប មានបរិវារមួយរូប ៗ ៥០០ បាននៅក្នុងឃោសិតារាមទៀបក្រុងកោសម្ពី ។ ថ្ងៃមួយ ក្នុងបណ្តាភិក្ខុពីររូបនោះ ព្រះធម្មកថិកទៅបង្គន់ ហើយបន្សល់ទឹកសម្រាប់ជម្រះទុកក្នុងភាជនៈក្នុងបន្ទប់ទឹកនោះ ហើយក៏ចេញមក ខាងក្រោយមកព្រះវិន័យធរចូលទៅបន្ទប់ទឹកនោះ ឃើញទឹកនោះ ចេញមកសួរព្រះធម្មកថិកថា “ម្នាលអាវុសោ លោកបន្សល់ទឹកទុកឬ” ?

ធម្ម. ករុណា លោកដ៏មានអាយុ ។

វិ. លោកមិនដឹងថាជាអាបត្តិ ព្រោះការបន្សល់ទឹកទុកឬ ?

ធម្ម. ករុណា ខ្ញុំមិនដឹង ។

វិ. អាវុសោ លោកមិនដឹងថាជាអាបត្តិ ដោយការបន្សល់ទឹកទុកនេះ ក៏ណេហ្គីយចុះ

ធម្ម. បើដូច្នោះ ខ្ញុំនឹងសម្តែងអាបត្តិនោះចេញ ។

វិ. ម្នាលអាវុសោ ប្រសិនបើសេចក្តីនុ៎ះលោកមិនមានចិត្តក្លែងព្រោះការមិនមានសតិ, អាបត្តិមិនមាន ។

ព្រះធម្មកថិកនោះ បានជាអ្នកមានការឃើញអាបត្តិនោះថាមិនមែនអាបត្តិ ។

ចំណែកព្រះវិន័យធរបានប្រាប់ដល់សិស្សរបស់ខ្លួនថា "ព្រះ-ធម្មកថិករូបនោះសូម្បីត្រូវអាបត្តិក៏មិនដឹង" ។ សិស្សរបស់ព្រះវិន័យ-ធរនោះ ឃើញសិស្សរបស់ព្រះធម្មកថិកនោះហើយ បានពោលថា "ព្រះឧបជ្ឈាយ៍របស់ពួកលោកសូម្បីត្រូវអាបត្តិហើយ ក៏មិនដឹងថាជាអាបត្តិ" ។ សិស្សរបស់ធម្មកថិកនោះទៅប្រាប់ដល់ឧបជ្ឈាយ៍របស់ខ្លួន ។ ព្រះធម្មកថិកនោះនិយាយយ៉ាងនេះថា "ព្រះវិន័យធររូបនេះ កាលមុននិយាយថា "មិនជាអាបត្តិ" ឥឡូវនេះនិយាយថាជាអាបត្តិ" ព្រះវិន័យ-

ធរនោះនិយាយមុសា” សិស្សរបស់ព្រះធម្មកថិកនោះនិយាយថា “ព្រះឧបជ្ឈាយ៍របស់ពួកលោកនិយាយមុសា” ។ សិស្សរបស់ព្រះវិន័យ-ធរ និងព្រះធម្មកថិកនោះញ៉ាំងជម្លោះឲ្យចម្រើនហើយ ដោយប្រការយ៉ាងនេះ ។

ខាងក្រោយមក ព្រះវិន័យធរបានឱកាសហើយ ក៏បានធ្វើឧក្ខេបនីយកម្មដល់ព្រះធម្មកថិក ព្រោះទោសដែលមិនឃើញអាបត្តិចាប់ពីពេលនោះមក សូម្បីពួកឧបដ្ឋាកអ្នកថ្វាយបច្ច័យរបស់ភិក្ខុពីររូបនោះក៏បានបែកជាពីរពួក ។ ពួកភិក្ខុនីអ្នកទទួលឱវាទក្តី ពួកអារក្ខទេវតាក្តី របស់ភិក្ខុពីររូបនោះ ពួកអាកាសដ្ឋទេវតាជាមិត្តឃើញ ព្រមទាំងមិត្តសម្ភពរបស់ពួកអារក្ខទេវតាទាំងនោះក្តី, ពួកបុថុជ្ជនទាំងពួងក្តី បានបែកជាពីរពួក រហូតដល់ព្រហ្មលោកក៏មានសំឡេងគឹកកងប្រព្រឹត្តទៅដូចគ្នា បានមានរហូតដល់អនិដ្ឋព្រហ្ម ។

## ព្រះសាស្តាត្រាស់ប្រៀនប្រដៅឲ្យសាមគ្គីគ្នា

គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះតថាគត ក្រាបទូលដល់

ការដែលពួកភិក្ខុអ្នកលើកវត្តប្រកាន់ថា "ព្រះធម្មកថិករូបនេះ សង្ឃលើកវត្តហើយដោយកម្មដែលប្រកបដោយធម៌" និងការដែលពួកភិក្ខុអ្នកប្រព្រឹត្តតាមធម្មកថិកដែលសង្ឃ លើកវត្តហើយប្រកាន់ថា "ព្រះ-ឧបជ្ឈាយ៍របស់ពួកយើង សង្ឃលើកវត្តហើយដោយកម្មដែលមិនបានប្រកបដោយធម៌" និងការដែលពួកភិក្ខុអ្នកប្រព្រឹត្តតាមព្រះធម្ម-កថិកដែលសង្ឃលើកវត្តទាំងនោះ សូម្បីដែលពួកភិក្ខុអ្នកលើកវត្តហាមហើយ ក៏នៅចចេសត្រាច់តាមហែហមចោមរោមព្រះធម្មកថិកនោះដដែល ។ ព្រះមានព្រះភាគបញ្ជូនឱវាទទៅថា "ភិក្ខុទាំងឡាយចូរព្រមព្រៀងគ្នា" អស់វារៈពីរដង ទ្រង់ព្រះសណ្ដាប់ថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយមិនប្រាថ្នានឹងជាអ្នកព្រមព្រៀងគ្នាទេ"ក្នុងវារៈទីបី ទ្រង់ព្រះសណ្ដាប់ថា "ភិក្ខុសង្ឃបែកគ្នាហើយ" ដូច្នេះទើបស្ដេចយាងទៅកាន់សំណាក់របស់ភិក្ខុទាំងឡាយ ហើយត្រាស់ទោសក្នុងការលើកវត្តរបស់ពួកភិក្ខុអ្នកលើកវត្ត និងទោសក្នុងការមិនឃើញអាបត្តិរបស់ពួកភិក្ខុក្រៅនេះ ហើយទ្រង់អនុញ្ញាតសង្ឃកម្មទាំងឡាយ

មានឧបោសថជាដើមក្នុងសីមាជាមួយគ្នា ក្នុងវត្តឃោសិតារាមនោះ ឯង ដល់ភិក្ខុទាំងឡាយទៀត ហើយទ្រង់បញ្ញត្តវត្តក្នុងពេលឆាន់ថា "ម្នាលភិក្ខុទាំងឡាយ គប្បីអង្គុយជាជួរលើអាសនៈមួយៗជាចន្លោះៗ" ដូច្នេះជាដើម ដល់ភិក្ខុទាំងឡាយអ្នកកើតការប្រកួតប្រកាន់គ្នាក្នុងទីទាំងឡាយ មានពេលឆាន់ ជាដើម ហើយទ្រង់ព្រះសណ្ដាប់ថា "សូម្បីឥឡូវនេះ ភិក្ខុទាំងឡាយក៏នៅតែកើតការប្រកួតប្រកាន់គ្នា ទើបស្ដេចយាងទៅវត្តឃោសិតារាមនោះ ហើយត្រាស់ហាមថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំធ្វើការបែកបាក់ប្រកួតប្រកាន់គ្នា" ដូច្នេះជាដើម ហើយទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយដែលឈ្មោះថាការប្រកួតប្រកាន់គ្នា ការជម្លោះ ការប្រកាន់ខ្វែងគំនិតគ្នា និងការវិវាទគ្នានោះ នាំមកនូវសេចក្ដីវិនាស, ពិតណាស់ សូម្បីសត្វចៀបកប្បាសអាស្រ័យការឈ្លោះគ្នាអាចធ្វើឲ្យស្ដេចដំរីដល់ការអស់ជីវិត" ដូច្នេះហើយ ទ្រង់ត្រាស់លដុកិកជាតក* ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សូមអ្នក

---

* ខុ. ជា. បញ្ចក. ។

ទាំងឡាយចូរព្រមព្រៀងគ្នាចុះ កុំវិវាទគ្នាឡើយ ព្រោះថា សូម្បីសត្វចៀបកប្បាសជាច្រើនពាន់អាស្រ័យការវិវាទគ្នា បានដល់ការអស់ជីវិត” ដូច្នេះហើយ ត្រាស់វដ្តកជាតក* ។

## ត្រាស់ប្រៀនប្រដៅប៉ុន្មានក៏មិនជឿ

សូម្បីយ៉ាងនេះពួកភិក្ខុទាំងនោះក៏មិនស្តាប់ កាលភិក្ខុដែលជាធម្មវាទីរូបណាមួយមិនពេញចិត្តឲ្យតថាគតលំបាក ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគជាម្ចាស់ ជាស្តេចនៃធម៌ទ្រង់រង់ចាំសិនចុះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់មានការខ្វល់ខ្វាយតិច ព្យាយាមប្រកបធម៌ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌ចុះ ពួកខ្ញុំព្រះអង្គនឹងប្រាកដព្រោះការប្រកួតប្រកាន់ ការជម្លោះ ការប្រកាន់ខ្វែងគំនិតគ្នា និងការវិវាទគ្នានោះឯង ព្រះមានព្រះភាគត្រាស់ដំណាល ដល់ការដែលព្រះបាទទីឃីតិកោសលរាជត្រូវព្រះបាទព្រហ្មទត្តដណ្តើមយករាជសម្បត្តិ ព្រះអង្គបន្ទំភេទមិនឲ្យ

* ខុ. ជា. ឯក. ៗ

នរណាស្គាល់ ( ទ្រង់គង់នៅក្នុងក្រុងពារាណសី ) ត្រូវព្រះបាទព្រហ្ម-ទត្តចាប់ផ្តាច់ព្រះជន្ម និងការដែលព្រះបាទព្រហ្មទត ព្រមទាំងទីឃាវុ-កុមារនោះព្រមព្រៀងគ្នា ចាប់ផ្តើមពីពេលដែលទីឃាវុកុមារបានថ្វាយជីវិតដល់ព្រះអង្គថា "ម្នាលភិក្ខុទាំងឡាយ រឿងនេះបានមានព្រះបាទក្រុងកាសី ( មួយព្រះអង្គ ) ទ្រង់ព្រះនាមថា ព្រះបាទព្រហ្មទត្ត" ដូច្នេះជាដើម សូម្បីត្រាស់ប្រៀនប្រដៅថា "ម្នាលភិក្ខុទាំងឡាយសេចក្តីអត់ធន់ និងការស្ងប់ស្ងៀមបែបនោះ បានមានហើយដល់ព្រះរាជាទាំងនោះ អ្នកមានដំបងដែលកាន់ទុកហើយ អ្នកមានសស្ត្រានៅក្នុងដៃហើយ ម្នាលភិក្ខុទាំងឡាយ ការដែលអ្នកទាំងឡាយបួសហើយក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយដោយប្រពៃយ៉ាងនេះ គួរជាអ្នកអត់ធន់ ជាអ្នកស្ងប់ស្ងៀម និងគប្បីស្អាតក្នុងធម្មវិន័យនេះឯង" ដូច្នេះហើយ ក៏មិនអាចនឹងធ្វើភិក្ខុទាំងឡាយឲ្យព្រមព្រៀងគ្នាបានឡើយ ។

# ព្រះសាស្តាទ្រង់អផ្សុកទើបស្តេចគេចទៅចាំវស្សា នៅក្នុងព្រៃរក្ខិតវ័ន

ព្រះអង្គទ្រង់អផ្សុកព្រះទ័យព្រោះនៅច្របូកច្របល់នោះ ទ្រង់ព្រះចិន្តាថា "ឥឡូវនេះ តថាគតនៅច្របូកច្របល់ជាទុក្ខ ហើយភិក្ខុទាំងនេះមិនធ្វើ ( តាម ) ពាក្យរបស់យើង បើដូច្នោះយើងគប្បីគេចអំពីពួកនៅមួយព្រះឯង" ដូច្នេះស្តេចត្រាច់បិណ្ឌបាតនៅក្នុងក្រុងកោសម្ពីមិនត្រាស់ប្រាប់ពួកភិក្ខុសង្ឃ ទ្រង់កាន់បាត្រចីវររបស់ព្រះអង្គស្តេចយាងទៅពាលកលោណការាមតែមួយព្រះអង្គឯង ត្រាស់ឯកចារិកវត្តដល់ព្រះភគ្គុត្ថេរក្នុងពាលកលោណការាមនោះហើយ ត្រាស់អានិសង្សនៃការសាមគ្គីរសដល់កុលបុត្រ ៣ នាក់ក្នុងមិគទាវ័នឈ្មោះ បាចិនវង្សហើយស្តេចយាងទៅកាន់ស្រុកបាលិលេយ្យកៈ ដូចបានស្តាប់មកគ្រានោះ ព្រះមានព្រះភាគទ្រង់អាស្រ័យស្រុកបាលិលេយ្យកៈ ស្តេចចាំវស្សានៅក្រោមដើមសាលព្រឹក្សធំ ក្នុងដងព្រៃរក្ខិតវ័ន ដែលដំរីបាលិលេយ្យកៈឧបដ្ឋាកនៅជាសុខ ។

## ពួកឧបាសកទូន្មានភិក្ខុ

ចំណែកពួកឧបាសកអ្នកនៅក្នុងក្រុងកោសម្ពីនោះឯង ទៅកាន់វិហារមិនឃើញព្រះសាស្ដា ទើបសួរថា "ព្រះសាស្ដាស្ដេចយាងទៅណា លោកម្ចាស់" ? ភិក្ខុទាំងនោះពោលថា "ស្ដេចទៅកាន់ដងព្រៃបាលិលេយ្យកៈហើយ" ។

ឧ. ព្រោះហេតុអ្វី លោកម្ចាស់ ?

ភ. ព្រះអង្គទ្រង់ព្យាយាមនឹងធ្វើពួកយើងឲ្យព្រមព្រៀងគ្នា តែពួកយើង មិនបានព្រមព្រៀងគ្នាទេ ។

ឧ. បពិត្រលោកដ៏ចម្រើន លោកទាំងឡាយបួសក្នុងសំណាក់របស់ព្រះសាស្ដាហើយ កាលព្រះអង្គទ្រង់ធ្វើសាមគ្គី, មិនបានជាអ្នកសាមគ្គីគ្នាហើយឬ ?

យ៉ាងនោះឯង អ្នកមានអាយុ ពួកមនុស្សគិតគ្នាថា "ពួកភិក្ខុទាំងនេះបួសក្នុងសំណាក់ព្រះសាស្ដាហើយ, កាលព្រះអង្គទ្រង់ធ្វើសាមគ្គីក៏មិនសាមគ្គីគ្នា ពួកយើងមិនបានឃើញព្រះសាស្ដាព្រោះអា-

ស្រ័យភិក្ខុទាំងនេះ, ពួកយើងនឹងមិនថ្វាយអាសនៈ នឹងមិនធ្វើសាមីចិកម្ម មានការសំពះជាដើមដល់ភិក្ខុទាំងនេះ” ចាប់ផ្ដើមពីនោះមកក៏មិនធ្វើសូម្បីត្រឹមតែសាមីចិកម្មដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងឡាយស្គាំងស្គមព្រោះការមានអាហារតិច, ដោយពីរបីថ្ងៃប៉ុណ្ណោះក៏ជាមនុស្សត្រង់ សម្ដែងនូវទោសដែលប្រព្រឹត្តកន្លងហើយដល់គ្នានិងគ្នា ញុំាងគ្នានិងគ្នាឲ្យអត់ទោសឲ្យ ហើយពោលថា ម្នាលឧបាសក និងឧបាសិកាទាំងឡាយ យើងទាំងឡាយព្រមព្រៀងគ្នាហើយ, ចំណែកពួកលោកចូរប្រគេនបច្ច័យ ៤ ដល់ពួកយើងដូចកាលមុន” ។

ឧ. ពួកលោកសូមឲ្យព្រះសាស្ដាអត់ទោសឲ្យហើយឬ ?

ភិ. ម្នាលអ្នកដ៏មានអាយុ យើងទាំងឡាយមិនទាន់សូមឲ្យទ្រង់អត់ទោសនៅឡើយ ។

ឧ. បើដូច្នោះ សូមពួកលោកចូរសូមខមាទោសព្រះសាស្ដាទៅ ចំណែកពួក យើងទាំងឡាយនឹងជាអ្នកប្រាកដស្មើដោយកាលមានហើយក្នុងកាលមុន ក្នុងកាលពួកលោកសូមឲ្យព្រះសាស្ដាអត់ទោស

ឲ្យហើយ ។

ភិក្ខុទាំងឡាយមិនអាចនឹងទៅកាន់សំណាក់ព្រះសាស្តា ព្រោះជាកាលនៅក្នុងវស្សា ញុំាងកាលខាងក្នុងវស្សានោះ ឲ្យកន្លងទៅដោយលំបាក ។

## ដំរីបាលិលេយ្យកៈឧបដ្ឋាកព្រះសាស្តា

ចំណែកព្រះសាស្តា ដែលដំរីដ៏ប្រសើរនោះផ្គត់ផ្គង់ ទ្រង់គង់នៅហើយជាសុខ ។ ចំណែកដំរីនោះលះបង់នូវហ្វូងចូលទៅកាន់ដងព្រៃនោះដើម្បីប្រយោជន៍ដល់កិរិយានៅជាសុខដែរ ។ ព្រះធម្មសង្គាហកាចារ្យពោលទុកយ៉ាងណា ?

ព្រះធម្មសង្គាហកាចារ្យពោលទុកថា (គ្រានោះ ការត្រិះរិះបានមានដល់ស្តេចដំរីនោះថា ) យើងនៅច្រឡូកច្រឡំនឹងពួកដំរីឈ្មោលទាំងឡាយ ដំរីញីទាំងឡាយ ដំរីស្ទាវទាំងឡាយ និងកូនដំរីទាំងឡាយ យើងទំពាស៊ីនូវស្មៅទាំងឡាយមានចុងរេចផង, ហើយពួកវារង់ចាំទំពាស៊ីមែកឈើដែលយើងបំបាក់ហើយផង ហើយយើងផឹកទឹកល្អក់

ផង, កាលយើងចុះ និងឡើងកាន់កំពង់ ពួកដំរីញីក៏ដើរត្រដុសកាយទៅ បើដូច្នោះគួរតែយើងនឹងចៀសចេញអំពីហ្វូងនៅតែម្នាក់ឯង” ។ គ្រានោះឯង ស្តេចដំរីនោះចៀសចេញចាកហ្វូងចូលទៅកាន់ព្រៃដែលនៅក្នុងស្រុកបាលិលេយ្យកៈឈ្មោះរក្ខិតវ័ន ក្រោមដើមសាលព្រឹក្សធំ ត្រង់កន្លែងដែលព្រះសាស្តាស្តេចគង់នៅ,លុះចូលទៅហើយ ថ្វាយបង្គំព្រះមានព្រះភាគហើយ រមិលមើលមិនឃើញវត្ថុណាៗដទៃ ទើបប្រហារនៅទីជិតនៃដើមសាលព្រឹក្សដោយជើង ឈូស (ឲ្យរាបស្មើ) កាន់យកនូវមែកឈើដោយប្រមោយ បោសសំអាតទីនោះ ចាប់ផ្តើមពីនោះមក ស្តេចដំរីនោះចាប់ផ្ទាំងដោយប្រមោយដងទឹកឆាន់ ទឹកប្រើប្រាស់មកដំកល់ទុក, កាលទ្រង់ព្រះបំណងដោយទឹកក្តៅ, ក៏ចាត់ចែងទឹកក្តៅថ្វាយ ។ ស្តេចដំរីនោះចាត់ចែងទឹកក្តៅបានយ៉ាងណា ? ស្តេចដំរីនោះកូតមែកឈើដោយប្រមោយឲ្យកើតជាភ្លើង ដាក់ឧសឲ្យភ្លើងឆេះឡើង ដុតសិលាក្នុងគំនរភ្លើងនោះ ហើយប្រមៀលដុំសិលាទាំងនោះទៅដោយកំណាត់ឈើ បោះចុះក្នុងត្រពាំងតូច ដែលខ្លួនកំណាត់

ទុក ខណៈនោះ ដាក់ប្រមោយចុះទៅ ដឹងថាទឹកក្តៅហើយ ទើបទៅថ្វាយបង្គំព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា "បាលិលេយ្យកៈ ទឹកឯងដាំហើយឬ" ? ដូច្នេះហើយ ស្តេចយាងទៅស្រង់ក្នុងទីនោះ ។ ក្នុងកាលនោះ ស្តេចដំរីនោះនាំផ្លែឈើផ្សេងៗ មកថ្វាយដល់ព្រះសាស្តា ។ ក៏កាលព្រះសាស្តានឹងស្តេចចូលកាន់ស្រុកដើម្បីបិណ្ឌបាត ស្តេចដំរីនោះយកបាត្រចីវរដាក់ទុកលើក្បាល តាមសម្តេចព្រះសាស្តាទៅ ។ ព្រះសាស្តាស្តេចយាងដល់ដែនរបស់អ្នកស្រុកហើយប្រាប់ថា "បាលិ-លេយ្យកៈ តាំងពីទីនេះទៅ ឯងមិនអាចទៅបានទេ, ឯងចូរយកបាត្រចីវររបស់យើងមក" ដូច្នេះហើយ ឲ្យស្តេចដំរីនោះយកបាត្រចីវរនោះមកថ្វាយ ហើយស្តេចចូលកាន់ស្រុកដើម្បីបិណ្ឌបាត ។ ចំណែកស្តេចដំរីនោះឈរនៅទីនោះឯងរហូត ទាល់តែព្រះសាស្តាស្តេចចេញមកក្នុងវេលាព្រះសាស្តាស្តេចមកធ្វើការទទួល ហើយកាន់បាត្រចីវរដោយន័យដូចមុន (នាំទៅ) ដាក់ចុះនៅក្នុងទីប្រថាប់ ហើយបក់ដោយស្លឹកឈើថ្វាយព្រះសាស្តា ។ ក្នុងរាត្រីស្តេចដំរីនោះកាន់កំណាត់ឈើធំ

ដោយប្រមោយ ដើរទៅក្នុងចន្លោះ ៗ នៃដងព្រៃរហូតដល់អរុណរះ ឡើង ដើម្បីការពារអន្តរាយដែលនឹងកើតមានពីម្រឹគកាច ដោយតាំង ចិត្តថា "នឹងរក្សាព្រះសាស្តា" បានឮថា ព្រៃនោះមានឈ្មោះថា រក្ខិត-វនសណ្ឌៈ ចាប់តាំងពីកាលនោះមក ។ លុះអរុណរះឡើងហើយ, ស្តេចដំរីនោះធ្វើវត្តទាំងពួងដោយឧបាយដូចមុននោះឯង ចាប់តាំងពី ការថ្វាយទឹកលាងព្រះភក្ត្រ ។

## ស្វាថ្វាយសំបុកឃ្មុំ

ក្នុងកាលនោះ ស្វាមួយ ឃើញដំរីនោះក្រោកឡើងហើយៗ ធ្វើអភិសមាចារិកវត្ត ( គឺការបដិបត្តិ ) ដល់ព្រះតថាគតហើយ គិតថា "យើងក៏នឹងធ្វើអ្វីៗថ្វាយផងដែរ" ថ្ងៃមួយឃើញសំបុកឃ្មុំហ្នឹងមែក ឈើដែលមិនមានរមេ កាច់មែកឈើហើយ នាំសំបុកឃ្មុំព្រមទាំង មែកឈើទៅកាន់សំណាក់ព្រះសាស្តា បានក្តិចស្លឹកចេកទ្រាប់ថ្វាយ ។ ព្រះសាស្តាទ្រង់ទទួលហើយ, ពានរក្រឡេកមើលដោយគិតថា "ព្រះ សាស្តានឹងទ្រង់ធ្វើការបរិភោគឬទេហ្ន៎"? ឃើញព្រះសាស្តាទ្រង់ទទួល

ហើយគង់ស្ងៀម គិតថា "មានហេតុអ្វីហ្ន៎" ទើបចាប់ចុងមែកឈើត្រឡប់មើល ឃើញកូនឃ្មុំហើយ ទើបចាប់កូនឃ្មុំទាំងនោះស្រាលៗ នាំចេញហើយក៏បានថ្វាយសាជាថ្មី ។ ព្រះសាស្ដាទ្រង់សោយហើយ ។ ស្វានោះមានចិត្តត្រេកអរ បានចាប់មែកឈើទុំៗឈររាំ ក្នុងកាលនោះមែកឈើដែលស្វានោះចាប់ហើយក្ដី មែកឈើដែលស្វានោះជាន់ហើយក្ដីក៏បាក់ទៅ ។ស្វានោះធ្លាក់ចុះចំចុងគល់ឈើមួយ មានខ្លួនដែលចុងគល់ឈើចាក់ហើយ មានចិត្តជ្រះថ្លា ធ្វើកាលកិរិយាហើយ កើតក្នុងវិមានមាសកំពស់ ៣០ យោជន៍ ក្នុងឋានតាវត្តិង្ស មានទាងទេពអប្សរ ១០០០ ជាបរិវារ ។

## ស្ដេចដំរីសង្កេតមើលវត្តរបស់ព្រះអានន្ទ

កាលដែលព្រះតថាគត ដែលស្ដេចដំរីឧបដ្ឋាក ទ្រង់គង់នៅក្នុងដងព្រៃឈ្មោះរក្ខិតវ័ននោះ បានប្រាកដក្នុងជម្ពូទ្វីបទាំងមូល ។ ត្រកូលធំៗ គឺលោកសេដ្ឋីអនាថបិណ្ឌិក និងនាងវិសាខាមហាឧបាសិកាយ៉ាងនេះជាដើម បានបញ្ជូនសាសន៍អំពីនគរសាវត្ថី ទៅចំពោះព្រះអានន្ទ

ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ចូរសម្តែងព្រះសាស្តាដល់ពួកខ្ញុំម្ចាស់" ។ ចំណែកភិក្ខុ ៥០០ រូប អ្នកនៅក្នុងទិសចាំវស្សាហើយ ចូលទៅរកព្រះអានន្ទត្ថេរអង្វរថា "អានន្ទដ៏មានអាយុ ធម្មកថាក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ខ្ញុំម្ចាស់ទាំងឡាយ ខានបានស្តាប់យូរមកហើយ, អានន្ទដ៏មានអាយុ ឥឡូវនេះ ខ្ញុំម្ចាស់ទាំងឡាយគប្បីបានស្តាប់ធម្មីកថា ក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគចុះ" ។ ព្រះថេរៈនាំភិក្ខុទាំងនោះទៅកាន់ទីនោះហើយ គិតថា "ការចូលទៅកាន់សំណាក់ព្រះតថាគត ដែលស្តេចគង់នៅតែមួយព្រះអង្គឯងអស់ត្រៃមាស ព្រមទាំងភិក្ខុមានប្រមាណដល់ទៅប៉ុណ្ណេះ មិនសមគួរទេ"។ដូច្នេះហើយ ទើបបញ្ឈប់ភិក្ខុទាំងនោះទុកខាងក្រៅ ហើយចូលទៅគាល់ព្រះសាស្តាតែម្នាក់ឯងប៉ុណ្ណោះ ។ ស្តេចដំរីបាលិលេយ្យកៈឃើញព្រះអានន្ទត្ថេរនោះហើយ កាន់កំណាត់ឈើដេញ ព្រះអានន្ទ ។ ព្រះសាស្តាទតឃើញហើយ ត្រាស់ថា "ចៀសចេញទៅ បាលិលេយ្យកៈ កុំហាមឡើយ, ភិក្ខុនោះជាពុទ្ធុបដ្ឋាក" ។ ដំរីបាលិ លេយ្យកៈនោះ

បោលកំណាត់ឈើទៅក្នុងទីនោះឯង ហើយបានអើពើដល់ការទទួលបាត្រចីវរ ។ ព្រះថេរៈមិនបានឲ្យ ។ ស្ដេចដំរីបានគិតថា "ប្រសិនបើភិក្ខុរូបនេះនឹងមានវត្តដែលបានរៀនហើយ, លោកគង់នឹងមិនដាក់បរិក្ខាររបស់ខ្លួនទុកលើផ្ទាំងសិលា ដែលជាទីប្រថាប់របស់ព្រះសាស្ដាទេ" ។ ព្រះថេរៈបានដាក់បាត្រ ចីវរទុកលើផែនដី ។

## មិនបានសម្លាញ់ដែលមានបញ្ញាត្រាច់ទៅតែម្នាក់ឯងប្រសើរជាង

ពិតណាស់ ជនអ្នកដល់ព្រមហើយដោយវត្ត រមែងមិនដាក់បរិក្ខាររបស់ខ្លួនលើទីអង្គុយ ឬលើទីដេករបស់គ្រូ ។ ស្ដេចដំរីនោះឃើញអាការនោះហើយ បានជាអ្នកមានចិត្តជ្រះថ្លា ។ ព្រះថេរៈអភិវាទព្រះសាស្ដាហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្ដាត្រាស់សួរថា "ម្នាលអានន្ទ អ្នកមកតែម្នាក់ឯងប៉ុណ្ណោះឬ" ? ទ្រង់ស្ដាប់ការដែលព្រះថេរៈជាអ្នកមកព្រមនឹងភិក្ខុ ៥០០ រូប ហើយត្រាស់ថា "ក៏ភិក្ខុទាំងនោះនៅទីណា" ? កាលព្រះថេរៈទូលថា "ខ្ញុំព្រះអង្គមិនជ្រាប

ទឹកព្រះទ័យរបស់ព្រះអង្គ ទើបបញ្ឈប់ភិក្ខុទាំងឡាយទុកខាងក្រៅ មកហើយ (តែម្នាក់ឯង)" ត្រាស់ថា "ហៅភិក្ខុទាំងឡាយមកចុះ" ព្រះថេរៈបានធ្វើតាមព្រះបញ្ជាហើយ ។ ភិក្ខុទាំងនោះមកថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈនឹងភិក្ខុទាំងឡាយហើយ ។ កាលភិក្ខុទាំងនោះទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាព្រះពុទ្ធដ៏សុខុម និងជាក្សត្រដ៏សុខុម ព្រះអង្គប្រថាប់ឈរ និងប្រថាប់គង់តែមួយព្រះអង្គឯងអស់ត្រៃមាស ធ្វើកិច្ចដែលធ្វើបានដោយលំបាក, អ្នកធ្វើវត្ត និងបដិវត្តក្តី អ្នកថ្វាយទឹកលាងព្រះភក្រ្តក្តី ប្រហែលជាមិនមានហើយ" ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កិច្ចទាំងពួងរបស់តថាគត ដំរីបាលិលេយ្យកៈធ្វើហើយ ។ ក៏បុគ្គលអ្នកបានសម្លាញ់បែបនេះនៅជាមួយគ្នាគួរ, កាលបើមិនបានសម្លាញ់(បែបនេះ)ភាពជាអ្នកត្រាច់ទៅតែម្នាក់ឯងប៉ុណ្ណោះប្រសើរជាង" ដូច្នេះហើយ បានភាសិត ៣ គាថា ក្នុងនាគវគ្គទាំងនោះថា ៖

បើបុគ្គលបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្ដីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសម្លាញ់នោះឯង ។ បើស្វែងរកមិនបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែម្នាក់ឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយស្ដេចទៅតែមួយព្រះអង្គ ពុំនោះសោត ដូចដំរីឈ្មោះមាតង្គៈ ដែលលះបង់ហ្វូងត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ដូច្នោះដែរ ។ ការត្រាច់ទៅរបស់បុគ្គលតែឯកឯង ជាគុណជាតិប្រសើរបំផុត ( ព្រោះថា ) សហាយតាគុណ រមែងមិនមានក្នុងបុគ្គលពាលឡើយ បុគ្គលនោះគប្បីជាអ្នកមិនមានសេចក្ដី

ខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯង ហើយមិនគប្បីធ្វើអំពើបាប ទាំងឡាយ ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្ដី ខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯកឯងក្នុងព្រៃដូច្នោះដែរ ។

ក្នុងកាលចប់គាថា ភិក្ខុទាំង ៥០០ រូប បានតាំងនៅក្នុងព្រះ-អរហត្ត ព្រះអានន្ទត្ថេរក្រាបទូលសាសន៍ដែលត្រកូលធំៗ មានលោកសេដ្ឋីអនាថបិណ្ឌិកជាដើមផ្ញើរមកហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវក ៥ កោដិ មានលោកសេដ្ឋីអនាថបិណ្ឌិកជាប្រ-ធាន សង្ឃឹមការស្ដេចយាងមករបស់ព្រះអង្គ" ព្រះសាស្ដាត្រាស់ថា "បើដូច្នោះអ្នកចូរទទួលបាត្រចីវរ" ដូច្នេះហើយឲ្យព្រះថេរៈទទួលបាត្រចីវរហើយស្ដេចយាងចេញទៅ ។ ស្ដេចដំរីបានទៅឈររាំងផ្លូវ ។ ភិក្ខុទាំងឡាយឃើញដូច្នោះ ទូលសួរព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន ស្ដេចដំរីធ្វើអ្វី" ? ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ដំរីប្រាថ្នានឹងថ្វាយភិក្ខាដល់អ្នកទាំងឡាយ, ក៏ដំរីនេះ បានធ្វើឧបការៈដល់តថាគតអស់រាត្រីយូរ, ការញុំាងចិត្តដំរីនេះ ឲ្យកករល្អក់មិនគួរ,

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រឡប់វិញចុះ” ព្រះសាស្តាទ្រង់នាំភិក្ខុទាំងឡាយស្តេចត្រឡប់វិញ ។

ចំណែកដំរីចូលទៅកាន់ដងព្រៃហើយ ប្រមូលផ្លែឈើផ្សេងៗមានផ្លែខ្នុរ និងចេកជាដើមមកធ្វើឲ្យជាគំនរ, ក្នុងថ្ងៃស្អែកឡើង បានថ្វាយដល់ភិក្ខុទាំងឡាយ ។ ភិក្ខុ ៥០០ រូប មិនអាចឆាន់ផ្លែឈើទាំងឡាយឲ្យអស់ ។ ក្នុងកាលស្រេចភត្តកិច្ច ព្រះសាស្តាទ្រង់កាន់បាត្រចីវរស្តេចយាងចេញទៅ ។ ស្តេចដំរីទៅតាមចន្លោះៗនៃភិក្ខុទាំងឡាយឈរស្ទាក់ព្រះភក្ត្រព្រះសាស្តា ។ ភិក្ខុទាំងឡាយឃើញដូច្នោះ ទូលសួរព្រះមានព្រះភាគថា “បពិត្រព្រះអង្គដ៏ចម្រើន ដំរីនេះ ធ្វើអ្វី” ?

ស. ម្នាលភិក្ខុទាំងឡាយ ដំរីនេះនឹងបញ្ជូនពួកអ្នកទៅហើយបបួលឲ្យ តថាគតត្រឡប់វិញ ។

ក. បពិត្រព្រះអង្គ យ៉ាងនោះពិតមែនឬ ?

ស. ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះហើយ ។

## ដំរីស្លាប់ទៅកើតជាទេវបុត្រ

ខណៈនោះ ព្រះសាស្តាត្រាស់ទឹងដំរីនោះថា "បាលិលេយ្យកៈ នេះគឺជាការទៅមិនវិលត្រឡប់របស់តថាគត, ឈានក្តី, វិបស្សនាក្តី, មគ្គ និងផលក្តី រមែងមិនមានដល់ឯងក្នុងអត្តភាពនេះ, ឯងឈប់ចុះ" ដំរីបានស្តាប់ពាក្យដូច្នោះហើយ បានស៊កប្រមោយចូលទៅក្នុងមាត់ ស្រែកយំ ដើរតាមទៅខាងក្រោយៗ ។ ក៏ស្តេចដំរីនោះនិមន្តព្រះសាស្តាឲ្យត្រឡប់វិញបាន រមែងបដិបត្តិដោយអាការនុ៎ះឯងរហូតអស់ជីវិត ។ ចំណែកព្រះសាស្តា ស្តេចយាងដល់ព្រំដែនស្រុកហើយ ក៏ត្រាស់ថា "បាលិលេយ្យកៈ ចាប់ពីនេះទៅ មិនមែនទីកន្លែងរបស់ឯងទេ, ជាទីលំនៅរបស់ពួកមនុស្ស ។ មានអន្តរាយបៀតបៀននៅជុំវិញ, ឯងចូរឈប់ចុះ" ដំរីនោះឈរយំនៅក្នុងទីនោះ, លុះព្រះសាស្តាទ្រង់លះបង់គន្លងចក្ខុទៅ, មានបេះដូងបែក ។ ធ្វើកាលកិរិយាហើយ កើតក្នុងកណ្តាលនាងទេពអប្សរ ១០០០ ក្នុងវិមានមាសកំពស់ ៣០ យោជន៍ទាវតិង្ស ព្រោះសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា ឈ្មោះរបស់ទេវបុត្រ

នោះថា "បាលិលេយ្យកទេវបុត្រ" ។ ចំណែកព្រះសាស្ដាស្ដេចយាង ដល់វត្តជេតពនហើយដោយលំដាប់ ។

## ភិក្ខុក្រុងកោសម្ពីទូលសូមខមាទោសព្រះសាស្ដា

ភិក្ខុក្រុងកោសម្ពីដឹងថា "ព្រះសាស្ដាស្ដេចយាងដល់ក្រុងសាវត្ថីហើយ" បានទៅកាន់ទីនោះ ដើម្បីនឹងក្រាបទូលសូមខមាទោសព្រះសាស្ដា ។ ព្រះបាទកោសលទ្រង់ស្ដាប់ថា "ពួកភិក្ខុក្រុងកោសម្ពី អ្នកបង្ករជម្លោះទាំងនោះមក" ទើបចូលទៅគាល់ព្រះសាស្ដាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងមិនព្រមឲ្យភិក្ខុទាំងនោះ ចូលមកកាន់ដែនរបស់ខ្ញុំព្រះអង្គទេ" ។ ព្រះសាស្ដាទ្រង់ត្រាស់តបថា "បពិត្រមហារាជ ភិក្ខុទាំងនោះជាអ្នកមានសីល, តែមិនកាន់យកពាក្យរបស់តថាគត ព្រោះវិវាទគ្នានិងគ្នាប៉ុណ្ណោះ, ឥឡូវនេះ លោកទាំងឡាយមកដើម្បីសូមខមាទោសតថាគត បពិត្រមហារាជ ឲ្យភិក្ខុទាំងនោះចូលមកចុះ" ។

ចំណែកលោកសេដ្ឋីអនាថបិណ្ឌិកទូលថា "បពិត្រព្រះអង្គដ៏

ចម្រើន ខ្ញុំព្រះអង្គនឹងមិនព្រមឲ្យភិក្ខុទាំងនោះចូល មកកាន់វិហារ" ដូច្នេះហើយ ត្រូវព្រះសាស្តាទ្រង់ហាមដូចយ៉ាងនោះ ហើយបានទៅស្មៀម ។ ក៏កាលភិក្ខុទាំងនោះ ដល់ក្រុងសាវត្ថីដោយ លំដាប់ហើយ, ព្រះមានព្រះភាគបញ្ជាឲ្យប្រទានសេនាសនៈក្នុងទីដ៏សមគួរមួយ ធ្វើឲ្យជាទីស្ងាត់ដល់លោកទាំងឡាយ ។ ភិក្ខុពួកដទៃមិនអង្គុយ មិនឈររួមនឹងភិក្ខុទាំងនោះ ។

ពួកជនអ្នកមកហើយៗទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុពួកណា ជាភិក្ខុក្រុងកោសម្ពី អ្នកបង្ករការវិវាទគ្នាទាំងនោះ" ? ព្រះសាស្តាទ្រង់សម្តែងថា "ពួកនោះ" ។ ភិក្ខុក្រុងកោសម្ពីទាំងនោះ ត្រូវពួកជនអ្នកមកហើយ ៗ ចង្អុលថា "នុ៎ះ ពួកភិក្ខុក្រុងកោសម្ពី ដែលជាអ្នកបង្ករការជម្លោះ នុ៎ះពួកភិក្ខុក្រុងកោសម្ពី ដែលជាអ្នកបង្ករការជម្លោះ" ដូច្នេះមិនលើកសិរសាឡើង ព្រោះការអៀន-ខ្មាស សំយុងកដាក់មុខចុះទៀបបាទមូលនៃព្រះមានព្រះភាគ ទូលសូមខមាទោសព្រះមានព្រះភាគ ។

ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយធ្វើកម្មធ្ងន់ហើយ, អ្នកទាំងឡាយសូម្បីបួសហើយក្នុងសំណាក់របស់ព្រះពុទ្ធប្រាកដដូចតថាគត, កាលតថាគតធ្វើការសាមគ្គី មិនធ្វើ ( តាម ) ពាក្យរបស់តថាគត, ចំណែកបណ្ឌិតដែលមានក្នុងកាលមុន ស្តាប់ឱវាទរបស់មាតា និងបិតាដែលជាអ្នកត្រូវប្រហារជីវិត, កាលមាតាបិតានោះសូម្បីត្រូវប្រហារជីវិត, ក៏មិនកន្លងឱវាទនោះ ខាងក្រោយបានគ្រងរាជសម្បត្តិក្នុងដែនទាំងពីរ” ដូច្នេះហើយ ត្រាស់សម្ដែងទីឃាវុកុមារជាតក[⊗] ដូចមុនទៀត ហើយត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារសូម្បីកាលព្រះមាតា និងបិតាត្រូវប្រហារជីវិតយ៉ាងនោះ, ក៏មិនឈានកន្លងឱវាទរបស់ព្រះមាតា និងបិតាទាំងនោះ ហើយខាងក្រោយមក បានធីតារបស់ព្រះបាទព្រហ្មទត្តគ្រងរាជ្យ-សម្បត្តិក្នុងដែនកោសល និងកាសីទាំងពីរ, ចំណែកពួកអ្នកទាំងឡាយមិនធ្វើ ( តាម ) ពាក្យរបស់តថាគត ធ្វើកម្មធ្ងន់ណាស់” ដូច្នេះហើយ

[⊗] ខុ. ជា. បញ្ចក. ។

ទ្រង់ត្រាស់ព្រះគាថានេះថា ៖

**៥ បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ**
**យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។**

ជនទាំងឡាយដទៃ ( ក្រៅអំពីបណ្ឌិត ) តែងមិនដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះដូច្នេះឡើយ ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះ ដូច្នេះការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់ពីជនទាំងនោះ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **បរេ** ជាដើម សេចក្តីថា ពួកជនអ្នកធ្វើការឈ្លោះប្រកែកគ្នា វៀរបណ្ឌិតទាំងឡាយចេញ គឺពួកដទៃក្រៅអំពីបណ្ឌិតនោះ ឈ្មោះថា ពួកជនដទៃ, ពួកជនដទៃនោះ ធ្វើការខ្វល់ខ្វាយនៅក្នុងជំនុំសង្ឃនោះ រមែងមិនដឹងខ្លួនថា "យើងទាំងឡាយ

រមែងវិនាស បានដល់ ចូលទៅកាន់ទីជិតនៃសំណាក់មច្ចុជានិច្ច" ។

បណ្ដាព្រះគាថាថា **យេ ច តត្ថ វិជានន្តិ** សេចក្ដីថា ជនទាំងឡាយណា ដែលជាបណ្ឌិតក្នុងពួកនោះ រមែងដឹងខ្លួនថា "យើងទាំងឡាយ រមែងចូលទៅកាន់ទីនៃជិតមច្ចុ" ។

បាទព្រះគាថាថា **តតោ សម្មន្តិ មេធគា** សេចក្ដីថា ជនទាំងនោះដឹងយ៉ាងនេះ ញុំាងការធ្វើទុកក្នុងចិត្តដោយប្រពៃឲ្យកើតឡើងហើយ រមែងបដិបត្តិដើម្បីស្ងប់ការព្យាយាម គឺការឈ្លោះប្រកែកគ្នា, កាលបើដូច្នោះ ការឈ្លោះប្រកែកគ្នាទាំងនោះរមែងស្ងប់ ព្រោះការបដិបត្តិរបស់បណ្ឌិតទាំងនោះ ។

ម្យ៉ាងទៀត គប្បីជ្រាបការអធិប្បាយក្នុងព្រះគាថានេះ យ៉ាងនេះថា **បរេ ច** ជាដើម សេចក្ដីថា ជនទាំងឡាយសូម្បីដែលយើង (តថាគត) ពោលប្រៀនប្រដៅថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំបានធ្វើការឈ្លោះប្រកែកគ្នាឡើយ" ដូច្នេះជាដើមក្នុងកាលមុនក៏មិនស្ដាប់ ព្រោះមិនទទួលឱវាទរបស់តថាគត ឈ្មោះថា ជនពួកដទៃ ។

ពួកជនដទៃនោះ រមែងមិនដឹងខ្លួនថា "យើងទាំងឡាយប្រកាន់ខុស ដោយអំណាចអគតិ មាន ឆន្ទៈ ជាដើម រមែងវិនាស បានដល់ ព្យាយាមដើម្បីញ៉ាំងការចម្រើននៃហេតុដែលធ្វើសេចក្ដីវិនាស មានការឈ្លោះប្រកែកគ្នាជាដើមក្នុងកណ្ដាលសង្ឃនេះ" ។ តែឥឡូវនេះ បុរសជាបណ្ឌិតទាំងឡាយណា ក្នុងរវាងនៃលោកទាំងឡាយនោះ ពិចារណាដឹងច្បាស់ថា កាលមុនយើងទាំងឡាយព្យាយាមដោយអំណាចអគតិ មាន ឆន្ទៈ ជាដើម បដិបត្តិដោយមិនប្រពៃហើយ, ការព្យាយាមដែលរាប់ថា ការឈ្លោះប្រកែកគ្នាក្នុងកាលឥឡូវនេះ ទាំងនេះរមែងស្ងប់អំពីសំណាក់បណ្ឌិតទាំងឡាយនោះ ៗ គឺព្រោះអាស្រ័យបុរសដែលជាបណ្ឌិតទាំងឡាយនោះដោយប្រការ ដូច្នេះ" ។

ក្នុងកាលចប់គាថា ភិក្ខុដែលប្រជុំគ្នានោះបានតាំងនៅក្នុងអរិយផលទាំងឡាយ មានសោតាបត្តិជាដើម ដូច្នេះឯង ។

( រឿងភិក្ខុភិក្ខុក្រុងកោសម្ពី ចប់ )

# ៦ រឿងចុល្លកាល និង មហាកាល

## សេចក្តីខាងដើម

ព្រះសាស្តា កាលស្តេចចូលទៅអាស្រ័យសេតព្យនគរ ទ្រង់គង់នៅក្នុងព្រៃធ្នង់ ទ្រង់ប្រារព្ធចុល្លកាល និងមហាកាល ត្រាស់ធម្មទេសនានេះថា "**សុភានុបស្សឹ វិហរន្តំ**" ជាដើម ។

សេចក្តីពិស្តារថា កុដុម្ពិក៏អ្នកស្រុកសេតព្យនគរ ៣ នាក់បងប្អូន គឺចុល្លកាល ១ មជ្ឈិមកាល ១ មហាកាល ១ ។ បណ្តាបងប្អូន ៣ នាក់នោះ បងប្រុសច្បង និងប្អូនប្រុសពៅ ត្រាច់ទៅក្នុងទិសទាំងឡាយនាំទំនិញមកដោយរទេះ ៥០០ ។ មជ្ឈិមកាលលក់ទំនិញដែលបង និងប្អូននាំមក ។

ខាងក្រោយមក សម័យមួយ បងប្អូនទាំងពីរនោះផ្ទុកទំនិញផ្សេងៗ ដោយរទេះ ៥០០ ទៅកាន់ក្រុងសាវត្ថី ដោះរទេះទាំងឡាយក្នុងចន្លោះក្រុងសាវត្ថី និង វត្តជេតពន ។

## <u>មហាកាលស្តាប់ធម៌ហើយលាប្អូនប្រុសទៅបួស</u>

ក្នុងបណ្តាបងប្អូនពីរនាក់នោះ មហាកាលឃើញអរិយសាវក

ទាំងឡាយអ្នកក្រុងសាវត្ថី មានដៃកាន់កម្រងផ្កាឈើ និងគ្រឿងក្រអូបជាដើមទៅដើម្បីស្តាប់ធម៌ក្នុងវេលាល្ងាច ទើបសួរថា "ជនទាំងនោះទៅណាហ្ន៎" ? បានស្តាប់សេចក្តីនោះហើយគិតថា "សូម្បីយើងក៏នឹងទៅដែរ" ហៅប្អូនប្រុសមកហើយ ប្រាប់ថា "ហៃបា ឯងចូរជាអ្នកមិនប្រមាទក្នុងរទេះទាំងឡាយ, ចំណែកយើងនឹងទៅស្តាប់ធម៌" ដូច្នេះហើយទៅថ្វាយបង្គំព្រះតថាគត អង្គុយនៅទីបំផុតនៃបរិស័ទហើយ ។

ថ្ងៃនោះ ព្រះសាស្តា កាលនឹងត្រាស់អនុបុព្វីកថាតាមអធ្យាស្រ័យរបស់មហាកាលនោះ ទើបត្រាស់ទោស និងការសៅហ្មងរបស់កាមទាំងឡាយដោយបរិយាយជាច្រើន ដោយអំណាចនៃសូត្រ មានទុក្ខក្ខន្ធសូត្រជាដើម ។ មហាកាលបានស្តាប់ធម្មទេសនានោះហើយក៏គិតថា "មនុស្សយើងចាំបាច់ត្រូវលះបង់វត្ថុទាំងពួងហើយទៅ, ភោគៈ (និង) ញាតិទាំងឡាយ រមែងមិនជាប់តាមបុគ្គលអ្នកទៅកាន់បរលោកឡើយ, យើងនឹងត្រូវការអ្វីដោយការនៅគ្រប់គ្រងផ្ទះ យើងនឹងបួស" កាលមហាជនទាំងឡាយថ្វាយបង្គំហើយចៀសចេញទៅ ទូលសូម

បព្វជ្ជានឹងព្រះសាស្តា កាលព្រះសាស្តាត្រាស់សួរថា "អ្នកដទៃដែលអ្នកគួរលាមិនមានទេឬ" ? ទូលថា "ប្អូនប្រុសរបស់ខ្ញុំព្រះអង្គមាន" កាលព្រះអង្គត្រាស់ថា "បើដូច្នោះ អ្នកចូរទៅលាគេចុះ" ទទួលថា "ប្រពៃហើយ ព្រះអង្គ" ត្រឡប់មកប្រាប់ប្អូនប្រុសដូច្នេះថា "ម្នាលប្អូនប្រុស ប្អូនឯងចូរគ្រប់គ្រង សម្បត្តិទាំងអស់នេះចុះ" ។

ច. ក៏បងឯងដូចម្តេចដែរ ?

ម. បងនឹងបួសក្នុងសំណាក់ព្រះសាស្តា ។ គេអង្វរបងប្រុសនោះដោយប្រការផ្សេងៗ ក៏មិនអាចឲ្យត្រឡប់វិញបាន, ទើបពោលថា "ល្អហើយបង សូមបងធ្វើតាមអធ្យាស្រ័យចុះ" ។ មហាកាលទៅបួសក្នុងសំណាក់ព្រះសាស្តាហើយ ។ ចំណែកចុល្លកាលក៏ ( ទៅ ) បួស ដោយតាំងចិត្តថា "យើងនឹងបបួលបងប្រុសឲ្យសឹក" ។

## ព្រះមហាកាលបំពេញសោសានិកធុតង្គ

ក្នុងកាលខាងក្រោយមក មហាកាលបានឧបសម្បទាហើយ ចូលទៅគាល់ព្រះសាស្តា ទូលសួរដល់ធុរៈក្នុងព្រះសាសនា, កាល

ព្រះសាស្តាត្រាស់ប្រាប់ធុរៈពីរយ៉ាងហើយ, ទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងមិនអាចបំពេញគន្ថធុរៈបានទេ ព្រោះខ្ញុំព្រះអង្គបួសក្នុងកាលនៃខ្លួនជាមនុស្សចាស់, តែនឹងបំពេញវិបស្សនាធុរៈឲ្យបរិបូណ៌” ទូលសូមព្រះអង្គឲ្យត្រាស់ប្រាប់សោសានិកធុតង្គ រហូតដល់ព្រះអរហត្ត, លុះកន្លងបឋមយាម កាលមហាជនដេកលក់អស់គ្រប់គ្នាហើយ, ទៅកាន់ព្រៃស្មសានវេលាទៀបភ្លឺ កាលជនទាំងអស់នៅមិនទាន់ក្រោកឡើង (ភ្ញាក់) នៅឡើយត្រឡប់មកកាន់វិហារវិញ ។

## របៀបអ្នកនៅក្នុងព្រៃស្មសាន

គ្រានោះ ស្ត្រីអ្នករកស៊ីរៀបចំខ្មោចម្នាក់ឈ្មោះកាឡី អ្នកយាមព្រៃស្មសានឃើញទីឈរ ទីអង្គុយ និងទីចង្ក្រមរបស់ព្រះថេរៈ គិតថា “នរណាហ្ន៎ មកកាន់ទីនេះ ? យើងនឹងរង់ចាំចាប់ខ្លួន” កាលមិនអាចចាប់បាន, ថ្ងៃមួយ ទើបដុតប្រទីបទុកក្នុងខ្ទមជិតព្រៃស្មសាន នាំបុត្រធីតាទៅពួនចាំមើលនៅក្នុងទីកន្លែងមួយ ឃើញព្រះថេរៈដើរមកក្នុងមជ្ឈិមយាម ទើបទៅថ្វាយបង្គំ ហើយនិយាយថា “បពិត្រលោកដ៏ចរើន

លោកម្ចាស់ ស្នាក់នៅក្នុងទីកន្លែងរបស់ពួកខ្ញុំនេះឬ ?

ថ. ពរ ឧបាសិកា ។

ស. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម្មតាអ្នកនៅក្នុងព្រៃស្មសានទាំងឡាយរៀនរបៀប ( មុន ) ទើបនឹងគួរ ។

ព្រះថេរៈមិនពោលថា "ក៏អាត្មាភាពនឹងប្រព្រឹត្តតាមរបៀបដែលនាងប្រាប់ហើយយ៉ាងណាទៅ" ? ត្រឡប់ពោលថា "ធ្វើយ៉ាងណាទៅទើបនឹងគួរ ឧបាសិកា" ?

ស. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម្មតាអ្នកនៅក្នុងព្រៃស្មសានទាំងឡាយ គួរប្រាប់ការដែលខ្លួននៅក្នុងព្រៃស្មសាន ដល់អ្នកយាមព្រៃស្មសាន ដល់ព្រះមហាថេរៈក្នុងវិហារ និងដល់មេស្រុកជាមុនសិន ។

ថ. ព្រោះហេតុអ្វី ?

ស. ព្រោះពួកចោរធ្វើកម្មហើយត្រូវពួកម្ចាស់ ( ទ្រព្យ ) ដេញតាមស្ទាមជើងទៅ ក៏បោះកញ្ចប់កណ្ឌៈទុកក្នុងព្រៃស្មសាន ហើយ

ចៀសចេញទៅ កាលបើដូច្នោះ ពួកមនុស្សក៏ ( ចោមរោម ) ធ្វើអន្ត-រាយដល់មនុស្សអ្នកនៅក្នុងព្រៃស្មសាន តែកាលបានប្រាប់ដល់អ្នកដែលមានតួនាទីទាំងនោះហើយ អ្នកទាំងអស់នោះ រមែងជួយការពារអន្តរាយបាន ដោយពោលជានាថា "ពួកខ្ញុំម្ចាស់ជ្រាបសេចក្តីដែលលោកម្ចាស់ដ៏ចម្រើននេះ នៅក្នុងទីនេះអស់កាលមានប្រមាណប៉ុណ្ណោះ លោកម្ចាស់ដ៏ចម្រើនអង្គនេះមិនមែនជាចោរ ព្រោះដូច្នោះ គួរប្រាប់ដល់អ្នកទាំងនោះ ។

ថ. កិច្ចដទៃណាហ្ន៎ ដែលអាត្មាភាពគួរធ្វើ ?

ស. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម្មតាលោកម្ចាស់ដែលជាអ្នកនៅក្នុងព្រៃស្មសាន ចាំបាច់វៀរវត្ថុទាំងឡាយមាន ត្រី សាច់ ម្សៅល្ង និងស្ករអំពៅជាដើមចេញ, មិនគួរសឹងពេលថ្ងៃ មិនគួរជាអ្នកខ្ជិលច្រអូស គួរប្រារព្ធសេចក្តីព្យាយាម, មិនជាអ្នកអួតអាង មិនមែនជាអ្នកបោកប្រាស ជាអ្នកមានអធ្យាស្រ័យល្អ ពេលល្ងាចកាលជនដេកលក់អស់ហើយ គប្បីមកអំពីវិហារ, វេលាទៀបភ្លឺ កាលពួកជន

គ្រប់គ្នានៅមិនទាន់ក្រោក ( ភ្ញាក់ពីដេក ) នៅឡើយ គប្បីទៅវិហារ, បពិត្រលោកម្ចាស់ដ៏ចម្រើន បើលោកម្ចាស់នៅក្នុងទីនេះដោយអាការយ៉ាងនេះសោត នឹងអាចញុំាងកិច្ចរបស់បព្វជិត ឲ្យដល់ទីបំផុតបាន, បើពួកជននាំសាកសពមកបោះចោល, នាងខ្ញុំនឹងលើកឡើងកាន់ផ្ទះកំពូលដែលក្រាលដោយសំពត់កម្ពលធ្វើសក្ការបូជា ដោយវត្ថុទាំង-ឡាយមានគ្រឿងក្រអូប និងកម្រងផ្កាឈើជាដើម ហើយធ្វើការដុតសាកសព, ប្រសិនបើលោកម្ចាស់ដ៏ចម្រើន នៅមិនទាន់អាចដើម្បីញុំាងកិច្ចរបស់បព្វជិតឲ្យដល់ទីបំផុតបានសោត នាងខ្ញុំនឹងលើកឡើងកាន់ជើងថ្ករ ហើយបង្កាត់ភ្លើងដុត យកទំពក់ទាញ ( សាកសព ) យកចេញមកដាក់ទុកខាងក្រៅ ចិញ្ច្រាំដោយពូថៅ ពន្លះឲ្យជាកំណាត់តូច កំណាត់ធំ ហើយដាក់ក្នុងភ្លើង សម្តែងដល់លោក (លោកម្ចាស់ដ៏ចម្រើន ) ហើយទើបដុត ។

ពេលនោះព្រះថេរៈពោលនឹងនាងកាឡីនោះថា "ល្អហើយនាងដ៏ចម្រើន ក៏នាងឃើញរូបារម្មណ៍ណាមួយហើយ ចូរប្រាប់ដល់អាត្មា

កាពចុះ” នាងកាឡីទទួលថា “ព្រះករុណាលោកម្ចាស់” ព្រះថេរៈធ្វើសមណធម៌នៅក្នុងព្រៃស្មសានតាមអធ្យាស្រ័យរបស់ខ្លួន ។

## ព្រះចុល្លកាលអផ្សុក

ចំណែកព្រះចុល្លកាលត្រេរដេកក្រោកៗ នឹកដល់ឃរាវាស គិតដល់បុត្រ និងភរិយា គិតថា “បងប្រុសរបស់យើងនេះ ធ្វើកម្មធ្ងន់ក្រៃលែង” ។

## ព្រះមហាកាលពិចារណាសាកសពកុលធីតា

លំដាប់នោះ កុលធីតាម្នាក់បានធ្វើកាលកិរិយា ស្លាប់នៅក្នុងវេលាល្ងាច គឺនៅមិនទាន់ស្លេកស្លាំង ព្រោះព្យាធិកម្រើកឡើងមួយភ្លែតនោះ ។ ពួកញាតិសែងសាកសពកុលធីតានោះ ទៅកាន់ព្រៃស្មសានក្នុងវេលាល្ងាច ព្រមទាំងឧបករណ៍សម្រាប់ដុតផ្សេងៗ មានឧសនិងប្រេងជាដើម ឲ្យថ្លៃឈ្នួលដល់ស្ត្រីអ្នករក្សាព្រៃស្មសាន ដោយពាក្យថា “នាងចូរបាត់បែងដុតសាកសពនេះ” ដូច្នេះហើយ ប្រគល់ ( សាកសព ) ឲ្យហើយ ចៀសចេញទៅ ។ នាងដោះសំពត់ដណ្តប់

របស់កុលធីតានោះចេញហើយ ឃើញសរីរៈដែលស្លាប់ត្រឹមតែមួយក្លែតនោះសែនប្រណីត មានពណ៌ដូចមាស ទើបគិតថា "អារម្មណ៍នេះគួរនឹងសម្ដែងដល់លោកម្ចាស់" ហើយទៅក្រាបថ្វាយបង្គំព្រះថេរៈពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន អារម្មណ៍បែបនេះមាន, សូមលោកម្ចាស់គប្បីទៅ, ពិចារណាចុះ" ។

ព្រះថេរៈទទួល "ចម្រើនពរ" ដូច្នេះហើយឲ្យលើកសំពត់ដណ្ដប់ចេញហើយ ពិចារណាតាំងអំពីបាទដើងរហូតដល់ចុងសក់ ហើយនិយាយថា "រូបនេះប្រណីតក្រៃលែងណាស់ មានពណ៌ដូចជាមាស, នាងគប្បីដាក់រូបនោះក្នុងភ្លើង ក្នុងកាលណារូបទុំ ត្រូវអណ្ដាតភ្លើងធំរំលាយហើយ សឹមប្រាប់ដល់អាត្មាភាព" ដូច្នេះហើយ ទៅកាន់លំនៅរបស់ខ្លួនវិញ ។ នាងធ្វើយ៉ាងនោះហើយ ទើបប្រាប់ដល់ព្រះថេរៈ, ព្រះថេរៈទៅពិចារណា ។ ក្នុងទីដែលត្រូវអណ្ដាតភ្លើងប៉ះខ្ទប់ហើយៗ ពណ៌នៃសរីរៈបានដូចជាមេគោដាង ជើងទាំងពីរសំយុងចុះ ដៃទាំងពីររួញចូល ថ្ងាសមានស្បែករសាត់ចេញហើយ ។

## ព្រះមហាកាលសម្រេចព្រះអរហត្ត

ព្រះថេរៈពិចារណាថា "សរីរៈនេះជាធម្មជាតិតាំងនៅក្នុងហឫ-ទ័យ ធ្វើឲ្យមិនមានទីបំផុតដល់បុគ្គលអ្នកក្រឡេកមើលក្នុងកាលមុន, តែឥឡូវនេះ (ត្រឡប់) ដល់នូវការអស់ទៅ សូន្យទៅ" ។ ត្រឡប់ទៅកាន់ទីសម្រាកពេលយប់ អង្គុយពិចារណាដល់ការអស់ទៅ និងសូន្យទៅ ពោលគាថាថា ៖

"សង្ខារទាំងឡាយមិនទៀងមែនពិត មានកិរិយាកើតឡើង
នឹងវិនាសទៅវិញជាធម្មតា, កើតឡើងហើយ រមែងរលត់
ទៅវិញ លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើប
បាននូវសេចក្ដីសុខ" ។

ចំរើនវិបស្សនាបានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ កាលព្រះថេរៈបានសម្រេចជាព្រះអរហត្តហើយ, ព្រះ-សាស្ដាមានកិក្ខុសង្ឃចោមរោម ស្ដេចយាងទៅកាន់សេតព្យនគរ ហើយស្ដេចយាងចូលកាន់ព្រៃធ្នង់ ។

ពួកកិរិយារបស់ព្រះចុល្លកាល បានឮថា ព្រះសាស្តាស្តេចយាងមកដល់ហើយ គិតថា "ពួកយើងនឹង (ជួយគ្នា) ចាប់ស្វាមីរបស់ពួកយើង" ដូច្នេះ ហើយបញ្ជូន ( អ្នកបម្រើ ) ទៅអារាធនានិមន្តព្រះសាស្តា ។

## របៀបក្រាលអាសនៈសម័យពុទ្ធកាល

ក៏ក្នុងស្ថានទីដែលព្រះពុទ្ធទាំងឡាយ មិនទ្រង់ស្និទ្ធស្នាល គួរភិក្ខុមួយរូបអ្នកប្រាប់ការក្រាលអាសនៈ និងត្រូវទៅមុន ក៏អាសនៈសម្រាប់ព្រះពុទ្ធទាំងឡាយគប្បីឲ្យក្រាលនៅចំកណ្តាល, ក៏អាសនៈសំរាប់ព្រះសារីបុត្តត្ថេរគប្បីក្រាលខាងស្តាំ, ក៏អាសនៈសម្រាប់ព្រះមហាមោគ្គល្លានត្ថេរ គប្បីឲ្យក្រាលខាងឆ្វេងនៃអាសនៈរបស់ព្រះពុទ្ធនោះ, អាសនៈសម្រាប់ភិក្ខុសង្ឃ គប្បីឲ្យក្រាលក្នុងខាងទាំងពីរបន្ទាប់អំពីនោះទៅ ។ ព្រោះដូច្នោះ ព្រះមហាថេរៈសម្រាកនៅក្នុងទី ឃ្លុំចីវរបញ្ជូនព្រះចុល្លកាលទៅថា "លោកចូរទៅមុន ប្រាប់របៀបក្រាលអាសនៈ" ។

# ព្រះចុល្លកាលត្រូវស្ត្រីចាប់ផ្សឹក

ពួកជនក្នុងផ្ទះ ធ្វើការសើចចំអកឲ្យលោក ចាប់ពីកាលដែលពួកគេឃើញលោក (ក្លែង) ធ្វើក្រាលអាសនៈទៀបក្នុងទីបំផុតព្រះសង្ឃត្រូវក្រាលអាសនៈខ្ពស់ក្នុងទីបំផុតរបស់សង្ឃនវក ។ ព្រះចុល្លកាលប្រាប់ថា "ពួកនាងចូរកុំធ្វើយ៉ាងនោះ, ចូរក្រាលអាសនៈខ្ពស់ក្នុងទីខ្ពស់ក្រាលអាសនៈទាបក្នុងទីទាប" ។

ពួកស្ត្រីធ្វើដូចមិនឮពាក្យរបស់លោក គម្រាមថា "លោកដើរធ្វើអី ? នាទីឲ្យក្រាលអាសនៈមិនសមគួរដល់លោកឬ ? លោកលានរណាទៅបួស ? លោកនរណាជាអ្នកព្រមឲ្យបួស ? មកទីនេះធ្វើអ្វី" ? ដូច្នេះហើយ ជួយគ្នាទាញស្បង់ និងចីវរចេញ ហើយឲ្យស្លៀកសំពត់ស ពាក់កម្រងផ្កាឈើលើសិរសា ហើយបញ្ជូនទៅដោយពាក្យថា "លោកចូរទៅនាំព្រះសាស្តាមក, ពួកយើងនឹងក្រាលអាសនៈ" ។

ចុល្លកាលតាំងនៅក្នុងភាវៈនៃភិក្ខុអស់កាលមិនយូរ មិនទាន់មានវស្សានៅឡើយក៏សឹក ទើបមិនខ្មាសអៀន ព្រោះហេតុនោះ

ទើបជាអ្នកអស់សេចក្តីវង្វេងសដោយកិរិយាអាការនោះ ទៅថ្វាយបង្គំព្រះសាស្តាហើយ នាំភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានមក ។

ក៏ក្នុងកាលស្រេចភត្តកិច្ចរបស់ភិក្ខុសង្ឃ ពួកភរិយារបស់មហាកាលក៏គិតគ្នាថា "ស្ត្រីទាំងនេះរួមគ្នាចាប់ស្វាមីរបស់ខ្លួនបាន ពួកយើងក៏នឹងចាប់ស្វាមីរបស់ពួកយើងដែរ" ទើបឲ្យនិមន្តព្រះសាស្តាដើម្បីប្រយោជន៍ដល់ការសោយភត្តាហារក្នុងថ្ងៃស្អែក ។

## ព្រះមហាកាលក៏ត្រូវភរិយាចាប់ផ្សឹក

ក៏ក្នុងកាលនោះ ភិក្ខុរបជទៃបានទៅ ( ប្រាប់ ) របៀបក្រាលអាសនៈ ។ ស្ត្រីទាំងនោះមិនបានឱកាស ក្នុងខណៈនោះ អារាធនាភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យគង់ ហើយបានថ្វាយភិក្ខា, ក៏ចុល្លកាលមានភរិយាពីរនាក់, មជ្ឈិមកាលមានបួននាក់, មហាកាលមានប្រាំបីនាក់, ចំណែកភិក្ខុទាំងឡាយប្រាថ្នាធ្វើភត្តកិច្ច បានអង្គុយធ្វើភត្តកិច្ចហើយ ។

ពួកដែលប្រាថ្នាទៅខាងក្រៅក៏ក្រោកចេញទៅ, ចំណែកព្រះ-

សាស្តាប្រថាប់គង់ទ្រង់ធ្វើភត្តកិច្ច ។ ក្នុងកាលស្រេចភត្តកិច្ចរបស់ព្រះអង្គហើយ ស្ត្រីទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកាលធ្វើអនុមោទនាដល់ពួកខ្ញុំព្រះអង្គហើយសឹមនិមន្តទៅ, សូមព្រះអង្គស្តេចយាងទៅមុនចុះ" ។

ព្រះសាស្តាទ្រង់ត្រាស់ថា "ប្រពៃហើយ" ស្តេចបានយាងទៅមុនហើយ លុះដល់ទ្វារស្រុកភិក្ខុសង្ឃក៏លើកទោសថា "ហេតុដូចម្តេច ទើបព្រះសាស្តាទ្រង់ធ្វើយ៉ាងហ្នឹង ? ព្រះអង្គទ្រង់ជ្រាបហើយទើបទ្រង់ធ្វើ ឬមិនទ្រង់ជ្រាបហើយទ្រង់ធ្វើហ្ន៎ ? កាលពីម្សិលអន្តរាយនៃបព្វជ្ជាកើតឡើងដល់ចុល្លកាល ព្រោះកាលដែលព្រះអង្គយាងទៅមុន, ថ្ងៃនេះអន្តរាយមិនបានមាន ព្រោះភិក្ខុដទៃនិមន្តទៅមុន, ឥឡូវនេះ ព្រះសាស្តាបញ្ជាឲ្យព្រះមហាកាលត្រឡប់ ហើយស្តេចយាងមក, ក៏ភិក្ខុអ្នកមានសីលដល់ព្រមហើយដោយអាចារៈ ស្ត្រីទាំងនោះនឹងធ្វើអន្តរាយនៃបព្វជ្ជាដល់ព្រះមហាកាលនោះបានដែរឬ" ?

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ

ស្ដេចយាងមកទ្រង់ឈរត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលនូវពាក្យអ្វី" ? ភិក្ខុទាំងនោះក្រាបទូលសេចក្ដីនុ៎ះ ។

ស. ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់មហាកាលថា ដូចចុល្លកាលឬ ?

ក. យ៉ាងនោះហើយ ព្រះអង្គ ព្រោះចុល្លកាលនោះមានភរិយាពីរនាក់ ( ចំណែក ) ព្រះមហាកាលនេះមានភរិយាដល់ទៅ ៨ នាក់, លោកត្រូវភរិយាទាំង ៨ ពទ្ធចាប់ហើយ នឹងធ្វើអ្វីបាន ព្រះអង្គ ?

## ព្រះមហាកាលជាអ្នកមិនញាប់ញ័រ

ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំបាននិយាយយ៉ាងនោះឡើយ, ចុល្លកាលក្រោកឡើងហើយ ក្រោកឡើងព្រមហើយ ច្រើនទៅដោយអារម្មណ៍ថាល្អ ដូចដើមឈើដែលមានកម្លាំងទុព្វលដុះនៅក្បែរមាត់ជ្រោះ និងភ្នំដែលដាច់, ចំណែកព្រះមហាកាលបុត្ររបស់តថាគតតាមឃើញអារម្មណ៍ថាមិនល្អ ជាអ្នកមិនញាប់ញ័រឡើយ ដូចភ្នំថ្មតាន់" ដូច្នេះហើយ បានភាសិតព្រះគាថា

ទាំងនេះថា ៖

៦ សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ
តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្វលំ ។
អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ
តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ ។

បុគ្គលតាមឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយ៍ទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ ។ ឯបុគ្គលដែលតាមឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយ៍ទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធាប្រារព្ធព្យាយាម កិលេសមារតែងគ្របសង្កត់បុគ្គលនោះ

មិនបាន ដូចខ្យល់គ្របសង្កត់ភ្នំថ្មតាន់មិនបានដូច្នោះ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សុភានុបស្សឹ** បានដល់អ្នកតាមឃើញនូវអារម្មណ៍ថាល្អ ។ អធិប្បាយថា អ្នកបណ្ដោយចិត្តទៅក្នុងអារម្មណ៍ដែលគួរប្រាថ្នា ។ ក៏បុគ្គលណាកាលកាន់យកនិមិត្តអនុព្យញ្ជនៈ រមែងកាន់យកថា "ក្រចកទាំងឡាយល្អ, ស្អាត" ។ កាន់យកថា "ម្រាមទាំងឡាយល្អ, ស្អាត" ។ កាន់យកថា "ដៃទាំងពីរ ជើងទាំងពីរ ស្មងទាំងពីរ ភ្លៅទាំងពីរ ចង្កេះ ពោះ សុដន្ទទាំងពីរ ក បបូរមាត់ ធ្មេញទាំងឡាយ មាត់ ច្រមុះ ភ្នែកទាំងពីរ ត្រចៀកទាំងពីរ ចិញ្ចើមទាំងពីរ ថ្ងាស សក់ទាំងឡាយ ល្អ ស្អាត" ។ កាន់យកថា "សក់ រោម ក្រចក ធ្មេញ ស្បែក ល្អ ស្អាត" ។ ( ឬ ) កាន់យកថា "ពណ៌ល្អ ទ្រង់ទ្រាយល្អ" ។ បុគ្គលនោះ ឈ្មោះថា តាមឃើញនូវអារម្មណ៍ថាល្អ ។ បុគ្គលនោះ គឺអ្នកតាមឃើញនូវអារម្មណ៍ថាល្អយ៉ាងនោះ ។

បទថា **ឥន្ទ្រិយេសុ** បានដល់ ក្នុងឥន្ទ្រីយ៍ ៦ មានចក្ខុន្ទ្រីយ៍ជាដើម ។

បទថា **អសំវុតំ** បានដល់ អ្នកមិនរក្សាទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម ។

បទថា **អមត្តញ្ញុំ** សេចក្តីថា ដែលឈ្មោះថា អ្នកមិនស្គាល់ប្រមាណក្នុងភោជន ព្រោះមិនដឹងប្រមាណនេះ គឺប្រមាណក្នុងការស្វែងរក ប្រមាណក្នុងការទទួល ប្រមាណក្នុងការបរិភោគ ។ ន័យម្យ៉ាងទៀត ដែលឈ្មោះថា អ្នកមិនស្គាល់ប្រមាណព្រោះមិនដឹងប្រមាណនេះ គឺប្រមាណក្នុងការពិចារណា ប្រមាណក្នុងការលះ គឺមិនដឹងថា "ភោជននេះប្រកបដោយធម៌ នេះមិនប្រកបដោយធម៌" ។

បទថា **កុសីតំ** សេចក្តីថា ដែលឈ្មោះថាអ្នកខ្ជិលច្រអូស ព្រោះភាពជាអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃកាមវិតក្ក ព្យាបាទវិតក្កនិងវិហឹង្សាវិតក្ក ។

បទថា **ហីនវីរិយំ** សេចក្តីថា អ្នកមិនមានសេចក្តីព្យាយាម

គឺអ្នកវៀរ ចាកការធ្វើសេចក្ដីព្យាយាមក្នុងឥរិយាបថទាំង ៤ ។

បទថា **បសហតិ** ប្រែថា រមែងគ្របសង្កត់ គឺញាំញី ។

បាទព្រះគាថា **វាតោ រុក្ខំវ ទុព្ពលំ** សេចក្ដីថា ដូចខ្យល់ដ៏មានកម្លាំងញាំងដើមឈើដែលមានកម្លាំងទុព្វល ដែលដុះនៅក្បែរមាត់ជ្រោះ ។ អធិប្បាយថា ដូចយ៉ាងថាខ្យល់នោះ ញុំាងចំណែកផ្សេងៗ មានផ្កា ផ្លែ ស្លឹកខ្ចីជាដើម នៃដើមឈើនោះឲ្យធ្លាក់ចុះមកខ្លះ កាច់មែកតូចខ្លះ កាច់មែកធំខ្លះ បក់ដកដើមឈើនោះព្រមទាំងឫស ធ្វើឲ្យឫសឡើងខាងលើ មែកចុះក្រោម យ៉ាងណាមិញ, មារ គឺកិលេសដែលកើតក្នុងខាងក្នុង រមែងញុំាងបុគ្គលបែបនោះបាន ដូច្នោះដែរ, គឺកិលេសមារធ្វើឲ្យត្រូវអាបត្តិតូចៗ ដូចខ្យល់មានកម្លាំងខ្លាំងញុំាងចំណែកផ្សេងៗ មានផ្កា ផ្លែ ស្លឹកខ្ចីជាដើម នៃដើមឈើដែលមានកម្លាំងទុព្វលឲ្យជ្រុះចុះមកខ្លះ, ធ្វើឲ្យត្រូវអាបត្តិមាននិស្សគ្គីយ៍ជាដើម ដូចខ្យល់ដ៏មានកម្លាំងធ្វើការកាច់មែកឈើតូចៗខ្លះ, ធ្វើឲ្យត្រូវអាបត្តិសង្ឃាទិសេសទាំង ១៣ ដូចខ្យល់មានកម្លាំងខ្លាំងធ្វើការកាច់

មែកឈើធំខ្លះ, ធ្វើឲ្យត្រូវអាបត្តិបារាជិកនាំចេញចាកសាសនា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ល្អហើយ ឲ្យដល់ភាពជាគ្រហស្ថដោយពីរបីថ្ងៃប៉ុណ្ណោះ ដូចខ្យល់មានកម្លាំងខ្លាំងផក ( ដើមឈើ ) ធ្វើឲ្យរលំចុះ មានឫសឡើងលើ មានមែកចុះក្រោមខ្លះ ។ កិលេសមាររមែងញាំញីបុគ្គលបែបនោះ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ។

បទថា **អសុភានុបស្សឹ** សេចក្ដីថា អ្នកឃើញនូវអារម្មណ៍មិនល្អ ១០ យ៉ាង យ៉ាងណានីមួយថាមិនល្អ ។ គឺប្រកបក្នុងមនសិការដោយភាពជារបស់បដិកូល បានដល់ ឃើញសក់ទាំងឡាយដោយភាពជារបស់មិនល្អ មិនស្អាត ឃើញរោម ក្រចក ធ្មេញស្បែក ពណ៌សម្បុរ ទ្រង់ទ្រាយដោយភាពជារបស់មិនល្អ មិនស្អាត ។

បទថា **ឥន្ទ្រិយេសុ** បានដល់ក្នុងឥន្ទ្រិយ៍ ៦ ។ បទថា **សុសំវុតំ** បានដល់ អ្នកប្រាសចាកការកាន់យក មានការកាន់យកនូវនិមិត្តជាដើម គឺអ្នកមានទ្វារដែលបិទហើយ ។

បទថា **មត្តញ្ញុំ** សេចក្ដីថា អ្នកស្គាល់ប្រមាណក្នុងភោជន

មានន័យផ្ទុយនឹងភាពជាអ្នកមិនស្គាល់ប្រមាណ ។

បទថា **សទ្ធំ** សេចក្ដីថា អ្នកប្រកបដោយលោកិយសទ្ធា មានការជឿកម្ម និងផលជាលក្ខណៈ ១ និងប្រកបដោយលោកុត្តរសទ្ធា ពោលគឺការជ្រះថ្លា ដែលមិនកម្រើកញាប់ញ័រក្នុងវត្ថុទាំង ៣ មួយ ។

បទថា **អារទ្ធវិរិយំ** បានដល់ អ្នកផ្គងឡើងនូវសេចក្ដីព្យាយាម គឺជាអ្នកមានការព្យាយាមពេញលេញហើយ ។

បទថា **តំ វេ** បានដល់ បុគ្គលនោះ គឺបែបនោះ ។

អធិប្បាយថា ខ្យល់ដែលមានកម្លាំងខ្សោយ បក់ស្រាលៗ រមែងមិនអាចឲ្យសិលាតាន់ញាប់ញ័របានយ៉ាងណាមិញ កិលេសមារ ដែលមានកម្លាំងខ្សោយ សូម្បីកើតឡើងក្នុងខាងក្នុង រមែងគ្របសង្កត់ (បុគ្គលនោះ) មិនបាន គឺមិនអាចធ្វើឲ្យញាប់ញ័ររញ្ជួយបាន ដូច្នោះ ។

## មហាកាលហោះគេចភរិយា

ស្ត្រីទាំងនោះ ដែលជាភរិយាចាស់របស់ព្រះមហាកាលនោះ ឡោមពទ្ធព្រះថេរៈ ហើយពោលពាក្យជាដើមថា “លោកលានរណា

ទៅបួស ឥឡូវនេះ លោកនឹងជាគ្រហស្ថ ឬនឹងមិនជាគ្រហស្ថ" ? ដូច្នេះហើយ បានជាអ្នកប្រាថ្នាដើម្បីនឹងនាំចេញនូវសំពត់ទាំងឡាយ ( របស់ព្រះថេរៈ ) ។

ព្រះថេរៈកំណត់អាការរបស់ស្ត្រីនោះបានហើយ ក្រោកចាក អាសនៈ ហើយហោះទៅដោយឫទ្ធិ ទម្លាយនូវហោជាងនៃដំបូលផ្ទះ កំពូល ទៅតាមអាកាស, កាលព្រះសាស្តាទ្រង់ត្រាស់គាថាចប់, សរ-សើរព្រះសរីរៈរបស់ព្រះសាស្តាដែលមានវណ្ណៈដូចមាស ចុះមកថ្វាយបង្គំព្រះយុគលបាទរបស់ព្រះតថាគត ។

ក្នុងកាលចប់គាថា ភិក្ខុដែលប្រជុំគ្នា តាំងនៅក្នុងអរិយផល ទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

( រឿងចុល្លកាល និងមហាកាលចប់ )

# ៧ រឿងព្រះទេវទត្ត

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបាន សំពត់កាសាវៈដែលបុគ្គលនាំមកពីដែនគន្ធារៈរបស់ព្រះទេវទត្ត ក្នុងក្រុងរាជគ្រឹះ ត្រាស់បឋមទេសនានេះថា "អនិក្កសាវោ" ជាដើម ។

## ព្រះសារីបុត្រសម្តែងធម៌ដល់អ្នកក្រុងរាជគ្រឹះ

សេចក្តីពិស្តារថា សម័យមួយ ព្រះអគ្គសាវកទាំងពីរនាំបរិវាររបស់ខ្លួនមួយអង្គៗ ៥០០ រូប ទៅទូលលាព្រះសាស្តាហើយ បានចេញចាកវត្តជេតពន ហើយទៅកាន់ក្រុងរាជគ្រឹះ ។

អ្នកក្រុងរាជគ្រឹះរួមគ្នាជាពួក មានពីរនាក់ខ្លះ បីនាក់ខ្លះ ច្រើននាក់ខ្លះ បានថ្វាយអាគន្តុកទាន ។ ថ្ងៃមួយព្រះសារីបុត្រកាលនឹងធ្វើអនុមោទនាសម្តែងធម៌យ៉ាងនេះថា "ឧបាសក ឧបាសិកាទាំងឡាយ អ្នកថ្វាយទានដោយខ្លួនឯង ( តែ ) មិនបបួលអ្នកដទៃ, ទាយកនោះរមែងបានភោគសម្បត្តិក្នុងទីដែលខ្លួនកើតហើយៗ ( តែ ) មិនបានបរិវារសម្បត្តិ, អ្នកបបួលអ្នកដទៃធ្វើ ចំណែកខ្លួនឯងមិនឲ្យ, អ្នកនោះ

រមែងបានបរិវារសម្បត្តិក្នុងទីដែលខ្លួនកើតហើយៗ ( តែ ) មិនបាន ភោគសម្បត្តិ, អ្នកដែលមិនឲ្យដោយខ្លួនឯងផង មិនបបួលអ្នកដទៃផង បុគ្គលនោះ រមែងមិនបានសូម្បីវត្ថុត្រឹមតែបាយបុងអង្ករល្មមចំ-អែតផ្ទៃ រមែងជាមនុស្សអនាថា រកបច្ច័យមិនបានក្នុងទីដែលខ្លួនកើតហើយៗ, អ្នកដែលឲ្យទានដោយខ្លួនឯងផង ទាំងបបួលអ្នកដទៃឲ្យឲ្យផង បុគ្គលនោះរមែងបានទាំងភោគសម្បត្តិ ទាំងបរិវារសម្បត្តិក្នុងទីដែលខ្លួនកើតហើយៗអស់រយអត្តភាពខ្លះ ពាន់អត្តភាពខ្លះ សែនអត្តភាពខ្លះ ។

## និមន្តភិក្ខុ ១០០០ រូបទទួលភត្តាហារ

បុរសដែលជាបណ្ឌិតម្នាក់ ស្តាប់ព្រះធម្មទេសនានោះហើយ គិតថា "អ្នកដ៏ចម្រើនព្រះធម្មទេសនាគួរអស្ចារ្យណាស់, លោកម្ចាស់សារីបុត្រពោលហេតុនៃសេចក្តីសុខ, យើងធ្វើកម្មដែលញុំាងសម្បត្តិទាំងពីរនេះឲ្យសម្រេចរមែងសមគួរ" ដូច្នេះហើយ ទើបនិមន្តព្រះថេរៈថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្ងៃស្អែកនេះ សូមលោកម្ចាស់ទាំង

ឡាយទទួលភិក្ខារបស់ខ្ញុំ" ។

ព្រះថេរៈសួរថា "ឧបាសក អ្នកត្រូវការភិក្ខុប៉ុន្មានអង្គ ឧបាសកសួរត្រឡប់ទៅវិញថា "ភិក្ខុដែលជាបរិវាររបស់លោកម្ចាស់ មានប៉ុន្មានអង្គ" ?

ថ. មានប្រមាណ ១០០០ អង្គ ឧបាសក ។

ឧ. បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មួយអន្ទើដោយភិក្ខុជាបរិវារទាំងអស់មេត្តាទទួលភិក្ខារបស់ខ្ញុំ ។ ព្រះថេរៈទទួលហើយដោយតុណ្ហីភាព ។

## ឧបាសកបបួលអ្នកស្រុកថ្វាយភត្តាហារ

ឧបាសកត្រាច់ទៅក្នុងផ្លូវព្រះនគរ បបួលដោយពាក្យថា "ម្នាលអ្នកទាំងឡាយ ខ្ញុំនិមន្តភិក្ខុទុក ១០០០ រូប អ្នកទាំងឡាយនឹងអាចថ្វាយភិក្ខាមានចំនួនប៉ុន្មាន ? ពួកមនុស្សពោលដោយសមគួរដល់កម្លាំងរបស់ខ្លួនៗ ថា ពួកខ្ញុំនឹងប្រគេនដល់ភិក្ខុ ១០ រូប, ពួកខ្ញុំ ២០ រូប ពួកខ្ញុំ ១០០ រូប ។

ឧបាសកពោលថា “បើដូច្នោះ យើងទាំងឡាយនឹងប្រជុំគ្នាដាំស្លរួមគ្នាក្នុងទីតែមួយចុះ, សូមលោកគ្រប់ៗគ្នា ចូររួបរួមវត្ថុផ្សេងៗ មានប្រេង ល្ង អង្ករ ទឹកដោះថ្លា ស្ករអំពៅជាដើម” ដូច្នេះហើយ ឲ្យរួមគ្នាទុកក្នុងទីតែមួយ ។ គ្រានោះ កុដុម្ពិក៍ម្នាក់ឲ្យសំពត់កាសាវៈដែលនាំមកពីដែនគន្ធារៈដែលមានតម្លៃ ១ សែន ដល់ឧបាសកនោះ ហើយប្រាប់ថា “បើវត្ថុសម្រាប់ឲ្យទានរបស់លោក មិនគ្រប់គ្រាន់សោត, លោកចូរចំណាយសំពត់មួយផ្ទាំងនេះ ឲ្យគ្រប់ចំណែកដែលខ្វះខាត, បើវត្ថុសម្រាប់ធ្វើទានរបស់លោកគ្រប់គ្រាន់ហើយ លោកចូរប្រគេន ( សំពត់មួយផ្ទាំងនេះ ) ដល់ភិក្ខុរូបណាដែលលោកប្រាថ្នា” ។ ក្នុងគ្រានោះ វត្ថុសម្រាប់ឲ្យទានគ្រប់យ៉ាងរបស់ឧបាសកនោះគ្រប់គ្រាន់ហើយ ។ វត្ថុណាៗឈ្មោះថាខ្វះខាតមិនមាន ឧបាសកនោះទើបសួរមនុស្សទាំងឡាយថា “សំពត់កាសាវៈដែលមានតម្លៃកាត់ថ្លៃមិនបានមួយផ្ទាំងនេះ ដែលកុដុម្ពិក៍ម្នាក់ពោលយ៉ាងនេះ ហើយប្រគល់ឲ្យខ្ញុំ ។ ទេយ្យធម៌ ( របស់ពួកយើង ) ក៏មាននៅសល់ផងដែរ, យើងទាំងឡាយ

នឹងប្រគេនសំពត់កាសាវៈមួយផ្ទាំងនេះ ដល់លោកម្ចាស់អង្គណា” ?

## ប្រគេនសំពត់តម្លៃមួយសែនដល់ទេវទត្ត

ពួកខ្លះពោលថា “ប្រគេនដល់ព្រះសារីបុត្តត្ថេរ” ពួកខ្លះពោលថា “ព្រះថេរៈច្រើនមកក្នុងវេលាសន្ទូងមានកាលចាស់ជុំវិញហើយ ក៏ទៅជាប្រក្រតី ព្រះទេវទត្តជាសម្លាញ់ក្នុងពិធីមង្គល និងអពមង្គលទាំងឡាយរបស់ពួកយើង តាំងនៅជានិច្ចដូចពាងទឹក, ពួកយើងនឹងប្រគេនសំពត់មួយផ្ទាំងនោះដល់លោក” សូម្បីកាលពាក្យប្រព្រឹត្តទៅច្រើនផ្លូវ ( យ៉ាងនោះ ) ពួកដែលពោលថា “គួរប្រគេនដល់ទេវទត្ត” មានចំនួនច្រើនជាង ។ កាលបើដូច្នោះ ពួកគេទើបបានប្រគេនសំពត់កាសាវៈនោះដល់ទេវទត្ត ។

## ព្រះទេវទត្តស្លៀកដណ្ដប់សំពត់កាសាវៈ មិនសមគួរដល់ខ្លួន

ព្រះទេវទត្តកាត់សំពត់នោះហើយ ដេរជ្រលក់ហើយ ស្លៀកដណ្ដប់ហើយត្រាច់ទៅ ។ ពួកមនុស្សឃើញលោកហើយ ក៏និយាយ

គ្នាថា "សំពត់មួយផ្ទាំងនេះមិនសមគួរដល់ទេវទត្តទេ សមគួរដល់ព្រះសារីបុត្រ ព្រះទេវទត្តស្លៀកដណ្ដប់សំពត់ដែលមិនសមគួរដល់ខ្លួនត្រាច់ទៅ" ។ គ្រានោះ ភិក្ខុអ្នកនៅក្នុងទិសផ្សេងមួយរូប ( ចេញ ) អំពីក្រុងរាជគ្រឹះទៅកាន់ក្រុងសាវត្ថីថ្វាយបង្គំព្រះសាស្ដា ជាអ្នកដែលព្រះសាស្ដាទ្រង់ធ្វើបដិសណ្ឋារៈ ត្រាស់សួរដល់ ការនៅជាសុខរបស់ព្រះអគ្គសាវកទាំងពីរហើយ ក៏ក្រាបទូលរឿងនោះទាំងអស់ ចាប់តាំងពីដើម ។

ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុ ទេវទត្តនោះទ្រទ្រង់សំពត់ដែលមិនសមគួរដល់ខ្លួនក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ, សូម្បីក្នុងកាលមុនទេវទត្តទ្រទ្រង់ហើយដូចគ្នា" ដូច្នេះហើយ ទ្រង់នាំអតីតនិទានមក ( ត្រាស់ថា ) ៖

## កាលមុនទេវទត្តជានាយព្រានដំរី

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិ ក្នុងព្រះនគរពារាណសី, នាយព្រានដំរីអ្នកនគរពារាណសីម្នាក់, សម្លាប់

ដំរីទាំងឡាយហើយ នាំក្អក ស្បែក ពោះវៀនធំ និងសាច់ដុំមកហើយ លក់ចិញ្ចឹមជីវិត ។ គ្រានោះ ដំរីជាច្រើនពាន់ដើររកស៊ីនៅក្នុងព្រៃមួយ ជួបព្រះបច្ចេកពុទ្ធច្រើនព្រះអង្គ ចាប់ផ្ដើមពីកាលនោះ កាលនឹងទៅ លុតជង្គង់ទាំងពីរចុះ ហើយធ្វើសេចក្ដីគោរពក្នុងកាលដែលទៅ និង មក ( គ្រប់ពេល ) ហើយទើបចៀសចេញទៅ ថ្ងៃមួយព្រានដំរីឃើញ កិរិយានោះហើយ គិតថា "យើងសម្លាប់ដំរីទាំងនេះបានដោយលំបាក, ក៏ក្នុងកាលទៅនិងមក ដំរីទាំងនេះរមែងធ្វើសេចក្ដីគោរពព្រះបច្ចេក ពុទ្ធទាំងឡាយ, វាឃើញអ្វីហ្ន៎ ? ទើបធ្វើសេចក្ដីគោរព", កំណត់បាន ថា "ឃើញសំពត់កាសាវៈ" ដូច្នេះហើយត្រិះរិះថា "ឥឡូវនេះ យើងបាន សំពត់កាសាវៈរមែងគួរ" ។ កាលព្រះបច្ចេកពុទ្ធមួយរូបចុះទៅកាន់ ជាតស្រះស្រង់ទឹក ដាក់សំពត់កាសាវៈទាំងឡាយទុកនៅក្បែរមាត់ ស្រះ, ទើបលួចចីវរនោះទៅ ចាប់លំពែងអង្គុយដណ្ដប់អវយវៈព្រម ទាំងក្បាលក្បែរផ្លូវ ដែលដំរីទាំងនោះទៅមក ។ ហ្វូងដំរីឃើញគេ ហើយទើបធ្វើសេចក្ដីគោរពដោយសម្គាល់ថា "ព្រះបច្ចេកពុទ្ធ" ហើយ

ក៏ចៀសចេញទៅ ។ ព្រានដំរីនោះយកលំពែងពួយត្រូវដំរីមួយដែលដើរខាងក្រោយដំរីទាំងនោះឲ្យស្លាប់ ហើយកាន់យកចំណែកផ្សេងៗមានភ្លុកជាដើម កប់ចំណែកដែលនៅសល់ក្នុងផែនដីហើយចៀសចេញទៅ ។

ក្នុងកាលជាចំណែកខាងក្រោយមក ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតដំរី បានជាប្រធាននៃដំរី ជាម្ចាស់នៃហ្វូង (ជាមេក្លោង) ក៏ក្នុងកាលនោះ ព្រានដំរីនោះក៏នៅតែធ្វើយ៉ាងនោះដដែល ។ ព្រះបរមពោធិសត្វដឹងនូវការអស់ទៅនៃបរិស័ទរបស់ខ្លួន ទើបសួរថា "ដំរីទាំងនេះទៅណាអស់ ? ទើបបានរលោះទៅ" កាលដំរីទាំងនោះឆ្លើយថា "មិនដឹងទេនាយ" គិតថា "ដំរីទាំងឡាយកាលនឹងទៅណាមិនទាន់ប្រាប់យើង ( ជាមុនសិនទេ ) នឹងមិនគប្បីទៅ អន្តរាយគប្បីមាន" នឹកសង្ស័យថា "អន្តរាយគប្បីមានពីសំណាក់នៃបុរស ដែលអង្គុយគ្របដណ្តប់សំពត់កាសាវៈក្នុងទីកន្លែងមួយ" ដើម្បីឃ្លាំចាប់បុរសនោះ ក៏បញ្ជូនដំរីទាំងអស់ឲ្យទៅមុន ចំណែកខ្លួនឯងដើរមកខាងក្រោយ,

ព្រានដំរីនោះ កាលដំរីដ៏សេសធ្វើសេចក្តីគោរពហើយដើរទៅ, ឃើញព្រះបរមពោធិសត្វកំពុងដើរមក ទើបសំរឹទ្ធិចីវរ ហើយពួយនូវលំពែងទៅ ។

ព្រះបរមពោធិសត្វ កាលប្រុងនូវស្មារតីហើយដើរមក ថយត្រឡប់ទៅខាងក្រោយ ហើយគេចនូវលំពែង ។

គ្រានោះ ព្រះបរមពោធិសត្វ ស្ទុះចូលទៅដើម្បីនឹងចាប់ព្រានដំរីនោះ ដោយធ្វើទុកក្នុងចិត្តថា "បុរសនេះឲ្យដំរីរបស់យើងវិនាសហើយ" ។ នាយព្រានដំរីពួនទីងដើមឈើមួយដើម ។

គ្រានោះ ព្រះបរមពោធិសត្វយកប្រមោយចាប់ព្រានដំរីដោយការធ្វើទុកក្នុងចិត្តថា "នឹងចាប់បោកទៅហ្នឹងផែនដី" (គ្រានោះ) ឃើញសំពត់កាសាវៈដែលព្រានដំរីនាំចេញមកសម្តែង ក៏អត់សង្កត់ដោយធ្វើទុកក្នុងចិត្តថា "បើយើងនឹងប្រទូសរ៉ាយចំពោះបុរសនេះសោត ។ ឈ្មោះថាអៀនខ្មាសចំពោះព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពច្រើនពាន់អង្គ និងជាការដែលយើងទម្លាយហើយ" សាកសួរថា "ញាតិ

របស់យើងប្រមាណប៉ុណ្ណោះ អ្នកឯងឲ្យវិនាសហើយឬ" ?

ព្រានដំរីទទួលសារភាពថា "អើ នាយ" ។

ព្រះមហាបុរសពោលថា "ព្រោះហេតុអ្វីអ្នកឯងទើបបានធ្វើកម្មដ៏គ្រោតគ្រាតយ៉ាងនេះ ? អ្នកឯងស្លៀកដណ្ដប់នូវសំពត់មិនសមគួរដល់ខ្លួន សមគួរដល់លោកអ្នកដែលមានរាគៈទៅប្រាសហើយទាំងឡាយ កាលធ្វើកម្មដ៏លាមកបែបនេះ ឈ្មោះថាធ្វើកម្មដ៏ធ្ងន់" ។

លុះពោលយ៉ាងនុ៎ះហើយ កាលនឹងសង្កត់សង្កិនឲ្យក្រៃលែងឡើង ទើបពោលនូវគាថាថា ៖

បុគ្គលណា នៅមានទឹកចត់ គឺរាគាទិក្កិលេសក្នុងសន្ដាន ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយ៍ និងសច្ចៈ ហើយស្លៀកដណ្ដប់សំពត់កាសាវៈ បុគ្គលនោះមិនគួរនឹងស្លៀកដណ្ដប់សំពត់កាសាវៈឡើយ ។

លុះតែបុគ្គលណា មានទឹកចត់ គឺរាគាទិក្កិលេសខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំក្នុងចតុប្បារិសុទ្ធិសីល

ប្រកបដោយការទូន្មាននូវឥន្ទ្រិយ៍ និងសច្ចៈ បុគ្គលនោះឯង
ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈបាន ។

សេចក្តីនេះ បណ្ឌិតគប្បីសម្តែងតាមរឿងឆទ្ទន្តជាតកចុះ ។

## របស់ល្អរមែងសមគួរដល់មនុស្សល្អ មិនសមគួរ ដល់មនុស្សអាក្រក់ទេ

ព្រះសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមក ( សម្តែង ) ហើយ ទ្រង់ប្រជុំជាតកថា "ព្រានដំរីក្នុងកាលនោះបានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ដំរីដ៏ប្រសើរដែលជាអ្នកផ្ចាញ់ផ្ចាលព្រានដំរីនោះ គឺតថាគតនេះឯង" ដូច្នេះ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលនេះប៉ុណ្ណោះទេ ។ សូម្បីក្នុងកាលមុន ទេវទត្តក៏ទ្រទ្រង់នូវសំពត់មិនសមគួរដល់ខ្លួនដូចគ្នា" ដូច្នេះហើយ បានភាសិតព្រះគាថាទាំងនេះថា ៖

៧ អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហិស្សតិ
អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។

**យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ**
**ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។**

បុគ្គលណា នៅមានទឹកចត់ គឺរាគាទិក្កិលេសក្នុងសន្ដាន ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រីយ៍ និងសច្ចៈ ហើយស្លៀកដណ្ដប់សំពត់កាសាវៈ បុគ្គលនោះមិនគួរនឹងស្លៀកដណ្ដប់សំពត់កាសាវៈឡើយ ។

លុះតែបុគ្គលណា មានទឹកចត់ គឺរាគាទិក្កិលេសខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រីយ៍ និងសច្ចៈ បុគ្គលនោះឯង ទើបគួរនឹងស្លៀកដណ្ដប់សំពត់កាសាវៈបាន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អនិក្កសាវោ** សេចក្ដីថា អ្នកដែលឈ្មោះថាមានទឹកចត់ គឺរាគាទិក្កិលេស ព្រោះកិលេសដូចទឹកចត់ទាំងឡាយ មានកាមរាគៈជាដើម ។

បទថា **បរិទហេស្សតិ** សេចក្តីថា នឹងប្រើប្រាស់ដោយអំណាចនៃការស្លៀក ការដណ្តប់ និងការក្រាល ។

ព្រះបាលីថា “**បរិទហិស្សតិ**” ក៏បាន ។

បាទព្រះគាថា **អបេតោ ទមសច្ចេន** សេចក្តីថា ប្រាសចាក, អធិប្បាយថា “ព្រាត់ប្រាស” ចាកការទូន្មាននូវឥន្ទ្រិយ៍ និងវចីសច្ចៈ ដែលជាចំណែកនៃបរមត្ថសច្ចៈ ។

បទថា **ន សោ** ជាដើម សេចក្តីថា បុគ្គលនោះ គឺបុគ្គលបែបនោះ រមែងមិនគួរស្លៀកដណ្តប់សំពត់កាសាវៈ ។

បទថា **អវន្តកសាវស្ស** សេចក្តីថា ជាអ្នកមានទឹកចត់ គឺរាគាទិក្កិលេសខ្ជាក់ចោលហើយ មានទឹកចត់ គឺរាគាទិក្កិលេសបោះបង់ចោលហើយ បានដល់មានទឹកចត់ គឺរាគាទិក្កិលេសដែលបោះបង់ហើយដោយមគ្គទាំង ៤ ។

បទថា **សីលេសុ** បានដល់ ក្នុងចតុប្បារិសុទ្ធិសីល ៤ ។

បទថា **សុសមាហិតោ** តម្កល់មាំ គឺតាំងនៅដោយល្អ ។

បទថា **ឧភតោ** សេចក្តីថា ប្រកបដោយការទូន្មានឥន្ទ្រិយ៍ និងវចីសច្ចៈ មានប្រការដូចពោលហើយ ។

បទថា **សវេ** ជាដើម សេចក្តីថា បុគ្គលនោះ គឺបែបនោះ ទើបគួរស្លៀកដណ្តប់សំពត់កាសាវៈនោះ ។

ក្នុងកាលចប់គាថា ភិក្ខុអ្នកនៅក្នុងទិសផ្សេងនោះ បានជាសោតាបន្ន ។ ជនសូម្បីពួកដទៃមានចំនួនច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានសម្រេចប្រយោជន៍ដល់មហាជនដោយប្រការ ដូច្នេះឯង ។

( រឿងព្រះទេវទត្តចប់ )

# ៨ រឿងសញ្ជ័យ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការមិនមកនៃសញ្ជ័យ ( បរិព្វាជក ) ដែលព្រះអគ្គសាវកទាំងពីរអង្គក្រាបទូលហើយ ទ្រង់ត្រាស់ព្រះធម្មទេសនានេះថា “**អសារេ សារមតិនោ**” ជាដើម ។ អនុបុព្វីកថា ក្នុងរឿងសញ្ជ័យនោះ មានដូចតទៅនេះ ៖

## <u>ព្រះសាស្ដាបានទទួលការព្យាករណ៍អំពីព្រះពុទ្ធ ២៣ ព្រះអង្គ</u>

សេចក្ដីពិស្ដារថា ក្នុងទីបំផុត ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប អំពីភទ្ទកប្បនេះទៅ ព្រះសាស្ដារបស់យើងទាំងឡាយ ជាកុមាររបស់ព្រាហ្មណ៍នាមថា សុមេធ នៅក្នុងអមរវតីនគរ ដល់ការសម្រេចសិល្បៈគ្រប់យ៉ាងហើយ ដោយកាលកន្លងទៅនៃមាតា និងបិតា ទ្រង់បរិច្ចាគទ្រព្យរាប់បានច្រើនកោដិ បួសជាឥសីនៅក្នុងហិមវន្តប្រទេស ញ៉ាំងឈាន និងអភិញ្ញាឲ្យកើតហើយ កាលទៅតាមអាកាសឃើញមហាជនដែលកំពុងជម្រះផ្លូវ ដើម្បីជាប្រយោជន៍ដល់កិរិយាស្ដេច

(ចេញ) ចាកសុទស្សនវិហារចូលទៅកាន់អមរវតីនគរ នៃព្រះទស-ពលព្រះនាមថា ទីបង្ករ សូម្បីខ្លួនឯងក៏កាន់យកប្រទេស (កន្លែង) មួយ កាលប្រទេសនោះនៅមិនទាន់សម្រេច,ដេកទ្រាលលើភក់ធ្វើឲ្យជាស្ពានដើម្បីព្រះសាស្តាទ្រង់យាងមកហើយ ដោយប្រាថ្នាថា "សូមឲ្យព្រះសាស្តាព្រមទាំងភិក្ខុសង្ឃសាវកកុំទ្រង់ជាន់លើភក់ សូមទ្រង់ជាន់យើង ស្តេចយាងទៅចុះ" លុះព្រះសាស្តាទ្រង់ឃើញហើយ ក៏ទ្រង់ព្យាករថា "បុគ្គលនេះជា ពុទ្ធង្កូរ នឹងបានជាព្រះពុទ្ធព្រះនាមថាគោតម ក្នុងទីបំផុត ៤ អសង្ខ្យេយ្យ កម្រៃមួយសែនកប្បក្នុងអនាគត" ក្នុងសម័យតមកនៃព្រះសាស្តាព្រះអង្គនោះ ក៏បានទទួលការព្យា-ករណ៍ក្នុងសំណាក់ព្រះពុទ្ធ ២៣ ព្រះអង្គ ដែលស្តេចឧប្បត្តិឡើងញុំាងលោកឲ្យភ្លឺស្វាងហើយ គឺព្រះកោណ្ឌញ្ញៈ ១ ព្រះសុមង្គលៈ ១ ព្រះ-សុមនៈ ១ ព្រះរេវតៈ ១ ព្រះសោភិតៈ ១ ព្រះអនោមទស្សី ១ ព្រះបទុម ១ ព្រះនារទៈ ១ ព្រះបទុមុត្តរៈ ១ ព្រះសុមេធៈ ១ ព្រះសុជាតិ ១ ព្រះបិយទស្សី ១ ព្រះអត្ថទស្សី ១ ព្រះធម្មទស្សី ១

ព្រះសិទ្ធត្ថ ១ ព្រះតិស្សៈ ១ ព្រះបុស្សៈ ១ ព្រះវិបស្សី ១ ព្រះសិខី ១ ព្រះវេស្សភូ ១ ព្រះកកុសន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១” ទ្រង់បំពេញបារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ (កាល) ឋិតនៅក្នុងអត្តភាពជាព្រះវេស្សន្តរទ្រង់ឲ្យមហាទាន ដែលធ្វើឲ្យផែនដីកម្រើក ៧ ដង ទ្រង់បរិច្ចាគព្រះឱរស និងព្រះជយា, ក្នុងទីបំផុតព្រះជន្មាយុ ក៏ទ្រង់បដិសន្ធិក្នុងតុសិតបុរី ឋិតនៅក្នុងតុសិតបុរីនោះរហូតអស់ព្រះជន្មាយុ, កាលទេវតាក្នុងម៉ឺនចក្រវាឡប្រជុំគ្នាអារាធនាថា ៖

“បពិត្រព្រះមហាវីរៈ កាលនេះ ជាកាលរបស់ព្រះអង្គហើយ សូមព្រះអង្គស្ដេចបដិសន្ធិក្នុងព្រះគភ៌នៃព្រះមាតា ត្រាស់ដឹងអមតបទ ញ៉ាំងលោកនេះ និងទេវលោកឲ្យឆ្លង ” ។

ទ្រង់ប្រមើលមើលនូវឋានៈធំៗដែលគួរប្រមើលមើល ៥ស្ដេចចុតិអំពីតុសិតបុរីនោះហើយ ទ្រង់បដិសន្ធិក្នុងសក្យត្រកូល ដែលពួកព្រះញាតិបម្រើដោយមហាសម្បត្តិក្នុងសក្យត្រកូលនោះ ទ្រង់ដល់នូវ

ការចម្រើនវ័យដោយលំដាប់ សោយសិរីរាជសម្បត្តិក្នុងប្រាសាទទាំង ៣ ដែលសមគួរដល់រដូវទាំង ៣ ដូចសិរីសម្បត្តិក្នុងទេវលោក ។

## ទ្រង់ឃើញទេវទូតហើយស្តេចបព្វជ្ជា

ក្នុងសម័យដែលស្តេចយាងទៅដើម្បីក្រសាលព្រះឧទ្យាន ក៏ទ្រង់ឃើញទេវទូត ៣ ពោលគឺមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ដោយលំដាប់ ទ្រង់កើតការសង្វេគ ហើយក៏ទ្រង់ត្រឡប់ទៅកាន់ប្រាសាទវិញ ។ ក្នុងថ្ងៃទី ៤ ទ្រង់ឃើញបព្វជិត ញុំាងសេចក្តីពេញព្រះហឫទ័យឲ្យកើតឡើងថា " ការបព្វជ្ជាល្អ " ស្តេចយាងទៅកាន់ឧទ្យាន ញុំាងថ្ងៃឲ្យអស់ទៅក្នុងឧទ្យាននោះ ទ្រង់គង់ក្បែរមាត់ស្រះបោក្ខរណីដែលជាមង្គល ដែលវេស្សកម្មទេវបុត្រ ក្លែងភេទជាជាងខ្មាន់ព្រះកែសមកប្រដាប់តុបតែង ថ្វាយទ្រង់ព្រះសណ្តាប់នូវព្រះរាជសាសន៍ថា "ព្រះរាហុលប្រសូតហើយ ទ្រង់ជ្រាបដល់សេចក្តីស្នេហាក្នុងបុត្តជាសភាពមានកម្លាំង" ទ្រង់ព្រះតម្រិះថា "យើងនឹងកាត់ចំណងនេះ កុំឲ្យជាគ្រឿងចង ( យើង ) បាន" វេលារសៀលស្តេចយាងចូល

ទៅកាន់ព្រះនគរ ទ្រង់ព្រះសណ្តាប់នូវគាថានេះ ដែលធីតារបស់ព្រះមាតុច្ឆា ព្រះនាមថា កិសាគោតមី ភាសិតថា ៖

“ព្រះរាជកុមារនេះ ជាព្រះរាជឱរសរបស់ព្រះមាតា និង បិតា និងជាព្រះស្វាមីរបស់ព្រះនាងណាៗ ព្រះមាតា ព្រះបិតា និងព្រះនាងនោះៗរលត់ (ត្រជាក់ចិត្ត) ដោយពិតប្រាកដ ” ។

ទ្រង់គិតថា “យើងដែលព្រះនាងគោតមីនេះ (សូធ្យ) ឲ្យបានឮនិព្វុតបទហើយ ទើបដោះសង្វារជាវិការនៃកែវមុក្តាអំពីព្រះសុរង ទ្រង់ប្រទានឲ្យដល់ព្រះនាងកិសាគោតមី ហើយស្តេចចូលកាន់ក្រឡាព្រះបន្ទំរបស់ព្រះអង្គ ទ្រង់គង់លើទីព្រះបន្ទំដ៏មានសិរី ទ្រង់ទតឃើញប្រការដែលប្លែករបស់ស្ត្រីរបាំដែលចូលដល់ការដេកលក់ហើយ ទ្រង់មានព្រះហឫទ័យនឿយណាយ ទើបដាស់នាយឆន្នមាត្យឲ្យក្រោកឡើង ហើយត្រាស់ឲ្យនាំយកសេះគន្ធកៈមក ស្តេចឡើងកាន់សេះ គន្ធកៈ ទ្រង់មានឆន្នមាត្យជាគ្នា ដែលទេវតាម៉ឺនចក្រវាឡចោមរោមហើយ

ស្តេចចេញមហាភិនេស្រ្កម ទ្រង់បព្វជ្ជានៅក្បែរឆ្នេរស្ទឹងអនោមា, ស្តេចត្រាច់យាងទៅដល់ក្រុងរាជគ្រឹះដោយលំដាប់ ស្តេចត្រាច់បិណ្ឌ-បាតក្នុងក្រុងរាជគ្រឹះនោះ ទ្រង់គង់នៅនាញកភ្នំឈ្មោះបណ្ឌវៈ ដែលព្រះរាជានៃដែនមគធៈទ្រង់អញ្ជើញដោយរាជសម្បត្តិ ទ្រង់បដិសេធនូវពាក្យអញ្ជើញនោះ ទ្រង់ទទួលបេ្តជ្ញាអំពីព្រះរាជាក្នុងដែនមគធៈអង្គនោះដើម្បីប្រយោជន៍ដល់ការបានសម្រេចសព្វញ្ញុតញ្ញាណហើយ និងស្តេចយាងមកកាន់ដែនរបស់ព្រះអង្គ ស្តេចចូលទៅរកអាឡារតាបសនិងឧទកតាបស ទ្រង់មិនពេញព្រះហឫទ័យនូវគុណវិសេសដែលទ្រង់បានសម្រេចក្នុងសំណាក់តាបសទាំងពីរនោះ ទ្រង់តាំងសេចក្តីព្យា-យាមដ៏ធំ អស់ ៦ ឆ្នាំ ។

## ទ្រង់សម្រេចសព្វញ្ញុតញ្ញាណហើយទ្រង់សម្តែងធម៌

ក្នុងថ្ងៃវិសាខបុណ្ណមីព្រឹកព្រលឹម ទ្រង់សោយបាយបាយាសដែលនាងសុជាតាថ្វាយហើយ ទ្រង់បណ្តែតថាសមាសក្នុងស្ទឹងនេរញ្ជរាញ៉ាំងកាលជាចំណែកនៃថ្ងៃឲ្យកន្លងទៅដោយសមាបត្តិផ្សេងៗ ក្នុងជង

ព្រៃធំក្បែរស្ទឹងនេរញ្ជរា, វេលាល្ងាចទ្រង់ទទួលស្មៅ ( ស្បូវ ) ដែលព្រាហ្មណ៍ឈ្មោះសោត្ថិយថ្វាយ ទ្រង់មានព្រះគុណដែលស្ដេចនាគ-រាជឈ្មោះកាឡសរសើរហើយ ស្ដេចយាងទៅកាន់មណ្ឌលពោធិព្រឹក្សទ្រង់ធ្វើនូវការប្ដេជ្ញាថា "យើងនឹងមិនទម្លាយបល្ល័ង្កនេះដរាបណាដែលចិត្តរបស់យើងនៅមិនទាន់រួចផុតចាកអាសវៈទាំងឡាយ ដោយការមិនចូលទៅប្រកាន់មាំ" ទ្រង់គង់បែរព្រះភក្ត្រទៅកាន់ទិសបូព៌ា ( ទិសខាងកើត) កាលព្រះអាទិត្យនៅមិនទាន់អស្ដង្គត, ទ្រង់កម្ចាត់បង់នូវមារនិងពលមារបាន, ទ្រង់សម្រេចបុព្វេនិវាសញ្ញាណក្នុងបឋមយាម, បានសម្រេចចុតូបបាតញ្ញាណក្នុងមជ្ឈិមយាម, ញុំាំងព្រះញាណឲ្យចុះក្នុងបច្ចយាការក្នុងបច្ឆិមយាម, ក្នុងវេលាអរុណរះឡើង ទ្រង់បានសំរេចនូវសព្វញ្ញុតញ្ញាណ ដែលប្រដាប់ដោយគុណគ្រប់យ៉ាង មានទសពលញ្ញាណ និងចតុវេសារជ្ជញ្ញាណជាដើម ទ្រង់ញុំាំងកាលឲ្យកន្លងទៅក្នុងពោធិមណ្ឌលអស់ ៧ សប្ដាហ៍, ក្នុងសប្ដាហ៍ទី ៨ ទ្រង់គង់នៅនាគល់នៃដើមជ្រៃ ទ្រង់ដល់ភាពជាអ្នកខ្វល់ខ្វាយតិច ដោយពិចារណា

ឃើញថា ធម៌ជាសភាពជ្រាលជ្រៅដែលសហម្បតីព្រហ្ម មានមហាព្រហ្មមួយម៉ឺនជាបរិវារអារាធនាឲ្យទ្រង់សម្ដែងធម៌ ទ្រង់ពិចារណាមើលសត្វលោកដោយពុទ្ធចក្ខុហើយ ទ្រង់ទទួលពាក្យអារាធនារបស់ព្រហ្ម ទ្រង់ប្រមើលមើលថា "យើងគប្បីសម្ដែងធម៌ដល់នរណាជាដំបូង" ទ្រង់ជ្រាបថា អាឡារតាបស និងឧទកតាបសធ្វើមរណកាលហើយ ទ្រង់ត្រឡប់រឭកដល់ឧបការៈច្រើនរបស់បញ្ចវគ្គិយភិក្ខុ ទ្រង់ក្រោកចាកអាសនៈយាងទៅកាន់កាសីបុរី ក្នុងចន្លោះផ្លូវបានសន្ទនាជាមួយនឹងឧបកាជីវក ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ស្ដេចយាងដល់លំនៅរបស់បញ្ចវគ្គិយភិក្ខុនៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ញុំាងបញ្ចវគ្គិយភិក្ខុទាំងនោះដែលហៅ ( ព្រះអង្គ ) ដោយពាក្យដែលមិនសមគួរឲ្យដឹងខ្លួនហើយ កាលនឹងញុំាងព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធានឲ្យផឹកអមតៈ ទើបទ្រង់សម្ដែងធម្មចក្ក ទ្រង់មានធម្មចក្កដ៏បវរដែលឲ្យប្រព្រឹត្តទៅហើយ, ក្នុងតិថិទី ៥ នៃបក្ខ ទ្រង់ញុំាងភិក្ខុទាំងអស់នោះឲ្យតាំងនៅក្នុងព្រះអរហត្ត, ក្នុងថ្ងៃមួយជាមួយ

គ្នានោះ ទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់យសកុលបុត្ត ហើយទ្រង់ត្រាស់ហៅគេដែលជាអ្នកនឿយណាយ លះបង់ផ្ទះចេញមកក្នុងវេលាយប់ថា "មកណេះចុះយស" ធ្វើគេឲ្យសម្រេចសោតាបត្តិផលក្នុងវេលាយប់នោះឯង ក្នុងថ្ងៃស្អែកឡើង ទើបឲ្យសម្រេចព្រះអរហត្ត ទ្រង់ញ៉ាំងសម្លាញ់របស់យស ៥៤ នាក់ដទៃទៀតឲ្យបព្វជ្ជា ដោយឯហិភិក្ខុឧបសម្បទា ហើយឲ្យបានសម្រេចព្រះអរហត្ត ។

## ព្រះសាស្ដាទ្រង់បញ្ជូនសាវកទៅប្រកាសព្រះសាសនា

កាលព្រះអរហន្តកើតឡើងក្នុងលោក ៦១ ព្រះអង្គដោយប្រការយ៉ាងនេះហើយ, ព្រះសាស្ដាស្ដេចនៅចាំវស្សា បវារណាហើយទ្រង់បញ្ជូនភិក្ខុ ៦០ រូបទៅកាន់ទិសទាំងឡាយដោយព្រះពុទ្ធតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរត្រាច់ទៅកាន់ចារិកចុះ" ដូច្នេះជាដើម ។ ចំណែកព្រះអង្គទ្រង់យាងទៅកាន់ឧរុវេលាប្រទេស ក្នុងចន្លោះផ្លូវ បានទ្រង់សម្ដែងធម៌ប្រោសភទ្ទវគ្គិយកុមារ ៣០ នាក់ នៅក្នុងដងព្រៃកប្បាសិកាវន, បណ្ដាភទ្ទវគ្គិយកុមារ ៣០ រូបនោះ យ៉ាងទាបជាង

គេបន្ទន់បានជាសោតាបន្ន, ខ្ពស់ជាងគេបន្ទន់បានជាព្រះអនាគាមី ។ ព្រះអង្គទ្រង់ឲ្យកុលបុត្តិយទាំងអស់នោះបព្វជ្ជាដោយ ឯហិភិក្ខុភាវៈ ដូចគ្នាហើយ ទ្រង់បញ្ជូនទៅកាន់ទិសទាំងឡាយ, ចំណែកព្រះអង្គស្តេចយាងទៅកាន់ឧរុវេលាប្រទេស ទ្រង់សម្តែងបាដិហារិយ៍ ៣៥ ប្រការ ទូន្មានជដិលបីនាក់បងប្អូន ដែលមានជដិល ១០០០ នាក់ជាបរិវារ មានឧរុវេលាកស្សបជាដើមឲ្យបព្វជ្ជាដោយឯហិភិក្ខុភាវៈដូចគ្នាហើយ ឲ្យប្រជុំគ្នានៅក្នុងគយាសីសប្រទេស ឲ្យតាំងនៅក្នុងព្រះអរហត្តដោយអាទិត្តបរិយាយទេសនា ហែហមដោយព្រះអរហន្តមួយពាន់អង្គនោះ ស្តេចយាងទៅកាន់ឧទ្យានលដ្ឋិវ័នជិតព្រះនគររាជគ្រឹះ ដោយទ្រង់ព្រះតម្រិះថា "នឹងដោះពាក្យប្តេជ្ញាដែលថ្វាយទុកដល់ព្រះបាទពិម្ពិសារ" ទ្រង់ត្រាស់ព្រះធម្មកថាដ៏ពីរោះដល់ព្រះរាជា អ្នកទ្រង់ព្រះសណ្តាប់ដំណឹងថា "ព្រះសាស្តាស្តេចយាងមកហើយ" ស្តេចមកគាល់ព្រមទាំងព្រាហ្មណ៍ និងគហបតី ១២ នហុត[១] ញ៉ាំងព្រះរាជាព្រមទាំងព្រាហ្មណ៍ និងគហបតី

[១] ១ នហុត = ១០,០០០ នាក់

១១ នហុតឲ្យតាំងនៅក្នុងសោតាបត្តិផល ១ នហុតទៀតឲ្យតាំងនៅក្នុងសរណៈ ៣, ថ្ងៃស្អែកឡើងមានព្រះគុណដែលស្ដេចទេវរាជទ្រង់ក្មេងភេទជាមាណពសរសើរហើយ ស្ដេចយាងចូលទៅកាន់ព្រះនគររាជគ្រឹះ ទ្រង់ធ្វើភត្តកិច្ចក្នុងព្រះរាជនិវេសន៍ ទ្រង់ទទួលវេឡុវនារាម ទ្រង់គង់នៅក្នុងវេឡុវនារាមនោះឯង ។ ព្រះសារីបុត្ត និងព្រះមោគ្គល្លានចូលទៅគាល់ព្រះអង្គក្នុងវេឡុវនារាមនោះ ។

## អនុបុព្វីកថាក្នុងរឿងព្រះសារីបុត្រ និងព្រះមោគ្គល្លាននោះមានដូចតទៅនេះ

សេចក្ដីពិស្ដារថា កាលព្រះពុទ្ធជាម្ចាស់មិនទាន់ទ្រង់ឧប្បត្តិឡើងនោះឯង បានមានស្រុកព្រាហ្មណ៍ពីរតំបន់ គឺឧបតិស្សគ្រាម ១ កោលិតគ្រាម ១ ក្នុងទីមិនឆ្ងាយពីក្រុងរាជគ្រឹះ ។ ក្នុងបណ្ដាស្រុកទាំងពីរនោះ ក្នុងថ្ងៃដែលនាងព្រាហ្មណីឈ្មោះសារីនៅក្នុងឧបតិស្សគ្រាមតាំងគភ៌នោះឯង ។ សូម្បីនាងព្រាហ្មណីឈ្មោះមោគ្គល្លីដែលនៅក្នុងកោលិតគ្រាមក៏តាំងគភ៌ដែរ ។ បានឮមកថា ត្រកូលទាំងពីរនោះបាន

ជាសម្លាញ់នឹងគ្នាជាប់តមករហូតដល់ ៧ ជួរត្រកូល ។ ព្រាហ្មណ៍ដែលជាស្វាមីបានឲ្យវិធីបរិហារគព៌ដល់ព្រាហ្មណីទាំងពីរនោះ ក្នុងថ្ងៃតែមួយដូចគ្នា ។ ដោយកាលកន្លងទៅ ១០ ខែ នាងព្រាហ្មណីទាំងពីរនោះក៏ប្រសូតបុត្រ ។ ក្នុងថ្ងៃដាក់ឈ្មោះពួកញាតិដាក់ឈ្មោះបុត្ររបស់សារីព្រាហ្មណីថា "ឧបតិស្សៈ" ព្រោះជាបុត្រនៃត្រកូលមេស្រុកក្នុងឧបតិស្សគ្រាម, ដាក់ឈ្មោះបុត្ររបស់មោគ្គល្លីព្រាហ្មណីថា "កោលិតៈ" ព្រោះជាបុត្រនៃត្រកូលមេស្រុកក្នុងកោលិតគ្រាម ។ ក្មេងទាំងពីរនោះដល់ការចម្រើនវ័យហើយ បានដល់ការសម្រេចសិល្បៈគ្រប់យ៉ាង ។ ក្នុងវេលាទៅកាន់ស្ទឹង ឬស្ទួនដើម្បីប្រយោជន៍ដល់ការលេងឧបតិស្សមាណពមានអង្រឹងស្នែងជាវិការនៃមាស ៥០០ គ្រឿងហែហម, កោលិតៈមានរថទឹមដោយសេះអាជានេយ្យ ៥០០ ជាគ្រឿងហែហមការពារ, ជនទាំងពីរមានមាណពជាបរិវារម្នាក់ៗ ៥០០ ។ ក៏ក្នុងក្រុងរាជគ្រឹះមានមហោស្រពលើកំពូលភ្នំរៀងរាល់ឆ្នាំ ។ ពួកញាតិបានលើកគ្រែតម្រួតគ្នាដើម្បីកុមារទាំងពីរនោះ ក្នុងទីជាមួយគ្នានោះឯង ។

សូម្បីកុមារទាំងពីរក៏អង្គុយមើលមហោស្រពរួមគ្នា រមែងសើចក្នុងឋានៈដែលគួរសើច រមែងដល់ការស្លុតចិត្តក្នុងឋានៈដែលគួរស្លុតចិត្ត រមែងឲ្យរង្វាន់ក្នុងឋានៈដែលគួរឲ្យរង្វាន់ ។ ថ្ងៃមួយកាលកុមារទាំងពីរនាក់នោះមើលមហោស្រពដោយទំនងនេះ ការសើចក្នុងឋានៈដែលគួរសើច ឬការស្លុតចិត្តក្នុងឋានៈដែលគួរស្លុតចិត្ត ឬការឲ្យរង្វាន់ក្នុងឋានៈដែលគួរឲ្យរង្វាន់ មិនបានមានហើយដូចក្នុងថ្ងៃមុនៗ ព្រោះញាណដល់ការចាស់ក្លាហើយ ។ ក៏ជនទាំងពីរគិតយ៉ាងនេះថា “នឹងមានអ្វីទៅ ? ដែលគួរមើលក្នុងមហោស្រពហ្នឹង, ជនទាំងអស់នេះកាលមិនទាន់ដល់ ១០០ ឆ្នាំ, ក៏នឹងដល់ភាពជាភាវៈរកបញ្ញត្តិមិនបាន, យើងទាំងពីរនាក់គួរស្វែងរកធម៌ដែលជាគ្រឿងរួចផុតយ៉ាងឯក” ដូច្នេះហើយកាន់យកជាអារម្មណ៍អង្គុយនៅហើយ ។លំដាប់នោះកោលិតៈនិយាយនឹងឧបតិស្សៈថា “ឧបតិស្សសម្លាញ់ ហេតុដូចម្ដេចអ្នកទើបមិនសើចរីករាយដូចក្នុងថ្ងៃដទៃៗ ថ្ងៃនេះអ្នកមានចិត្តមិនរីករាយស្រស់ស្រាយ អ្នកកំណត់អ្វីបានឬ ? ឧបតិស្សៈនោះពោលថា “ម្នាលកោលិតៈសម្លាញ់

យើងអង្គុយគិតដល់ហេតុនេះថា ក្នុងការមើលមនុស្សទាំងនេះ មិនជាសារៈ, ការមើលនេះមិនមានប្រយោជន៍, យើងគួរស្វែងរកមោក្ខធម៌ដើម្បីខ្លួន សម្លាញ់ឯងព្រោះហេតុអ្វីទើបមិនរីករាយស្រស់ស្រាយ" ។ សូម្បីកោលិតៈនោះក៏ប្រាប់ដូច្នោះដែរ ។ គ្រានោះ ឧបតិស្សៈដឹងនូវភាវៈនៃកោលិតៈនោះជាអ្នកមានអធ្យាស្រ័យដូចខ្លួន ទើបពោលថា "សម្លាញ់អើយ យើងទាំងពីរគិតគ្នាល្អហើយ, ក៏យើងគួរស្វែងរកមោក្ខធម៌, ធម្មតាអ្នកស្វែងរកមោក្ខធម៌ ត្រូវតែបព្វជ្ជាមួយប្រភេទប៉ុណ្ណោះទើបគួរ, យើងទាំងពីរនឹងបព្វជ្ជាក្នុងសំណាក់បុគ្គលណាទៅ" ?

## សម្លាញ់ពីរនាក់ដាក់កតិកាគ្នា

ក៏ដោយសម័យនោះឯង សញ្ជ័យបរិព្វាជកអាស្រ័យនៅក្នុងក្រុងរាជគ្រឹះជាមួយបរិព្វាជកបរិស័ទមួយពួកធំ សារីបុត្រ និងមោគ្គល្លានទាំងពីរនោះ សម្រេចគ្នាថា "យើងនឹងបួសក្នុងសំណាក់លោកសញ្ជ័យនោះ" ម្នាក់ៗបញ្ជូនមាណព ៥០០ ទៅដោយពាក្យថា "អ្នកទាំងឡាយចូរយកអង្រឹងស្នែង និងរថនេះទៅចុះ" ព្រមទាំងមាណព

៥០០ បួសហើយក្នុងសំណាក់សញ្ជ័យ ។ ចាប់ផ្ដើមពីគេទាំងពីរនាក់បួសហើយសញ្ជ័យក៏បានដល់ការលើសដោយលាភ និងយសយ៉ាងខ្លាំង ។ គេទាំងពីរនាក់រៀនចប់លទ្ធិសម័យរបស់សញ្ជ័យតែពីរបីថ្ងៃប៉ុណ្ណោះ ទើបសួរថា "លោកអាចារ្យលទ្ធិដែលលោកចេះមានតែប៉ុណ្ណោះ ឬមានច្រើនជាងនេះទៀត ? កាលសញ្ជ័យឆ្លើយថា "មានតែប៉ុណ្ណោះឯង, អ្នកទាំងពីរចេះចប់អស់ហើយ" ។ គេទាំងពីរទើបគិតគ្នាថា "កាលបើយ៉ាងនេះ ការនៅប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់របស់លោកនេះក៏មិនមានប្រយោជន៍ យើងទាំងពីរចេញមកដើម្បីស្វែងរកមោក្ខធម៌, មោក្ខធម៌នោះ យើងមិនអាចឲ្យកើតឡើងបានក្នុងសំណាក់របស់លោកអាចារ្យនេះទេ, ជម្ពូទ្វីបនេះធំណាស់ យើងត្រាច់ទៅកាន់គាមនិគមជនបទ និងរាជធានី គង់នឹងបានអាចារ្យអ្នកសម្ដែងមោក្ខធម៌ម្នាក់ជាពិតប្រាកដ " ចាប់តាំងពីនោះមក នរណានិយាយក្នុងទីណាៗថា "សមណព្រាហ្មណ៍ដែលជាបណ្ឌិតមាន" គេទាំងពីរនាក់រមែងចូលទៅធ្វើការសន្ទនាសាកសួរក្នុងទីនោះៗ បញ្ហាដែលគេទាំងពីរសួរទៅ

អាចារ្យពួកដទៃមិនអាចឆ្លើយបាន, តែគេទាំងពីររមែងដោះស្រាយបញ្ហារបស់អាចារ្យទាំងនោះបាន ។ គេទាំងពីរនាក់ដើរសាកសួរទូទៅពេញជម្ពូទ្វីបយ៉ាងនោះហើយ ក៏ត្រឡប់មកកាន់លំនៅរបស់ខ្លួនទើបធ្វើកតិកាគ្នាថា "ម្នាលកោលិតៈសម្លាញ់ ក្នុងបណ្តាយើងទាំងពីរនាក់ អ្នកណាបានសម្រេចអមតធម៌មុន អ្នកនោះចូរប្រាប់ "ដល់គ្នា" ។

កាលគេទាំងពីរនាក់ដាក់កតិកាគ្នាយ៉ាងនោះ ព្រះសាស្តាស្តេចយាងដល់ក្រុងរាជគ្រឹះដោយលំដាប់ដូចដែលពោលមកហើយ ទ្រង់ទទួលវេឡុវ័នហើយ ទ្រង់គង់នៅក្នុងវេឡុវ័ន ។ ក្នុងកាលនោះ ព្រះ-អស្សជិត្ថេរ ក្នុងចំណោមព្រះបញ្ចវគ្គីយ៍រវាងព្រះអរហន្ត ៦១ អង្គដែលព្រះសាស្តាទ្រង់បញ្ជូនទៅដើម្បីប្រកាសគុណព្រះរតនត្រៃដោយព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរចារិកទៅដើម្បីប្រ-យោជន៍ដល់ជនជាច្រើនចុះ ។ ត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ថ្ងៃស្អែកឡើង លោកកាន់បាត្រ និងចីវរទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាតពីព្រឹកព្រលឹម ។

សម័យនោះ ឧបតិស្សបរិព្វាជក ធ្វើកត្តកិច្ចពីព្រឹកព្រលឹម ហើយទៅកាន់អារាមរបស់បរិព្វាជកជួបព្រះថេរៈ ទើបគិតថា អ្នកបួសបែបនេះយើងមិនធ្លាប់បានជួបសោះ, ភិក្ខុរូបនេះ ( គង់ ) ជាមនុស្សម្នាក់បណ្តាអ្នកដែលជាព្រះអរហន្ត ឬអ្នកសម្រេចព្រះអរហត្តមគ្គក្នុងលោក, ដូចម្តេចហ្ន៎ ទើបយើងបានចូលទៅរកភិក្ខុនេះ ហើយសួរថា "បពិត្រលោកម្ចាស់ លោកម្ចាស់បួសឧទ្ទិសចំពោះនរណា ? នរណាជាសាស្តារបស់លោកម្ចាស់ ? ឬថាលោកម្ចាស់ពេញចិត្តធម៌របស់នរណា" ?

គ្រានោះ ការត្រិះរិះនេះបានមានដល់ឧបតិស្សៈថា "កាលនេះមិនមែនកាលគួរសួរបញ្ហានឹងភិក្ខុនេះទេ, ភិក្ខុនេះកំពុងចូលទៅកាន់ចន្លោះស្រុកត្រាច់បិណ្ឌបាត, បើដូច្នោះ យើងកាលស្វែងរកមោក្ខធម៌ដែលបុគ្គលអ្នកមានសេចក្តីត្រូវការដឹង ហើយគួរតែជាប់តាមភិក្ខុរូបនេះទៅខាងក្រោយៗ" ។ គេឃើញព្រះថេរៈបានបិណ្ឌបាតហើយទៅកាន់ឱកាសមួយ ហើយដឹងថាព្រះថេរៈនោះប្រាថ្នានឹងគង់ ទើបបាន

ចាត់ចែងតាំងរបស់បរិញ្វាជកសម្រាប់ខ្លួនប្រគេន ។ សូម្បីក្នុងវេលាដែលលោកឆាន់ស្រេចហើយ ក៏បានប្រគេនទឹកក្នុងកំសៀវរបស់ខ្លួនដល់ព្រះថេរៈ ។ លុះធ្វើអាចរិយវត្តយ៉ាងនោះហើយ ទើបធ្វើបដិសណ្ឋារយ៉ាងចាប់ចិត្តនឹងព្រះថេរៈដែលឆាន់ស្រេចហើយ ក៏សួរយ៉ាងនេះថា "បពិត្រលោកម្ចាស់ ឥន្ទ្រីយ៍របស់លោកម្ចាស់ផូរផង់ក្រៃលែងណាស់ ពណ៌សម្បុរបរិសុទ្ធផូរផង់, លោកម្ចាស់បួសឧទ្ទិសចំពោះបុគ្គលណា ? បុគ្គលណាជាសាស្តារបស់លោកម្ចាស់ ? ម្យ៉ាងវិញទៀត លោកម្ចាស់គាប់ចិត្តនឹងធម៌របស់បុគ្គលណា ?

## ព្រះអស្សជិសម្តែងបេះដូងព្រះសាសនា

ព្រះថេរៈគិតថា "ធម្មតាបរិញ្វាជកនេះ រមែងជាបដិបក្ខចំពោះព្រះសាសនា, យើងនឹងសម្តែងជម្រៅក្នុងព្រះសាសនាដល់បរិញ្វាជកនេះ" ។

កាលនឹងសម្តែងការដែលខ្លួនបួសថ្មី ទើបពោលថា "ម្នាលអ្នកដ៏មានអាយុ យើងជាអ្នកថ្មី ទើបបួសហើយអស់កាលមិនយូរ ទើប

តែមកកាន់ធម្មវិន័យនេះ, យើងនឹងមិនអាចសម្ដែងធម៌ឲ្យពិស្ដារបានទេ” ។ បរិព្វាជកប្រាប់ថា “ខ្ញុំព្រះករុណាឈ្មោះឧបតិស្សៈ សូមលោកម្ចាស់ពោលតាមសមត្ថភាពចុះ ទោះតិច ឬច្រើនក៏ដោយ សេចក្ដីនុ៎ះជាភារៈរបស់ខ្ញុំករុណា ដើម្បីចាក់ធ្លុះដោយន័យមួយរយ ឬមួយពាន់ន័យ” ដូច្នេះហើយ ពោលថា ៖

“ទោះតិច ឬច្រើនក៏ដោយ សូមលោកម្ចាស់សម្ដែងមកចុះ, ចុះ ចូរប្រាប់ដល់ខ្ញុំម្ចាស់តែសេចក្ដីប៉ុណ្ណោះ, ខ្ញុំម្ចាស់ត្រូវការអត្ថ និងព្យញ្ជនៈច្រើនបានប្រយោជន៍អ្វី ” ។

កាលឧបតិស្សៈពោលយ៉ាងនោះហើយ ព្រះថេរៈទើបពោលគាថាថា ៖

“ធម៌ទាំងឡាយ មានហេតុជាដែនកើត ព្រះតថាគតទ្រង់ត្រាស់សម្ដែងនូវហេតុនៃធម៌ទាំងនោះ និងហេតុនៃការរំលត់នូវធម៌ទាំងនោះ ព្រះមហាសមណៈមានប្រប្រតីពោលយ៉ាងនេះ” ។

## ឧបតិស្សៈ និង កោលិតៈសម្រេចព្រះសោតាបន្ន

បរិញ្វាជកស្តាប់ត្រឹមតែពីរបទខាងដើមប៉ុណ្ណោះ ក៏តាំងនៅក្នុងសោតាបត្តិផលដែលដល់ព្រមដោយន័យមួយពាន់, ព្រះថេរៈញុំាងបាទព្រះគាថាពីរបទក្រៅនេះឲ្យចប់ទៅ ក្នុងកាលដែលគេជាព្រះ-សោតាបន្ន ។ គេជាព្រះសោតាបន្នហើយ កាលគុណវិសេសថ្នាក់ខ្ពស់មិនទាន់បានប្រព្រឹត្តទៅ, ក៏កំណត់ថា "ហេតុក្នុងវត្ថុនេះ នឹងមានទើបពោលនឹងព្រះថេរៈថា "បពិត្រលោកដ៏មានអាយុ សូមលោក-ម្ចាស់កុំអាលបង្កើននូវធម្មទេសនាខាងលើអី កិច្ចទេសត្រឹមប៉ុណ្ណឹងចូរស្ងេះសិនចុះ, ព្រះសាស្តារបស់ពួកយើងព្រះអង្គគង់នៅទីណា" ? ព្រះថេរៈឆ្លើយថា "ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន" គេប្រាប់ថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តទៅមុនចុះ ខ្ញុំម្ចាស់មានសម្លាញ់ម្នាក់ទៀត ហើយខ្ញុំម្ចាស់ទាំងពីរនាក់ បានដាក់កតិកាគ្នានិងគ្នាទុកថា អ្នកណាបានសម្រេចអមតៈមុន អ្នកនោះចូរប្រាប់ដល់គ្នា, ខ្ញុំម្ចាស់ដោះពាក្យបេ្តជ្ញានោះហើយ នឹងនាំសម្លាញ់ទៅកាន់សំណាក់ព្រះសាស្តា

តាមដែលលោកទៅហើយនោះឯង” ដូច្នេះហើយ ថ្វាយបង្គំបាទាទាំងពីររបស់ព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ធ្វើប្រទក្សិណ ៣ ជុំ បញ្ជូនព្រះថេរៈទៅហើយ បានត្រឡប់ទៅកាន់អារាមរបស់បរិព្វាជក ។ ក៏កោលិតបរិព្វាជក ឃើញឧបតិស្សៈមកអំពីចម្ងាយគិតថា “ថ្ងៃនេះទឹកមុខរបស់សម្លាញ់យើងមិនដូចក្នុងថ្ងៃដទៃៗ គេគង់នឹងបានសម្រេចអមតៈដោយពិតប្រាកដ ទើបសួរដល់ការសម្រេចអមតៈ” ។ សូម្បីឧបតិស្សបរិព្វាជកនោះក៏ទទួលថា “អើ សម្លាញ់ អមតៈយើងបានសម្រេចហើយ” បានភាសិតគាថាទាំងនោះឯងដល់កោលិតបរិព្វាជកនោះ ។

ក្នុងកាលចប់គាថា កោលិតៈតាំងនៅក្នុងសោតបត្តិផលហើយ ទើបពោលថា ម្នាលសម្លាញ់ “ព្រះសាស្តារបស់ពួកយើងគង់នៅទីណា ?

ឧ. គង់នៅក្នុងវត្តវេឡុវ័ន សម្លាញ់ ដំណឹងនេះព្រះអស្សជិ-ត្ថេរ ជាព្រះអាចារ្យរបស់យើងបានប្រាប់ហើយ ។

ក. ម្នាលសម្លាញ់ បើដូច្នោះ យើងទៅគាល់ព្រះសាស្តាចុះ ។

## ឧបតិស្សៈ និង កោលិតៈបបួលសញ្ជ័យ ទៅគាល់ព្រះសាស្តា

ក៏ធម្មតាព្រះសារីបុត្តត្ថេរនេះ រមែងជាអ្នកបូជាអាចារ្យសូម្បី ក្នុងកាលគ្រប់កាល ព្រោះដូច្នោះ ទើបពោលនឹងសម្លាញ់យ៉ាងនេះថា “ម្នាលសម្លាញ់ យើងនឹងប្រាប់អមតៈ ដែលយើងទាំងពីរបានសំរេច ដល់សញ្ជ័យបរិព្វាជក ដែលជាអាចារ្យរបស់យើងខ្ទះ, លោកដឹងក៏ នឹងចាក់ធ្លុះ, កាលមិនចាក់ធ្លុះ, ជឿពួកយើងហើយនឹងទៅកាន់សំណាក់ ព្រះសាស្តា, ស្តាប់ទេសនារបស់ពុទ្ធបុគ្គលទាំងឡាយហើយនឹងធ្វើ ការចាក់ធ្លុះនូវមគ្គ និងផល ” ។

ខណៈនោះ ឧបតិស្សបរិព្វាជក និងកោលិតបរិព្វាជកទាំងពីរ នាក់ក៏បានទៅកាន់សំណាក់របស់សញ្ជ័យ ។ សញ្ជ័យលុះបានឃើញ គេក៏សួរថា “ម្នាលអ្នកទាំងពីរ អ្នកទាំងពីរបានអ្នកណាសម្តែងផ្លូវអមតៈ ឲ្យហើយឬ ? សម្លាញ់ទាំងពីរទើបប្រាប់ថា បានហើយលោកអាចារ្យ ព្រះពុទ្ធស្តេចឧប្បត្តិឡើងហើយក្នុងលោក ព្រះធម៌ក៏ឧប្បត្តិឡើងហើយ,

ព្រះសង្ឃក៏ឧប្បត្តិឡើងហើយ, លោកអាចារ្យប្រព្រឹត្តធម៌ទទេ មិនមានសារៈ អញ្ជើញលោកអាចារ្យមកចុះ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះសាស្ដា ” ។

ស. អ្នកទាំងពីរទៅចុះ ខ្ញុំមិនអាចទេ ។

សំ. ព្រោះហេតុអ្វី ?

ស. យើងធ្លាប់ជាអាចារ្យរបស់មហាជនហើយ, ការនៅជាអន្តេវាសិករបស់យើងនោះ ដូចជាការរញ្ជួយនៃទឹកក្នុងពាង, យើងមិនអាចនៅជាអន្តេវាសិកបានទេ ។

សំ. លោកអាចារ្យកុំធ្វើយ៉ាងនោះឡើយ ។

ស. ណ្ហើយចុះ បា អ្នកទាំងពីរនាំគ្នាទៅចុះ, យើងនឹងមិនអាចទេ ។

សំ. លោកអាចារ្យ ចាប់ដើមអំពីកាលនៃព្រះពុទ្ធជាម្ចាស់ស្ដេចឧប្បត្តិឡើងក្នុងលោក មហាជនមានគ្រឿងក្រអូប កម្រងផ្កាជាដើមក្នុងដៃទៅបូជាព្រះអង្គប៉ុណ្ណោះ, សូម្បីខ្ញុំទាំងពីរក៏នឹងទៅក្នុងទីនោះដែរ,

លោកអាចារ្យនឹង ធ្វើដូចម្តេច ?

ស. ម្នាលអ្នកទាំងពីរក្នុងលោកនេះមានមនុស្សល្ងង់ខ្លៅច្រើន ឬមាន មនុស្សជាបណ្ឌិតច្រើន ?

សំ. បពិត្រអាចារ្យ មនុស្សល្ងង់ខ្លៅមានច្រើន មនុស្សដែលជាបណ្ឌិត មានត្រឹមតែបន្តិចបន្តួចទេ ។

ស. ម្នាលអ្នកទាំងពីរ បើដូច្នោះ ពួកមនុស្សដែលជាបណ្ឌិតៗនឹងទៅកាន់សំណាក់ព្រះសមណគោតម, ពួកមនុស្សល្ងង់នឹងមកកាន់សំណាក់យើង អ្នកទាំងពីរទៅចុះ យើងមិនទៅទេ ។

សម្ងាញ់ទាំងពីរនោះក៏ពោលថា "លោកអាចារ្យ លោកនឹងប្រាកដខ្លួនឯងចុះ" ដូច្នេះហើយ ចៀសចេញទៅ ។ កាលសម្លាញ់ទាំងពីរនោះទៅហើយ ។ បរិស័ទរបស់សញ្ជ័យបែកគ្នាជាពីរពួក ខណៈនោះអារាមនៅទទេ ។ សញ្ជ័យនោះឃើញអារាមទទេហើយ ក៏ក្អួតឈាមដ៏ក្តៅៗ ។ ក្នុងបណ្តាបរិព្វាជក ៥០០ នាក់ដែលទៅជាមួយនឹងសម្លាញ់ទាំងពីរនោះ បរិស័ទរបស់សញ្ជ័យ ត្រឡប់មកវិញ ។

សម្លាញ់ទាំងពីរបានទៅកាន់វត្តវេឡុវ័ន ព្រមទាំងបរិវារជក ២៥០ នាក់ ដែលជាអន្តេវាសិករបស់ខ្លួន ។

## សិស្សសម្រេចអរហត្តផលមុនអាចារ្យ

ព្រះសាស្តា ទ្រង់គង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ ៤ ទ្រង់ទតឃើញបរិវារជកទាំងនោះអំពីចម្ងាយហើយ ត្រាស់ហៅភិក្ខុទាំង-ឡាយដោយព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ជនជាសម្លាញ់ទាំងពីរកំពុងមកគឺកោលិតៈនិងឧបតិស្សៈ ទាំងពីរនាក់នោះនឹងជាគូសាវកដ៏ឆ្នើមរបស់តថាគត" ។ សម្លាញ់ទាំងពីរនាក់នោះថ្វាយបង្គំព្រះសាស្តាហើយអង្គុយក្នុងទីដ៏សមគួរមួយ, គេទាំងពីរបានក្រាបទូលពាក្យនេះហ្នឹងព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីបានបព្វជ្ជា គប្បីបានឧបសម្បទាក្នុងសំណាក់របស់ព្រះមានព្រះភាគចុះ" ព្រះមានព្រះភាគទ្រង់ត្រាស់ថា "អ្នកទាំងឡាយចូរមកជាភិក្ខុចុះ, ធម៌តថាគតសម្តែងល្អហើយ ចូរប្រព្រឹត្តព្រហ្មចារ្យ ដើម្បីធ្វើទីបំផុតនៃទុក្ខដោយប្រពៃចុះ" ។ មនុស្សទាំងអស់បានជាអ្នកទ្រទ្រង់បាត្រ និងចីវរ

ដែលសម្រេចដោយឫទ្ធិ ដូចជាព្រះថេរៈ ១០០ វស្សា ។

គ្រានោះ ព្រះសាស្តា ទ្រង់ពង្រីកព្រះធម្មទេសនាដោយអំណាចចរិយាដល់បរិស័ទរបស់ឧបតិស្សៈ និងកោលិតៈនោះ វៀរព្រះអគ្គសាវកទាំងពីរចេញ, ជនដ៏សេសក៏បានសម្រេចព្រះអរហត្ត ។ ក៏កិច្ចដោយមគ្គខាងលើរបស់ព្រះអគ្គសាវកទាំងពីរនៅមិនទាន់បានសរេច ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសាវកបារមីញាណជាគុណធំ ។

គ្រាក្រោយមក ក្នុងថ្ងៃទី ៧ អំពីថ្ងៃដែលខ្លួនបួសហើយ ព្រះមហាមោគ្គល្លានចូលទៅអាស្រ័យស្រុកឈ្មោះកល្លវាឡ ក្នុងដែនមគធៈ, កាលថីនមិទ្ធៈគ្របសង្កត់, ដែលព្រះសាស្តាទ្រង់ឲ្យសង្វេគហើយ បន្ទោបង់ថីនមិទ្ធៈបាន កំពុងស្តាប់ព្រះធាតុកម្មដ្ឋាន ដែលតថាគតប្រទានហើយ បានញ៉ាំងកិច្ចក្នុងមគ្គ ៣ ខាងលើឲ្យសម្រេចហើយតាំងនៅក្នុងទីបំផុតសាវកបារមីញាណ ។

ចំណែកព្រះសារីបុត្រ កន្លងទៅបានកន្លះខែអំពីថ្ងៃដែលខ្លួនបួស

ចូលទៅអាស្រ័យក្រុងរាជគ្រឹះនោះឯង គង់នៅក្នុងគុហាឈ្មោះសូករខាតាជាមួយនឹងព្រះសាស្ដា, កាលព្រះសាស្ដាទ្រង់សម្ដែងវេទនាបរិគ្គហសូត្រដល់ទីឃនខបរិព្វាជកដែលជាក្មួយប្រុសរបស់ខ្លួន, បញ្ជូនញាណឲ្យទៅតាមលំអាននៃព្រះសូត្រ ក៏បានសម្រេចនូវទីបំផុតសាវកបារមីញាណ ដូចអ្នកបរិភោគភត្តដែលគេជូសឲ្យអ្នកដទៃ ។

មានពាក្យសួរថា "ក៏ព្រះសារីបុត្រ ជាអ្នកមានបញ្ញាច្រើនមិនមែនឬ ? កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបសម្រេចសាវកបារមីញាណយឺតជាងព្រះមហាមោគ្គល្លាន" ។

ឆ្លើយថា "ព្រោះមានបរិកម្មច្រើន" ដូចយ៉ាងមនុស្សទុគ៌តទាំងឡាយប្រាថ្នាទៅកាន់ទីណាៗ ក៏ចេញទៅបានភ្លាមៗ, ចំណែកព្រះរាជាចាំបាច់ត្រូវការត្រៀមច្រើន មានការត្រៀមដំរីព្រះរាជពាហនៈជាដើមទើបសមគួរ យ៉ាងណាមិញ, ឧបមេយ្យនេះគប្បីជ្រាបដូច្នោះដែរ ។

## ពួកភិក្ខុតិះដៀលព្រះសាស្ដា

ក៏ក្នុងវេលាថ្ងៃរសៀលនោះឯង ព្រះសាស្ដាទ្រង់ប្រជុំសាវក

ក្នុងវត្តវេឡុវ័ន ប្រទានតំណែងអគ្គសាវកដល់ព្រះថេរៈទាំងពីរ ហើយទ្រង់សម្តែងព្រះបាតិមោក្ខ ។ ពួកភិក្ខុតិះដៀលថា "ព្រះសាស្តាប្រទាន ( តំណែង ) ដល់ភិក្ខុទាំងឡាយដោយការយោគយល់មុខ, ព្រះអង្គកាលនឹងប្រទានតំណែងអគ្គសាវក គួរប្រទានដល់បញ្ចវគ្គីយ៍ដែលជាអ្នកបួសមុន ។ កាលមិនទ្រង់រមិលមើលនូវបញ្ចវគ្គីយ៍ទាំងនោះ ក៏គួរប្រទានដល់ភិក្ខុ ៥៥ រូប មានព្រះយសត្ថេរជាប្រធាន, កាលមិនទ្រង់រមិលមើលនូវភិក្ខុទាំងនោះ ក៏គួរប្រទានដល់ភិក្ខុភទ្ទវគ្គីយ៍, កាលមិនទ្រង់រមិលមើលនូវភិក្ខុទាំងនោះ ក៏គួរប្រទានដល់ភិក្ខុ ៣ នាក់បងប្អូនមានព្រះឧរុវេលកស្សបជាដើម, តែព្រះសាស្តាទ្រង់លះបង់ភិក្ខុទាំងនោះ មានប្រមាណប៉ុណ្ណេះ កាលនឹងទ្រង់ប្រទានតំណែងអគ្គសាវក ក៏បានទ្រង់ប្រទានតំណែងអគ្គសាវក ដល់ភិក្ខុដែលទើបបួសក្រោយគេបង្អស់ ។ ឈ្មោះថាប្រទានហើយដោយការយល់មុខ ។

## បុព្វកម្មរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ

ព្រះសាស្តា ទ្រង់ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំង

ឡាយនិយាយអ្វី” ? កាលភិក្ខុទាំងឡាយក្រាបទូលថា “ខ្ញុំព្រះអង្គទាំងឡាយពោលនូវរឿងឈ្មោះនេះ” ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយតថាគតមិនយោគយល់មុខឲ្យ ( តំណែង ) ដល់ពួកភិក្ខុទេ, តែតថាគតឲ្យតំណែងដែលខ្លួនប្រាថ្នាហើយៗនោះឯង ដល់ភិក្ខុទាំងនោះ, ក៏អញ្ញាកោណ្ឌញ្ញៈ កាលថ្វាយទានទាក់ទងសន្ទូងដ៏ថ្លៃង ៩ ដង ក្នុងវដ្តសន្ទូងមួយវដ្ត មិនបានប្រាថ្នាតំណែងអគ្គសាវកទេ តែបានប្រាថ្នាដើម្បីចាក់ធ្លុះព្រះអរហត្ត ដែលជាធម៌ប្រសើរមុនសាវកទាំងពួង” ។ ភិក្ខុទាំងឡាយក្រាបទូលថា “បពិត្រព្រះមានជោគក្នុងកាលណា ? ព្រះសាស្តាទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនឹងស្តាប់ឬ ? ភិក្ខុទាំងនោះក្រាបទូលថា “ស្តាប់ព្រះអង្គ ” ។

ព្រះសាស្តា ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ចាប់ពីកប្បនេះទៅ ៩១ កប្ប ព្រះមានព្រះភាគព្រះនាមថា វិបស្សី ស្តេចឧប្បត្តិឡើងហើយក្នុងលោក ។ ក្នុងកាលនោះកុដុម្ពីក៏ពីរនាក់បងប្អូន គឺមហាកាលនិងចុល្លកាល ញ៉ាំងបុគ្គលឲ្យព្រោះស្រូវសាលីក្នុងស្រែដ៏ធំ ។ ថ្ងៃមួយ

ចុល្លកាលទៅស្រែ បកនូវដង្ហើមនៃស្រូវសាលីមួយដើមហើយទំពាស៊ី ។ ដង្ហើមនៃស្រូវសាលីនោះ ជាវត្ថុមានរសឆ្ងាញ់ក្រៃលែង ។ គេប្រាថ្នានឹងថ្វាយនូវទាននៃដង្ហើមស្រូវសាលីនោះដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ទើបចូលទៅរកបងប្រុសហើយ និយាយថា "បង ខ្ញុំនឹងបកដង្ហើមនៃស្រូវសាលី ចំអិនឲ្យជារបស់គួរដល់ព្រះពុទ្ធទាំង-ឡាយហើយថ្វាយទាន" ។ បងប្រុសពោលថា "ឯងនិយាយអ្វី ? ការបកដង្ហើមនៃស្រូវសាលីធ្វើទាន មិនធ្លាប់មានឡើយក្នុងអតីតៈ និងមិនមានក្នុងអនាគត, ឯងកុំធ្វើសន្ទូងឲ្យវិនាសឡើយ" ។ គេអង្វរហើយអង្វរទៀត គ្រានោះ បងប្រុសនិយាយនឹងគេថា "បើដូច្នោះ ឯងត្រូវបែងចែកស្រែជាពីរចំណែក ចូរកុំប៉ះពាល់នូវចំណែករបស់យើង ចូរធ្វើនូវកម្មដែលឯងប្រាថ្នាក្នុងស្រែ ដែលជាចំណែករបស់ខ្លួនចុះ" ។ គេទទួលព្រមថា "សាធុ" ចែកស្រែគ្នាហើយ បានសូមឧបករណ៍ និងមនុស្សជាច្រើនបកហើយ ឲ្យរម្ងាស់ជាទឹកដោះស្រស់ លាយជាមួយទឹកដោះថ្លា ទឹកឃ្មុំ និងស្ករ ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជា

ប្រធាន ក្នុងកាលស្រេចកត្តកិច្ចហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ទានដ៏ថ្លៃរបស់ខ្ញុំព្រះអង្គនេះ ចូរប្រព្រឹត្តទៅដើម្បីការចាក់ផ្ទះធមិដ៏ប្រសើរមុនគេបង្អស់ចុះ" ។ ព្រះសាស្តាត្រាស់ថា ចូរជាយ៉ាងនោះចុះ ហើយបានធ្វើអនុមោទនា ។ គេទៅពិនិត្យមើលឃើញស្រែណែនតាន់តាប់តាមដោយកួរស្រូវសាលី ហាក់ដូចជាគេចងទុកជាចង្កោមៗ ក្នុងស្រែទាំងអស់ មានបីតិ ៥ យ៉ាងហើយ គិតថា "ជាលាភរបស់យើងហ្ន៎" ដល់វេរធ្វើអំបុក បានថ្វាយទានដ៏ថ្លៃដោយអំបុក, បានថ្វាយទាក់ទងដោយសន្ទូងដ៏ថ្លៃ ព្រមជាមួយនឹងអ្នកស្រុកទាំងឡាយ ដល់វេរប្រូតបានថ្វាយទានដ៏ថ្លៃក្នុងវេរប្រូត ក្នុងកាលជាទីធ្វើនូវកណ្តាប់ បានថ្វាយទានដ៏លើសក្នុងកាលជាទីធ្វើកណ្តាប់ ក្នុងកាលជញ្ជូនកណ្តាប់ទៅគរក្នុងលាន ក៏បានថ្វាយទានដ៏ឆ្ងើមក្នុងកាលនោះដែរ ក្នុងកាលបែន ( បោកបញ្ជាន់ ) ទានដ៏ថ្លៃក្នុងការនាំស្រូវចូលជង្រុក បានថ្វាយទានដ៏ថ្លៃរួម ៩ ដង ក្នុងសន្ទូងមួយវេរដោយប្រការយ៉ាងនេះ ។ ក្នុងទីកន្លែងនៃសន្ទូងដែលកុដុម្ពិកឈ្មោះ

ចុល្លកាលនោះកាន់យកហើយៗបានពេញដូចដើមគ្រប់ៗវារៈ ។ សន្ទូង បានលូតលាស់ល្អឡើងយ៉ាងក្រៃលែង, ធម្មតាធម៌រមែងរក្សានូវអ្នករក្សាធម៌ ( សមដូចដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ) ៖

"ធម៌រមែងរក្សាអ្នកមានប្រក្រតីប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ រមែងនាំសុខមកឲ្យ នេះជាអានិសង្សក្នុងធម៌ដែលគេប្រព្រឹត្តល្អ អ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងមិនទៅកាន់ទុគ្គតិ" ។

អញ្ញាកោណ្ឌញ្ញៈ ប្រាថ្នាដើម្បីចាក់ធ្លុះធម៌ដ៏កំពូលមុនគេបង្អស់ ទើបបានថ្វាយទានដ៏ថ្លៃថ្នាង ៩ ដង ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមថា វិបស្សី ដោយប្រការយ៉ាងនេះឯង ។

មួយវិញទៀត សូម្បីក្នុងកាលនៃព្រះពុទ្ធព្រះនាម បទុមុត្តរៈ ក្នុងហង្សវតីនគរ ក្នុងទីបំផុតមួយសែនកប្បពីកទូកប្បនេះទៅ គេថ្វាយមហាទានអស់ ៧ ថ្ងៃ ហើយក្រាបចុះក្នុងទីជិតព្រះបាទនៃព្រះមានព្រះភាគអង្គនោះ តាំងសេចក្តីប្រាថ្នាដើម្បីការចាក់ធ្លុះធម៌ដ៏ផ្តើមមុនគេ

បន្ទស់ដូចគ្នាដែរ ។ តថាគតបានប្រទានតំណែង ដែលអញ្ញាកោណ្ឌញ្ញៈនេះប្រាថ្នាហើយដោយប្រការយ៉ាងនេះ តថាគតមិនបានយោគយល់មុខទេ” ។

## បុព្វកម្មរបស់ជន ៥៥ នាក់ មានយសកុលបុត្រជាដើម

ភិក្ខុទាំងឡាយក្រាបទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន ជន ៥៥ នាក់ មានយសកុលបុត្រជាប្រធាន ធ្វើកម្មអ្វីទុក” ?

ព្រះសាស្ដា ទ្រង់ត្រាស់ថា “សូម្បីជន ៥៥ នាក់នោះបានប្រាថ្នានូវព្រះអរហត្តក្នុងសំណាក់ព្រះពុទ្ធមួយព្រះអង្គ ធ្វើកម្មដែលជាបុណ្យទុកច្រើនហើយ ខាងក្រោយមកកាលព្រះពុទ្ធនៅមិនទាន់ឧប្បត្តិឡើង, ជាសម្លាញ់នឹងគ្នា ធ្វើបុណ្យរួមគ្នា ដើរចាត់ចែងសាកសពមនុស្សគ្មានទីពឹង ។ ថ្ងៃមួយ ពួកគេជួបស្ត្រីស្លាប់ទាំងមានគភ៌ បំណងថា “នឹងដុត” ទើបនាំទៅកាន់ព្រៃស្មសាន ជនទាំងនោះសម្រាកនៅក្នុងព្រៃស្មសាន ៥ នាក់ ដោយប្រាប់ថា “ពួកលោកចូរដុត” ជនដ៏សេសចូល

ទៅកាន់ស្រុក ។

ទារកឈ្មោះយសយកឈើស្ទូលចាក់សពនោះ ប្រែត្រឡប់ទៅត្រឡប់មក ដុតបានអសុភសញ្ញាហើយ ។ គេសម្តែងដល់សម្លាញ់ ៤ នាក់ សូម្បីក្រៅពីនេះថា "ម្នាលអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំង-ឡាយចូរមើលសាកសពនេះដែលមានស្បែក គឺភ្លើងកម្ចាត់បង់ហើយក្នុងទីនោះៗ ដូចជារូបគោពពាល មិនស្អាត ស្អុយ ជាវត្ថុគួរឲ្យខ្ពើម" ។ ជនទាំង ៤ នាក់នោះក៏បានអសុភសញ្ញាក្នុងសាកសពនោះ ។ គេទាំង ៥ នាក់ទៅស្រុកបានប្រាប់ដល់សម្លាញ់ដ៏សេស ។ ចំណែកព្រះយសទៅផ្ទះហើយបានប្រាប់ដល់មាតាបិតា និងភរិយា ។ អ្នកទាំងអស់គ្នានោះក៏ចម្រើនអសុភសញ្ញាដែរ នេះជាបុព្វកម្មរបស់ជន ៥៥ នាក់ មានយសកុលបុត្រជាប្រធាននោះ ។ ព្រោះដូច្នោះឯង សេចក្តីសម្គាល់ក្នុងផ្ទះដ៏ដេរដាសដោយស្ត្រីថា ដូចព្រៃស្មសាន ក៏កើតដល់ព្រះយស ។ ដោយឧបនិស្ស័យសម្បត្តិនោះ ការសម្រេចគុណវិសេស ទើបកើតឡើងដល់ពួកគេទាំងអស់ ។ ជនទាំងនេះបានទទួលផល ដែលខ្លួន

ប្រាថ្នាហើយ ដោយប្រការយ៉ាងនេះ ។ មិនមែនតថាគតយោគយល់មុខទេ” ។

## បុព្វកម្មរបស់ភទ្ទវគ្គីយ៍ ៣០ នាក់

ភិក្ខុទាំងឡាយទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន ក៏ព្រះភទ្ទវគ្គិយភិក្ខុជាសម្លាញ់គ្នាបានធ្វើកម្មអ្វីទុកទៅ ព្រះអង្គ” ?

ព្រះអង្គទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ សូម្បីពួកភទ្ទវគ្គីយ៍នោះ ក៏បានប្រាថ្នាព្រះអរហត្តក្នុងសំណាក់ព្រះពុទ្ធក្នុងកាលមុនហើយធ្វើបុណ្យ នាកាលព្រះពុទ្ធនៅមិនទាន់ស្តេចឧប្បត្តិ ជាអ្នកលេង ៣០ នាក់ បានស្តាប់តុណ្ឌិលោវាទ បានរក្សាសីល ៥ រហូតអស់ ៦ ម៉ឺនឆ្នាំ ។ សូម្បីភទ្ទវគ្គីយ៍ទាំងនេះ ក៏បានសម្រេចផលដែលខ្លួនប្រាថ្នាហើយៗ ដូចគ្នាដោយប្រការយ៉ាងនេះ ។ មិនមែនតថាគតយោគយល់ហើយប្រទានតំណែងដល់ភិក្ខុទាំងឡាយនោះទេ” ។

## បុព្វកម្មរបស់ជដិល ៣ នាក់បងប្អូន

ភិក្ខុទាំងឡាយទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន ក៏កស្សបៈ

៣នាក់បងប្អូន មានឧរុវេលកស្សបៈជាដើម បានធ្វើនូវកម្មអ្វីទុកទៅ”ៗ

ព្រះអង្គទ្រង់ត្រាស់ថា “គេប្រាថ្នាព្រះអរហត្តដែរ ធ្វើបុណ្យទុកហើយ ក៏ក្នុង ៩២ កប្បអំពីកប្បនេះទៅមានព្រះពុទ្ធពីរព្រះអង្គ គឺព្រះពុទ្ធព្រះនាម តិស្សៈ ព្រះពុទ្ធព្រះនាមផុស្សៈ ស្តេចឧប្បត្តិហើយ ព្រះរាជាព្រះនាមថាមហិន្ទ បានជាព្រះបិតារបស់ព្រះពុទ្ធ ទ្រង់ព្រះនាមថា ផុស្សៈ ៗ ក៏កាលព្រះអង្គទ្រង់បានសម្រេចសម្ពោធិញាណហើយ, ព្រះឱរសតូចរបស់ព្រះរាជា បានជាព្រះអគ្គសាវក បុត្ររបស់បុរោហិតបានជាព្រះសាវកទី ២ ៗ ព្រះរាជាបានស្តេចយាងទៅកាន់សំណាក់ព្រះសាស្តា ទ្រង់ត្រួតមើលនូវជនទាំងនោះថា “រាជឱរសអង្គច្បងរបស់យើងជាព្រះពុទ្ធ, រាជឱរសប្អូនជាអគ្គសាវក, បុត្របុរោហិតជាព្រះសាវកទី ២” ទ្រង់បន្លឺព្រះឧទាន ៣ ដងថា “ព្រះពុទ្ធរបស់ខ្ញុំ, ព្រះធម៌របស់ខ្ញុំ, ព្រះសង្ឃរបស់ខ្ញុំ, ខ្ញុំម្ចាស់សូមនមស្ការដល់ព្រះមានព្រះភាគ ទ្រង់ជាព្រះអរហន្តត្រាស់ដឹងដោយប្រពៃហើយដោយព្រះអង្គឯង” ដូច្នេះហើយ ក្រាបចុះទៀបបាទមូលរបស់ព្រះសាស្តា ទ្រង់

ទទួលបេ្តជ្ញាថា “បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលឥឡូវនេះ ហាក់ដូចជាកាលជាទីអង្គុយលក់ ក្នុងទីបំផុតនៃអាយុមានប្រមាណ ៩ ម៉ឺនឆ្នាំ, សូមព្រះអង្គកុំស្តេចយាងទៅកាន់ទ្វារផ្ទះរបស់ពួកជនដទៃ សូមទ្រង់ទទួលបច្ច័យ ៤ របស់ទូលបង្គំ រហូតអស់វេលាដែលទូលបង្គំនៅមានជីវិត” ដូច្នេះហើយ ទ្រង់ធ្វើពុទ្ធុបដ្ឋាកជាប្រចាំ ។ ម្យ៉ាងទៀត ព្រះរាជាទ្រង់មានព្រះរាជឱរសដទៃ ៣ ព្រះអង្គទៀត ។ បណ្តាព្រះរាជឱរស ៣ ព្រះអង្គនោះ ព្រះរាជឱរសអង្គច្បងមានទាហានជាបរិវារ ៥០០ អង្គកណ្តាល មាន ៣០០ អង្គតូចមាន ២០០ ។

ព្រះរាជឱរសទាំងនោះ ក្រាបទូលសូមឱកាសនឹងព្រះបិតាថា “សូម្បីទូលបង្គំទាំងឡាយ នឹងនិមន្តព្រះម្ចាស់បងសោយ” សូម្បីទូលសូមរឿយៗ ក៏មិនបាន, កាលបច្ចន្តជនបទកម្រើកហើយ, ត្រូវបញ្ជូនទៅដើម្បីប្រយោជន៍រម្ងាប់បច្ចន្តជនបទនោះ, ញុំាងបច្ចន្តជនបទឲ្យស្ងប់រម្ងាប់ ហើយមកកាន់សំណាក់ព្រះរាជបិតា ។ គ្រានោះ ព្រះរាជបិតាទ្រង់បបោសអង្អែលព្រះឱរសទាំង ៣ នោះហើយ ទ្រង់ថើបត្បូងព្រះ

សិរសា ត្រាស់ថា "បាទាំងឡាយ បិតាឲ្យពរដល់ពួកបុត្រ" ។ ព្រះ-ឱរសទាំង ៣ នោះទូលថា "ប្រពៃហើយព្រះបិតា" ធ្វើព្រះពរឲ្យជាការដែលកាន់យកហើយ, ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ព្រះបិតាត្រាស់ទៀតថា "បាទាំងឡាយ ពួកបុត្រចូរទទួលពរចុះ" ក្រាបទូលថា "បពិត្រព្រះបិតា សេចក្តីប្រាថ្នានូវវត្ថុណាៗដទៃរបស់ទូលបង្គំមិនមាន ។ តាំងអំពីឥឡូវនេះ ទូលបង្គំនឹងនិមន្តព្រះម្ចាស់បងសោយ, សូមព្រះរាជទានពរនេះដល់ទូលបង្គំចុះ" ។

រ. ម្នាលបុត្រ ឲ្យមិនបាន ។

អ. កាលមិនព្រះរាជទានជានិច្ចកាល ក៏សូមព្រះរាជទានត្រឹមតែ ៧ ឆ្នាំ ។

រ. ម្នាលបុត្រ ឲ្យមិនបាន ។

អ. បើដូច្នោះ ក៏ព្រះរាជទានត្រឹមតែ ៦-៥-៤-៣-២-១ ឆ្នាំ ៧-៦-៥-៤-៣ ខែ ។

រ. ម្នាលបុត្រ ឲ្យមិនបាន ។

អ. ណ្ហើយចុះ ព្រះបិតាសូមទ្រង់ព្រះរាជទាន ត្រឹមតែ ៣ ខែ ដល់ខ្ញុំព្រះអង្គទាំងឡាយ ម្នាក់មួយខែៗ ។

រ. ប្រពៃហើយបុត្រ, បើដូច្នោះ បុត្រចូរនិមន្តឲ្យបានបាន ៣ ខែ ។

ក៏បុរសនាយឃ្លាំងរបស់ព្រះរាជបុត្រទាំងបីអង្គនោះ មានតែម្នាក់ អ្នកប្រកបកិច្ចការទូទៅក៏មានតែម្នាក់ដែរ ។ ព្រះរាជបុត្រទាំង ៣ អង្គនោះ មានបុរស ១២ ម៉ឺនជាបរិវារ ។ ព្រះរាជឱរសទាំងបីអង្គបញ្ជាឲ្យហៅបរិវារទាំងនោះមកហើយ ត្រាស់ថា "យើងទាំងបីនឹងរក្សាសីល ១០ ស្លៀកដណ្តប់នូវសំពត់កាសាយៈពីរផ្ទាំង នៅរួមជាមួយព្រះ-សាស្តាអស់ ៣ ខែនេះ, ពួកអ្នកទាំងឡាយ ចូរកាន់យកនូវវត្ថុដែលបុគ្គលគប្បីឲ្យប្រព្រឹត្តក្នុងទានមានប្រមាណប៉ុណ្ណោះ ញុំាងវត្ថុដែលបុគ្គលគប្បីទំពាស៊ី និងវត្ថុដែលបុគ្គលគប្បីបរិភោគឲ្យប្រព្រឹត្តទៅដល់ភិក្ខុ ៩ ម៉ឺនរូប និងដល់ទាហានរបស់យើង ១០០០, ព្រោះ អំណឹះពីនេះទៅ ពួកយើងមិនពោលនូវពាក្យអ្វីៗ ទាំងអស់" ។

ព្រះឱរសទាំង ៣ អង្គនោះ នាំបុរសជាបរិវារមួយពាន់សមាទាន

សីល ១០ ស្មៀកដណ្តប់សំពត់កាសាយៈ នៅតែក្នុងទីវត្ត ។ បុរសនាយឃ្លាំង និងបុរសអ្នកប្រកបក្នុងកិច្ចការទូទៅបើកស្បៀងតាមវារៈៗ អំពីឃ្លាំងទាំងឡាយរបស់ព្រះរាជបុត្រជាបងប្អូនទាំង ៣ អង្គថ្វាយទាន ។

## បរិភោគអាហារដែលគេឧទ្ទិសចំពោះភិក្ខុសង្ឃ ស្លាប់ទៅកើតជាប្រេត

ក៏កូនរបស់ពួកកម្មករ ស្រេកឃ្លាំត្រូវការបបរ និងកត្តជាដើម ។ កម្មករទាំងនោះ កាលភិក្ខុសង្ឃនៅមិនទាន់មក ក៏ឲ្យវត្ថុមានបបរ និងបាយជាដើមដល់កូនទាំងនោះ ។ ក្នុងពេលដែលភិក្ខុសង្ឃឆាន់ស្រេចហើយ មិនដែលមានវត្ថុអ្វីសល់ឡើយ ។

ក្នុងកាលតមក ពួកកម្មករទាំងនោះនិយាយអាងថា “យើងនឹងឲ្យដល់ពួកក្មេង” ដូច្នោះហើយ ទទួលទៅបរិភោគខ្លួនឯងខ្លះ, មិនត្រឹមតែប៉ុណ្ណោះ ឃើញអាហារសូម្បីដ៏ជាទីគាប់ចិត្តក៏មិនអាចនឹងអត់ទ្រាំបាន ។ ក៏ពួកគេមានប្រមាណ ៨ ម៉ឺន ៤ ពាន់នាក់ ។ ពួកគេបរិភោគ

អាហារដែលថ្វាយសង្ឃហើយ ព្រោះកាយបែកធ្លាយបានទៅកើតក្នុងបេតវិស័យ ។

ចំណែកព្រះឱរស ៣ នាក់បងប្អូន ព្រមទាំងបុរសមួយពាន់ធ្វើកាលកិរិយាហើយកើតក្នុងទេវលោកអស់ ៩២ ពាន់កប្ប ។

ព្រះរាជឱរស ៣ នាក់បងប្អូនប្រាថ្នានូវព្រះអរហត្ត បានធ្វើកល្យាណកម្មក្នុងកាលនោះដោយប្រការយ៉ាងនេះ ជដិល ៣ នាក់បងប្អូននោះ បានទទួលផលដែលខ្លួនប្រាថ្នាហើយដូចគ្នា តថាគតមិនបានយោគយល់មុខឲ្យទេ ។

ចំណែកអ្នកប្រកបក្នុងកិច្ចការទូទៅរបស់ព្រះរាជឱរស ៣ អង្គនោះ ក្នុងកាលនោះបានជាព្រះបាទពិម្ពិសារ ។ នាយឃ្លាំងបានជាវិសាខឧបាសក ។ កម្មកររបស់ព្រះរាជបុត្រទាំង ៣ នោះ កើតក្នុងបេតវិស័យ ត្រាច់រង្គាត់ទៅមកដោយអំណាចសុគតិ និងទុគ្គតិ ក្នុងកប្បនេះកើតក្នុងបេតលោកនោះឯងអស់ ៤ ពុទ្ធន្តរ ។

## ពួកប្រេតសួរវេលាបានអាហារនឹងព្រះពុទ្ធ ៣ ព្រះអង្គ

ប្រេតទាំងនោះ ចូលគាល់ព្រះមានព្រះភាគព្រះនាមថា កកុសន្ធោ ដែលមានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ស្តេចឧប្បត្តិឡើងមុនព្រះពុទ្ធគ្រប់ព្រះអង្គក្នុងភទ្ទកប្បនេះ ទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាប្រាប់នូវកាលជាទីបានអាហារដល់ខ្ញុំព្រះអង្គទាំងឡាយ" ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ពួកអ្នកទាំងឡាយនៅមិនទាន់បានក្នុងកាលនៃតថាគតទេ, តែខាងក្រោយនៃតថាគត កាលមហាប្រឹថពីដុះខ្ពស់ឡើងបានកំពស់ប្រមាណមួយយោជន៍ ព្រះពុទ្ធទ្រង់ព្រះនាមថា កោនាគមនៈ នឹងឧប្បត្តិឡើង, អ្នកទាំងឡាយគប្បីសួរព្រះអង្គចុះ" ។

ប្រេតទាំងនោះ ញុំាងកាលមានប្រមាណប៉ុណ្ណោះឲ្យអស់ទៅ កាលព្រះពុទ្ធទ្រង់ព្រះនាមថា កោនាគមនៈ នោះស្តេចឧប្បត្តិឡើងហើយ ក៏បានទូលសួរព្រះអង្គ សូម្បីព្រះពុទ្ធអង្គនោះក៏ត្រាស់ថា "ពួកអ្នកទាំងឡាយនឹងនៅមិនទាន់បានក្នុងកាលនៃតថាគតទេ តែខាងក្រោយ

នៃតថាគត កាលមហាប្រឹថពីដុះខ្ពស់ឡើងបានមួយយោជន៍ ព្រះពុទ្ធ ព្រះនាមថា កស្សបៈ នឹងឧប្បត្តិឡើង ពួកអ្នកទាំងឡាយគប្បីទូលសួរព្រះអង្គចុះ" ។

ប្រេតទាំងនោះ ញុំាងកាលមានប្រមាណប៉ុណ្ណោះឲ្យអស់ទៅហើយ, លុះព្រះពុទ្ធទ្រង់ព្រះនាមថាកស្សបៈស្តេចឧប្បត្តិឡើងហើយ, ក៏ទូលសួរព្រះអង្គ ។ សូម្បីព្រះពុទ្ធអង្គនោះ ក៏ត្រាស់ថា "ពួកអ្នកទាំងឡាយនឹងនៅមិនទាន់បានក្នុងកាលនៃតថាគតទេ តែខាងក្រោយនៃតថាគត កាលមហាប្រឹថពីដុះឡើងបានប្រមាណមួយយោជន៍ ព្រះពុទ្ធព្រះនាមថា គោតម នឹងស្តេចឧប្បត្តិឡើង ។ ក្នុងកាលនោះ ញាតិរបស់អ្នកទាំងឡាយនឹងជាព្រះរាជាទ្រង់ព្រះនាមថា ពិម្ពិសារថ្វាយទានដល់ព្រះសាស្តាហើយ នឹងឲ្យចំណែកកុសលទានដល់ពួកអ្នក ពួកអ្នកនឹងបាន ( អាហារ ) ក្នុងគ្រានោះ" ។ មួយពុទ្ធន្តរបានប្រាកដដល់ប្រេតទាំងនោះដូចថ្ងៃស្អែកឡើង ។

## ពួកប្រេតរួចផុតទុក្ខព្រោះផលទាន

ប្រេតទាំងនោះ កាលព្រះតថាគតស្តេចឧប្បត្តិហើយ, កាលព្រះបាទពិម្ពិសារថ្វាយទានក្នុងថ្ងៃខាងដើម ។ ស្រែកសំឡេងបន្ទឺគួរឲ្យខ្លាច សម្តែងខ្លួនដល់ព្រះរាជាក្នុងរាត្រីហើយ ។ ថ្ងៃស្អែកឡើងព្រះរាជាស្តេចទ្រង់យានមកកាន់វត្តវេឡុវ័ន ក្រាបទូលរឿងនោះដល់ព្រះតថាគត ។

ព្រះសាស្តា ទ្រង់ត្រាស់ថា "មហាបពិត្រ ក្នុងទីបំផុត ៩២ កប្បអំពីកប្បនេះទៅ ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថា ផុស្សៈ ពួកប្រេតទាំងនោះជាញាតិរបស់ព្រះអង្គ បានបរិភោគអាហារដែលគេថ្វាយដល់ភិក្ខុសង្ឃ កើតក្នុងបេតលោកហើយ ត្រាច់រង្គាត់ទៅមក បានទូលសួរព្រះពុទ្ធជាច្រើនព្រះអង្គ ដែលស្តេចឧប្បត្តិឡើង មានព្រះកកុសន្ធៈជាដើម ដែលព្រះពុទ្ធទាំងនោះត្រាស់ប្រាប់ពាក្យនេះៗហើយ សង្ឃឹមចំពោះទានរបស់ព្រះអង្គរហូតអស់កាលប៉ុណ្ណោះ ។ ម្សិលមិញ កាលព្រះអង្គទ្រង់ថ្វាយនូវទានហើយ មិនបានទទួលចំណែកបុណ្យ ក៏បាន

ធ្វើយ៉ាងនេះ” ។ ព្រះរាជាទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន ក៏កាលទូលបង្គំថ្វាយទានសូម្បីកាលឥឡូវនេះ ប្រេតទាំងនោះនឹងបានទទួលដែរឬ” ?

ព្រះសាស្តាទ្រង់ត្រាស់ថា “មហាបពិត្រ បាន” ។ ព្រះរាជាទ្រង់និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានក្នុងថ្ងៃស្អែកឡើង ហើយបានឧទ្ទិសចំណែកបុណ្យថា “បពិត្រព្រះអង្គដ៏ចម្រើន សូមបាយ និងទឹកដ៏ជាទិព្វ ចូរសម្រេចដល់ពួកប្រេតទាំងនោះដោយមហាទាននេះ” ។ បាយ និងទឹកដ៏ជាទិព្វកើតហើយដល់ប្រេតទាំងនោះដូច្នេះឯង ។ ស្អែកឡើងប្រេតទាំងនោះ អាក្រាតកាយសម្តែងខ្លួនដល់ព្រះរាជា ។ ព្រះរាជាទូលថា “ថ្ងៃនេះ ពួកប្រេតអាក្រាតកាយសម្តែងខ្លួនដល់ខ្ញុំព្រះអង្គ” ។ ព្រះសាស្តាត្រាស់ថា “មហាបពិត្រ ព្រះអង្គមិនបានថ្វាយសំពត់” ។ ថ្ងៃស្អែកឡើង ព្រះរាជាថ្វាយសំពត់ចីវរទាំង-ឡាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយទ្រង់ឧទ្ទិសចំណែកបុណ្យថា “សូមសំពត់ដ៏ជាទិព្វទាំងឡាយ ចូរសម្រេចដល់ប្រេតទាំង

នោះអំពីចីវរទាននេះចុះ” ។ ក្នុងខណៈនោះឯង សំពត់ទិព្វកើតឡើងដល់ប្រេតទាំងនោះហើយ ។ ប្រេតទាំងនោះលះបង់អត្តភាពជាប្រេតតាំងនៅក្នុងអត្តភាពដែលជាទិព្វ ។ ព្រះសាស្តា កាលនឹងទ្រង់ធ្វើអនុមោទនា ក៏ទ្រង់ធ្វើអនុមោទនាដោយតិរោកុឌ្ឌសូត្រថា “**តិរោកុឌ្ឌេសុ តិដ្ឋន្តិ**” ជាដើម ។ ក្នុងទីបំផុតនៃការអនុមោទនា ធម្មាភិសម័យមានដល់សត្វ ៨ ម៉ឺន ៤ ពាន់ ។ ព្រះសាស្តា លុះទ្រង់ត្រាស់រឿងជដិល ៣ នាក់បងប្អូនហើយ ទ្រង់នាំព្រះធម្មទេសនានេះមកដោយប្រការដូច្នេះ ។

## បុព្វកម្មរបស់ព្រះអគ្គសាវកទាំងពីរ

ភិក្ខុទាំងឡាយទូលសួរថា “ក៏ព្រះអគ្គសាវកទាំងពីរបានធ្វើកម្មអ្វីទុក ព្រះអង្គ” ?

ព្រះសាស្តា ត្រាស់ថា អគ្គសាវកទាំងពីរធ្វើសេចក្តីប្រាថ្នាដើម្បីបានជាអគ្គសាវក ។ ពិតណាស់ ក្នុងទីបំផុតមួយអសង្ខេយ្យកំរៃមួយសែនកប្បអំពីកទ្ទកប្បនេះទៅ ព្រះសារីបុត្រកើតក្នុងត្រកូលព្រាហ្មណ៍មហាសាលមាននាមថា សរទមាណព ។ ព្រះមោគ្គល្លាន

កើតក្នុងត្រកូលគហបតីមហាសាល មាននាមថា សិរីវឌ្ឍនកុដុម្ពិក ។ មាណពទាំងពីរនោះបានជាសម្លាញ់លេងដីជាមួយគ្នា ។ សារទមាណពដោយកាលកន្លងទៅនៃបិតាបានគ្រប់គ្រងទ្រព្យជាច្រើន ដែលជាមត៌ករបស់ត្រកូល ។ ក្នុងថ្ងៃមួយនៅក្នុងទីស្ងាត់បានគិតថា "យើងរមែងដឹងអត្តភាពក្នុងលោកនេះប៉ុណ្ណោះ, មិនដឹងអត្តភាពក្នុងលោកខាងមុខទេ តែធម្មតាសេចក្តីស្លាប់របស់សត្វទាំងឡាយដែលកើតមកហើយជារបស់ទៀង ។ គួរតែយើងបួសជាបព្វជិត ហើយធ្វើការស្វែងរកមោក្ខធម៌ ។

សារទមាណពនោះចូលទៅរកសម្លាញ់ហើយ ក៏និយាយថា "សិរីវឌ្ឍន៍សម្លាញ់ខ្ញុំនឹងបួសស្វែងរកមោក្ខធម៌ លោកនឹងអាចបួសជាមួយយើង ឬមិនអាចទេ" ។ សិរីវឌ្ឍន៍ឆ្លើយថា "ខ្ញុំមិនអាចទេសម្លាញ់ លោកបួសម្នាក់ឯងចុះ" ។ សារទៈនោះគិតថា "ធម្មតាអ្នកដែលទៅកាន់បរលោកនាំសម្លាញ់ ឬញាតិមិត្តទៅជាមួយមិនមាន, កម្មដែលខ្លួនធ្វើហើយរមែងជារបស់ខ្លួនឯង" ។ ពេលនោះ សារទមាណពក៏ឲ្យបើក

ឃ្លាំងកែវចេញឲ្យមហាទានដល់មនុស្សកំព្រា អ្នកដំណើរ មនុស្សសុំទាន និងស្មូមយាចកទាំងឡាយ ចូលទៅកាន់ជើងភ្នំបួសជាឥសី ។ ជនទាំងឡាយបួសតាមសរទៈនោះដោយអាការយ៉ាងនេះ គឺម្នាក់ ពីរនាក់ បីនាក់ រហូតមានជដិលប្រមាណ ៧ ម៉ឺន ៤ ពាន់នាក់ ។ សរទជដិលនោះញ៉ាំងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតហើយ ប្រាប់កសិណបរិកម្មដល់ជដិលទាំងនោះ ។ សូម្បីជដិលទាំងឡាយនោះក៏ញ៉ាំងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងដែរ ។ ក្នុងសម័យនោះ ព្រះពុទ្ធទ្រង់ព្រះនាមថា អនោមទស្សី ស្តេចឧប្បត្តិឡើងហើយក្នុងលោក, នគរមានឈ្មោះថាចន្ទវតី, ក្សត្រព្រះនាមថា យសវន្ត ជាព្រះបិតា, ព្រះទេវីព្រះនាមថា យសោធរា ជាព្រះមាតា ។ ដើមអង្គ្រងជាកន្លែងត្រាស់ដឹង,ព្រះអគ្គសាវកទាំងពីរឈ្មោះនិស្សភៈ១ឈ្មោះអនោមៈ១,ឧបដ្ឋាកឈ្មោះវរុណ, អគ្គសាវិកាទាំងពីរនាមថា សុន្ទរា ១ សុមនា ១, ព្រះជន្មាយុមានដល់មួយសែនឆ្នាំ, ព្រះសរីរៈកំពស់ ៥៨ ហត្ថ, រស្មីនៃព្រះសរីរៈផ្សាយទៅរហូត ១២ យោជន៍, ភិក្ខុមួយសែនអង្គជាបរិវារ ។

ថ្ងៃមួយ ក្នុងវេលាទៀបភ្លឺព្រះពុទ្ធទ្រង់នាមថា អនោមទស្សី ស្ដេចចេញចាកមហាករុណាសមាបត្តិ ទ្រង់ពិចារណាមើលសត្វលោក ទ្រង់ឃើញសរទតាបសហើយ ទ្រង់ព្រះតម្រិះថា “តថាគតទៅកាន់សំណាក់សរទតាបសក្នុងថ្ងៃនេះជាបច្ច័យ ព្រះធម្មទេសនានឹងមានគុណធំ ហើយសរទតាបសនោះនឹងប្រាថ្នាតំណែងជាព្រះអគ្គសាវក, សិរិវឌ្ឍនកុដុម្ពីក៏ដែលជាសម្លាញ់តាបសនោះ នឹងប្រាថ្នាតំណែងជាព្រះអគ្គសាវកទីពីរ ក្នុងកាលចប់ទេសនា ជដិល ៧ ម៉ឺន ៤ ពាន់នាក់ជាបរិវារតាបសនោះនឹងបានសម្រេចព្រះអរហត្ត, តថាគតគួរទៅកាន់ទីនោះ” ។ ដូច្នេះហើយ កាន់បាត្រ និងចីវររបស់ព្រះអង្គ មិនត្រាស់ហៅបុគ្គលណាដទៃ ស្ដេចយាងទៅតែមួយព្រះអង្គឯង ដូចរាជសីហ៍ កាលអន្តេវាសិកទាំងឡាយរបស់សរទតាបសទៅហើយ ដើម្បីត្រាចបាច់ផលាផល, ទ្រង់អធិដ្ឋានថា សូមសរទតាបសចូរដឹងនូវភាវៈនៃយើងជាព្រះពុទ្ធ” ។ កាលសរទតាបសឃើញហើយ ស្ដេចចុះចាកអាកាស ប្រថាប់ឈរលើផែនដី ។

សរទតាបសឃើញព្រះពុទ្ធានុភាព និងការសម្រេចនៃព្រះ-សរីរៈ ពិចារណានូវមន្តសម្រាប់ទាយលក្ខណៈ ក៏ដឹងបានថា “អ្នកដែលប្រកបដោយលក្ខណៈទាំងនេះ កាលនៅគ្រប់គ្រងផ្ទះរមែងបានជាស្តេចចក្រពត្តិ, កាលចេញបួសនឹងបានជាព្រះសព្វញ្ញុពុទ្ធ មានកិលេសដូចជាដំបូលបើកហើយក្នុងលោក, បុរសនេះជាព្រះពុទ្ធដោយគ្មានសង្ស័យ” ទើបធ្វើការក្រោកទទួល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន បានចាត់ចែងអាសនៈថ្វាយ ។

ព្រះមានព្រះភាគ ទ្រង់គង់ប្រថាប់លើអាសនៈដែលក្រាលទុកហើយ ។ សូម្បីសរទតាបសក៏កាន់អាសនៈ ដែលសមគួរដល់ខ្លួនហើយអង្គុយក្នុងចំណែកម្ខាង ។ ក្នុងសម័យនោះ ជដិល ៧ ម៉ឺន ៤ ពាន់កាន់ផលាផលទាំងឡាយដ៏ប្រណីតៗ ដែលមានឱជាមកដល់សំណាក់អាចារ្យ ហើយសម្លឹងមើលអាសនៈដែលព្រះពុទ្ធគង់ និងអាចារ្យហើយ ក៏និយាយថា “ក្នុងលោកនេះអ្នកដែលធំជាងលោកអាចារ្យរមែងមិនមាន ក៏បុរសម្នាក់នេះ នឹងជាធំជាងអាចារ្យឬ” ?

សរទតាបសឆ្លើយថា "ម្នាលអ្នកទាំងឡាយ ពួកអ្នកនិយាយអ្វី, ពួកអ្នកប្រាថ្នាដើម្បីធ្វើភ្នំសិនេរុដែលមានកំពស់ ៦៨ សែនយោជន៍ឲ្យស្មើនឹងគ្រាប់ស្ពៃ ដូច្នេះឬ ? អ្នកទាំងឡាយ ពួកអ្នកកុំធ្វើការប្រៀបធៀបយើងនឹងព្រះសព្វញ្ញុពុទ្ធឡើយ" ។

គ្រានោះ តាបសទាំងនោះគិតថា "បើបុរសនេះនឹងជាមនុស្សតូចតាច, ថោកទាបសោត, អាចារ្យរបស់ពួកយើងគង់មិនទាញយកវត្ថុបែបនេះមកឧបមាទេ, បុរសនេះនឹងជាធំក្រៃតណាទៅហ្ន៎" ដូច្នេះហើយ ទាំងអស់គ្នាបានក្រាបចុះទៀបព្រះបាទទាំងពីរថ្វាយបង្គំដោយសិរសា ។ គ្រានោះ អាចារ្យពោលនឹងតាបសទាំងនោះថា "អ្នកទាំងឡាយ ទេយ្យធម៌ដែលសមគួរដល់ព្រះពុទ្ធទាំងឡាយរបស់យើងមិនមាន, ហើយព្រះសាស្តាក៏ស្តេចយាងមកទីនេះក្នុងវេលាភិក្ខាចារ, ពួកយើងនឹងថ្វាយទេយ្យធម៌តាមការអាច តាមកម្លាំង ពួកអ្នកចូរនាំផលាផលដ៏ប្រណីតដែលមាននៅនោះមក," ដូច្នេះ ។ លុះឲ្យនាំមកហើយ លាងដៃទាំងពីរហើយ តាំងទុកក្នុងបាត្ររបស់ព្រះតថាគតដោយ

ខ្លួនឯង ។ គ្រាន់តែព្រះសាស្តាទ្រង់ទទួលផលាផលក្លាម,ទេវតាទាំងឡាយក៏ដាក់ឱជាដ៏ជាទិព្វចូលក្លាមដែរ ។ តាបសនោះបានគ្រងសូម្បីនូវទឹកថ្វាយដោយខ្លួនឯងដែរ ។

លំដាប់នោះ កាលព្រះសាស្តាទ្រង់គង់ធ្វើភត្តកិច្ចហើយ សរទតាបសនោះ ហៅអន្តេវាសិកទាំងអស់មកហើយ អង្គុយពោលសារាណីយកថាក្នុងទីជិតព្រះសាស្តា ។ ព្រះសាស្តា ទ្រង់ព្រះតម្រិះថា "សូមអគ្គសាវកទាំងពីរចូរមកព្រមជាមួយនឹងភិក្ខុសង្ឃ" ។ ព្រះអគ្គសាវកទាំងពីរនោះ ជ្រាបព្រះតម្រិះរបស់ព្រះសាស្តាហើយ មានព្រះខីណាស្រពមួយសែនជាបរិវារ មកថ្វាយបង្គំព្រះសាស្តាហើយ បានឈរក្នុងទីដ៏សមគួរមួយ ។

លំដាប់នោះ សរទតាបសហៅអន្តេវាសិកទាំងឡាយមកហើយពោលថា "ម្នាលអ្នកទាំងឡាយ សូម្បីអាសនៈព្រះពុទ្ធទ្រង់គង់ ក៏នៅទាប, ទាំងអាសនៈសម្រាប់សមណៈមួយសែនក៏មិនមាន, ពួកអ្នកទាំងឡាយគួរធ្វើពុទ្ធសក្ការៈឲ្យលើសលប់ក្នុងថ្ងៃនេះ ចូរនាំផ្កាឈើទាំង-

ឡាយដែលដល់ព្រមដោយពណ៌ និងក្លិនមកអំពីជើងភ្នំ” ។ វេលាដែល ពោលហាក់ដូចជាកាលដ៏យឺតយូរ, តែវិស័យឫទ្ធិរបស់អ្នកមានឫទ្ធិ ដែលបុគ្គលមិនគួរគិត, ព្រោះហេតុដូច្នោះ ដោយកាលត្រឹមតែ មួយរំពេចប៉ុណ្ណោះ តាបសទាំងនោះនាំផ្កាឈើទាំងឡាយដែលដល់ ព្រមដោយពណ៌ និងក្លិនមកហើយ ចាត់ចែងក្រាលអាសនៈផ្កាឈើ សំរាប់ព្រះពុទ្ធទាំងឡាយប្រមាណមួយយោជន៍ សម្រាប់ព្រះអគ្គ-សាវកទាំងពីរព្រះអង្គប្រមាណបីគាវុត, សម្រាប់ភិក្ខុដ៏សេសមានប្រ-មាណផ្សេងគ្នា មានប្រមាណកន្លះយោជន៍ជាដើម, សំរាប់ភិក្ខុបួសថ្មី ក្នុងសង្ឃ មានប្រមាណមួយឧសភៈ ( ២៥ ព្យាម ) នរណាៗមិនគប្បី គិតថា “ក្នុងអាស្រមបទមួយនឹងក្រាលអាសនៈធំដល់ម្ល៉ោះបានយ៉ាង ណា” ? ព្រោះថា នេះជាវិស័យរបស់ឫទ្ធិ, កាលក្រាលអាសនៈរួច ហើយយ៉ាងនោះ, សរទតាបសឈរប្រណម្យនូវអញ្ជលីចំពោះព្រះ-កក្រ្តនៃព្រះតថាគត ហើយក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គស្តេចឡើងកាន់អាសនៈផ្កាឈើនេះ ដើម្បីប្រយោជន៍

ដើម្បីសេចក្ដីសុខដល់ខ្ញុំព្រះអង្គ អស់កាលដ៏យូរអង្វែង" ។

ព្រោះហេតុនោះ ព្រះសារីបុត្រទើបពោលគាថាទុកថា ៖

"ខ្ញុំបានយកផ្កាឈើផ្សេងៗផង និងគ្រឿងក្រអូបផង រួមជាមួយគ្នា ក្រាលអាសនៈផ្កាឈើហើយ បានក្រាបទូលពាក្យនេះថា បពិត្រព្រះមហាវីរៈ អាសនៈដែលខ្ញុំព្រះអង្គក្រាលហើយនេះ សមគួរដល់ព្រះអង្គ ព្រះអង្គកាលនឹងញុំាងចិត្តរបស់ខ្ញុំព្រះអង្គឲ្យជ្រះថ្លា សូមព្រះអង្គចូរប្រថាប់គង់លើអាសនៈផ្កាឈើ ។

ព្រះពុទ្ធបានទ្រង់ញុំាងចិត្តរបស់ខ្ញុំព្រះអង្គ ឲ្យជ្រះថ្លាហើយ ញុំាងលោកនេះ និងទេវលោកឲ្យរីករាយហើយ ទើបប្រថាប់គង់លើអាសនៈផ្កាឈើអស់ ៧ យប់ ៧ ថ្ងៃ" ។

កាលព្រះសាស្ដាទ្រង់គង់ហើយយ៉ាងនោះ, ព្រះអគ្គសាវកទាំងពីរ និងភិក្ខុដ៏សេសក៏គង់លើអាសនៈដែលសមគួរហើយដល់ខ្លួនៗ ។ សរទតាបសបានកាន់ឆត្រផ្កាឈើធំ ឈរបាំងពីលើព្រះសិរសារបស់

ព្រះតថាគត ។ ព្រះសាស្តា ទ្រង់អធិដ្ឋានថា "សូមសក្ការៈរបស់ពួកជដិលនេះចូរមានផលច្រើន" ដូច្នេះហើយ ទ្រង់ចូលនិរោធសមាបត្តិ ។ អគ្គសាវកទាំងពីរក្តី ភិក្ខុដ៏សេសក្តី ដឹងថាព្រះសាស្តាទ្រង់ចូលសមាបត្តិហើយក៏ចូលសមាបត្តិដែរ ។ កាលព្រះតថាគតប្រថាប់គង់ចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ ។ ពួកអន្តេវាសិក កាលដល់វេលាត្រាច់ទៅភិក្ខា ។ បរិភោគមើមឈើផ្លែឈើក្នុងព្រៃហើយ ឈរប្រណម្យអញ្ជលីចំពោះព្រះពុទ្ធរហូតអស់កាលដ៏សេស ។ ចំណែកសរទតាបសមិនទៅសូម្បីកាន់ទីភិក្ខាចារ ឈរកាន់ឆត្រផ្កាឈើដដែលញ៉ាំងវេលាឲ្យកន្លងទៅដោយសេចក្តីសុខដែលកើតអំពី បីតិរហូតអស់ ៧ ថ្ងៃ ។ ព្រះសាស្តាស្តេចចេញអំពីនិរោធសមាបត្តិ ហើយត្រាស់ហៅព្រះនិសភ្កអគ្គសាវកដែលគង់ខាងស្តាំ ដោយព្រះតម្រាស់ថា "ម្នាលនិសភៈ អ្នកចូរធ្វើនូវអនុមោទនាគាថាប្រារព្ធចំពោះអាសនៈផ្កាឈើដល់តាបសទាំងឡាយដែលជាអ្នកធ្វើនូវសក្ការៈ" ព្រះថេរៈមានចិត្តត្រេកអរហាក់ដូចជាមេទ័ពធំបានជួបប្រសព្វនូវមហាលាភអំពីសម្នាក់

នៃស្ដេចចក្រពត្តិ តាំងនៅក្នុងសាវកបារមីញាណ ប្រារព្ធអនុមោទនា អាសនៈផ្កាឈើហើយ ។ ក្នុងទីបំផុតនៃធម្មទេសនារបស់ព្រះនិស្សភៈនោះ ព្រះសាស្ដាត្រាស់ហៅអគ្គសាវកទី ២ ដោយព្រះតម្រាស់ថា "ម្នាលភិក្ខុសូម្បីអ្នកក៏ចូរសម្ដែងធម៌ដែរ" ព្រះអនោមត្ថេរពិចារណាព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកហើយសម្ដែងធម៌ ។ ដោយធម៌ទេសនារបស់ព្រះអគ្គសាវកទាំងពីរ ការត្រាស់ដឹងក៏មិនមានសូម្បីដល់តាបសតែម្នាក់ ។

គ្រានោះព្រះសាស្ដា ទ្រង់តាំងនៅក្នុងពុទ្ធវិស័យរកប្រមាណមិនបានទ្រង់ផ្ដើមព្រះធម្មទេសនាហើយ ។ ក្នុងកាលចប់ទេសនាជដិល ៧ ម៉ឺន ៤ ពាន់ វៀរសរទតាបសចេញ បានសម្រេចព្រះអរហត្តទាំងអស់គ្នា ។ព្រះសាស្ដាទ្រង់លាព្រះហស្ថចេញហើយត្រាស់ថា "អ្នកទាំងឡាយចូរជាភិក្ខុចុះ" ។ សក់ និងពុកមាត់ ពុកចង្កាទាំងឡាយរបស់តាបសទាំងនោះក៏បានអន្តរធានបាត់អស់ក្នុងខណៈនោះឯង ។ បរិក្ខារទាំង ៨ ជាបរិក្ខារគឺបុញ្ញកម្មបំពាក់ឲ្យជាស្រេចព្ធដ៏កាយ ។

មានពាក្យសួរមកថា "ព្រោះហេតុអ្វី សរទតាបសទើបមិនបានសម្រេចព្រះអរហត្ត" ?

ឆ្លើយថា "ព្រោះភាពជាអ្នកមានចិត្តរាយមាយ" ។

បានឮមកថា ចាប់ផ្ដើមពីកាលដែលសរទតាបសនោះ ប្រារព្ធដើម្បីស្ដាប់ធម៌ទេសនារបស់ព្រះអគ្គសាវកដែលគង់លើអាសនៈទី ២ នៃព្រះពុទ្ធទាំងឡាយ តាំងនៅក្នុងសាវកបារមីញាណសម្ដែងធម៌ កើតការគិតឡើងថា "ឱហ្ន៎ សូម្បីយើងក៏គប្បីបានទទួលតំណែងដែលព្រះសាវករូបនេះបានទទួលក្នុងសាសនារបស់ព្រះពុទ្ធ ដែលនឹងទ្រង់កើតឡើងក្នុងអនាគត ដោយបរិវិតក្កនោះ ទើបសរទតាបសមិនបានអាចដើម្បីធ្វើការបោក់ធ្លុះមគ្គផលបាន ។ ក៏លោកថ្វាយបង្គំព្រះតថាគតហើយ ឈរនៅក្នុងទីចំពោះព្រះភក្ត្រក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលគង់លើអាសនៈក្នុងលំដាប់នៃព្រះអង្គមានព្រះនាមជាអ្វី ? ក្នុងសាសនារបស់ព្រះអង្គ" ។

ព្រះសាស្ដាត្រាស់ថា "ភិក្ខុអ្នកញ៉ាំងធម្មចក្រដែលតថាគតឲ្យ

ប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅតាម ដល់នូវទីបំផុតនៃសាវកបារមី-ញាណ ចាក់ធ្លុះនូវបញ្ហា ១៦ យ៉ាងតាំងនៅ, ភិក្ខុនេះឈ្មោះនិស្សភៈជាអគ្គសាវកក្នុងសាសនារបស់តថាគត” ។ លោកបានធ្វើសេចក្តីប្រាថ្នាថា “បពិត្រព្រះអង្គដ៏ចម្រើន ដោយផលនៃសក្ការៈដែលខ្ញុំព្រះ-អង្គបាំងឆត្រផ្កាឈើរហូតអស់ ៧ ថ្ងៃនេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាភាពជាសក្កទេវរាជ ឬភាពជាព្រហ្មយ៉ាងដទៃទេ តែសូមឲ្យខ្ញុំព្រះអង្គគប្បីបានជាអគ្គសាវករបស់ព្រះពុទ្ធមួយព្រះអង្គក្នុងអនាគត ដូចជាព្រះនិស្សភត្ថេរអង្គនេះ” ។

ព្រះសាស្តា ទ្រង់បញ្ជូនព្រះអនាគតំសញ្ញាណទៅពិចារណាថា “សេចក្តីប្រាថ្នារបស់បុរសនេះនឹងសម្រេចឬហ្ន៎ ? ទ្រង់បានឃើញថាកន្លងមួយអសង្ខេយ្យកម្រៃមួយសែនកប្បទៅនឹងបានសម្រេច កាលទ្រង់ឃើញហើយ ទើបត្រាស់នឹងសរទតាបសថា “សេចក្តីប្រាថ្នារបស់អ្នកនឹងមិនឥតប្រយោជន៍ទេ, ក៏ក្នុងអនាគតកន្លងទៅមួយអសង្ខេយ្យកម្រៃមួយសែនកប្ប ព្រះពុទ្ធព្រះនាមថា គោតម នឹងស្តេចកើតឡើង

ក្នុងលោក, ព្រះមាតារបស់ព្រះអង្គព្រះនាមថា មហាមាយាទេវី, ព្រះបិតារបស់ព្រះអង្គព្រះនាមថា សុទ្ធោទនមហារាជ, ព្រះឱរសនឹងមានព្រះនាមថារាហុល, ភិក្ខុដែលជាឧបដ្ឋាកនឹងមានព្រះនាមថា អានន្ទ, ព្រះអគ្គសាវកទី ២ នឹងមានព្រះនាមថា មោគ្គល្លាន, ចំណែកខ្លួនអ្នកនឹងជាព្រះអគ្គសាវករបស់ព្រះអង្គ នាមថា ធម្មសេនាបតីសារីបុត្រ” លុះទ្រង់ព្យាករតាបសយ៉ាងនោះហើយ ទ្រង់ត្រាស់ធម្មកថា មានភិក្ខុសង្ឃហែហម ហោះទៅតាមផ្លូវអាកាស ។

ចំណែកសរទតាបស ទៅកាន់សំណាក់ពួកព្រះថេរៈដែលជាអន្តេវាសិក ក៏បញ្ជូនដំណឹងទៅដល់សិរីវឌ្ឍកុដុម្ពិក៍ដែលជាសម្លាញ់ថា “បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយប្រាប់សម្លាញ់របស់ខ្ញុំម្ចាស់ផងថា “សរទតាបសដែលជាសម្លាញ់របស់លោកបានប្រាថ្នាតំណែងជាព្រះអគ្គសាវក ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមថាគោតម ដែលនឹងទ្រង់កើតឡើងក្នុងអនាគត ទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមអនោមទស្សីហើយ, លោកចូរប្រាថ្នាតំណែងជាព្រះអគ្គ

សាវកទី ២ ដែរទៅ" ។ លុះពោលយ៉ាងនោះហើយ បានធ្វើដំណើរ ទៅមុនព្រះថេរៈទាំងឡាយ បានឈរនៅក្បែរមាត់ទ្វារផ្ទះរបស់សិរិវឌ្ឍហើយ ។ សិរិវឌ្ឍពោលថា "អស់កាលដ៏យូរអង្វែងហើយលោកម្ចាស់ទើបមក" ដូច្នេះហើយ និមន្តឲ្យគង់លើអាសនៈ ខ្លួនឯងអង្គុយលើអាសនៈទាបជាង ហើយសួរថា "អន្តេវាសិករបស់លោកម្ចាស់បាត់ទៅណាអស់ មេ្តចមិនប្រាកដ" ?

សរទៈ យ៉ាងនោះហើយសម្លាញ់ ព្រះពុទ្ធអនោមទស្សី ស្តេចយាងមកអាស្រមរបស់អាត្មាភាពទាំងឡាយ, ពួកអាត្មាភាពធ្វើសក្ការៈព្រះអង្គតាមកម្លាំងរបស់ខ្លួន, ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសពួកអាត្មាភាពគ្រប់ៗ គ្នា, ក្នុងកាលចប់ទេសនា វៀរអាត្មាភាពចេញ ដ៏សេសបានសម្រេចព្រះអរហត្តហើយបួស ។ អាត្មាភាពឃើញព្រះនិស្សភត្ថេរអគ្គសាវករបស់ព្រះសាស្តា ទើបប្រាថ្នាតំណែងអគ្គសាវកក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមគោតម នឹងស្តេចកើតឡើងក្នុងអនាគត, សូម្បីលោកក៏ចូរប្រាថ្នាតំណែងអគ្គសាវកទី ២ ក្នុងសាសនា

របស់ព្រះអង្គដែរទៅ” ។

សិរីវឌ្ឍពោលថា បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់មិនមានសេចក្តីស្និទ្ធស្នាលជាមួយនឹងព្រះពុទ្ធទាំងឡាយឡើយ ។

សារទៈពោលថា ការដែលពោលជាមួយនឹងព្រះពុទ្ធ ចូរជាការៈរបស់អាត្មាភាពខ្លួនឯង, លោកចូរចាត់ចែងនូវសក្ការៈដ៏ថ្លៃថ្នូរឲ្យច្រើនចុះ, ។

សិរីវឌ្ឍស្តាប់ពាក្យរបស់សារទតាបសនោះហើយ បញ្ជាឲ្យធ្វើនូវទីប្រមាណ ៨ ករីស[១] ( ដោយព្រះរាជវង្វាស់ ) ក្បែរទ្វារនិវេសន៍របស់ខ្លួនឲ្យជាទីមានផ្ទៃដ៏រាបស្មើហើយ ឲ្យរោយរាយផ្កាឈើមានលាជជាគំរប់ប្រាំ ឲ្យធ្វើមណ្ឌបប្រក់ដោយផ្កាឧប្បលខៀវ តាក់តែងពុទ្ធាសនៈនិងអាសនៈសំរាប់ភិក្ខុដ៏សេស ចាត់ចែងសក្ការៈ និងគ្រឿងក្រអូបជាច្រើន ហើយបានឲ្យសញ្ញាដល់សារទតាបសដើម្បីប្រយោជន៍និមន្តព្រះពុទ្ធទាំងឡាយ ។

---

[១] ១ ករីស = ១២៥ ហត្ថ

ព្រះតាបស បាននាំភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានទៅកាន់លំនៅរបស់សិរីវឌ្ឍកុដុម្ពិក៍នោះ ។

ចំណែកសិរីវឌ្ឍកុដុម្ពិក៍ ធ្វើកិរិយាក្រោកទទួលបាត្រអំពីព្រះហស្តរបស់ព្រះតថាគត និមន្តស្តេចចូលទៅកាន់មណ្ឌប ថ្វាយទក្ខិណាដល់ភិក្ខុសង្ឃមាន ព្រះពុទ្ធជាប្រធានដែលគង់លើអាសនៈ ដែលគេតាក់តែងទុក អង្គាសដោយភោជនដ៏ប្រណីត ក្នុងវេលាសម្រេចភត្តកិច្ច និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យស្លៀកដណ្តប់សំពត់ដែលមានតម្លៃដ៏ថ្លៃ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការប្រុងប្រៀបនេះ មិនបានប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់តំណែងមានប្រមាណតិចទេ សូមព្រះអង្គទ្រង់ធ្វើនូវសេចក្តីអនុគ្រោះដោយទំនងនេះឯងរហូត ៧ ថ្ងៃចុះ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។ សិរីវឌ្ឍញុំាងមហាទានឲ្យប្រព្រឹត្តទៅដោយទំនងនោះឯងរហូត ៧ ថ្ងៃ ថ្វាយបង្គំព្រះមានព្រះភាគហើយ ឈរប្រណម្យអញ្ជលី ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សរទតាបសដែលជាសម្លាញ់របស់ខ្ញុំព្រះអង្គប្រាថ្នា

ថា យើងគប្បីបានជាអគ្គសាវករបស់ព្រះសាស្ដាអង្គណា, ខ្ញុំព្រះអង្គក៏គប្បីបានជាអគ្គសាវកទី ២ របស់ព្រះសាស្ដាអង្គនោះដែរ” ព្រះសាស្ដាទ្រង់ពិចារណាដល់អនាគតកាល ទ្រង់ឃើញភាវៈ គឺការសម្រេចនៃសេចក្ដីប្រាថ្នារបស់សិរិវឌ្ឍកុដុម្ពិក៍ហើយ ទើបទ្រង់ព្យាករថា “ពីកប្បនេះកន្លងទៅ ១ អសង្ខេយ្យកម្រៃមួយសែនកប្ប សូម្បីអ្នកក៏នឹងបានជាអគ្គសាវកទី ២ របស់ព្រះពុទ្ធព្រះនាមគោតម” ។

សិរិវឌ្ឍស្ដាប់នូវការព្យាករណ៍ របស់ព្រះពុទ្ធទាំងឡាយហើយបានជាអ្នករីករាយហើយ ។ សូម្បីព្រះសាស្ដា ទ្រង់ធ្វើកត្តានុមោទនាហើយ ព្រមទាំងបរិវារស្ដេចយាងទៅកាន់វិហារវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្ដីប្រាថ្នា ដែលបុត្ររបស់តថាគតប្រាថ្នាហើយក្នុងកាលនោះ ។ អគ្គសាវកទាំង ២ នោះ បានតំណែងតាមដែលខ្លួនប្រាថ្នានោះឯង, តថាគតមិនបានយោគយល់មុខ ហើយប្រទានតំណែងនោះទេ” ។

## អគ្គសាវកទាំង ២ ទូលរឿងបច្ចុប្បន្នដល់ព្រះសាស្តា

កាលព្រះសាស្តា ត្រាស់ព្រះពុទ្ធវចនៈយ៉ាងនេះ, អគ្គសាវកទាំង ២ ថ្វាយបង្គំព្រះមានព្រះភាគក្រាបទូលរឿងបច្ចុប្បន្នទាំងអស់ថា "បពិត្រព្រះអង្គដ៏ចម្រើន (កាល) ខ្ញុំព្រះអង្គនៅជាអ្នកគ្រប់គ្រងផ្ទះទៅមើលមហោស្រពលើកំពូលភ្នំ" ដូច្នេះជាដើម រហូតដល់ការបាក់ផ្ទុះសោតាបត្តិផលអំពីសំណាក់ព្រះអស្សជិ ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំង ២ នោះ ទៅកាន់សំណាក់អាចារ្យសញ្ជ័យ ប្រាថ្នានឹងនាំលោកមកកាន់បាទមូលរបស់ព្រះអង្គ ប្រាប់ថាលទ្ធិរបស់លោកមិនមានសារៈ ហើយពោលអានិសង្សក្នុងការមកទីនេះ, អាចារ្យសញ្ជ័យឆ្លើយតបថា "ឥឡូវនេះ ឈ្មោះថា ការរស់នៅជាអន្តេវាសិករបស់យើង រមែងមានអាការប្រាកដដូចជាការរញ្ជួយទឹកក្នុងពាង យើងមិនអាចនឹងនៅជាអន្តេវាសិកបានទេ, កាលខ្ញុំព្រះអង្គប្រាប់ថា "បពិត្រលោកអាចារ្យ ពេលនេះមហាជនមានដៃកាន់វត្ថុមានគ្រឿងក្រអូប និងកម្រងផ្កាជាដើម នឹងទៅបូជាចំពោះព្រះសាស្តា

លោកនឹងមានអាការៈដូចម្ដេច ? ឆ្លើយថា អើ ក្នុងលោកនេះជនជាបណ្ឌិតមានច្រើន ឬក៏ជនល្ងង់ខ្លៅមានច្រើន ? កាលខ្ញុំព្រះអង្គឆ្លើយថា (ជនល្ងង់ខ្លៅមានច្រើន, ក៏ពោលថា បើដូច្នោះ ពួកជនជាបណ្ឌិតៗ នឹងទៅកាន់សំណាក់ព្រះគោតម, ពួកជនល្ងង់ខ្លៅនឹងមកកាន់សំណាក់របស់យើង, អ្នកទាំង ២ ទៅចុះ, មិនប្រាថ្នានឹងមក ព្រះអង្គ) ។

## អ្នកឃើញខុស និង អ្នកឃើញត្រូវបាន ទទួលផលផ្សេងគ្នា

ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សញ្ជ័យប្រកាន់យកវត្ថុដែលមិនមានសារៈ ថាមានសារៈ, ហើយប្រកាន់យកវត្ថុដែលមានសារៈថា (មិនមានសារៈ) ព្រោះការដែលខ្លួនជាមិច្ឆាទិដ្ឋិ ។ ចំណែកអ្នកទាំង ២ ដឹងនូវវត្ថុដែលមានសារៈ ថាមានសារៈ និងវត្ថុដែលមិនមានសារៈ ថាមិនមានសារៈ លះបង់វត្ថុដែលមិនជាសារៈចោល កាន់យកវត្ថុដែលមានសារៈប៉ុណ្ណោះ ព្រោះការដែលខ្លួនជាបណ្ឌិត" ដូច្នេះហើយ បានទ្រង់ភាសិតព្រះគាថា

ទាំងនេះថា ៖

៨ អសារេ សារមតិនោ សារេ ចាសារទស្សិនោ
តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។
សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ
តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

“ជនទាំងឡាយណា យល់ឃើញក្នុងធម៌ដែលមិនមានខ្លឹមថាជាធម៌មានខ្លឹម យល់ឃើញក្នុងធម៌ដែលមានខ្លឹមថាមិនមានខ្លឹម ជាអ្នកមានការត្រិះរិះខុសជាគោចរ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ ។ ជនទាំងឡាយណា យល់ឃើញនូវធម៌មានខ្លឹម ថាជាធម៌មានខ្លឹមផង យល់ឃើញនូវធម៌មិនមានខ្លឹម ថាជាធម៌មិនមានខ្លឹមផង ជាអ្នកអ្នកមានតម្រិះត្រូវជាគោចរ រមែងបាននូវធម៌ដែលមានខ្លឹម ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **អសារេ សារមតិនោ**

មានអត្ថថា ធម៌ទាំងនេះគឺ បច្ច័យ ៤ មិច្ឆាទិដ្ឋិដែលមានវត្ថុ ១០ ធម្ម-ទេសនាដែលជាឧបនិស្ស័យនៃមិច្ឆាទិដ្ឋិនោះ ឈ្មោះថាជាអសារៈ, អ្នកមានប្រក្រតីយល់ឃើញក្នុងធម៌ដែលមិនជាសារៈនោះថា "ជាសារៈ" ។

បាទព្រះគាថាថា **សារេ ចាសារទស្សិនោ** មានអត្ថថា ធម៌ទាំងនេះ គឺមិច្ឆាទិដ្ឋិដែលមានវត្ថុ ១០ ធម្មទេសនាដែលជាឧបនិស្ស័យនៃសម្មាទិដ្ឋិនោះ ឈ្មោះថា ជាសារៈ, អ្នកមានប្រក្រតីយល់ឃើញក្នុងធម៌ដែលជាសារៈនោះថា "នេះមិនជាសារៈទេ" ។

ពីរបទថា **តេ សារំ** ជាដើម មានអត្ថថា ជនទាំងនោះ គឺអ្នកយល់ខុសនោះ ជាអ្នកមានការត្រិះរិះខុសជាគោចរ ដោយអំណាចនៃវិតក្កទាំងឡាយ មានកាមវិតក្កជាដើម រមែងមិនសម្រេចនូវសីលសារៈ សមាធិសារៈ បញ្ញាសារៈ វិមុត្តិសារៈ វិមុត្តិញាណទស្សនៈ-សារៈ និងព្រះនិព្វានដែលជាបរមត្ថសារៈ ។

បទថា **សារញ្ច** សេចក្តីថា ដឹងសារៈ មានសីលសារៈជាដើមនោះឯងថា "នេះជាសារៈ" និងដឹងធម៌ដែលមិនមានសារៈ មាន

ប្រការដូចពោលហើយថា “នេះជាធម៌មិនមានសារៈ” ។

ពីរបទថា **តេ សារំ** ជាដើម សេចក្ដីថា ជនទាំងនោះ គឺបណ្ឌិតអ្នកកាន់យកនូវសម្មាទស្សនៈយ៉ាងនោះតាំងនៅ ជាអ្នកមានការត្រិះរិះត្រូវជាគោចរ ដោយអំណាចនៃការត្រិះរិះទាំងឡាយ មានការត្រិះរិះចេញចាកកាមជាដើម រមែងសម្រេចបាននូវវត្ថុដែលជាសារៈ មានប្រការដូចពោលហើយនោះ ។

ក្នុងកាលចប់ព្រះគាថា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ធម្មទេសនាបានជាប្រយោជន៍ដល់ជនដែលមកប្រជុំគ្នាហើយ ដូច្នេះឯង ។

( រឿងសញ្ជ័យ ចប់ )

❧ ❧ ❧

## ៩ រឿងព្រះនន្ទត្ថេរ

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**យថា អគារំ ទុច្ឆន្នំ** ” ជាដើម ។

### <u>ព្រះសាស្តាស្តេចយាងទៅកាន់ក្រុងកបិលពស្តុ</u>

សេចក្តីពិស្តារថា ព្រះសាស្តា ទ្រង់ញ៉ាំងព្រះធម្មចក្កដ៏បវរឲ្យប្រព្រឹត្តទៅ ហើយស្តេចយាងទៅកាន់ក្រុងរាជគ្រឹះ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន, បណ្តាទូត ១០ នាក់ ម្នាក់ៗ មានបរិវារមួយពាន់ ដែលព្រះបាទសុទ្ធោទនមហារាជ ទ្រង់បញ្ជូនទៅដោយព្រះរាជតម្រាស់ថា អ្នកទាំងឡាយចូរនាំបុត្តរបស់យើងមកសម្តែងដល់យើងចុះ, ក៏ព្រះកាឡុទាយិត្ថេរដែលទៅក្រោយគេបង្អស់ បានសម្រេចអរហត្តផលហើយ ដឹងនូវកាលជាទីស្តេចយាងទៅហើយ ពណ៌នាផ្លូវដោយគាថាប្រមាណ ៦០ គាថា នាំស្តេច ( ព្រះសាស្តា ) ដែលមានព្រះខីណាស្រព ២ ម៉ឺនហែហមហើយ ទៅកាន់កបិលពស្តុបុរី, ទ្រង់ធ្វើភ្លៀងបោក្ខរព័ស្សឲ្យជាហេតុកើតនៃរឿងហើយត្រាស់មហាវេស្សន្តរជាតកក្នុង

សមាគមព្រះញាតិ, ថ្ងៃស្អែកឡើង ស្ដេចយាងចូលទៅបិណ្ឌបាតប្រោស ព្រះបិតាឲ្យតាំងនៅក្នុងសោតាបត្តិផល ដោយព្រះគាថាថា “ឧត្តិដ្ឋេ នប្បមជ្ជេយ្យ” ជាដើម, ប្រោសព្រះនាងមហាបជាបតិគោតមី ឲ្យតាំងនៅក្នុងសោតាបត្តិផល ហើយប្រោសព្រះរាជា ( ព្រះបិតា ) ឲ្យតាំងនៅក្នុងសកទាគាមិផល ដោយព្រះគាថាថា “ធម្មញ្ចរេ សុចរិតំ” ជាដើម ។ ក៏ក្នុងកាលស្រេចភត្តកិច្ច ទ្រង់អាស្រ័យការពណ៌នាព្រះគុណរបស់រាហុលមាតា ត្រាស់ចន្ទកិន្នរីជាតក ក្នុងថ្ងៃទី ៣ អំពីថ្ងៃនោះ នាកាលវិវាហមង្គល និងគេហប្បវេសនមង្គលដើម្បីអភិសេកនន្ទកុមារ, កាលកំពុងប្រព្រឹត្តទៅ, ស្ដេចចូលទៅបិណ្ឌបាត ប្រទានបាត្រក្នុងព្រះហស្ដនៃនន្ទកុមារ ត្រាស់មង្គល ( ឲ្យពរ ) ស្ដេចក្រោកចាកអាសនៈហើយចៀសចេញទៅដោយមិនបានទ្រង់ទទួលបាត្រអំពីព្រះហស្ដនៃនន្ទកុមារឡើយ ។

ចំណែកនន្ទកុមារនោះ ដោយការគោរពចំពោះព្រះតថាគត ទើបមិនអាចទូល ( តឿន ) ថា បពិត្រព្រះអង្គដ៏ចម្រើន “សូមព្រះអង្គ

ទ្រង់ទទួលបាត្រទៅចុះ” តែគិតយ៉ាងនេះថា “ព្រះសាស្ដា គង់នឹងទទួលបាត្រត្រង់ក្បាលជណ្ដើរ” សូម្បីក្នុងទីនោះព្រះសាស្ដាក៏មិនបានទ្រង់ទទួល ។ នន្ទកុមារក៏គិតថា “គង់នឹងទ្រង់ទទួលត្រង់ទីជិតជើងជណ្ដើរ” ។ សូម្បីក្នុងទីនោះ ព្រះសាស្ដាក៏មិនទ្រង់ទទួល ។ នន្ទកុមារគិតទៀតថា “នឹងទ្រង់ទទួលត្រង់ព្រះទីលានស្ដេច ( លានហ្លួង )” សូម្បីក្នុងទីនោះព្រះសាស្ដាក៏មិនទ្រង់ទទួល ។ ព្រះកុមារប្រាថ្នានឹងយាងត្រឡប់ ( តែ ) ស្ដេចយាងទៅដោយការមិនគាប់ព្រះទ័យ ដោយសារសេចក្ដីគោរពចំពោះព្រះតថាគត ទើបមិនអាចទូលថា “សូមព្រះអង្គទ្រង់ទទួលបាត្រចុះ” ទ្រង់យាងដោយការនឹកគិតថា “ព្រះអង្គនឹងទ្រង់ទទួលក្នុងទីនេះ, ព្រះអង្គនឹងទ្រង់ទទួលក្នុងទីនេះ” ក្នុងខណៈនោះ ស្ដ្រីពួកដទៃឃើញអាការនោះហើយ ក៏ប្រាប់នាងជនបទកល្យាណីថា “បពិត្រព្រះនាងម្ចាស់ ព្រះមានព្រះភាគទ្រង់នាំនន្ទកុមារស្ដេចទៅហើយ គង់នឹងពង្រាត់នន្ទកុមារអំពីព្រះនាងម្ចាស់ហើយ ” ។

ចំណែកជនបទកល្យាណីបានស្ដាប់ពាក្យនោះហើយ មាននូវ

ដំណក់ទឹកទាំងឡាយកំពុងហូរចេញអំពីសក់ទាំងឡាយ ដែលស្ត្រីទាំងឡាយសិតជ្រងឡើងហើយបានពាក់កណ្ដាល ប្រញាប់ទៅទូលថា "បពិត្រព្រះអយ្យបុត្រ សូមព្រះអយ្យបុត្រ ស្ដេចយាងមកឆាប់ៗណ៎" ។ ពាក្យនាងជនបទកល្យាណីនោះ ហាក់ដូចជាធ្លាក់ចុះទៅតាំងនៅទទឹងព្រះហឫទ័យនៃនន្ទកុមារ សូម្បីព្រះសាស្ដាក៏មិនទ្រង់ទទួលបាត្រអំពីដៃរបស់នន្ទកុមារនោះសោះឡើយ ទ្រង់នាំនន្ទកុមារនោះទៅកាន់វិហារ ហើយទ្រង់ត្រាស់សួរថា "នែ៎ នន្ទ អ្នកបួសឬ" នន្ទកុមារនោះ ដោយសារការគោរពចំពោះព្រះសាស្ដា ទើបមិនហ៊ានទូលថា "នឹងមិនបួស" ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណានឹងបួស" ព្រះសាស្ដា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះអ្នកទាំងឡាយចូរឲ្យនន្ទកុមារបួសចុះ" ។

## រាហុលកុមារទូលសូមកំណាប់ទ្រព្យអំពីព្រះសាស្ដា

ព្រះសាស្ដា ស្ដេចយាងទៅកាន់ក្រុងកបិលពស្ដុ ក្នុងថ្ងៃទី ៣ ទ្រង់ញ៉ាំងនន្ទកុមារឲ្យបួស, ក្នុងថ្ងៃទី ៧ ព្រះមាតារបស់ព្រះរាហុល-

កុមារទ្រង់ប្រដាប់តាក់តែងព្រះកុមារហើយ ទ្រង់បញ្ជូនទៅកាន់សំណាក់ព្រះមានព្រះភាគ ដោយព្រះតម្រាស់ថា “នែ៎ កូន កូនឯងចូរមើលព្រះសមណៈដែលមានសមណៈ ២ ម៉ឺនចោមរោមហែហម ទ្រង់មានពណ៌សម្បុរដូចមាស មានលម្អនៃរូបដូចព្រហ្ម, ព្រះសមណៈនោះជាព្រះបិតារបស់កូនឯង, ឃ្លាំងនៃកំណប់ទ្រព្យធំៗ ទាំងឡាយបានកើតហើយក្នុងកាលដែលព្រះបិតារបស់កូនឯងប្រសូត, ចាប់ដើមពីពេលដែលព្រះអង្គចេញបួស ម៉ែមិនដែលឃើញសោះឡើយ” កូនឯងចូលទៅសូមមត៌កអំពីព្រះអង្គថា “បពិត្រព្រះបិតា ខ្ញុំព្រះអង្គជាកុមារ, ដល់អភិសេកហើយ នឹងជាស្ដេចចក្រពត្តិ, ខ្ញុំព្រះអង្គមានសេចក្ដីត្រូវការដោយទ្រព្យ, សូមព្រះបិតាព្រះរាជទានកំណប់ទ្រព្យដល់ទូលព្រះបង្គំជាខ្ញុំ ត្បិតថា បុត្ររមែងជាម្ចាស់នៃសម្បត្តិរបស់ព្រះបិតា” ។ ព្រះ-កុមារស្ដេចយាងទៅកាន់សំណាក់ព្រះមានព្រះភាគ ថ្វាយបង្គំហើយត្រឡប់បាននូវសេចក្ដីស្នេហាក្នុងព្រះបិតា ត្រេកអរសប្បាយរីករាយហើយទូលថា “បពិត្រព្រះសមណៈ ព្រះឆាយារបស់សម្ដេចបិតាគួរ

ឲ្យជាទីជ្រះថ្លាណាស់” បានឈរពោលសូម្បីពាក្យដទៃដែលសមគួរដល់ខ្លួនជាច្រើន, ព្រះមានព្រះភាគទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយ ទ្រង់អនុមោទនាហើយ ស្តេចក្រោកចាកអាសនៈចៀសចេញទៅ ។ សូម្បីព្រះកុមារក៏ទូលសូមថា “បពិត្រព្រះសមណៈ សូមប្រទានមត៌កដល់ខ្ញុំព្រះអង្គចុះ, បពិត្រព្រះសមណៈ សូមប្រទានមត៌កដល់ខ្ញុំព្រះអង្គចុះ” ដូច្នេះហើយ ស្តេចជាប់តាមព្រះមានព្រះភាគទៅ ។ សូម្បីព្រះមានព្រះភាគក៏មិនទ្រង់ឲ្យព្រះកុមារត្រឡប់ ។ ចំណែកបរិជនក៏មិនអាចដើម្បីនឹងយាងព្រះកុមារ ដែលស្តេចយាងទៅជាមួយនឹងព្រះមានព្រះភាគឲ្យត្រឡប់បាន ។ ព្រោះហេតុដូច្នោះ ព្រះកុមារនោះបានស្តេចយាងទៅកាន់អារាមជាមួយនឹងព្រះមានព្រះភាគដែរ ។

ក្នុងលំដាប់នោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា “កុមារនេះចង់បានទ្រព្យដែលជាសម្បត្តិរបស់ព្រះបិតា ទ្រព្យនោះជាទ្រព្យប្រព្រឹត្តទៅតាមវដ្ដៈ ជាទ្រព្យប្រកបដោយសេចក្ដីចង្អៀតចង្អល់ ណ្ហើយចុះ តថាគតនឹងឲ្យអរិយទ្រព្យ ៧ ប្រការដែលតថាគតបានចំពោះ

ហើយទៀបគល់នៃពោធិព្រឹក្សដល់កុមារ និងធ្វើរាហុលកុមារឲ្យជាម្ចាស់នៃមត៌កដែលជាលោកុត្តរៈ ។

## រាហុលកុមារបព្វជ្ជា

គ្រានោះឯង ព្រះមានព្រះភាគទ្រង់ឲ្យហៅព្រះសារីបុត្រមកហើយត្រាស់ថា "ម្នាលសារីបុត្រ អ្នកចូរឲ្យរាហុលកុមារបួសចុះ" ។ ព្រះថេរៈញុំាងព្រះកុមារនោះឲ្យបួសហើយ ។ ក៏កាលព្រះកុមារនោះបួសហើយ ។ ទុក្ខមានប្រមាណយ៉ាងក្រៃលែងបានកើតឡើងដល់ព្រះរាជា ព្រោះបានទ្រង់ព្រះសណ្ដាប់នូវដំណឹងនោះ ។

ព្រះរាជាមិនអាចដើម្បីអត់សង្កត់នូវសេចក្ដីទុក្ខនោះបាន ស្ដេចយាងទៅកាន់សំណាក់ព្រះមានព្រះភាគ ទ្រង់ព្រមានហើយ ទូលសូមនូវពរថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមព្រះពរ លោកម្ចាស់ទាំងឡាយមិនគប្បីបំបួសនូវកុលបុត្រ ដែលមាតាបិតាមិនទាន់អនុញ្ញាត ព្រះមានព្រះភាគទ្រង់ថ្វាយព្រះពរនោះដល់ព្រះរាជាហើយ, ថ្ងៃស្អែកឡើង សោយព្រះក្រយាហារពេលព្រឹកក្នុងព្រះរាជនិវេសន៍ហើយ

កាលព្រះរាជាទ្រង់គង់ក្នុងទីដ៏សមគួរហើយពិតទូលថា "បពិត្រព្រះ-អង្គដ៏ចម្រើន ក្នុងវេលាដែលព្រះអង្គទ្រង់បំពេញទុក្ករកិរិយា ទេវតាមួយអង្គចូលទៅជួបខ្ញុំព្រះអង្គហើយប្រាប់ថា "ព្រះឱរសរបស់ព្រះអង្គសោយទិវង្គតហើយ" ខ្ញុំព្រះអង្គមិនជឿពាក្យរបស់ទេវតានោះ ទើបហាមឃាត់ទេវតានោះថា បុត្ររបស់យើងបើមិនទាន់បានសម្រេចនូវពោធិញាណទេ រមែងមិនធ្វើមរណកាលឡើយ ដូច្នេះហើយ ត្រាស់ថា "មហាបពិត្រ ឥឡូវនេះព្រះអង្គនឹងជឿបានដូចម្ដេច ? សូម្បីកាលមុន កាលព្រាហ្មណ៍សម្ដែងរាងឆ្អឹងដល់ព្រះអង្គ ទូលថា បុត្ររបស់ព្រះអង្គសោយទិវង្គតហើយ ព្រះអង្គមិនទ្រង់ជឿ" បានទ្រង់ត្រាស់មហាធម្មបាលជាតក ព្រោះឧប្បត្តិហេតុនៃរឿងនេះ ។ ក្នុងកាលចប់ព្រះគាថា ព្រះរាជាតាំងនៅក្នុងអនាគាមិផល ។

ព្រះមានព្រះភាគ ប្រោសព្រះបិតាឲ្យតាំងនៅក្នុងផល ៣ ដោយប្រការដូច្នេះហើយ មានភិក្ខុសង្ឃចោមរោមហែហម ស្ដេចយាងត្រឡប់ទៅកាន់ក្រុងរាជគ្រឹះវិញទៀត ពេលនោះទ្រង់ទទួលពាក្យប្ដេជ្ញា

របស់អនាថបិណ្ឌិកសេដ្ឋី ដើម្បីប្រយោជន៍ដល់ការយាងមកកាន់ក្រុងសាវត្ថី, នាកាលវត្តជេតពនមហាវិហាររួចស្រេចហើយ ស្ដេចយាងទៅចាំវស្សានៅក្នុងវត្តជេតពនមហារនោះ ។

## ព្រះនន្ទបង់សឹក

កាលព្រះសាស្ដា គង់នៅក្នុងវត្តជេតពនយ៉ាងនេះនោះឯង, ព្រះនន្ទកើតការអផ្សុកឡើងហើយ ទើបប្រាប់សេចក្ដីនោះដល់ភិក្ខុទាំង-ឡាយថា "អ្នកដ៏មានអាយុ ខ្ញុំមិនត្រេកអរចំពោះការប្រព្រឹត្តិព្រហ្ម-ចរិយៈ, មិនអាចនឹងបន្តការប្រព្រឹត្តិព្រហ្មចរិយៈទៅបានទៀតទេ, ខ្ញុំនឹងត្រឡប់ទៅជាភេទថោកទាបវិញ"។ ព្រះមានព្រះភាគទ្រង់ព្រះសណ្ដាប់នូវរឿងនោះហើយ ត្រាស់ឲ្យហៅព្រះនន្ទមកគាល់ ហើយត្រាស់ពាក្យនេះថា "នែ៎ នន្ទ បានឮថា អ្នកឯងប្រាប់ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា អាវុសោ ខ្ញុំមិនត្រេកអរចំពោះការប្រព្រឹត្តិព្រហ្មចរិយៈ មិនអាចនឹងបន្តការប្រព្រឹត្តិព្រហ្មចរិយៈទៅបានទៀតទេ, ខ្ញុំនឹងត្រឡប់ទៅជាភេទថោកទាបវិញហើយ យ៉ាងនេះពិតមែនឬ ?

ន. បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនុ៎ះមែន ។

ក. នែ៎ នន្ទ ក៏អ្នកមិនត្រេកអរចំពោះការប្រព្រឹត្តិព្រហ្មចរិយៈ, មិនអាចដើម្បីនឹងបន្តការប្រព្រឹត្តិព្រហ្មចរិយៈ, នឹងពោលលាសិក្ខា សឹកដើម្បីភេទដ៏ថោកទាប ដោយសារអ្វី ?

ន. បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គចេញមកអំពីផ្ទះ នាងជនបទកល្យាណី មានសក់ដែលស្ត្រីទាំងឡាយសិតជ្រងឡើង ហើយបានពាក់កណ្តាល បានស្រែកផ្តាំពាក្យយ៉ាងនេះនឹងខ្ញុំព្រះអង្គ ថា បពិត្រព្រះអយ្យបុត្ត សូមព្រះអយ្យបុត្តគប្បីមកឆាប់ៗណា៎ បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះឯង កាលរឭកដល់ពាក្យនោះ ទើប មិនត្រេកអរចំពោះព្រហ្មចរិយៈ មិនអាចដើម្បីបន្តនូវព្រហ្មចរិយៈបាន នឹងចង់សឹកមកដើម្បីភេទដ៏ថោកទាប ។

## ព្រះសាស្តាទ្រង់ទូន្មានព្រះនន្ទ

គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចាប់ដៃព្រះនន្ទត្រង់ដើម ដៃហើយ នាំទៅកាន់តាវត្តិង្សទេវលោកដោយកម្លាំងឫទ្ធិ, ក្នុងចន្លោះ

ផ្លូវទ្រង់សម្តែងមេស្វា ដែលមានរោមរបោចមួយ ដែលមានត្រចៀកប្រមុះ និងកន្ទុយដាច់ អង្គុយលើទីបំផុតនៃជង្គត់ដែលភ្លើងឆេះ ក្នុងស្រែដែលភ្លើងឆេះមួយ ហើយទ្រង់សម្តែងនាងទេពអប្សរ ៥០០ដែលមានជើងដូចជាជើងព្រាប ដែលមកកាន់ទីបម្រើនៃសក្កទេវរាជក្នុងតាវត្តិង្សព្ភពិភព ។

លុះទ្រង់សម្តែងហើយ ត្រាស់យ៉ាងនេះថា "នៃនន្ទ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ? ចំណែកណាហ្ន៎ ? មានរូបល្អជាង គួរដល់កិរិយាមៀងមើលជាង និងគួរជ្រះថ្លាជាង, នាងជនបទកល្យាណី ឬទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាបនេះ" ។ ព្រះនន្ទបានស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន មេស្វាដែលមានរោមរបោច មានត្រចៀក ប្រមុះ និងកន្ទុយដាច់នោះយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន នាងជនបទកល្យាណីក៏ដូច្នោះដែរ, ដោយការប្រៀបធៀបគ្នា នាងជនបទកល្យាណីរមែងមិនចូលដល់កិរិយារាប់ រមែងមិនដល់មួយចំណិត រមែងមិនដល់មួយចំណែកនៃ

នាងទេពអប្សរផង ដែលពិតនាងទេពអប្សរ ៥០០ នេះឯង មានរូបល្អជាង គួរឲ្យចង់មើលជាង និងគួរឲ្យជ្រះថ្លាជាង" ។

ក. ម្នាលនន្ទ អ្នកចូរត្រេកអរចុះ, ម្នាលនន្ទ អ្នកចូរត្រេកអរចុះ, តថាគតនឹងជាអ្នកធានាដើម្បីញុំាងអ្នកឲ្យបានចំពោះនាងទេព-អប្សរ ៥០០ ដែល មានជើងដូចជើងព្រាប ។

ខ. បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើព្រះមានព្រះភាគជាអ្នកធានាដើម្បីញុំាងខ្ញុំព្រះអង្គឲ្យបានចំពោះនាងទេពអប្សរ ៥០០ ដែលមានជើងដូចជាព្រាបសោត, ខ្ញុំព្រះអង្គនឹងត្រេកអរចំពោះព្រហ្មចរិយៈ ។

គ្រានោះឯង ព្រះមានព្រះភាគទ្រង់នាំព្រះនន្ទទៅបាត់អំពីទេវ-លោកនោះ ហើយបានមកប្រាកដក្នុងវត្តជេតពនដូចដើមវិញ ។

ភិក្ខុទាំងឡាយបានស្តាប់ហើយថា "បានឮថា ព្រះនន្ទជាព្រះអនុជរបស់ព្រះមានព្រះភាគ ជាបុត្ររបស់ព្រះមាតុច្ឆា ប្រព្រឹត្តព្រហ្ម-ចរិយៈព្រោះហេតុនៃនាងទេពអប្សរទាំងឡាយ, បានឮថា ព្រះមានព្រះភាគទ្រង់ជាអ្នកធានា ដើម្បីឲ្យព្រះនន្ទបានចំពោះនាងទេពអប្សរ

៥០០ ដែលមានជើងដូចជើងព្រាប” ។

## ព្រះនន្ទសម្រេចអរហត្តផល

គ្រានោះឯង ពួកភិក្ខុដែលជាសម្លាញ់របស់ព្រះនន្ទ ហៅព្រះនន្ទដោយវាទៈថា អ្នកស៊ីឈ្នួលផង ដោយវាទៈថា អ្នកដែលព្រះមានព្រះភាគទ្រង់លោះផងឬថា “ព្រះនន្ទជាអ្នកស៊ីឈ្នួលផង, ព្រះនន្ទដែលព្រះសាស្តាទ្រង់លោះហើយផង, ព្រះនន្ទប្រព្រឹត្តព្រហ្មចរិយៈព្រោះហេតុនៃនាងទេពអប្សរ ៥០០, បានឮថា ព្រះមានព្រះភាគទ្រង់ជាអ្នកធានាដើម្បីឲ្យព្រះនន្ទបានចំពោះនាងទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប” ។

គ្រានោះឯង ព្រះនន្ទចង្អៀតចង្អល់ ធុញទ្រាន់ ខ្មីមរអើមចំពោះវាទៈថា អ្នកស៊ីឈ្នួលផង ចំពោះវាទៈថា អ្នកដែលព្រះសាស្តាទ្រង់លោះមកផងរបស់ពួកភិក្ខុដែលជាសម្លាញ់ តែម្នាក់ឯងចៀសចេញទៅហើយ មិនប្រមាទ មានសេចក្តីព្យាយាម មានខ្លួនបញ្ជូនទៅហើយ មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់នូវទីបំផុតនៃព្រហ្មចរិយៈដ៏

កំពូល ដែលកុលបុត្រទាំងឡាយចេញចាកផ្ទះ បួសមិនមានផ្ទះ ដើម្បីប្រយោជន៍ដល់គុណវិសេសឯណា បានសម្រេចនូវគុណវិសេសនោះ ដោយប្រពៃណីក្នុងទិដ្ឋធម៌ ដឹងច្បាស់ថា "ជាតិអស់ហើយ, ព្រហ្មចរិយៈចប់ហើយ, កិច្ចដែលត្រូវធ្វើៗ រួចស្រេចហើយ, កិច្ចដទៃដើម្បីភាពជាយ៉ាងនេះទៀតមិនមាន" ។ ជាការសម្តែងថា ព្រះនន្ទបានជាព្រះអរហន្តមួយអង្គ ក្នុងបណ្តាព្រះអរហន្តទាំងឡាយ ។

គ្រានោះ ទេវតាមួយអង្គ ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាងក្នុងចំណែកនៃរាត្រីហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះនន្ទជាព្រះអនុជរបស់ព្រះមានព្រះភាគ ជាបុត្តរបស់ព្រះមាតុច្ឆា ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ ដោយការដឹងច្បាស់ដោយបញ្ញាដ៏ប្រពៃនៃខ្លួនឯង សម្រេចហើយនូវក្នុងទិដ្ឋធម៌ ។ ញាណបានកើតឡើងសូម្បីដល់ព្រះមានព្រះភាគ (ដែរ) ថា "នន្ទបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ

ដែលមិនមានអាសវៈ ព្រោះការអស់ទៅនៃអាសវៈទាំងឡាយដោយការដឹងច្បាស់ដោយបញ្ញាដ៏ប្រពៃរបស់ខ្លួនឯង សម្រេចហើយនៅក្នុងទិដ្ឋធម៌" ។ ព្រះនន្ទនោះ ដោយកាលកន្លងទៅនៃរាត្រីនោះ ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ បានក្រាបទូលពាក្យនេះថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ជាអ្នកធានាដើម្បីឲ្យខ្ញុំព្រះអង្គបានចំពោះនូវនាងទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាបដោយការអះអាងណា, បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដោះព្រះមានព្រះភាគអំពីការអះអាងជានានោះ"។ ព្រះមានព្រះភាគត្រាស់ថា "ម្នាលនន្ទ សូម្បីតថាគតក៏កំណត់ដឹងចិត្តរបស់អ្នកដោយចិត្ត ( របស់តថាគត ) ហើយជ្រាបថា "នន្ទបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់ទៅនៃអាសវៈ ដោយការដឹងដោយបញ្ញាដ៏ប្រពៃរបស់ខ្លួនឯង សម្រេចហើយនៅក្នុងទិដ្ឋ-ធម៌" ។ សូម្បីទេវតាក៏ប្រាប់សេចក្តីនេះដល់តថាគតថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះនន្ទបានធ្វើជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ

ដែលមិនមានអាសវៈ ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ប្រពៃរបស់ខ្លួនឯង សម្រេចហើយនៅក្នុងទិដ្ឋធម៌ ” ។ ម្នាលនន្ទ កាលណាចិត្តរបស់អ្នករួចផុតហើយចាកអាសវៈទាំងឡាយ ព្រោះការមិនប្រកាន់មាំ, កាលនោះ តថាគតក៏រួចផុតអំពីការធានានោះដែរ” គ្រានោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីនេះហើយ ទ្រង់បន្លឺឧទាននេះក្នុងវេលានោះថា ៖

ភក់ គឺកាមដែលបុគ្គលណាឆ្លងបានហើយ, បន្លា គឺកាមដែលបុគ្គលណាញាំញីបានហើយ បុគ្គលនោះដល់ហើយដោយលំដាប់ នូវកិរិយាអស់ទៅនៃមោហៈ រមែងមិនញាប់ញ័រក្នុងសុខ និងទុក្ខ ។

## ព្រះនន្ទត្រូវចោទប្រកាន់

ថ្ងៃមួយ ភិក្ខុទាំងឡាយសួរព្រះនន្ទថា “នែ៎ អាវុសោ នន្ទ កាលមុនលោកពោលថា “ខ្ញុំជាអ្នកអផ្សុកហើយ, ឥឡូវនេះ ចិត្តរបស់លោកយ៉ាងណាដែរ” ? ព្រះនន្ទឆ្លើយថា “អាវុសោ ការអាលោះអាល័យក្នុង

កាពជាគ្រហស្ថរបស់យើងមិនមាន" ។ ពួកភិក្ខុបានស្តាប់ពាក្យនោះ ហើយ ពោលថា ព្រះនន្ទពោលមិនពិត ព្យាករនូវព្រះអរហត្តផល, ក្នុងថ្ងៃមុនពោលថា ខ្ញុំជាអ្នកអផ្សុកហើយ (តែ) ឥឡូវនេះពោលថា សេចក្តីអាល័យក្នុងកាពជាគ្រហស្ថរបស់យើងមិនមាន ដូច្នេះហើយ ទៅក្រាបទូលសេចក្តីនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយក្នុងថ្ងៃមុនៗ អត្តភាពរបស់ព្រះនន្ទបាន ដូចជាផ្ទះដែលគេប្រក់មិនល្អ, (តែ) ឥឡូវនេះដូចជាផ្ទះដែលគេប្រក់ ល្អហើយ ព្រោះថា នន្ទនេះ ចាប់ដើមពីកាលដែលខ្លួនឃើញនាងទេព-អប្សរហើយ ព្យាយាមដើម្បីធ្វើនូវទីបំផុតនៃកិច្ចរបស់បព្វជិត បាន សម្រេចកិច្ចនោះហើយ" បានទ្រង់ភាសិតព្រះគាថានេះថា ៖

៩ យថា អគារំ ទុច្ឆន្នំ វុដ្ឋិ សមតិវិជ្ឈតិ
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។

ផ្ទះដែលប្រក់ខ្ជិះខ្ជាហើយ ដំណក់ទឹកភ្លៀង រមែងលិច
ស្រោចយ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំ

ទុកហើយ រាគៈរមែងចាក់ដោតយ៉ាងនោះឯង ។

**យថា អគារំ សុច្ឆន្នំ វុដ្ឋិ ន សមតិវិជ្ឈតិ**

**ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។**

ផ្ទះដែលប្រក់ល្អហើយ ដំណក់ទឹកភ្លៀង រមែងមិនលិចស្រោច យ៉ាងណាមិញ ចិត្តដែលបុគ្គលអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតបាន យ៉ាងនោះឯង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា អគារំ គឺនូវផ្ទះប្រភេទណាមួយ ។

បទថា ទុច្ឆន្នំ គឺដែលគេប្រក់រង្វើលៗ មានប្រហោងតូច និងធំ ។

បទថា **សមតិវិជ្ឈតិ** គឺគ្រាប់ភ្លៀងរមែងលិចស្រោចបាន ។

បទថា **អភាវិតំ** ជាដើម សេចក្ដីថា រាគៈរមែងចាក់ដោតចិត្តដែលបុគ្គលមិនបានអប់រំ ព្រោះជាធម្មជាតិឆ្ងាយអំពីភាវនា ដូចជាគ្រាប់ភ្លៀងលិចស្រោចផ្ទះនោះសព្វដូច្នោះ, មិនមែនជារាគៈម្យ៉ាង

ប៉ុណ្ណោះទេ, សព្វកិលេសទាំងឡាយ មានទោសៈ មោហៈ និងមានះជាដើម ក៏រមែងចាក់ធ្លុះចិត្តបែបនោះដូចគ្នាដែរ ។

បទថា **សុភាវិតំ** បានដល់ ដែលបានអប់រំល្អហើយ ដោយអំណាចសមថភាវនា និងវិបស្សនាភាវនា, កិលេសទាំងឡាយមានរាគៈជាដើម រមែងមិនអាចចាក់ធ្លុះចិត្តបែបនោះបានឡើយ ដូចគ្រាប់ភ្លៀងមិនអាចលិចស្រោចផ្ទះ ដែលគេប្រក់ល្អហើយបានដូច្នោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានមានប្រយោជន៍ដល់មហាជនហើយយ៉ាងនេះ ។

## ព្រះនន្ទត្រូវល្បួងលួងលោមអំពីមាតុគ្រាម

ក្រោយមក ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា "ម្នាលអាវុសោ ដែលឈ្មោះថា ព្រះពុទ្ធទាំងឡាយ ជាអច្ឆរិយបុគ្គលពិតៗ ព្រះនន្ទអាស្រ័យនាងជនបទកល្យាណីអផ្សុកហើយ ព្រះសាស្តាទ្រង់ធ្វើពួកនាងទេពអប្សរឲ្យជាអាមិស ( នុយ ) ទ្រង់ទូន្មានហើយ" ។ ព្រះ-

សាស្ដាស្ដេចយាងមកត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎?" កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយកថាឈ្មោះនេះ" ដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយមិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន នន្ទ និងតថាគតក៏បានល្បួងលួងលោមដោយមាតុគ្រាមហើយទ្រង់ទូន្មានដែរ" ដូច្នេះហើយ ដែលភិក្ខុទាំងនោះអារាធនា ទើបទ្រង់នាំអតីតនិទានមក ( ត្រាស់ថា ) ៖

## បុព្វកម្មរបស់ព្រះនន្ទ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រប់គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី បានមានឈ្មួញអ្នកក្រុងពារាណសីម្នាក់ ឈ្មោះកប្បកៈ លាឈ្មោលរបស់គាត់មួយនាំភារៈ ( វត្ថុ ) ទៅបានមួយកុម្ភៈ វាដើរទៅបានមួយថ្ងៃ ៧ យោជន៍, សម័យមួយ គាត់ទៅកាន់ក្រុងតក្កសិលា ( ព្រម ) ទាំងភារៈដែលនាំទៅដោយលា លេងលាទៅជរាបលក់ទំនិញអស់ ។ គ្រានោះ លានោះត្រាច់ទៅលើខ្នងប្រឡាយឃើញ

មេលាមួយក៏ចូលទៅរក ។ នាងលាកាលនឹងធ្វើបដិសណ្ឋារៈជាមួយនឹងលាឈ្មោលនោះ ទើបពោលថា "អ្នកមកអំពីទីណា" ?

លាឈ្មោល. មកពីក្រុងពារាណសី ។

លាញី. អ្នកមកដោយកម្មអ្វី ?

លាឈ្មោល. ដោយកម្មរបស់ឈ្នួញ ។

លាញី. អ្នកនាំទំនិញទៅបានប៉ុន្មាន ?

លាឈ្មោល. ទំនិញប្រមាណមួយកុម្ភៈ ។

លាញី. កាលអ្នកនាំទំនិញប្រមាណប៉ុណ្ណោះទៅ ទៅបានប៉ុន្មានយោជន៍ ?

លាឈ្មោល. បាន ៧ យោជន៍ ។

លាញី. ក្នុងទីដែលលោកទៅហើយ នាងលាណាមួយដែលជាអ្នកធ្វើការប្រេបាច់ជើង ឬគក់ខ្នងឲ្យដល់លោកមានដែរឬទេ ?

លាឈ្មោល. នែ៎ នាងដ៏ចម្រើន មិនមានទេ ។

លាញី. កាលបើដូច្នោះ លោករមែងសោយនូវទុក្ខធំ ?

ពិតណាស់ ដែលឈ្មោះថា អ្នកធ្វើកម្មមានការប្រេបាច់ជើង ជាដើម សម្រាប់សត្វតិរច្ឆានទាំងឡាយរមែងមិនមានសូម្បីដោយពិត ប៉ុន្តែ នាងលាពោលពាក្យបែបនោះ ដើម្បីការទាក់ទងដល់កាមសំយោជនៈ, លាឈ្មោលនោះអផ្សុកឡើងដោយពាក្យរបស់នាងលានោះ ។

ចំណែកកប្បកពាណិជ្ជ លក់ទំនិញអស់ហើយទៅកាន់ទីដែលលាស្នាក់នៅហើយពោលថា "នែ៎ បា អ្នកចូរមក យើងនឹងទៅ" លាឈ្មោលនោះឆ្លើយថា "លោកចូរទៅចុះ, ខ្ញុំមិនទៅទេ" លំដាប់នោះនាយកប្បកៈអង្វរលាឈ្មោលនោះហើយ អង្វរទៀត គិតថា "យើងនឹងញ៉ាំងលាដែលមិនប្រាថ្នានឹងទៅនោះឲ្យខ្លាចហើយនឹងនាំទៅ" ដូច្នេះហើយ ពោលគាថានេះថា ៖

យើងនឹងធ្វើជន្ទញមានបន្លាស្រួចប្រវែង ១៦ អង្គុលី
ដល់ឯង, យើងចាក់កាយរបស់ឯង នែ៎លា អ្នកឯង
ចូរដឹងយ៉ាងនេះចុះ" ។

លាបានស្តាប់ពាក្យនោះហើយ ឆ្លើយតបថា "កាលបើដូច្នោះ,

ខ្ញុំម្ចាស់ក៏នឹងដឹងកិច្ចដែលគួរធ្វើដល់លោកដែរ” ដូច្នេះហើយ ពោលគាថានេះថា ៖

លោកនឹងធ្វើជន្ទញមានបន្ទាស្រួចប្រវែង ១៦ អង្គុលី
ដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់នឹងជ្រែងអំពីខាងមុខ នឹងប្រាយ
ឡើងអំពីខាងក្រោយ ហើយញ៉ាំងទំនិញរបស់លោក
ឲ្យធ្លាក់ទៅ, កប្បក: លោកចូរដឹងយ៉ាងនេះចុះ ។

ឈ្មួញបានស្តាប់ពាក្យនេះហើយ ទើបត្រិះរិះថា “ដោយហេតុដូចម្តេចហ្ន៎ លានេះទើបពោលពាក្យនេះនឹងយើង” ? ដូច្នេះហើយកាលរមិលមើលខាងនោះខាងនេះ ឃើញនាងលានោះហើយ គិតថាលានេះប្រហែលជាត្រូវនាងលានេះបង្រៀនហើយយ៉ាងនេះ, យើងចាំបាច់ត្រូវល្បួងវាដោយមាតុគ្រាមថា យើងនាំនាងដែលមានរូបយ៉ាងនេះមកឲ្យឯង ។ ហើយនឹងនាំទៅ ដូច្នេះ ទើបពោលគាថានេះថា ៖

“យើងនឹងនាំនាងលាក្រមុំ មានជើង ៤ មានមុខដូច
ស័ង្ខ មានអវយវៈទាំងពួងដ៏ល្អ មកជាភរិយារបស់

ឯង នែលា អ្នកឯងចូរដឹងយ៉ាងនេះចុះ” ។

លាបានស្តាប់ពាក្យនោះហើយ ក៏មានចិត្តត្រេកអរ ពោលគាថានេះថា ៖

“លោកនឹងនាំនាងលាក្រមុំ មានជើង ៤ មានមុខដូចស័ង្ខ មានអវយវៈទាំងពួងដ៏ល្អ មកជាកិរិយារបស់ខ្ញុំម្ចាស់, បពិត្រកប្បកៈ លោកចូរដឹងយ៉ាងនេះចុះ ខ្ញុំម្ចាស់នឹងទៅឲ្យរហ័សក្រៃលែងដល់ ១៤ យោជន៍ ។

គ្រានោះ នាយកប្បកៈទើបពោលនឹងលានោះថា “បើដូច្នោះឯងចូរមកចុះ” ដូច្នេះហើយ បានទាញទៅកាន់ទីរបស់ខ្លួន ។ លានោះដោយកាលកន្លងទៅពីរបីថ្ងៃ ទើបពោលនឹងនាយកប្បកៈថា “លោកបាននិយាយនឹងខ្ញុំម្ចាស់ថា នឹងនាំកិរិយាមកឲ្យឯង, ដូច្នេះមិនមែនឬ” នាយកប្បកៈឆ្លើយថា អើ យើងពោលពិតមែនហើយ, យើងនឹងមិនទម្លាយពាក្យរបស់ខ្លួនទេ, នឹងនាំកិរិយាមកឲ្យឯង, តែយើងនឹងឲ្យអាហារដល់ឯងតែម្នាក់ប៉ុណ្ណោះ, អាហារនោះគ្រប់គ្រាន់ដល់ឯងដែលមាន

ប្រពន្ធជាគម្រប់ពីរ ឬមិនគ្រប់គ្រាន់ក្តី ឯងគប្បីដឹងខ្លួនឯងចុះ សូម្បីកូនទាំងឡាយដែលអាស្រ័យការរួមសង្វាសរបស់ឯងទាំងពីរ ក៏កើតឡើង, អាហារនោះគ្រប់គ្រាន់ដល់ឯង និងកូនជាច្រើនក្តី ឬមិនគ្រប់គ្រាន់ក្តី, ឯងចូរដឹងខ្លួនឯងចុះ" ។ កាលនាយកប្បកៈនោះពោលដូច្នោះបានជាអ្នកអស់សេចក្តីអាល័យហើយ ។

ព្រះសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ញុំាងជាតកឲ្យចប់ទៅដោយព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ នាងលាក្នុងកាលនោះបានមកជានាងជនបទកល្យាណី, លាឈ្មោលបានមកជានន្ទ, ឈ្មួញបានមកជាតថាគត, សូម្បីក្នុងកាលមុន នន្ទហ្នឹងតថាគតក៏បានល្បួងដោយមាតុគ្រាម ទូន្មានហើយដោយប្រការយ៉ាងនេះ" ដូច្នេះឯង ៕

( រឿងព្រះនន្ទ ចប់ )

# ១០ រឿងនាយចុន្ទសូករិក

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុរសឈ្មោះ ចុន្ទសូករិក ត្រាស់ព្រះធម្មទេសនានេះថា "ឥធ សោចតិ បេច្ច សោចតិ" ជាដើម ។

## <u>នាយចុន្ទចិញ្ចឹមជីវិតដោយការចិញ្ចឹមជ្រូកលក់</u>

បានឮមកថា នាយចុន្ទសូករិកនោះ សម្លាប់ជ្រូកទាំងឡាយ ស៊ីផង លក់ផង ចិញ្ចឹមជីវិតអស់ ៥៥ ឆ្នាំ ។ ក្នុងកាលនៃអ្នកជនបទមានសេចក្ដីអត់ឃ្លាន ស្រូវឡើងថ្លៃ គាត់យករទេះផ្ទុកស្រូវនាំទៅកាន់ជនបទ ដូរកូនជ្រូកអ្នកស្រុកដោយស្រូវប្រមាណមួយនាឡិ ឬក៏ពីរនាឡិ ផ្ទុកពេញរទេះហើយ ត្រឡប់មកវិញ ពន្ធព័ទ្ធទីកន្លែងមួយដូចជាក្រោលខាងក្រោយទីលំនៅ ហើយដាំបន្លែក្នុងទីនោះឯង ដើម្បីកូនជ្រូកទាំងនោះ, កាលកូនជ្រូកទាំងនោះទំពាស៊ីនូវបន្លែផ្សេងៗខ្លះ សរីរវលញ្ជៈ (កំអែលនៃសរីរៈ) ខ្លះ ក៏ធំធាត់ឡើង, (គាត់) មានការប្រាថ្នាដើម្បីនឹងសម្លាប់នូវជ្រូកណាៗ ក៏ចងជ្រូកនោះៗ ឲ្យមាំនៅត្រង់ទី

សម្លាប់ ហើយវាយដោយឈើ ៤ ជ្រុង ដើម្បីឲ្យសាច់ក្នុងសរីរៈជ្រូកប៉ោងឡើងក្រាស់ ដឹងថាសាច់ក្រាស់ឡើងហើយ ក៏បើកមាត់ស៊កកំណាត់ឈើចូលទៅក្នុងចន្លោះនៃធ្មេញ ជន៍ទឹកក្តៅដែលកំពុងពុះស្រោចចូលទៅក្នុងមាត់ដោយនាឡិលោហៈ ទឹកក្តៅនោះចូលទៅក្នុងពោះទាំងពុះក្តៅនាំយកនូវករីសចេញមកតាមចំណែកខាងក្រោម (ទ្វារលាមក) ករីសបន្តិចនៅមានដរាបណា រមែងចេញជាទឹកល្អក់ដរាបនោះ កាលពោះស្អាតហើយ, ទើបចេញជាទឹកថ្លា ជាទឹកមិនល្អក់, ពេលនោះទើបគាត់ចាក់ទឹកដែលនៅសល់លើខ្នងជ្រូកនោះ ។ ទឹកនោះញ៉ាំងស្បែកខ្មៅឲ្យរបើកចេញ ។ ក្នុងលំដាប់នោះទើបគាត់រោលនូវរោមទាំងឡាយដោយគប់ស្មៅ ហើយកាត់ក្បាលដោយដាវដ៏មុត ។ ត្រងឈាមដែលហូរចេញដោយភាជនៈ ប្រឡាក់នូវសាច់ដោយឈាម ហើយចំអិនអង្គុយទំពាស៊ីក្នុងកណ្តាលនៃបុត្រ និងភរិយា លក់នូវសាច់ដ៏សេស ។

កាលគាត់ចិញ្ចឹមជីវិតដោយទំនងនេះនោះឯង ពេលវេលាបានកន្លងទៅ ៥៥ ឆ្នាំ ។ កាលព្រះតថាគតទ្រង់គង់នៅក្នុងធុរវិហារ, ការបូជា

ដោយផ្កាត្រឹមតែមួយក្តាប់ក្តី ការថ្វាយកិក្ខាត្រឹមតែមួយវែកក្តី បុណ្យដទៃសូម្បីតែបន្តិចក្តី មិនបានមានហើយសូម្បីតែមួយថ្ងៃ ។

គ្រានោះ រោគកើតឡើងហើយក្នុងសរីរៈរបស់គាត់ កំដៅក្នុងអវិចិមហានរកប្រាកដដល់គាត់ទាំងកំពុងរស់នៅ ។

## អវិចិមហានរកក្តៅជាងភ្លើងធម្មតា

ដែលឈ្មោះថាកំដៅក្នុងអវិចិមហានរក រមែងជាសភាវៈដែលអាចទំលាយនូវភ្នែកទាំងឡាយ របស់អ្នកដែលឈរសម្លឹងមើលនៅក្នុងទីប្រមាណមួយរយយោជន៍បាន ។ សមដូចពាក្យ ដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ៖

"កំដៅក្នុងអវិចិមហានរក ផ្សាយទៅបានរហូត ១
រយយោជន៍ដោយជុំវិញ តាំងនៅគ្រប់កាល" ។

ហើយព្រោះហេតុតែកំដៅនៅក្នុងអវិចិនរកនោះ មានប្រមាណក្រៃលែងជាងកំដៅនៃភ្លើងធម្មតា ទើបព្រះនាគសេនត្ថេរពោលឧបមានេះទុកថា "មហាបពិត្រ សូម្បីថ្មប្រមាណប៉ុនផ្ទះកំពូល ដែលដាក់ចុះ

ទៅក្នុងភ្លើងនរក រមែងដល់ការលោយមួយរំពេចយ៉ាងណា ចំណែកឯសត្វដែលកើតក្នុងនរកនោះ ដូចជាសត្វដែលតាំងក្នុងផ្ទៃនៃមាតា រមែងមិនរលួយទៅព្រោះកម្លាំងនៃកម្ម ។

## នាយចុន្ទៈសោយផលកម្មទាន់ហន់

កាលកំដៅនោះប្រាកដដល់នាយចុន្ទសូករិកនោះហើយ, អាការៈដ៏សមគួរដល់កម្មក៏កើតឡើង ។ គាត់ស្រែកសំឡេងដូចជាជ្រូក ( ស្រែកដូចជាជ្រូក ) ត្រាច់ទៅដោយជង្គង់តែក្នុងកណ្តាលនៃផ្ទះនោះឯង, ម្តងទៅកាន់ទិសខាងកើត ម្តងទៅកាន់ទិសខាងលិច ។

គ្រានោះ ពួកមនុស្សដែលនៅក្នុងផ្ទះរបស់គាត់ ចាប់គាត់យ៉ាងមាំហើយបិទមាត់ ។ ធម្មតាផលនៃកម្ម អ្នកណាមួយមិនអាចដើម្បីហាមឃាត់បាន ។ គាត់ដើរស្រែកទៅខាងនោះផង ខាងនេះផង ។ មនុស្សក្នុងផ្ទះ ៧ ខ្នងដោយជុំវិញ រមែងមិនបានការលក់ ។ ម្យ៉ាងទៀត មនុស្សក្នុងផ្ទះទាំងអស់ កាលមិនអាចហាមនូវការចេញទៅខាងក្រៅរបស់គាត់ ដែលត្រូវមរណភ័យគម្រាមហើយ ទើបបិទទ្វារផ្ទះ

អន្តុយរក្សាខាងក្រៅផ្ទះ ដោយប្រការដែលគាត់នៅខាងក្នុង មិនអាចនឹងត្រាច់ទៅខាងក្រៅបាន ។

## សោយផលកម្មក្នុងសម្បរាយភព

សូម្បីនាយចុន្ទសូករិក ដើរស្រែកម្តងទៅខាងណោះ ម្តងមកខាងណេះ ខាងក្នុងផ្ទះនោះឯង ដោយកំដៅនៃភ្លើងនរក ។ គាត់ត្រាច់ទៅរហូតអស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៨ ធ្វើកាលកិរិយាហើយទៅកើតក្នុងអវិចិមហានរក ។ អវិចិមហានរក អ្នកប្រាជ្ញគប្បីពណ៌នាតាមទេវទូតសូត្រចុះ ។

## ពួកភិក្ខុយល់ថាគាត់សម្លាប់ជ្រូកធ្វើវិធីមង្គល

ពួកភិក្ខុកាលនិមន្តទៅតាមទ្វារផ្ទះរបស់គាត់ បានឮសំឡេងនោះហើយ ជាអ្នកមានការសម្គាល់ថា "សំឡេងជ្រូក" ទៅកាន់វិហារអង្គុយក្នុងសំណាក់ព្រះសាស្តា ហើយក្រាបទូលយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន កាលជ្រូកទាំងឡាយដែលនាយចុន្ទសូករិកបិទទ្វារផ្ទះសម្លាប់, ថ្ងៃនេះជាថ្ងៃទី ៧, មង្គលកិរិយាណាៗប្រហែលជាមានក្នុង

ផ្ទះ ( របស់គាត់ ), បពិត្រព្រះអង្គដ៏ចម្រើន មេត្តាចិត្ត ឬករុណាចិត្ត សូម្បីតែមួយរបស់គាត់ដែលជាអ្នកសម្លាប់ជ្រូកទាំងឡាយ មានប្រមាណប៉ុណ្ណោះមិនមាន, ក៏សត្វដែលជាអ្នកកាចឃោរឃៅយ៉ាងនេះខ្ញុំព្រះអង្គទាំងឡាយមិនធ្លាប់បានឃើញសោះឡើយ" ។

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ នាយចុន្ទសូករិកសម្លាប់ជ្រូករហូតអស់ ៧ ថ្ងៃនេះក៏ទេ ។ តែថា ផលដែលសមគួរដល់កម្មកើតឡើងហើយដល់គាត់ កំដៅនៃភ្លើងក្នុងអវិចិមហានរកប្រាកដដល់គាត់ទាំងដែលនៅរស់នោះឯង, ដោយកំដៅនៃភ្លើងនរកនោះ គាត់ស្រែកដូចជ្រូកត្រាច់ទៅក្នុងនិវេសន៍រហូតអស់ ៧ ថ្ងៃ ។ ថ្ងៃនេះធ្វើកាលកិរិយាហើយ ( ទៅ ) កើតក្នុងអវិចិ" កាលពួកភិក្ខុក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន គាត់សោកសៅយ៉ាងនេះក្នុងលោកនេះហើយ ទៅកើតក្នុងឋានដែលជាទីសោកសៅដដែលទៀតឬ" ? ព្រះសម្មាសម្ពុទ្ធត្រាស់ថា "អើ យ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថា អ្នកប្រមាទហើយ ទោះបីជាគ្រហស្ថក៏ដោយ បព្វជិតក៏ដោយ រមែងសោក

សៅក្នុងលោកទាំងពីរដោយពិតប្រាកដ” ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

**១០ ឥធ សោចតិ បេច្ច សោចតិ បាបការី ឧភយត្ថ**
**សោចតិ សោ សោចតិ សោ វិហញ្ញតិ ទិស្វា**
**កម្មកិលិដ្ឋមត្តនោ ។**

បុគ្គលអ្នកធ្វើបាប តែងសោកសៅក្នុងលោកទាំងពីរ
គឺសោកសៅក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១
បុគ្គលនោះ រមែងសោកសៅ ក្តៅក្រហាយ ព្រោះ
ឃើញអំពើសៅហ្មងរបស់ខ្លួន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **បាបការី** ជាដើម សេចក្តីថាបុគ្គលអ្នកធ្វើបាបកម្មមានប្រការផ្សេងៗ រមែងសោកសៅក្នុងលោកនេះ ក្នុងពេលជិតស្លាប់ដោយចំណែកមួយពិតប្រាកដ ដោយគិតថា “កម្មល្អយើងមិនទាន់បានធ្វើទុក កម្មអាក្រក់យើងធ្វើទុកហើយ” នេះជាការ

សោកសៅព្រោះកម្មរបស់គេ, ក៏កាលគេសោយផល រមែងសោកសៅក្នុងលោកខាងមុខ នេះជាសេចក្ដីសោកសៅព្រោះវិបាកក្នុងលោកខាងមុខរបស់គេ, គេរមែងសោកសៅក្នុងលោកទាំងពីរយ៉ាងនេះឯង, ដោយហេតុនោះឯង សូម្បីនាយចុន្ទសូករិកនោះ រមែងសោកសៅទាំងដែលខ្លួននៅរស់ ។

បាទព្រះគាថាថា **ទិស្វា កម្មកិលិដ្ឋមត្តនោ** សេចក្ដីថា គេឃើញកម្មដ៏សៅហ្មងរបស់ខ្លួនហើយ រមែងសោកសៅដោយប្រការផ្សេងៗ ដែលឈ្មោះថា រមែងក្ដៅក្រហាយ គឺរមែងលំបាក ។

ក្នុងកាលចប់គាថា ភិក្ខុជាច្រើនបានសម្រេចជាព្រះអរិយបុគ្គលមាន សោតាបន្ន ជាដើម ទេសនាបានមានប្រយោជន៍ហើយ ដល់មហាជនដោយប្រការដូច្នេះឯង ។

( រឿងនាយចុន្ទសូករិក ចប់ )

# ១១ រឿងធម្មិកឧបាសក

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធធម្មិកឧបា-សក ត្រាស់ព្រះធម្មទេសនានេះថា "**ឥធ មោទតិ បេច្ច មោទិ**" ជាដើម ។

## ឧបាសក និង ក្រុមគ្រួសារបំពេញកុសលជានិច្ច

បានឮមកថា ក្នុងក្រុងសាវត្ថី បានមានឧបាសកអ្នកបដិបត្តិធម៌ប្រមាណ ៥០០ នាក់ ។ បណ្តាឧបាសកទាំងនោះ មួយរូបៗ មានឧបាសកជាបរិវារប្រាំរយៗ ឧបាសកដែលជាប្រធាននៃឧបាសកទាំងនោះមានបុត្រ ៧ នាក់ ធីតា ៧ នាក់ ។ បណ្តាបុត្រ និងធីតាទាំងនោះម្នាក់ៗបានមានសលាកយាគូ, សលាកភត្ត, បក្ខិកភត្ត, សង្ឃភត្ត, ឧបោសថិកភត្ត, អាគន្តុកភត្ត, វស្សាវាសិកភត្តមួយៗ ។ ជនទាំងនោះបានជាអ្នកឈ្មោះថា អនុជាតបុត្រទាំងអស់គ្នា ។(ជាការដែលសំដែងថា ) សលាកយាគូជាដើមមួយៗ គឺរបស់បុត្រ ១៤ នាក់ របស់ភរិយាម្នាក់ របស់ឧបាសកម្នាក់ រមែងប្រព្រឹត្តទៅដោយប្រការដូច្នេះ ។

ឧបាសកព្រមទាំងបុត្រ និងភរិយាជាអ្នកមានសីល មានកល្យាណ-ធម៌ មានសេចក្ដីត្រេកអរក្នុងការចែកទាន ដោយប្រការដូច្នេះ ។ គ្រាក្រោយមក រោគកើតឡើងដល់គាត់ ។ អាយុសង្ខារសោបសូន្យដោយជុំវិញហើយ ។

## ឧបាសកឈឺដេកស្ដាប់ធម៌

ឧបាសកប្រាថ្នានឹងស្ដាប់ធម៌ទើបបញ្ជូន ( មនុស្ស ) ទៅកាន់សំណាក់ព្រះសាស្ដា ដោយក្រាបទូលថា "សូមព្រះអង្គមេត្តាបញ្ជូនភិក្ខុ ៨ រូប ឬ ១៦ រូប ដល់ខ្ញុំព្រះអង្គ ។ ព្រះសាស្ដា ទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅ ។ ភិក្ខុទាំងនោះនិមន្តទៅហើយអង្គុយលើអាសនៈដែលគេក្រាលទុក ពទ្ធគ្រែរបស់ឧបាសក ឧបាសកពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ការឃើញលោកម្ចាស់ដ៏ចម្រើនទាំងឡាយ នឹងជារបស់ដែលខ្ញុំព្រះករុណាបានដោយលំបាក, ខ្ញុំករុណាជាមនុស្សទុព្វលភាព, សូមលោកម្ចាស់ទាំងឡាយ ចូរស្វាធ្យាយនូវព្រះសូត្រណាមួយដល់ខ្ញុំព្រះអង្គចុះ ។

ទើបសួរថា “ម្នាលឧបាសក លោកប្រាថ្នានឹងស្តាប់នូវសូត្រណា” ? កាលឧបាសកប្រាប់ថា “សតិប្បដ្ឋានសូត្រដែលព្រះពុទ្ធគ្រប់ព្រះអង្គមិនទ្រង់លះបង់ហើយ” ទើបផ្តើមសូធ្យព្រះសូត្រថា “**ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា**” ជាដើម “ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវមូលតែមួយប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ” ។

## ទេវតានាំរថមកទទួលឧបាសកទៅទេវលោក

ក្នុងខណៈនោះ រថ ៦ គ្រឿង ប្រដាប់ដោយអលង្ការគ្រប់យ៉ាងទឹមដោយសេះសិន្ធពមួយពាន់ ទំហំប្រមាណបាន ១៥៥ យោជន៍ មកអំពីទេវលោក ៦ ជាន់ ។ ទេវតាដែលឈរនៅលើរថទាំងនោះ ម្នាក់ៗក៏អញ្ជើញថា “បពិត្រលោកដ៏ចម្រើន យើងនឹងនាំលោកទៅកាន់ទេវលោករបស់យើង យើងនឹងនាំលោកទៅកាន់ទេវលោករបស់យើង, សូមលោកកើតក្នុងទីនេះ ដើម្បីសេចក្តីត្រេកអរក្នុងទេវលោករបស់យើង ដូចបុគ្គលដែលទម្លាយភាជនៈដី ហើយកាន់យកភាជនៈមាស” ។

ឧបាសកមិនប្រាថ្នានឹងឲ្យអន្តរាយដល់ការស្តាប់ធម៌ ទើបពោលថា "អ្នកទាំងឡាយ ចូរបង្អង់សិន ចូរបង្អង់សិន" ។

## ពួកភិក្ខុ និង បុត្រធីតារបស់ឧបាសកយល់ខុស

ភិក្ខុមួយអង្គៗ ឈប់ស្ងៀមដោយយល់ថា "ឧបាសកនិយាយមកកាន់ពួកយើង" ។ គ្រានោះ បុត្រ និងធីតារបស់ឧបាសកគិតថា "បិតារបស់ពួកយើងពីមុន ជាអ្នកមិនឆ្អែតដោយការស្តាប់ធម៌, តែឥឡូវនេះ ស្រាប់តែឲ្យនិមន្តភិក្ខុមកធ្វើកាសូធ្យាយហើយ ឃាត់ដោយខ្លួនឯង ដែលឈ្មោះថា សត្វអ្នកមិនខ្លាចចំពោះសេចក្តីស្លាប់ មិនមាន" ដូច្នេះហើយ បានយំកន្ទក់កន្ទេញ ។

ពួកភិក្ខុប្រឹក្សាគ្នាថា "ឥឡូវនេះមិនជាឱកាស" ទើបក្រោកអំពីអាសនៈចៀសចេញទៅ ឧបាសកញ៉ាំងវេលាបន្តិចឲ្យកន្លងទៅហើយ ត្រឡប់បានស្មារតីសួរកូនៗថា ព្រោះហេតុអ្វី ទើបពួកឯងនាំគ្នាកន្ទក់កន្ទេញ" ?

ពួកបុត្រទើបប្រាប់ថា "បពិត្របិតា បិតាឲ្យនិមន្តភិក្ខុមកហើយ

ស្ដាប់ធម៌ ហាមឃាត់ដោយខ្លួនឯង, កាលបើដូច្នេះ ពួកខ្ញុំក៏គិតថា ឈ្មោះថា សត្វអ្នកមិនខ្វាចសេចក្ដីស្លាប់ មិនមាន” ដូច្នេះ ទើបកន្ទក់កន្ទេញ ។

ឧ. ក៏លោកម្ចាស់ដ៏ចម្រើនទាំងឡាយ ទៅណាអស់ ?

ប៉ុ. បពិត្របិតា លោកម្ចាស់ដ៏ចម្រើនទាំងឡាយ លោកនិយាយគ្នាថា “មិនជាឱកាស ក្រោកចាកអាសនៈចៀសចេញទៅហើយ” ។

ឧ. បិតាមិនបាននិយាយជាមួយនឹងលោកម្ចាស់ដ៏ចម្រើននោះទេ ។

ប៉ុ. បើដូច្នេះ បិតានិយាយជាមួយនឹងនរណា ?

ទេវតាប្រដាប់រថ ៦ គ្រឿង នាំមកអំពីទេវលោក ៦ ជាន់ចតនៅឰដ៏អាកាសមួយអន្លើៗធ្វើនូវសំឡេងថា សូមលោកចូរត្រេកអរក្នុងទេវលោករបស់ខ្ញុំម្ចាស់, សូមលោកត្រេកអរក្នុងទេវលោករបស់ខ្ញុំម្ចាស់ បិតានិយាយជាមួយនឹងទេវតាទាំងនោះ ។

ប៉ុ. បពិត្របិតា រថនៅទីណា ពួកខ្ញុំមិនឃើញ ?

ឧ. ក៏កម្រងផ្កាដើម្បីបិតា មានដែរទេ ?

បុ. បពិត្របិតា មាន ។

ឧ. ទេវលោកជាន់ណា គួរជាទីត្រេកអរជាង ។

បុ. បពិត្រព្រះបិតា ភពតុសិតដែលជាទីនៅនៃព្រះពោធិសត្វគ្រប់ព្រះអង្គ នៃព្រះពុទ្ធមាតា និងនៃព្រះពុទ្ធបិតា ជាទីត្រេកអរជាង ។

ឧ. បើដូច្នោះ ពួកកូនឯងចូរអធិដ្ឋានថា "សូមកម្រងផ្កានេះចូរចតនៅហ្នឹងរថដែលមកអំពីភពតុសិត, ដូច្នេះហើយ ចូរបោះកម្រងផ្កាទៅចុះ" ។

បុត្រទាំងឡាយនោះបានបោះកម្រងផ្កាទៅហើយ ។ កម្រងផ្កានោះបានជាប់ហ្នឹងនឹមនៃរថសំយុងចុះព្ធដ៏អាកាស ។ មហាជនឃើញតែកម្រងផ្កានោះ មិនឃើញរថទេ ។ ឧបាសកនិយាយថា អ្នកទាំង-ឡាយឃើញកម្រងផ្កានោះទេ" ? កាលបុត្រឆ្លើយថា "ឃើញ" ទើបពោលថា "កម្រងផ្កានោះព្យួរនៅហ្នឹងរថដែលមកអំពីតុសិត យើងនឹងទៅកាន់តុសិត ពួកឯងកុំព្រួយឡើយ, ពួកឯងមានសេចក្តីប្រាថ្នានឹងកើតក្នុងសំណាក់របស់យើង ក៏ចូរធ្វើបុណ្យទាំងឡាយតាមទំនងដែល

យើងធ្វើហើយចុះ ដូច្នេះហើយ ធ្វើកាលកិរិយា បដិសន្ធិនៅលើរថដែលមកអំពីភពតុសិត អត្តភាពរបស់គាត់កំពស់ប្រមាណ ៣ គាវុតប្រដាប់ដោយគ្រឿងអលង្ការ ៦០ រទេះកើតហើយក្នុងខណៈនោះឯង ។ នាងទេពអប្សរមួយពាន់ចោមរោមហើយ ។ វិមានកែវប្រមាណ ២៥ យោជន៍ កើតប្រាកដហើយ ។

ព្រះសាស្តា ត្រាស់សួរភិក្ខុទាំងនោះ ដែលជាអ្នកមកដល់វិហារហើយដោយលំដាប់ថា "ម្នាលភិក្ខុទាំងឡាយ ឧបាសកបានស្តាប់ធម្មទេសនាហើយឬ ? បពិត្រព្រះអង្គដ៏ចម្រើន បានស្តាប់ហើយ ប៉ុន្តែឧបាសកបានហាមឃាត់នូវពួកខ្ញុំព្រះអង្គក្នុងចន្លោះនោះឯងថា "សូមលោកបង្អង់សិន, ខណៈនោះបុត្រ និងធីតារបស់ឧបាសកនោះកន្ទក់កន្ទេញ, ពួកខ្ញុំព្រះអង្គក៏ប្រឹក្សាគ្នាថា ក្នុងកាលឥឡូវនេះ មិនជាឱកាស, ទើបក្រោកចាកអាសនៈចេញមក" ។

ម្នាលភិក្ខុទាំងឡាយ ឧបាសកនោះមិនបានពោលហ្នឹងពួកអ្នកទេ, ក៏ទេវតាប្រដាប់រថ ៦ គ្រឿង នាំមកអំពីទេវលោក ៦ ជាន់

អញ្ជើញឧបាសកនោះ លោកមិនប្រាថ្នានឹងធ្វើអន្តរាយដល់ការសម្តែងធម៌ ទើបពោលហាមនឹងទេវតាទាំងនោះ ។

ភ. បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះពិតមែនឬ ?

ស. ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ។

ភ. ឥឡូវនេះ ឧបាសកនោះកើតនៅទីណា ?

ស. ម្នាលភិក្ខុទាំងឡាយ ក្នុងតុសិតទេវលោក ។

ភ. បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកនោះបាននូវការរីករាយក្នុងកណ្តាលនៃក្រុមញាតិនៅក្នុងលោកនេះហើយ ឥឡូវនេះកើតនៅក្នុងឋានមួយដែលជាទីរីករាយដដែលទៀតឬ ?

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ព្រោះបុគ្គលអ្នកមិនប្រមាទហើយទាំងឡាយ ទោះបីជាគ្រហស្ថក្តី បព្វជិតក្តី រមែងបាននូវការរីករាយក្នុងលោកទាំងពួងដោយពិត" ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា ៖

**១១ ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ**

សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ
គឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១
បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញ
អំពើបរិសុទ្ធរបស់ខ្លួន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **កតបុញ្ញោ** ជាដើម សេចក្ដីថា បុគ្គលអ្នកធ្វើកុសលមានប្រការផ្សេងៗ រមែងរីករាយដោយការរីករាយព្រោះកម្មក្នុងលោកនេះថា "កម្មអាក្រក់យើងមិនបានធ្វើទេ, កម្មល្អយើងបានធ្វើហើយហ្ន៎" លះបង់លោកនេះទៅហើយ រមែងរីករាយដោយការរីករាយព្រោះវិបាក, ឈ្មោះថា រមែងរីករាយក្នុងលោកទាំងពីរ យ៉ាងនេះឯង ។

បទថា **កម្មវិសុទ្ធឹ** ជាដើម សេចក្ដីថា សូម្បីធម្មិកឧបាសកក៏ឃើញកម្មដ៏បរិសុទ្ធ គឺការដល់ព្រមនៃបុញ្ញកម្មរបស់ខ្លួនហើយ ក្នុង

កាលមុនអំពីការធ្វើកាលកិរិយា រមែងរីករាយសូម្បីក្នុងលោកនេះ, ធ្វើកាលកិរិយាស្លាប់ទៅហើយ ឥឡូវនេះក៏រមែងរីករាយ គឺរមែងរីករាយក្រៃលែងពិត សូម្បីក្នុងលោកខាងមុខ ។

កាលចប់គាថា ជនជាច្រើនបានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើម, ព្រះធម្មទេសនាបានមានប្រយោជន៍ដល់មហាជនដូច្នេះឯង ។

( រឿងធម្មិកឧបាសក ចប់ )

# ១២ រឿងទេវទត្ត

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះទេវ-ទត្តត្រាស់ព្រះធម្មទេសនានេះថា "**ឥធ តប្បតិ បេច្ច តប្បតិ**" ជាដើម ។

## <u>សក្យៈទាំង ៦ អង្គទ្រង់ព្រះផ្នួស</u>

រឿងព្រះទេវទត្ត ព្រះសាស្ដាត្រាស់ជាតកទាំងអស់ ដែលទ្រង់ប្រារព្ធព្រះទេវទត្តឲ្យពិស្ដារហើយ តាំងពីវេលាដែលផ្នួសរហូតដល់ត្រូវផែនដីស្រូប ។ ក៏សេចក្ដីសង្ខេបក្នុងរឿងព្រះទេវទត្តនេះ មានដូចតទៅនេះ ៖

កាលព្រះសាស្ដា ទ្រង់អាស្រ័យនិគមឈ្មោះ អនុបិយៈ របស់ពួកមល្លក្សត្រ ទ្រង់គង់នៅក្នុងអនុបិយអម្ពវ័ននោះឯង, ក្នុងថ្ងៃទទួលព្រះលក្ខណៈរបស់ព្រះតថាគតនោះ ត្រកូលព្រះញាតិ ៨ ម៉ឺនប្រគល់ព្រះឱរស ៨ ម៉ឺនឲ្យដោយពាក្យថា "សិទ្ធត្ថកុមារជាព្រះរាជាក៏ដោយ ជាព្រះពុទ្ធក៏ដោយ, និងមានក្សត្រជាបរិវារត្រាច់ទៅ" កាលព្រះឱរស

ទាំងនោះបួសហើយដោយច្រើន, ពួកព្រះញាតិឃើញសក្យៈ ៦ ព្រះអង្គ គឺភទ្ទិយរាជ អនុរុទ្ធ អានន្ទ ភគ្គុ កិម្ពិលៈ ទេវទត្ត មិនទាន់បានបួស ក៏សន្ទនាគ្នាថា "ពួកយើងញ៉ាំងកូនៗ របស់ខ្លួនឲ្យបួសបាន, សក្យៈទាំង ៦ នេះប្រហែលជាមិនមែនព្រះញាតិទេដឹង ? ព្រោះដូច្នោះ ទើបមិនបានទ្រង់ព្រះផ្នួស" ។

គ្រានោះ មហានាមសក្យៈ ចូលទៅរកព្រះអនុរុទ្ធហើយត្រាស់ថា "ម្នាលប្អូន អ្នកដែលចេញបួសអំពីត្រកូលរបស់យើងមិនទាន់មាន, ប្អូននឹងបួស ឬថា បងនឹងបួស" ក៏អនុរុទ្ធកុមារនោះជាក្សត្រសុខុមាលជាតិ មានភោគសម្បូណ៌ សូម្បីពាក្យថា "មិនមាន" ព្រះអង្គក៏មិនធ្លាប់ទ្រង់ព្រះសណ្ដាប់ ។ ពិតណាស់ ថ្ងៃមួយ កាលក្សត្រទាំង ៦ ព្រះអង្គនោះទ្រង់ល្បែងកូនឃ្លី អនុរុទ្ធកុមារទ្រង់បរាជ័យដោយនំ ហើយបញ្ជូន (មនុស្ស) ទៅដើម្បីត្រូវការនំ ។ គ្រានោះ ព្រះមាតារបស់លោកទ្រង់ចាត់ចែងនំបញ្ជូនទៅ ។ ក្សត្រទាំងឡាយសោយហើយ ទ្រង់លេងទៀត ។ ព្រះអនុរុទ្ធនោះឯងជាចំណែកចាញ់រឿយៗ ទៅ ។ ចំណែក

ព្រះមាតាកាលព្រះអនុរុទ្ធបញ្ជូនមនុស្សទៅហើយទៅទៀត ក៏បញ្ជូននំទៅដល់ ៣ ដង ក្នុងវារៈទី ៤ ផ្តាំទៅថា "នំមិនមាន" ព្រះកុមារទ្រង់សម្គាល់ថា "នំនេះនឹងជានំប្លែកមួយប្រភេទ" ព្រោះទ្រង់មិនធ្លាប់បានឮពាក្យថា "មិនមាន" ក៏បញ្ជូនមនុស្សទៅថា "ចូរនាំនំមិនមាននោះមកចុះ" ។

ចំណែកព្រះមាតារបស់ព្រះអនុរុទ្ធ កាលគេទូលថា "បពិត្រព្រះនាងម្ចាស់ សូមព្រះនាងម្ចាស់ប្រទាននំមិនមាន" ទើបទ្រង់ព្រះតម្រិះថា "កូនរបស់យើងមិនធ្លាប់បានឮពាក្យថា ( មិនមាន ) តែយើងនឹងឲ្យដឹងសេចក្តីនោះដោយឧបាយនេះ" ទើបទ្រង់បិទថាសមាសទទេដោយថាសមាសដទៃហើយបញ្ជូនទៅ ។

ពួកទេវតាដែលថែរក្សាព្រះនគរគិតថា ព្រះអនុរុទ្ធសក្យៈបានថ្វាយភត្តដែលជាចំណែកខ្លួន ដល់ព្រះបច្ចេកពុទ្ធព្រះនាមថា ឧបរិដ្ឋៈក្នុងកាលដែលខ្លួនជាអន្នភារៈ ទ្រង់ធ្វើសេចក្តីប្រាថ្នាទុកថា ( សូមខ្ញុំព្រះអង្គកុំបានស្តាប់ពាក្យថា ( មិនមាន ) កុំស្គាល់ទីកើតនៃភោគៈ, បើព្រះ

អនុរុទ្ធនេះនឹងទ្រង់ឃើញថាសទទេសោត, ពួកយើងក៏នឹងមិនបានចូលទៅកាន់ទេវសមាគម, ទាំងសិរសោរបស់ពួកយើងក៏នឹងបែកជា ៧ ចំរៀក” ពេលនោះ ក៏បានធ្វើថាសនោះឲ្យពេញដោយនំទិព្វ ថាសនោះលុះគេដាក់ចុះត្រង់ទីលានលេងល្បែងកូនឃ្លីហើយក៏បើកឡើង ក្លិននំផ្សាយទៅពេញទាំងព្រះនគរ ។ ចំណិតនំនោះគ្រាន់តែក្សត្រទាំង ៦ ចាប់ដាក់ចូលទៅក្នុងព្រះឱស្ឋប៉ុណ្ណោះ ក៏ផ្សាយទូទៅពេញប្រសាទសម្រាប់ទទួលរសទាំង ៧ ពាន់ ។

ព្រះកុមារនោះទ្រង់ព្រះតម្រិះថា “យើងគង់នឹងមិនជាទីស្រឡាញ់របស់ព្រះមាតា ទើបព្រះមាតាមិនទ្រង់ធ្វើនំមិនមាននេះប្រទានដល់យើង រហូតអស់វេលាដល់ត្រឹមនេះ, ចាប់តាំងពីនេះទៅ យើងនឹងមិនស៊ីនំដទៃ” ដូច្នេះហើយ ស្តេចយាងទៅកាន់ជំណាក់ ទូលសួរព្រះមាតាថា “បពិត្រព្រះមាតា ខ្ញុំព្រះអង្គជាទីស្រឡាញ់របស់ព្រះមាតា ឬក៏មិនជាទីស្រឡាញ់ទេ” ?

ម. នែ៎ កូន កូនឯងរមែងជាទីស្រឡាញ់យ៉ាងក្រៃលែងរបស់

ព្រះមាតា ដូចដួងភ្នែករបស់អ្នកដែលមានតែភ្នែកម្ខាង និងដូចដួងចិត្ត របស់ព្រះមាតា ដូច្នោះ ។

អ. កាលបើដូច្នោះ ព្រោះហេតុដូចម្ដេច ទើបព្រះមាតាមិនទ្រង់ធ្វើនំមិនមានប្រទានឲ្យដល់ទូលព្រះបង្គំជាខ្ញុំ រហូតអស់កាលត្រឹមមានប្រមាណប៉ុណ្ណេះ ។

ព្រះនាងសាកសួរមហាតលិកដែលស្និទ្ធស្នាលថា "នំអ្វីៗ មាននៅក្នុងថាសឬ"? មហាតលិកទូលថា "បពិត្រព្រះនាងម្ចាស់ ថាសពេញទៅដោយនំ, នំបែបនេះទូលបង្គំក៏មិនធ្លាប់បានឃើញដែរ" ។ ព្រះនាងទ្រង់ព្រះតម្រិះថា "បុត្ររបស់យើងនឹងជាអ្នកមានបុណ្យ មានអភិនីហារបានធ្វើទុកហើយ, ទេវតាទាំងឡាយនឹងដាក់នំឲ្យពេញថាសហើយបញ្ជូនទៅ ។ លំដាប់នោះ ទើបព្រះឱរសទូលព្រះមាតាថា "បពិត្រព្រះមាតាចាប់តាំងពីថ្ងៃនេះទៅ បុត្រនឹងមិនសោយនំដទៃ, សូមព្រះមាតាគប្បីធ្វើនំមិនមានតែម្យ៉ាងឲ្យដល់ខ្ញុំ" ។ ចាប់តាំងពីនោះមកសូម្បីព្រះនាង កាលព្រះកុមារនោះទូលថា "បុត្រត្រូវការសោយ

នំ” ក៏ទ្រង់គ្របថាសទទេនោះឯងដោយថាសដទៃ បញ្ជូនទៅប្រទាន ដល់កុមារនោះ ។ ទេវតាទាំងឡាយបញ្ជូនទំនិពថ្វាយព្រះកុមារនោះ រហូតដែលលោកនៅជាយរាវាស ។

## សក្យៈទាំងពីរសន្ទនាគ្នាអំពីរឿងបួស និង ការងារ

ព្រះកុមារនោះ កាលមិនទ្រង់ជ្រាបសូម្បីពាក្យមានប្រមាណប៉ុណ្ណេះ នឹងទ្រង់ជ្រាបដល់ការបួសបានយ៉ាងណា ? ព្រោះដូច្នោះ ទើបព្រះអនុរុទ្ធទូលសួរព្រះជេដ្ឋាថា “ការបួសនេះតើដូចម្តេច” ? កាលព្រះមហានាមត្រាស់ថា “អ្នកបួសត្រូវកោរសក់ និងពុកមាត់ ពុកចង្កា ត្រូវស្លៀកដណ្តប់សំពត់កាសាយៈ ត្រូវដេកលើកម្រាលស្លឹកឈើ ឬលើគ្រែដែលក្រងដោយផ្តៅ ត្រាច់បិណ្ឌបាត នេះឈ្មោះថាការបួស” ទើបទូលថា “បពិត្រម្ចាស់បង ខ្ញុំជាសុខុមាលជាតិ, ខ្ញុំនឹងមិនអាចបួសបានទេ” ។ ព្រះមហានាមត្រាស់ថា “នែប្អូន បើដូច្នោះ ប្អូនឯងចូររៀនការងាររបស់យរាវាសចុះ ក៏ក្នុងបណ្តាយើងទាំងពីរនាក់ ប្រសិនបើមិនមាននរណាម្នាក់បួសមិនសមគួរសោះឡើយ” ។

ខណៈនោះ អនុរុទ្ធកុមារទូលសួរព្រះម្ចាស់បងថា "ដែលឈ្មោះថាការងារនេះដូចម្តេចដែរ ? កុលបុត្រដែលមិនដឹងសូម្បីទីកើតនៃភត្តនឹងធ្វើការងារបានយ៉ាងណា ?

## សក្យៈទាំង ៣ សន្ទនាគ្នាអំពីទីកើតនៃភត្ត

ក៏ថ្ងៃមួយ ការសន្ទនាគ្នាបានកើតឡើងដល់សក្យៈទាំង ៣ ព្រះអង្គថា "ភត្តកើតឡើងទីណា ?" កិម្ពិលកុមារឆ្លើយថា "កើតឡើងក្នុងជង្រុក គ្រានោះ ភទ្ទិយកុមារត្រាស់ជំទាស់កិម្ពិលកុមារថា "អ្នកមិនទាន់ជ្រាបទីកើតនៃភត្ត, ដែលឈ្មោះថាភត្ត រមែងកើតឡើងត្រង់ឆ្នាំងបាយ" ។ អនុរុទ្ធកុមារត្រាស់ជំទាស់ថា "សូម្បីអ្នកទាំងពីរក៏មិនទាន់ទ្រង់ជ្រាបធម្មតាភត្តរមែងកើតឡើងក្នុងថាសមាសប្រមាណ ១ ហត្ថក្តាប់ ។

បានឮមកថា បណ្តាក្សត្រទាំង ៣ អង្គនោះ ថ្ងៃមួយ កម្ពិល-កុមារទ្រង់ឃើញគេជញ្ជូនស្រូវចេញអំពីជង្រុក ក៏យល់ក្នុងព្រះទ័យថា "ស្រូវទាំងនេះកើតឡើងហើយក្នុងជង្រុកនោះឯង" ។

ចំណែកព្រះភទ្ទិយកុមារ ថ្ងៃមួយ ទ្រង់ឃើញគេដួសភត្តចេញ

អំពីឆ្នាំងបាយក៏យល់ក្នុងព្រះទ័យថា "កត្តកើតឡើងក្នុងឆ្នាំងបាយនោះឯង" ។

ចំណែកអនុរុទ្ធកុមារ ទ្រង់មិនដែលឃើញអ្នកគរស្រូវ អ្នកដាំបាយ ឬអ្នកដួសបាយអ្វីទាំងអស់, ទ្រង់ឃើញតែបាយ ដែលគេដួសហើយកម្ពល់ទុកចំពោះព្រះភក្ត្រប៉ុណ្ណោះ ។ ទើបព្រះអង្គទ្រង់យល់ក្នុងព្រះទ័យថា "កត្តកើតឡើងក្នុងថាស ក្នុងវេលាដែលត្រូវការបរិភោគ" ក្សត្រទាំង ៣ ព្រះអង្គនោះ រមែងមិនទ្រង់ជ្រាបសូម្បីទីកើតនៃកត្តដោយប្រការយ៉ាងនេះ ។ ព្រោះហេតុដូច្នោះ អនុរុទ្ធកុមារនេះ ក៏ទូលសួរថា "ដែលឈ្មោះថា ការងារនេះតើដូចម្តេច ? លុះបានទ្រង់ស្តាប់កិច្ចការដែលឃរាវាសទឹងគប្បីធ្វើប្រចាំឆ្នាំ មានជាអាទិថា "ដំបូងត្រូវឲ្យភ្ជួរស្រែ" ទើបត្រាស់ថា "ទីបំផុតនៃការងារទាំងឡាយនឹងប្រាកដនៅពេលណា, កាលណា ទើបខ្ញុំនឹងមានការខ្វល់ខ្វាយតិច ប្រើប្រាស់ភោគៈបានទៅ" កាលព្រះមហានាមត្រាស់ប្រាប់ការមិនមានទីបំផុតនៃការងារទាំងឡាយហើយ ទូលថា "បើយ៉ាងនោះសូមម្ចាស់បងនោះឯង ទ្រង់គ្រប់គ្រងឃរាវាសចុះ ខ្ញុំមិនត្រូវការភាពជាឃរាវាសនោះ

ទេ” ដូច្នេះហើយ ចូលគាល់ព្រះមាតា ក្រាបទូលថា “បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាតឲ្យខ្ញុំចុះ ខ្ញុំនឹងបួស” កាលព្រះនាងទ្រង់ហាមដល់ ៣ ដង ត្រាស់ថា “បើព្រះភទ្ទិយៈដែលជាសម្លាញ់របស់កូននឹងបួសសោត, ចូរកូនបួសព្រមជាមួយនឹងព្រះអង្គចុះ” ទើបចូលទៅគាល់ព្រះភទ្ទិយៈនោះទូលថា “សម្លាញ់ ការបួសរបស់ខ្ញុំជាប់ទាក់នឹងព្រះអង្គ ដូច្នេះហើយ បានញ៉ាំងព្រះភទ្ទិយៈនោះឲ្យយល់ព្រមដោយប្រការផ្សេងៗ ។ ក្នុងថ្ងៃទី ៧ ទ្រង់ទទួលបេ្តជ្ញាដើម្បីប្រយោជន៍បួសជាមួយនឹងព្រះអង្គ ។

## ឧបាលិចេញបួសជាមួយនឹងសក្យៈទាំង ៦ អង្គ

ពេលនោះ ក្សត្រទាំង ៦ អង្គនេះ គឺ ភទ្ទិយសក្យរាជ អនុរុទ្ធ អានន្ទ ភគ្គុ កិម្ពិលៈ និងទេវទត្ត មានឧបាលិដែលជានាយកូសាមាលាជាគម្រប់ ៧ ទ្រង់សោយមហាសម្បត្តិរហូត ៧ ថ្ងៃ ដូចទេវតាសោយទិព្វសម្បត្តិ, ហើយស្តេចយាងចេញដោយចតុរង្គសេនា ដូចស្តេចយាងទៅកាន់ព្រះឧទ្យាន ដល់ដែននៃក្សត្រអង្គដទៃហើយ ទ្រង់បញ្ជូនកងទ័ពទាំងអស់ឲ្យត្រឡប់ទៅដោយព្រះរាជអាជ្ញា ស្តេចយាង

ចូលទៅកាន់ដែននៃក្សត្រអន្តដទៃ ក្នុងបណ្ដាមនុស្សទាំង ៧ នាក់នោះ ក្សត្រ ៦ ព្រះអង្គ ទ្រង់ដោះអាភរណៈរបស់ខ្លួនៗ ធ្វើជាកញ្ចប់ហើយ ត្រាស់ថា "នែ៎ នាយឧបាលិ អញ្ជើញលោកត្រឡប់ទៅវិញចុះ ទ្រព្យប៉ុណ្ណេះល្មមចិញ្ចឹមជីវិតរបស់លោកបានហើយ" ដូច្នេះហើយ ប្រទានដល់ឧបាលិ ។ ឧបាលិបម្រះននៀលហើយខ្សឹកខ្សួលទៀបទីជិតព្រះ-បាទនៃក្សត្រទាំងនោះហើយ ទើបក្រោកឡើងកាន់កញ្ចប់អាភរណៈនោះត្រឡប់ទៅ ។ ក្នុងកាលនៃជនទាំងនោះកើតជាពីរពួក ព្រៃហាក់ដូចជាដល់នូវការទួញយំ, ផែនដីហាក់ដូចជាដល់នូវអាការញាប់ញ័រ ។ ចំណែកឧបាលិកូសាមាលាទៅបានបន្តិច ក៏ត្រឡប់គិតយ៉ាងនេះថា "ពួកសក្យៈកាចសម្បើមណាស់ នឹងគប្បីសម្លាប់យើងដោយការយល់ក្នុងព្រះទ័យថា "ព្រះកុមារទាំងឡាយត្រូវបុគ្គលផ្ដាច់ព្រះជន្មហើយដូច្នេះក៏បាន, ក៏ធម្មតាថា សក្យកុមារទាំងនេះ ទ្រង់លះបង់សម្បត្តិបែបនេះ បោះបង់ចោលអាភរណៈដែលកាត់ថ្លៃមិនបានទាំងនេះ ដូចដុំស្ដោះ ហើយនឹងបួស, ចុះអញមានអ្វីជាហេតុ មានអ្វីជាជំទាស់

ទើបនឹងមិនបួស ? លុះគិត ( ដូច្នេះ ) ហើយ ក៏ស្រាយបង្វិចទ្រព្យ
ចេញយកអាភរណៈទាំងនោះព្យួរទុកហ្នឹងដើមឈើ ហើយពោលថា
"អ្នកដែលមានសេចក្ដីត្រូវការចូរកាន់យកចុះ" ដូច្នេះហើយ ទៅកាន់
សំណាក់នៃសក្យកុមារទាំងនោះ សក្យៈទាំងនោះត្រាស់សួរថា "ព្រោះ
ហេតុអ្វី ក៏លោកត្រឡប់មកវិញ" ? គេក្រាបទូលសេចក្ដីនោះ ។

## សក្យៈទាំង ៦ អង្គសម្រេច

គ្រានោះ សក្យកុមារទាំងនោះ ទ្រង់នាំនាយកូសាមាលាឈ្មោះ
ឧបាលិទៅកាន់សំណាក់ព្រះសាស្ដា ថ្វាយបង្គំព្រះមានព្រះភាគហើយ
ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយជាសក្យៈ
មានការប្រកាន់ខ្លួនជាប្រចាំ ( សន្ដាន ) បុរសនេះជាអ្នកបម្រើពួកខ្ញុំព្រះ
អង្គរហូតអស់កាលយូរ, សូមព្រះអង្គមេត្តាឲ្យបុរសនេះបួសមុនចុះ,
ខ្ញុំព្រះអង្គទាំងឡាយនឹងធ្វើសាមីចិកម្ម មានការអភិវាទជាដើមដល់គេ
ការប្រកាន់ខ្លួនរបស់ខ្ញុំព្រះអង្គទាំងឡាយ នឹងអស់ទៅដោយអាការ
យ៉ាងនេះ" ដូច្នេះហើយ ឲ្យនាយកូសាមាលាឈ្មោះឧបាលិនោះបួស

មុន ទើបខ្ញុំនឯងបួសជាខាងក្រោយ ។ បណ្ដាសក្យៈទាំង ៦ អង្គនោះ ព្រះភទ្ទិយៈបានជាព្រះអរហន្តតេវិជ្ជាក្នុងរវាងវស្សានោះឯង ។ ព្រះ-អនុរុទ្ធជាអ្នកមានចក្ខុជាទិព្វ ខាងក្រោយមកទ្រង់ស្ដាប់មហាបុរិស-វិតក្កសូត្រក៏បានសម្រេចព្រះអរហត្ត ។ ព្រះអានន្ទបានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះភគ្គុត្ថេរ និងព្រះកិម្ពិលៈ ខាងក្រោយមកចំរើនវិបស្សនាបានសម្រេចព្រះអរហត្ត ។ ព្រះទេវទត្តបានសម្រេចឫទ្ធិដែលជារបស់បុថុជ្ជន ។

## ព្រះទេវទត្តសម្ដែងឫទ្ធិដល់អជាតសត្តុរាជកុមារ

ក្នុងកាលតមក កាលព្រះសាស្ដាគង់នៅក្នុង ក្រុងកោសម្ពី, លាភ និងសក្ការៈជាច្រើនកើតឡើងដល់ព្រះសាស្ដាព្រមទាំងព្រះ-សង្ឃសាវក ។ មនុស្សទាំងឡាយដែលនៅក្នុងក្រុងកោសម្ពីនោះ មានដៃកាន់សំពត់ និងភេសជ្ជៈជាដើមចូលទៅកាន់វិហារ ហើយសួរគ្នាថា "ព្រះសាស្ដាទ្រង់គង់នៅទីណា ? ព្រះសារីបុត្តត្ថេរនៅទីណា ? ព្រះ-មហាមោគ្គល្លានត្ថេរនៅទីណា ? ព្រះមហាកស្សបនៅទីណា ? ព្រះ-

កុទ្ទិយត្រូវនៅទីណា ? ព្រះអនុរុទ្ធត្រូវនៅទីណា ? ព្រះអានន្ទត្រូវនៅទីណា ? ព្រះភគុត្រូវនៅទីណា ? ព្រះកម្ពិលត្រូវនៅទីណា ? ដូច្នេះហើយ ដើរត្រួតមើលទីអង្គុយរបស់ព្រះអសីតិមហាសាវក ។ ដែលឈ្មោះថាមានអ្នកសួរថា "ព្រះទេវទត្តត្រូវគង់ ឬឈរនៅទីណា" ? ដូច្នេះរមែងមិនមាន ព្រះទេវទត្តនោះក៏គិតថា យើងបួសព្រមជាមួយនឹងសក្យៈទាំងនេះដែរ ។ សក្យៈទាំងនេះជាខត្តិយបព្វជិត ។ សូម្បីយើងក៏ជាខត្តិយបព្វជិតដែរ ។ ពួកមនុស្សមានដៃកាន់លាភ និងសក្ការស្វែងរកលោកទាំងនេះ, គ្មានអ្នកណាមួយសួររកឈ្មោះរបស់យើងសោះ យើងនឹងសមាគមជាមួយនឹងនរណាហ្ន៎ គប្បីញុំាងនរណាឲ្យជ្រះថ្លា ហើយញុំាងលាភ និងសក្ការឲ្យកើតដល់យើង" ។ គ្រានោះការត្រិះរិះនេះមានដល់ព្រះទេវទត្តថា ព្រះបាទពិម្ពិសារព្រមទាំងបរិវារ ១១ នហុត ទ្រង់តាំងនៅក្នុងសោតាបត្តិផលហើយ ដោយការជួបព្រះសម្មាសម្ពុទ្ធតាំងពីគ្រាដំបូងម៉្លេះ, យើងមិនអាចសមាគមជាមួយនឹងព្រះរាជានោះបានទេ សូម្បីជាមួយនឹងព្រះបាទកោសល យើងក៏មិន

អាចសមាគមបានដែរ, ចំណែកព្រះអជាតសត្តុកុមារដែលជាឱរសរបស់ព្រះពិម្ពិសារនោះឯងមិនទាន់ដឹងនូវគុណ និងទោសរបស់អ្នកណាមួយ យើងនឹងសមាគមជាមួយនឹងកុមារនោះ” ព្រះទេវទត្តនោះក៏ចេញពីក្រុងកោសម្ពីទៅកាន់ក្រុងរាជគ្រឹះ និម្មិតនូវភេទជាកុមារតូចប្រដាប់អសិរពិស ៤ ព្ធដ៏ដៃ និងជើងទាំងឡាយ មួយត្រង់ក មួយធ្វើជាឈ្នួតត្រង់ក្បាល មួយពាក់ចៀងស្មាម្ខាង, ចុះចាកអាកាសដោយសង្ហារជាវិការៈនៃពស់ អង្គុយលើព្រះភ្លៅរបស់ព្រះអជាតសត្តុកុមារ, កាលព្រះកុមារនោះទ្រង់ខ្លាចហើយ ត្រាស់សួរថា “លោកជានរណា”? ក៏ថ្វាយព្រះពរថា “អាត្មាភាព គឺទេវទត្តដើម្បីនឹងបន្ទោបង់ការខ្លាចរបស់ព្រះកុមារ ក៏ផ្លាស់នូវអត្តភាពនោះមកជាភិក្ខុទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរឈរនៅចំពោះព្រះភក្ត្រ ញ៉ាំងព្រះកុមារនោះឲ្យទ្រង់ជ្រះថ្លា ញ៉ាំងលាភ និងសក្ការឲ្យកើតឡើងហើយដល់ខ្លួន ។

## ទេវទត្តព្យាយាមសម្លាប់ព្រះសម្មាសម្ពុទ្ធ

ព្រះទេវទត្តដែលត្រូវលាភ និងសក្ការគ្របសង្កត់ហើយ ញ៉ាំង

គំនិតដ៏លាមកឲ្យកើតឡើងថា "យើងនឹងគ្រប់គ្រងភិក្ខុសង្ឃ" ដូច្នេះហើយ ក៏សាបសូន្យចាកឫទ្ធិព្រមនឹងចិត្តុប្បាទដែលកើតឡើងនោះឯងថ្វាយបង្គំព្រះសាស្ដាដែលកំពុងសម្ដែងធម៌ដល់បរិស័ទ ព្រមទាំងព្រះរាជាក្នុងវត្តវេឡុវ័ន ក្រោកចាកអាសនៈហើយឈរផ្គងអញ្ជលីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពេលនេះព្រះមានព្រះភាគទ្រង់ព្រះជរាហើយ សូមព្រះមានព្រះភាគចូរទ្រង់ជាអ្នកខ្វល់ខ្វាយតិច ប្រកបរឿយៗ នូវធម៌ដែលជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌ចុះ, ខ្ញុំព្រះអង្គនឹងគ្រប់គ្រងភិក្ខុសង្ឃ សូមព្រះអង្គមេត្តាប្រគល់ភិក្ខុសង្ឃឲ្យដល់ខ្ញុំព្រះអង្គចុះ" ដូច្នេះហើយ ត្រូវព្រះសាស្ដាទ្រង់តិះដៀលដោយខេឡាសិក-វាទៈ[១] ទ្រង់ហាមឃាត់ហើយ, មិនពេញចិត្ត បានចងអាឃាតនេះនឹងព្រះសាស្ដា ជាលើកដំបូងហើយចៀសចេញទៅ ។

គ្រានោះ ព្រះមានព្រះភាគ ត្រាស់បញ្ជាឲ្យធ្វើបកាសនីយកម្ម[២] ក្នុងក្រុងរាជគ្រឹះដល់លោកហើយ, ទេវទត្តគិតថា "ឥឡូវយើងត្រូវព្រះ

[១] អ្នកបរិច្ចាគបច្ច័យដូចទឹកមាត់ (២) កម្មដែលសង្ឃគួរប្រកាស

សមណគោតមកម្ចាត់ហើយ, ឥឡូវនេះ យើងនឹងធ្វើសេចក្ដីវិនាសឲ្យដល់ព្រះសមណគោតម” ដូច្នេះហើយ ក៏ចូលទៅគាល់ព្រះរាជកុមារអជាតសត្តុ ទូលថា “បពិត្រព្រះកុមារ កាលមុនមនុស្សទាំងឡាយមានអាយុវែង, តែឥឡូវនេះមនុស្សមានអាយុខ្លី, ក៏ការដែលព្រះអង្គគប្បីសោយទិវង្គតតាំងពីនៅជាព្រះកុមារនោះ ជាឋានៈដែលប្រព្រឹត្តទៅបាន, បពិត្រព្រះកុមារ បើដូច្នោះ ព្រះអង្គចូរសម្លាប់នូវព្រះបិតាហើយចូរជាព្រះរាជាចុះ អាត្មាសម្លាប់ព្រះមានព្រះភាគហើយ នឹងជាព្រះពុទ្ធដែរ” កាលព្រះកុមារនោះតាំងនៅក្នុងរាជសម្បត្តិហើយ បានញុំាងព្រះរាជកុមារឲ្យទ្រង់បញ្ជូនបុរសទាំងឡាយទៅដើម្បីនឹងសម្លាប់ព្រះតថាគត, កាលបុរសទាំងនោះសម្រេចសោតាបត្តិផលហើយ ត្រឡប់មកវិញ, ក៏ឡើងកាន់ភ្នំគិជ្ឈកូដខ្លួនឯង ប្រមៀលថ្មដោយបំណងថា “យើងនឹងផ្ដាច់ផ្ដិលនូវព្រះសមណគោតមចាកជីវិតដោយខ្លួនឯង” បានធ្វើកម្ម គឺញុំាងព្រះលោហិតព្រះពុទ្ធឲ្យពុះពងឡើង, កាលមិនអាចសម្លាប់ដោយឧបាយសូម្បីបែបនេះ ក៏ញុំាងព្រះបាទអជាតសត្តុឲ្យ

បញ្ជារជបុរសឲ្យលែងនាឡាគិរីទៅទៀត, កាលដំរីនោះកំពុងដើរមក ព្រះអានន្ទត្ថេរព្រមលះបង់ជីវិតរបស់ខ្លួនថ្វាយព្រះសាស្ដា បានឈរបាំងនៅចំពោះព្រះភក្ត្រ ។

ព្រះសាស្ដា ទ្រង់ទូន្មានដំរីហើយ ស្ដេចចេញចាកព្រះនគរមកកាន់ព្រះវិហារ ទ្រង់សោយមហាទានដែលឧបាសកច្រើនពាន់នាំមកចំពោះហើយ ទ្រង់សំដែងអនុបុព្វីកថាប្រោសអ្នកក្រុងរាជគ្រឹះរាប់បាន ១៨ កោដិ ដែលប្រជុំគ្នាក្នុងថ្ងៃនោះ ធម្មាភិសម័យកើតមានដល់សត្វប្រមាណ ៨៤០០០ នាក់ ។

ព្រះមានព្រះភាគ ទ្រង់ព្រះសណ្ដាប់នូវកថាដែលពណ៌នាគុណរបស់ព្រះថេរៈថា "ឱ ហ្ន៎ ព្រះអានន្ទមានគុណច្រើនណាស់ កាលស្ដេចដំរីបែបនោះមក, បានព្រមលះបង់ជីវិតរបស់ខ្លួនឈរបាំងនៅចំពីមុខព្រះភក្ត្រព្រះសាស្ដា" ដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងកាលមុន អានន្ទនេះ ក៏ព្រមលះបង់ជីវិតដើម្បីប្រយោជន៍តថាគតហើយដែរ" ដែលភិក្ខុទាំងឡាយទូល

អាពាធនាហើយ ទើបទ្រង់ត្រាស់ចុល្លហង្សជាតក មហា ហង្សជាតក និងកក្ការុជាតក ។

## កម្មអាក្រក់របស់ព្រះទេវទត្តប្រាកដដល់មហាជន

កម្មរបស់ព្រះទេវទត្ត ព្រោះញុំាងព្រះអជាតសត្តុកុមារឲ្យសម្លាប់ព្រះបិតាក្ដី ព្រោះចាត់ចែងនាយខ្មាន់ធ្នូក្ដី ព្រោះប្រមៀលសិលាក្ដី មិនបានប្រាកដដូចការលែងដំរីនាឡាគិរីឡើយ ។ គ្រានោះឯង មហាជនបានជ្រួលជ្រើមថា សូម្បីព្រះរាជាក៏ព្រះទេវទត្តនោះឯងជាអ្នកចាត់ឲ្យសម្លាប់ សូម្បីនាយខ្មាន់ធ្នូក៏ព្រះទេវទត្តនោះឯងជាអ្នកចាត់ឲ្យបញ្ជូនទៅ សូម្បីសិលាក៏ព្រះទេវទត្តជាអ្នកប្រមៀលដែរ ។ ហើយ ឥឡូវនេះ លោកក៏បានលែងដំរីនាឡាគិរី, ព្រះរាជាទ្រង់សេពគប់នូវបុគ្គលដ៏លាមកបែបនេះ" ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវសំដីរបស់មហាជនហើយ ក៏បញ្ជាឲ្យនាំសម្រាប់ ៥០០ មកវិញ ហើយព្រះអង្គក៏មិនបានយាងទៅកាន់ទីបម្រើរបស់ព្រះទេវទត្តនោះទៀត, សូម្បីអ្នកនគរក៏មិនបានថ្វាយសូម្បីនូវភិក្ខាតិចតួច ដល់លោកដែលជាអ្នក

ចូលទៅកាន់ត្រកូល ។

## ព្រះទេវទត្តទូលសូមវត្ថុ ៥ ប្រការ

ព្រះទេវទត្តនោះសាបសូន្យចាកលាភ និងសក្ការហើយ ប្រាថ្នានឹងចិញ្ចឹមជីវិតដោយការបោកប្រាស ទើបចូលទៅគាល់ព្រះសាស្តា ទូលសូមវត្ថុ ៥ ប្រការ ត្រូវព្រះមានព្រះភាគទ្រង់ហាមថា "ម្នាលទេវទត្ត កុំឡើយ ភិក្ខុអង្គណាប្រាថ្នានឹងនៅព្រៃ ភិក្ខុអង្គនោះ ក៏ចូរជាអ្នកនៅព្រៃចុះ ដូច្នេះហើយ ទូលថា "ម្នាលអាវុសោ ពាក្យរបស់អ្នកណាល្អ របស់ព្រះតថាគត ឬក៏របស់យើង ត្បិតថាយើងពោលដោយអំណាចនៃការប្រតិបត្តិយ៉ាងឧក្រិដ្ឋយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស សូមភិក្ខុទាំងឡាយចូរជាអ្នកនៅព្រៃដរាបអស់ជីវិត ត្រាច់បិណ្ឌបាត ទ្រទ្រង់សំពត់បង្សុកូល នៅក្បែរគល់ឈើ កុំគប្បីឆាន់ត្រី និងសាច់រហូតអស់មួយជីវិត" ហើយពោលថា "ភិក្ខុណាប្រាថ្នានឹងរួចចាកទុក្ខ ភិក្ខុនោះចូរមកជាមួយនឹងយើង" ដូច្នេះហើយ ក៏ចៀសចេញទៅ ។ ភិក្ខុពួកខ្លះទើបតែបួសថ្មី មានការចេះ

ដ៏ឯតិចតួច បានស្តាប់ពាក្យរបស់ព្រះទេវទត្តនោះហើយ បបួលគ្នាថា "ព្រះទេវទត្តនិយាយត្រឹមត្រូវ ពួកយើងនឹងត្រាច់ទៅជាមួយនឹងព្រះទេវទត្តនោះ" ដូច្នេះហើយ ក៏បានសមាគមជាមួយនឹងព្រះទេវទត្ត ។

## ព្រះទេវទត្តបំបែកសង្ឃ

ព្រះទេវទត្តនោះ ញ៉ាំងជនដែលជាអ្នកជ្រះថ្លាក្នុងវត្ថុដ៏សៅហ្មង ឲ្យយល់ដោយវត្ថុ ៥ ប្រការនោះហើយ ព្រមជាមួយនឹងភិក្ខុ ៥០០ អង្គ ដើរសូម "បច្ច័យ" ក្នុងត្រកូលទាំងឡាយមកបរិភោគ ព្យាយាមដើម្បីបំបែកសង្ឃ ។ លោកដែលត្រូវព្រះមានព្រះភាគត្រាស់សួរថា "ម្នាលទេវទត្ត បានឮថា អ្នកឯងព្យាយាមដើម្បីទម្លាយសង្ឃ ដើម្បីទម្លាយចក្រពិតឬ" ? ក៏ទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពិតមែនហើយ"។សូម្បីព្រះអង្គទ្រង់ត្រាស់ទូន្មានដោយព្រះពុទ្ធវចនៈ មានជាអាទិថា "ម្នាលទេវទត្ត ការទម្លាយសង្ឃមានទោសធ្ងន់ណាស់" ក៏មិនបានអើពើចំពោះព្រះវាចារបស់ព្រះសាស្តាឡើយ ហើយក៏ចៀសចេញទៅ បានជួបព្រះអានន្ទដែលកំពុងត្រាច់ទៅបិណ្ឌបាតក្នុងក្រុង

រាជគ្រឹះ បានពោលនឹងព្រះអានន្ទថា ម្នាលអាវុសោ អានន្ទ ចាប់តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំករុណានឹងធ្វើឧបោសថ នឹងធ្វើសង្ឃកម្មវៀរចាកព្រះមានព្រះភាគ វៀរចាកភិក្ខុសង្ឃហើយ ។

ព្រះថេរៈក្រាបទូលសេចក្តីនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីនោះហើយ កើតធម្មសង្វេគ ទ្រង់ព្រះតម្រិះថា "ទេវទត្តធ្វើកម្មជាហេតុឲ្យខ្លួនឆេះក្នុងអវីចិមហានរក ដែលទាក់ទងដល់ការវិនាសដល់សត្វលោកព្រមទាំងទេវលោក" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯង ជនពាលធ្វើបានដោយលំបាកយ៉ាងក្រៃលែង ។

ទ្រង់បន្លឺព្រះឧទាននេះទៀតថា ៖

កម្មល្អមនុស្សល្អធ្វើបានដោយងាយ កម្មល្អមនុស្សអាក្រក់

ធ្វើបានដោយលំបាក កម្មអាក្រក់មនុស្សអាក្រក់ធ្វើបានដោយងាយ កម្មអាក្រក់ព្រះអរិយៈធ្វើបានដោយកម្រ ។

គ្រានោះឯង ព្រះទេវទត្តអង្គុយនៅក្នុងចំណោកម្ខាងជាមួយនឹងបរិស័ទរបស់ខ្លួនក្នុងថ្ងៃឧបោសថ ពោលថា "វត្ថុ ៥ ប្រការនេះ រមែងពេញចិត្តដល់ភិក្ខុណា, ភិក្ខុនោះចូរចាប់ស្លាក" កាលពួកភិក្ខុវជ្ជីបុត្ត ៥០០ រូប ដែលជាអ្នកទើបតែបួសថ្មី មិនទាន់ដឹងច្បាស់នូវធម៌វិន័យដែលព្រះមានព្រះភាគទ្រង់សម្ដែងល្អហើយ នាំគ្នាចាប់ស្លាក បានទម្លាយសង្ឃ នាំភិក្ខុទាំងនោះទៅកាន់គយាសីសប្រទេស ។

## អគ្គសាវកទាំងពីរនាំភិក្ខុត្រឡប់ចូលកាន់ពួកបាន

ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់នូវការដែលព្រះទេវទត្តនោះទៅកាន់គយាសីសប្រទេសនោះហើយ ក៏ទ្រង់បញ្ជូនព្រះអគ្គសាវកទាំងពីរទៅ ដើម្បីប្រយោជន៍ដល់ការនាំភិក្ខុទាំងនោះមកវិញ ។ ព្រះអគ្គសាវកទាំងពីរនោះទៅកាន់ទីនោះហើយ ប្រៀនប្រដៅដោយអនុសាសនីផង ដោយអាទេសនាបាដិហារិយ៍ផង និងឥទ្ធិបាដិហារិយ៍ផង

ញ៉ាំងភិក្ខុទាំងនោះឲ្យផឹកអមតធម៌ហើយ បាននាំមកតាមផ្លូវអាកាស ។

ចំណែកព្រះកោកាលិកៈពោលថា "ម្នាលទេវទត្តដ៏មានអាយុ លោកចូរក្រោកឡើងចុះ, ព្រះសារីបុត្រ និងព្រះមោគ្គល្លានាំយកភិក្ខុទាំងនោះទៅអស់ហើយ ខ្ញុំបានប្រាប់លោកហើយថា "នែ៎ អាវុសោ លោកកុំទុកចិត្តព្រះសារីបុត្រ និងព្រះមោគ្គល្លានឲ្យសោះ (ព្រោះ) ព្រះសារីបុត្រ និងព្រះមោគ្គល្លានមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក" ដូច្នេះហើយ យកជង្គង់ប្រហារត្រង់ទ្រូង ( ព្រះទេវទត្ត ) ។ លោហិតដ៏ក្តៅខ្លាំងឡើងអំពី មាត់របស់ព្រះទេវទត្តទីនោះនុ៎ះឯង ។

ចំណែកពួកភិក្ខុឃើញព្រះសារីបុត្រ មានភិក្ខុសង្ឃចោមរោមហែហមមកតាមអាកាសហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ព្រះសារីបុត្រក្នុងកាលទៅមានបុគ្គលជាគំរប់ទី ២ ប៉ុណ្ណោះទៅជាមួយ, ឥឡូវនេះមានបរិវារច្រើនមកជាមួយ រមែងល្អពិត ៗ" ។

# បុព្វកម្មរបស់ព្រះទេវទត្ត

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងកាលដែលលោកកើតក្នុងកំណើតជាតិរច្ឆានបុត្ររបស់តថាគតមកកាន់សំណាក់របស់តថាគត ក៏រមែងល្អដូចគ្នាដែរ" ដូច្នេះហើយ បានត្រាស់ជាតកនេះថា ៖

"សេចក្តីចម្រើន តែងមានដល់ពួកអ្នកមានសីលទាំង-
ឡាយ អ្នកប្រព្រឹត្តបដិសណ្ឋារៈ នាងចូរមើលម្រឹគ
ឈ្មោះលក្ខណៈ កំពុងដើរមកដែលពួកញាតិហែហម
ហើយ នាងឃើញម្រឹគឈ្មោះកាឡនេះ ដែលសាប
សូន្យបាកពួកញាតិ កំពុងដើរមកឬទេ"[១] ។

ដូច្នេះជាដើម, កាលពួកភិក្ខុក្រាបទូលទៀតថា "បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះទេវទត្តឲ្យព្រះសាវកទាំងពីរអង្គគង់ក្នុងខាងទាំងពីរហើយ ពោលថា យើងនឹងសម្តែងធម៌ដោយពុទ្ធលីលា, ធ្វើ

---

[១] លក្ខណជាតក

អកប្បកិរិយាតាមព្រះអង្គហើយ” ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវប៉ុណ្ណោះទេ, សូម្បីកាលមុនទេវទត្តនេះ ក៏ព្យាយាមធ្វើតាមកិរិយារបស់តថាគតដែរ តែមិនអាច” ដូច្នេះហើយ ទ្រង់ត្រាស់នទីចរកាកជាតក[១] ថា ៖

នែ៎ ក្អែកទឹកឈ្មោះវីរកៈ អ្នកឃើញសត្វស្លាបដែលពោលពាក្យពីរោះ មានផ្នត់កដូចជាផ្នត់កនៃក្ងោក ជាក្អែកគោកឈ្មោះ សវិដ្ឋកៈ ជាប្តីរបស់ខ្ញុំដែរឬ ។

ក្អែកសវិដ្ឋកៈ ការធ្វើតាមសត្វស្លាប អ្នកត្រាច់ទៅក្នុងទឹកនិងលើគោក បានបរិភោគត្រីស្រស់ជានិច្ចនោះ ត្រូវសារាយពន្លពន្លស្លាប់ទៅហើយ ។

ដូច្នេះជាដើម ។ សូម្បីថ្ងៃដទៃៗទៀត ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់ប្រារព្ធកថាដូច្នេះដែរ ត្រាស់ជាតកទាំងឡាយជាដើមយ៉ាងនេះថា ៖

“ម្នាលសេះឈ្មោះ ខទិរវនិយៈដ៏ចម្រើនអំបែងក្បាលបែក

---

[១] វីរកជាតក

ដោយការប្រហារតែម្តង ពួដ៏ដើមឈើណា ដើមនេះមាន

ស្លឹកល្អិតប្រកបដោយបន្លា តើជាឈើឈ្មោះអ្វី”។

“ខួរក្បាលរបស់អ្នកធ្លាយចេញផង លលាដ៏ក្បាលរបស់

អ្នកបែកធ្លាយផង ឆ្អឹងជំនីរទាំងអស់របស់អ្នកដីរបំបាក់

ហើយផង ក្នុងថ្ងៃនេះ អ្នកនៅរុងរឿងអ្វីទៀត” ។

ទ្រង់ប្រារព្ធកថាថា “ព្រះទេវទត្តជាមនុស្សអកតញ្ញូ ទើបទ្រង់

ត្រាស់ជាតកទាំងឡាយមានជាអាទិទៀតថា ៖

“កម្លាំងរបស់យើងមានហើយ យើងធ្វើកិច្ចដល់អ្នកតាម

កម្លាំងនោះ បពិត្រមិគរាជ ខ្ញុំសូមក្រាបថ្វាយបង្គំអ្នក

យើងត្រូវបានសាច់បន្តិចបន្តួចខ្លះ” ។

អ្នកចូលទៅតាមចន្លោះនៃធ្មេញរបស់ខ្ញុំ ដែលជាអ្នកស៊ី

( សាច់ ) និងឈាម ធ្វើនូវអំពើអាក្រក់ទាំងឡាយជានិច្ច

រស់នៅដោយសាច់ណា សាច់នោះ មានច្រើន” ។

ទ្រង់ប្រារព្ធការព្យាយាមដើម្បីនឹងសម្លាប់ ( ព្រះអង្គ ) របស់

ព្រះទេវទត្តនោះទៀត ត្រាស់ជាតកទាំងឡាយមានជាអាទិថា ៖

"ម្នាលដើមចម្បក់ទាំងឡាយ អ្នកជម្រុះផ្លែមកដោយហេតុណា ហេតុនោះអញជាអ្នកប្រើបានដឹងហើយ អញនឹងទៅកាន់ដើមចម្បក់ឯទៀត ផ្លែរបស់អ្នកអញមិនពេញចិត្តទេ"[១] ។

កាលនៅប្រព្រឹត្តទៅទៀតថា "ព្រះទេវទត្តសាបសូន្យហើយចាកឈាន ២ ប្រការ គឺ ចាកលាភ និងសក្ការៈ ១ ប្រការ ចាកសាមញ្ញផល ១ ប្រការ" ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងកាលមុនទេវទត្តក៏សាបសូន្យហើយដែរ ។ ដូច្នេះហើយ ត្រាស់ជាតកទាំងឡាយជាដើមថា ៖

"ភ្នែកទាំងឡាយបែកធ្លាយហើយ សំពត់បាត់ហើយ ការឈ្លោះក៏មានក្នុងផ្ទះនៃស្ត្រីជាសម្លាញ់ ការងារទាំងឡាយខូចទាំងសងខាង គឺក្នុងទឹកផង លើគោកផង"[២] ។

---

[១] កុរុង្គមិគជាតក [២] ឧភតោភដ្ឋជាតក

ព្រះសាស្តា កាលគង់នៅក្នុងក្រុងរាជគ្រឹះ ទ្រង់ប្រារព្ធទេវទត្ត ត្រាស់ជាតកជាច្រើនដោយប្រការយ៉ាងនោះហើយ ស្តេចយាងចេញចាកក្រុងរាជគ្រឹះទៅកាន់ក្រុងសាវត្ថី ទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ។

## ព្រះទេវទត្តឲ្យសាវកនាំទៅគាល់ព្រះសាស្តា

ចំណែកព្រះទេវទត្តមានជម្ងឺអស់ ៩ ខែ, ក្នុងកាលជាចុងក្រោយប្រាថ្នានឹងគាល់ព្រះសាស្តា ទើបប្រាប់ពួកសាវករបស់ខ្លួនថា "យើងប្រាថ្នានឹងគាល់ព្រះសាស្តា អ្នកទាំងឡាយចូរសម្តែងព្រះសាស្តានោះដល់យើងចុះ" កាលសាវកទាំងនោះឆ្លើយថា ក្នុងកាលដែលលោកនៅជាអ្នកអាច បានប្រព្រឹត្តជាអ្នកមានពៀរនឹងព្រះសាស្តា, ខ្ញុំម្ចាស់ទាំងឡាយនឹងមិននាំលោកទៅកាន់សំណាក់ព្រះសាស្តាទេ" ទើបពោលថា "លោកទាំងឡាយកុំឲ្យយើងវិនាសឡើយ យើងបានចងអាឃាតក្នុងព្រះសាស្តាហើយមែន, ប៉ុន្តែថា ព្រះសាស្តាមិនចងគំនុំចំពោះយើងសូម្បីប្រមាណប៉ុនចុងសក់ទេ" ពិតណាស់ ព្រះមានព្រះភាគនោះ ៖

ទ្រង់មានព្រះទ័យដ៏ស្មើក្នុងបុគ្គលទូទៅ គឺក្នុងនាយខ្មាន់ធ្នូ ក្នុងព្រះទេវទត្ត ក្នុងចោរអង្គុលិមាល៍ ក្នុងដំរីធនបាល និងក្នុងព្រះរាហុល ។

ព្រោះដូច្នោះ ទើបព្រះទេវទត្តអង្វរហើយអង្វរទៀតថា "សូមលោកទាំងឡាយ ចូរសម្តែងព្រះមានព្រះភាគដល់យើង" ។ ពេលនោះ ទើបសាវកទាំងនោះនាំព្រះទេវទត្តនោះ ចេញទៅដោយគ្រែតូច ភិក្ខុទាំងឡាយ បានឮដំណឹងថា "ព្រះទេវទត្តមក ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន បានឮដំណឹងថា ព្រះទេវទត្តមកដើម្បីប្រយោជន៍នឹងគាល់ព្រះអង្គ" ។ ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទេវទត្តនោះនឹងមិនបានឃើញតថាគតដោយអត្តភាពនេះទេ" ។ បានឮថា ពួកភិក្ខុរមែងមិនបានឃើញព្រះពុទ្ធទៀត ចាប់ដើមពីកាលដែលខ្វនសូមវត្ថុ ៥ ប្រការ, សភាវៈនេះរមែងជាធម្មតា, ពួកភិក្ខុក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះទេវទត្តមកដល់ទីឯណោះ និងទីឯណោះហើយ" ។

ស. ទេវទត្តចូរធ្វើអំពើឯណាដែលខ្លួនប្រាថ្នាចុះ, ( តែយ៉ាងណាណាក៏ដោយ ) គេក៏នឹងមិនបានឃើញតថាគតឡើយ ។

ក. បពិត្រព្រះអង្គដ៏ចម្រើន ព្រះទេវទត្តមកដល់ទីប្រមាណ ១ យោជន៍អំពីទីនេះហើយ, ( ហើយទូលតៗទៅទៀតថា ) បពិត្រព្រះអង្គដ៏ចម្រើន នៅសល់កន្លះយោជន៍ទៀតមកដល់ហើយ, បពិត្រព្រះអង្គដ៏ចម្រើន នៅសល់មួយគាវុតទៀតមកដល់ហើយ, បពិត្រព្រះអង្គដ៏ចម្រើន មកដល់ទីជិតស្រះបោក្ខរណីក្បែរវត្តជេតពនហើយ ។

ស. សូម្បីទេវទត្តនឹងចូលមកខាងក្នុងនៃវត្តជេតពនសោត, គេក៏នឹងមិនបានឃើញតថាគតដែរ ។

## ព្រះទេវទត្តត្រូវធរណីស្រូប

ពួកសាវកនាំព្រះទេវទត្តមកហើយ ដាក់គ្រែចុះត្រង់ឆ្នេរស្រះបោក្ខរណីដែលនៅក្បែរវត្តជេតពនហើយ ក៏ចុះទៅដើម្បីនឹងងូតទឹកក្នុងស្រះបោក្ខរណី ។

សូម្បីព្រះទេវទត្ត ក៏ក្រោកឡើងអំពីគ្រែហើយអង្គុយដាក់ជើង

ទាំងពីរលើផែនដី ជើងទាំងពីរនោះក៏លិចចុះទៅក្នុងផែនដី លោកលិចចុះទៅក្នុងផែនដីហើយដោយលំដាប់ គឺត្រឹមកជើង, ត្រឹមជង្គង់, ត្រឹមចង្កេះ, ត្រឹមដោះ, រហូតដល់ត្រឹមក, ក្នុងពេលដែលចង្កាតាំងនៅលើផែនដី បានពោលគាថានេះថា ៖

ខ្ញុំព្រះអង្គសូមដល់ព្រះពុទ្ធអង្គនោះ ជាបុគ្គលដ៏ប្រសើរ ជាទេវតាកន្លងបង់នូវទេវតា ជាសារថី ជាអ្នកទូន្មាននូនរជន មានព្រះចក្ខុដោយជុំវិញ មានព្រះលក្ខណៈ (មួយៗ) កើតដោយបុណ្យទាំងរយជាជាទីពឹង ដោយឆ្អឹងទាំងនេះ ព្រមទាំងជីវិត ។

បានឮថា "ព្រះតថាគតទ្រង់ឃើញនូវហេតុនេះ ទើបអនុញ្ញាតឲ្យព្រះទេវទត្តបួស ។ ប្រសិនបើ ព្រះទេវទត្តនោះ នឹងមិនបានបួសសោត, នៅជាគ្រហស្ថវិញនឹងបានធ្វើកម្មធ្ងន់, នឹងមិនអាចធ្វើបច្ច័យនៃកពតទៅបាន, ក៏លុះបួសហើយនឹងធ្វើកម្មធ្ងន់ក៏ពិតមែនហើយ, ប៉ុន្តែក៏នឹងអាចដើម្បីធ្វើបច្ច័យនៃកពតទៅបាន" ព្រោះហេតុដូច្នោះ ព្រះសាស្តា

ក៏អនុញ្ញាតឲ្យលោកបួស ។

## ព្រះទេវទត្តកើតក្នុងអវីចិត្រូវក្តាងដោយលំពែងដែក

ពិតណាស់ ព្រះទេវទត្តនោះ នឹងបានជាព្រះបច្ចេកពុទ្ធ នាមថា អដ្ឋិស្សរៈ ក្នុងទីបំផុតមួយសែនកប្បរាប់ពីកប្បនេះទៅ ព្រះទេវទត្តនោះលិចចូលទៅក្នុងផែនដីហើយ កើតក្នុងអវីចិមហានរក ។ ហើយលោកជាអ្នកកម្រើកមិនបាន ត្រូវភ្លើងឆេះ ព្រោះជាអ្នកប្រទូស្តចំពោះព្រះពុទ្ធអ្នកមិនញាប់ញ័រ ។ សរីរៈរបស់លោកកំពស់ប្រមាណ ១០០ យោជន៍ កើតក្នុងអវីចិដែលមានទំហំប្រមាណ ៣០០ យោជន៍, ក្បាលស៊កចូលទៅកាន់ផែនដែកខាងលើរហូតដល់គុម្ពត្រចៀក, ជើងទាំងពីរលិចចុះទៅក្នុងផែនដីដែកខាងក្រោមរហូតដល់កជើង, លំពែងដែកមានប្រមាណ ប៉ុនដើមត្នោតខ្នាតធំ, ចេញអំពីជញ្ជាំងខាងក្រោយចាក់ត្រង់កណ្តាលខ្នង ធ្លុះចេញមកតាមទ្រូងកប់ទៅនឹងជញ្ជាំងខាងមុខ, លំពែងមួយទៀតចេញពីជញ្ជាំងខាងស្តាំ ចាក់ទំលាយទ្រូវចំហៀងខាងស្តាំ ធ្លុះចេញទៅខាងឆ្វេងចូលទៅកាន់ជញ្ជាំងខាងឆ្វេង ។ លំពែង

មួយទៀត ចេញអំពីក្បៀនខាងលើចាក់ទំលាយនូវក្បាល ចេញទៅតាមចំណែកខាងក្រោម កប់ចូលទៅកាន់ផែនដីជាវិការនៃដែក, ព្រះទេវទត្តនោះជាអ្នកកម្រើកមិនបាន ដែលភ្លើងឆេះក្នុងអវិចិនោះដោយប្រការយ៉ាងនេះ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា "ព្រះទេវទត្តមកកាន់ទីប្រមាណប៉ុណ្ណេះ មិនទាន់បានគាល់ព្រះសាស្តាផង ក៏លិចចុះទៅហើយ" ។ ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទេវទត្តប្រព្រឹត្តខុសចំពោះតថាគតហើយ លិចចុះទៅកាន់ផែនដីក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ សូម្បីក្នុងកាលមុន លោកក៏លិចចុះហើយផងដែរ" ដើម្បីនឹងទ្រង់សម្តែងនូវការៈនៃព្រះទេវទត្តនោះជាអ្នកវង្វេងផ្លូវ ដែលព្រះអង្គលួមលោមឲ្យជួរចិត្ត ហើយលើកឡើងដាក់លើខ្នងរបស់ព្រះអង្គហើយឲ្យដល់ទីក្សេម ហើយត្រឡប់មកកាត់ក្លកទាំងឡាយដល់ទៅ ៣ ដង យ៉ាងនេះ គឺខាងចុង កណ្តាល និងគល់ ក្នុងវារៈទី ៣ កាលឃានកន្ទងចក្ខុរបស់មហាបុរសហើយ ក៏លិចចូលទៅក្នុងផែនដី ក្នុងកាល

ដែលព្រះអង្គជាស្តេចដំរី ទើបត្រាស់ជាតក[1] នេះជាដើមថា ៖

ប្រសិនបើគេឲ្យផែនដីទាំងមូលដល់បុរសអកតញ្ញូ ជាអ្នកឃើញទោសជានិច្ច ក៏មិនគប្បីញុំាងបុរសអកតញ្ញូនោះឲ្យត្រេកអរបានឡើយ ។

កាលកថាតាំងឡើងហើយដូច្នោះទៀត ក៏ទ្រង់ត្រាស់ខន្តិវាទីជាតកដើម្បីទ្រង់សម្តែងដល់ការដែលព្រះទេវទត្តនោះ ជាព្រះបាទកលាពុ ប្រព្រឹត្តខុសចំពោះព្រះអង្គ ដែលជាខន្តិវាទីតាបស ហើយលិចចូលទៅកាន់ផែនដី និងចុល្លធម្មបាលជាតកដើម្បីទ្រង់សម្តែងការដែលទេវទត្តនោះ ជាព្រះបាទមហាបតាបៈ ប្រព្រឹត្តខុសចំពោះព្រះ-អង្គកាលដែលនៅជាធម្មបាល ហើយលិចចូលទៅកាន់ផែនដី លុះព្រះទេវទត្តលិចចូលទៅកាន់ផែនដីហើយ, មហាជនក៏រីករាយត្រេកអរញុំាងគ្នានិងគ្នាឲ្យលើកឡើងនូវទង់ជ័យ និងទង់បដាព្រមទាំងដើមចេកទាំងឡាយ តម្កល់ធ្នាំងទឹកដែលពេញហើយ លេងនូវមហោស្រពដ៏ធំ

---

[1] សីលវនាគជាតក

ដោយប្រារព្ធថា "ជាលាភរបស់ពួកយើងហើយហ្ន៎" ។ ពួកភិក្ខុក្រាបទូលសេចក្ដីនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កាលទេវទត្តស្លាប់ហើយ មហាជនរីករាយត្រេកអរមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងកាលមុនក៏រីករាយត្រេកអរហើយដែរ" ។ ដើម្បីនឹងទ្រង់សម្ដែងការដែលមហាជនជាអ្នកត្រេកអរ ក្នុងកាលដែលព្រះរាជាព្រះនាមថា បិង្គលៈ ក្នុងនគរពារាណសីដ៏កាចអាក្រក់ មិនជាទីស្រឡាញ់នៃជនទូទៅសោយទិវង្គតហើយ ទើបត្រាស់បិង្គលជាតកនេះជាដើមថា ៖

"ជនទាំងអស់ ត្រូវស្ដេចបិង្គលៈបៀតបៀនហើយ កាលស្ដេចនោះសោយទិវង្គតហើយ ជនទាំងឡាយ រមែងបាននូវសេចក្ដីត្រេកអរ ម្នាលទ្វារបាល ស្ដេចអកណ្ហនេត្រជាទីស្រឡាញ់របស់អ្នកឬ ព្រោះហេតុអ្វីបានជាអ្នកយំ ។

ទ្វារបាលបុរសពោលថា ៖

"ព្រះរាជា មានព្រះនេត្រមិនខ្មៅ មិនមែនជាទីស្រឡាញ់

របស់ខ្ញុំទេ ខ្ញុំខ្លាចស្តេចនោះត្រឡប់មកវិញ (ព្រោះស្តេចនោះ) ទៅអំពីមនុស្សលោកនេះ គប្បីបៀតបៀនទូវមច្ចុរាជ មច្ចុរាជនោះ ក្រែងត្រូវស្តេចបិណ្ឌលៈបៀតបៀនហើយ គប្បីនាំមកទុកក្នុងមនុស្សលោកនេះវិញ ។

## អ្នកធ្វើបាបរមែងក្តៅក្រហាយក្នុងលោកទាំងពីរ

ភិក្ខុទាំងឡាយ ទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចំរើនឥឡូវនេះ ព្រះទេវទត្តកើតនៅក្នុងទីណា ?" ព្រះសាស្តាទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទេវទត្តកើតក្នុងអវិចិមហានរក" ភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះទេវទត្តក្តៅក្រហាយក្នុងលោកនេះហើយ ទៅកើតក្នុងទីក្តៅក្រហាយដដែលទៀតឬ ?

ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះហើយ ក៏ជនទាំងឡាយ ទោះបីជាបព្វជិតក្តី ជាគ្រហស្ថក្តី មានប្រក្រតីរស់នៅដោយសេចក្តីប្រមាទ រមែងក្តៅក្រហាយក្នុងលោកទាំងពីរពិតប្រាកដណាស់" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖

១២ ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ
បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយ ក្នុងលោក
ទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយ
ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រាហាយ
ដោយគិតឃើញថា បាបអញបានធ្វើហើយ លុះមរណ
កាលទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា **ឥធ តប្បតិ** សេចក្តីថា រមែងក្តៅក្រហាយក្នុងលោកនេះ ដោយហេតុត្រឹមតែទោមនស្ស ដោយការក្តៅក្រហាយព្រោះកម្ម ។

បទថា **បេច្ច** សេចក្តីថា ក្នុងលោកខាងមុខ រមែងក្តៅក្រហាយព្រោះទុក្ខដ៏យ៉ាងក្រៃលែង ដោយការក្តៅក្រហាយព្រោះវិបាក ។

បទថា **បាបការី** សេចក្តីថា អ្នកធ្វើបាបមានប្រការផ្សេងៗ ។

បទថា **ឧភយត្ថ** សេចក្តីថា ឈ្មោះថា រមែងក្តៅក្រហាយក្នុងលោកទាំងពីរ ដោយការក្តៅក្រហាយមានប្រការដូចពោលមកហើយនេះ ។

ពីរបទថា **បាបំ មេ** សេចក្តីថា ក៏អ្នកមានប្រក្រតីធ្វើបាបនោះ កាលក្តៅក្រហាយ ដោយការក្តៅក្រហាយព្រោះកម្ម ឈ្មោះថា រមែងក្តៅក្រហាយ ដោយគិតថា "កម្មអាក្រក់យើងធ្វើហើយ" សេចក្តីក្តៅក្រហាយនោះមានប្រមាណតិចតួចទេ, តែកាលការក្តៅក្រហាយព្រោះវិបាក ទៅកាន់ទុគ្គតិហើយ រមែងក្តៅក្រហាយយ៉ាងក្រៃលែង គឺរមែងក្តៅក្រហាយដ៏លើសលប់ ដោយការក្តៅក្រហាយដ៏អាក្រក់ក្រៃលែង ។

ក្នុងកាលចប់គាថា ជនជាច្រើន បានជាព្រះអរិយបុគ្គល មានព្រះសោតបន្នជាដើម ទេសនាបានជាប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ។

( រឿងព្រះទេវទត្ត ចប់ )

# ១៣ រឿងនាងសុមនាទេវី

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងសុមនាទេវី ត្រាស់ព្រះធម្មទេសនានេះថា “**ឥធ នន្ទតិ បេច្ច នន្ទតិ**” ជាដើម ។

## អប់រំកូនចៅឲ្យទទួលនាទីរបស់ខ្លួន

សេចក្ដីពិស្ដារថា ភិក្ខុ ២ ពាន់អង្គ រមែងឆាន់ក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីក្នុងក្រុងសាវត្ថីរាល់ៗថ្ងៃ, ក្នុងផ្ទះរបស់នាងវិសាខាមហាឧបាសិកាក៏ដូច្នោះដែរ ។ ក៏បុគ្គលណាៗក្នុងក្រុងសាវត្ថីជាអ្នកប្រាថ្នាដើម្បីឲ្យនូវទាន, បុគ្គលនោះៗ លុះត្រាតែបានឱកាសអំពីលោកទាំង ២ នោះសិនហើយ ទើបធ្វើបាន ។

សួរថា “ព្រោះហេតុអ្វី” ?

ឆ្លើយថា “ព្រោះអ្នកដទៃៗ សួរថា “អនាថបិណ្ឌិកសេដ្ឋី ឬនាងវិសាខាមកកាន់រោងទានរបស់លោកហើយឬ” កាលម្ចាស់ទានឆ្លើយថា “មិនបានមកទេ” រមែងតិះដៀលសូម្បីនូវទានដែលគេលះបង់ទ្រព្យ

ទាំងសែនហើយធ្វើថា "ទានហ្នឹង ឈ្មោះថាជាទានអ្វី" ? ព្រោះលោកទាំង ២ នោះ រមែងដឹងនូវការពេញចិត្តរបស់ភិក្ខុ និងកិច្ចដ៏សមគួរដល់ភិក្ខុសង្ឃ កាលលោកទាំងពីរនោះនៅ ពួកភិក្ខុរមែងឆាន់នូវវត្ថុដ៏សមគួរដល់ចិត្តពិត ។

ព្រោះហេតុនោះ បុគ្គលទាំងឡាយណា ដែលជាអ្នកប្រាថ្នាដើម្បីថ្វាយទាន ក៏អញ្ជើញលោកទាំង ២ នោះទៅ លោកទាំង ២ នោះរមែងមិនបានដើម្បីអង្គាសភិក្ខុទាំងឡាយក្នុងផ្ទះរបស់ខ្លួនៗ ព្រោះហេតុដូច្នោះ នាងវិសាខាកាលពិចារណាមើលថា "នរណាហ្ន៎ នឹងតាំងនៅក្នុងតំណែងរបស់យើងដើម្បីនឹងអង្គាសភិក្ខុសង្ឃ" ? ឃើញធីតារបស់បុត្រហើយ ក៏តាំងទុកក្នុងតំណែងរបស់ខ្លួន ។ ធីតានោះតែងតែអង្គាសភិក្ខុសង្ឃក្នុងផ្ទះរបស់នាងវិសាខានោះ ។

សូម្បីអនាថបិណ្ឌិកសេដ្ឋី ក៏តាំងទុកនូវធីតាច្បង ឈ្មោះមហាសុភទ្ទា, ក៏នាងមហាសុភទ្ទានោះ ធ្វើការខ្វល់ខ្វាយបម្រើភិក្ខុទាំងឡាយ ( និង ) ស្តាប់ធម៌ ជាសោតាបន្នហើយ បានទៅកាន់ត្រកូលរបស់

ស្វាមី ។

ក្នុងពេលនោះ អនាថបិណ្ឌិកសេដ្ឋី ក៏តាំងនាងចុល្លសុភទ្ទា ( ជំនួស ) សូម្បីនាងចុល្លសុភទ្ទានោះក៏ធ្វើដូច្នោះដែរ ជាព្រះសោតាបន្ន ហើយក៏ទៅកាន់ត្រកូលនៃស្វាមី ។ លំដាប់នោះ អនាថបិណ្ឌិកសេដ្ឋី ក៏តាំងធីតាតូចបំផុត ឈ្មោះនាងសុមនាទេវី ( ជំនួស ) ។

## នាងសុមានាឈឺហៅបិតាថាប្អូនប្រុស

ក៏នាងសុមនាទេវីនោះ ស្តាប់ធម៌ហើយ បានសម្រេចសកទាគាមិផល នៅជាកុមារិការសាប់រសល់ដោយការមិនសប្បាយបែបនោះ កាត់បង់នូវអាហារ មានសេចក្តីប្រាថ្នានឹងឃើញបិតា ក៏ឲ្យគេអញ្ជើញបិតាមក អនាថបិណ្ឌិកសេដ្ឋីលុះបានឮពាក្យបណ្តាំរបស់ធីតាក្នុងរោងទានមួយក៏មករកហើយនិយាយថា “នៃ នាងសុមនាអ្វី” ? ធីតានោះពោលទៅកាន់បិតាថា “នៃ ប្អូនប្រុស” អ្វីទៅ ?

ប. នៃនាង នាងរវើរវាយឬ ?

ធ. ម្នាលប្អូនប្រុស ខ្ញុំមិនរវើរវាយទេ ។

ប. ម្នាលនាង នាងភ័យឬ ?

ធ. ម្នាលប្អូនប្រុស ខ្ញុំមិនភ័យទេ ។

គ្រាន់តែនាង សុមនាទេវី ពោលបានត្រឹមតែប៉ុណ្ណេះក៏បានធ្វើកាលកិរិយាទៅ ។

## លោកសេដ្ឋីជាបិតាយំទៅទូលព្រះសាស្តា

លោកសេដ្ឋីនោះ សូម្បីជាសោតាបន្ន ក៏មិនអាចអត់សង្កត់នូវសេចក្តីសោកដែលកើតឡើងហើយក្នុងធីតាបាន បញ្ជាឲ្យគេបូជាសរីរៈសាកសពរបស់ធីតាហើយ យំទៅកាន់សំណាក់ព្រះសាស្តា កាលព្រះអង្គទ្រង់ត្រាស់សួរថា "ម្នាលគហបតី ព្រោះហេតុដូចម្តេច ទើបអ្នកមានទុក្ខ ខូចចិត្ត មានមុខទទឹកជោគដោយទឹកភ្នែក ចូលមកកាន់សំណាក់តថាគត ក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន នាងសុមនាទេវីជាធីតារបស់ខ្ញុំព្រះអង្គ ធ្វើមរណកាលហើយ ។

ស. កាលបើដូច្នោះ ហេតុអ្វី ទើបអ្នកសោក, សេចក្តីស្លាប់រមែងប្រព្រឹត្តទៅដោយចំណែកមួយដល់សព្វសត្វមិនមែនឬ ?

អ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងនូវហេតុនោះហើយ ក៏ប៉ុន្តែ ធីតារបស់ខ្ញុំព្រះអង្គដល់ព្រមហើយដោយហរិ និងឱត្តប្បបែបនេះ, ក្នុងពេលជិតស្លាប់នាងមិនអាចរក្សាទុកនូវសតិបាន រវើរវាយស្លាប់ទៅហើយ ព្រោះហេតុនោះទោមនស្ស មានប្រមាណមិនតិចកើតឡើងដល់ខ្ញុំព្រះអង្គ ។

ស. ម្នាលមហាសេដ្ឋី ក៏នាងនិយាយពាក្យអ្វី ?

អ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គហៅនាងថា នែ នាងសុមនា មានបញ្ហាអ្វី ? លំដាប់នោះ នាងក៏ពោលនឹងខ្ញុំព្រះអង្គថាអ្វី ? ប្អូនប្រុស, ពេលនោះ កាលខ្ញុំព្រះអង្គពោលថា នែ៎ នាង នាងរវើរវាយឬ ? នាងក៏ឆ្លើយថា នែ៎ ប្អូនប្រុស ខ្ញុំមិនរវើរវាយទេ, កាលខ្ញុំព្រះអង្គសួរថា នែ៎ នាង នាងភ័យខ្លាចឬ ? នាងឆ្លើយថា នែ៎ ប្អូនប្រុស ខ្ញុំមិនមែនភ័យខ្លាចទេ គ្រាន់តែពោលបានប្រមាណប៉ុណ្ណោះក៏ធ្វើកាលកិរិយាទៅ ។

គ្រានោះ ព្រះមានព្រះភាគត្រាស់នឹងសេដ្ឋីនោះថា “ម្នាលសេដ្ឋី

ធីតារបស់អ្នកមិនរវើរវាយទេ ។

អនាថបិណ្ឌិកសេដ្ឋីក្រាបទូលសួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបនាងនិយាយយ៉ាងនោះ ?

ព្រះសាស្តាត្រាស់ថា ព្រោះអ្នកប្អូននាងពិត ៗ ( ទើបនាងនិយាយយ៉ាងនោះទៅកាន់អ្នក ) ម្នាលគហបតី ក៏ធីតារបស់អ្នកជាធំជាងអ្នកដោយមគ្គ និងផល ។ ព្រោះអ្នកត្រឹមតែជាសោតាបន្ន, ចំណែកធីតារបស់អ្នកជាសកទាគាមី, ព្រោះនាងជាធំដោយមគ្គ និងផល, ទើបនាងពោលយ៉ាងនោះទៅកាន់អ្នក ។

អ. បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនុ៎ះពិតមែនឬ ?

ស. ម្នាលគហបតី យ៉ាងហ្នឹងឯង ។

អ. បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ នាងកើតនៅទីណា ?

កាលព្រះសាស្តា ត្រាស់ថា "ម្នាលគហបតី ក្នុងកពតុសិត លោកសេដ្ឋីទើបក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ធីតារបស់ខ្ញុំព្រះអង្គបាននូវការរីករាយក្នុងកណ្តាលពួកញាតិក្នុងលោកនេះ សូម្បី

ទៅអំពីលោកនេះ ក៏កើតក្នុងទីជាទីរីករាយឬ" ?

## អ្នកធ្វើបុណ្យរមែងរីករាយក្នុងលោកទាំងពីរ

គ្រានោះ ព្រះសាស្តាត្រាស់នឹងសេដ្ឋីនោះថា "ម្នាលគហបតី យ៉ាងនោះឯង" ធម្មតាអ្នកមិនប្រមាទ ទោះបីជាគ្រហស្ថក្តី ជាបព្វជិតក្តី រមែងរីករាយក្នុងលោកនេះផង ក្នុងលោកខាងមុខផងដោយពិត ។ ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

**១៣ ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ**
**បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ ។**

បុគ្គលអ្នកធ្វើបុណ្យ រមែងត្រេកអរ ក្នុងលោកទាំងពីរ គឺត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះរមែងត្រេកអរដោយឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់សុគតិ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ឥធ** សេចក្ដីថា រមែងរីករាយក្នុងលោកនេះ ដោយការរីករាយព្រោះកម្ម ។

បទថា **បេច្ច** សេចក្ដីថា រមែងរីករាយក្នុងលោកខាងមុខ ដោយការរីករាយព្រោះវិបាក ។

បទថា **កតបុញ្ញោ** គឺ អ្នកធ្វើបុណ្យមានប្រការផ្សេងៗ ។

បទថា **ឧភយត្ថ** សេចក្ដីថា រមែងរីករាយក្នុងលោកនេះ ដោយគិតថា "កុសលយើងបានធ្វើទុកហើយ, បាបយើងមិនបានធ្វើ" កាលសោយវិបាក ឈ្មោះថា រមែងរីករាយក្នុងលោកខាងមុខ ។

ពីរបទថា **បុញ្ញំ មេ** សេចក្ដីថា ក៏កាលរីករាយក្នុងលោកនេះ ឈ្មោះថា រមែងរីករាយអាស្រ័យការរីករាយព្រោះកម្ម ព្រោះហេតុត្រឹមតែសោមនស្សប៉ុណ្ណោះថា "យើងធ្វើបុណ្យទុកហើយ" ។

បទថា **ភិយ្យោ** ជាដើម សេចក្ដីថា ក៏គេទៅកាន់សុគតិហើយ កាលសោយទិព្វសម្បត្តិរហូតអស់៥៧កោដិឆ្នាំខ្ទះ៦០សែន

ឆ្នាំខ្លះ រមែងរីករាយយ៉ាងក្រៃលែងក្នុងតុសិតបុរី ដោយការរីករាយព្រោះវិបាក ។

ក្នុងកាលចប់គាថា ជនជាច្រើន បានជាអរិយបុគ្គល មានសោតាបន្ន ជាដើម ។ ព្រះធម្មទេសនា បានជាប្រយោជន៍ដល់មហាជនដូច្នេះឯង ។

( រឿងសុមនាទេវី ចប់ )

# ១៤ រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីររូប

## សេចក្តីខាងដើម

ព្រះសាស្តា កាលព្រះអង្គទ្រង់គង់នៅវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុដែលជាសម្លាញ់នឹងគ្នាពីររូប ត្រាស់ព្រះធម្មទេសនានេះថា "**ពហុម្បិ เប សហិតំ ភាសមានោ**" ដូច្នេះ ជាដើម ។

## <u>សម្លាញ់ពីរនាក់ចេញបួស</u>

សេចក្តីពិស្តារថា កុលបុត្តពីរនាក់, អ្នកក្រុងសាវត្ថីជាសម្លាញ់នឹងគ្នា ទៅកាន់វិហារស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាហើយ លះបង់កាមទាំងឡាយ ថ្វាយជីវិតចំពោះព្រះសាសនារបស់ព្រះសាស្តា បួសហើយនៅក្នុងសំណាក់អាចារ្យ និងព្រះឧបជ្ឈាយ៍អស់ ៥ វស្សា ហើយចូលទៅគាល់ព្រះសាស្តា ទូលសួរដល់ធុរៈក្នុងព្រះសាសនា បានស្តាប់វិបស្សនាធុរៈ និងគន្ថធុរៈដោយពិស្តារហើយ មួយអង្គក្រាបទូលមុនថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបួសហើយក្នុងកាលនៃខ្លួនជាមនុស្សចាស់ មិនអាចនឹងបំពេញគន្ថធុរៈបាន, តែណ្ហើយចុះខ្ញុំព្រះអង្គនឹងបំពេញវិបស្សនាធុរៈឲ្យពេញ" ដូច្នេះហើយ ញ៉ាំងព្រះ-

សាស្ដាឲ្យត្រាស់ប្រាប់វិបស្សនារហូតដល់ព្រះអរហត្ត, ព្យាយាមបំពេញវិបស្សនាក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។

ចំណែកភិក្ខុក្រៅនេះ គិតថា "យើងនឹងបំពេញគន្ថធុរៈ" ដូច្នេះហើយ រៀនព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកដោយលំដាប់ សម្ដែងធម៌សូត្រសរភញ្ញក្នុងទីដែលខ្លួនទៅហើយៗ ។ បង្រៀនធម៌ដល់ភិក្ខុ ៥០០ រូប បានជាអាចារ្យនៃគណៈធំៗ ១៨ គណៈ ។

ភិក្ខុទាំងឡាយ រៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះសាស្ដាហើយ ទៅកាន់លំនៅរបស់ព្រះថេរៈក្រៅនេះ (ភិក្ខុបំពេញវិបស្សនា) តាំងនៅក្នុងឱវាទរបស់លោកក៏បានសម្រេចព្រះអរហត្ត ហើយថ្វាយបង្គំព្រះថេរៈ ប្រាប់ថា "ខ្ញុំព្រះករុណាទាំងឡាយប្រាថ្នានឹងគាល់ព្រះ-សាស្ដា" ។

ព្រះថេរៈពោលថា "អាវុសោទាំងឡាយ ទៅចុះ, លោកទាំងឡាយចូរថ្វាយបង្គំព្រះសាស្ដា ថ្វាយបង្គំព្រះមហាថេរៈទាំង ៨០ អង្គតាមពាក្យរបស់ខ្ញុំករុណា, ចូរប្រាប់ព្រះថេរៈដែលជាសម្លាញ់របស់ខ្ញុំ

ផងថា "អាចារ្យរបស់យើងខ្ញុំទាំងឡាយសូមថ្វាយបង្គំលោក" ដូច្នេះហើយបញ្ជូនទៅ ។ ភិក្ខុទាំងនោះទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្ដា និងព្រះមហាថេរៈទាំង ៨០ អង្គហើយ ទៅកាន់សំណាក់ព្រះគន្ថិកត្ថេរ ប្រាប់ថា "បពិត្រលោកម្ចាស់ អាចារ្យរបស់យើងខ្ញុំទាំងឡាយសូមថ្វាយបង្គំលោកម្ចាស់" ក៏កាលព្រះគន្ថិកត្ថេរសួរថា "អាចារ្យរបស់ពួកអ្នកនោះជានរណា" ភិក្ខុទាំងនោះប្រាប់ថា "ជាសម្លាញ់របស់លោកម្ចាស់" ។

កាលព្រះថេរៈ ( វិបស្សកភិក្ខុ ) បញ្ជូនបណ្ដាំទៅសួរសុខទុក្ខយ៉ាងនេះរឿយៗ, ព្រះគន្ថិកភិក្ខុអត់សង្កត់អស់កាលបន្ដិចបន្តួច ខាងក្រោយមកមិនអាចនឹងអត់សង្កត់បាន, កាលពួកអាគន្តុកៈប្រាប់ថា "អាចារ្យរបស់ពួកយើងខ្ញុំសូមថ្វាយបង្គំលោកម្ចាស់" ដូច្នេះហើយ ក៏ពោលថា "អាចារ្យរបស់ពួកលោកជានរណា" កាលភិក្ខុទាំងឡាយប្រាប់ថា "ជាសម្លាញ់របស់លោកម្ចាស់" ទើបពោលថា "ក៏អ្វីខ្លះទៅដែលពួកលោករៀនក្នុងសំណាក់របស់ភិក្ខុនោះ បណ្ដានិកាយ មាន

ទីឃនិកាយជាដើម និកាយណាមួយឬ ឬបណ្ដាបិដក ៣ បិដកណាមួយឬ ដែលពួកអ្នកបានហើយ ?, ដូច្នេះហើយ គិតថា សម្លាញ់របស់យើង រមែងមិនដឹងគាថាសូម្បីប្រកបដោយបទ ៤, កាន់យកសំពត់ចូលព្រៃ បួសក្នុងកាលដែលខ្លួនជាមនុស្សចាស់ បានអន្ដេវាសិកច្រើនដល់ម៉្លេះ, ក្នុងកាលដែលលោកមកយើងគួរសួរបញ្ហាសាកមើល ។

## ព្រះថេរៈទាំងពីរជួបគ្នា

ក្នុងសម័យថ្ងៃមួយ ព្រះថេរៈ (វិបស្សកៈ) បានមកគាល់ព្រះសាស្ដា ទុកដាក់បាត្រចីវរក្នុងសំណាក់ព្រះថេរៈដែលជាសំឡាញ់ហើយ ទៅថ្វាយបង្គំព្រះសាស្ដា និងព្រះអសីតិមហាថេរៈ រួចក៏ត្រឡប់មកសំណាក់ព្រះថេរៈដែលជាសំឡាញ់វិញ ។ ខណៈនោះ ព្រះគន្ថិកត្ថេរឲ្យភិក្ខុទាំងឡាយធ្វើវត្តដល់ព្រះវិបស្សកៈហើយ កាន់យកអាសនៈស្មើគ្នាអង្គុយហើយ ដោយតាំងចិត្តថា "នឹងសួរបញ្ហា" ។

## ព្រះសាស្ដាសួរបញ្ហាព្រះថេរៈទាំងពីររូប

ខណៈនោះ ព្រះសាស្ដាទ្រង់ជ្រាបថា "គន្ថិកភិក្ខុនេះបៀតបៀន

នូវបុត្ររបស់តថាគត ដែលជាអ្នកមានសភាពបែបនេះហើយ កើតក្នុងនរក” ដោយទ្រង់អនុគ្រោះចំពោះព្រះគន្ថកភិក្ខុ ធ្វើហាក់ដូចជាស្ដេចយាងទៅកាន់វិហារ យាងទៅដល់លំនៅនៃព្រះថេរៈទាំង ២ គង់ហើយ ទ្រង់គង់លើពុទ្ធាសនៈដែលព្រះថេរៈក្រាលទុកហើយ ពិតណាស់ ភិក្ខុទាំងឡាយកាលនឹងគង់ក្នុងទីនោះ ៗ ក្រាលអាសនៈសម្រាប់ព្រះពុទ្ធស្រេចហើយទើបអង្គុយ ។ ព្រោះហេតុនោះ ទើបព្រះសាស្ដាគង់លើអាសនៈដែលព្រះគន្ថកភិក្ខុនោះក្រាលទុក ដោយប្រក្រតីនោះឯង ។ លុះទ្រង់គង់ហើយ ក៏ត្រាស់សួរបញ្ហាក្នុង បឋមជ្ឈានចំពោះគន្ថកភិក្ខុ កាលលោកឆ្លើយមិនបាន, ក៏ត្រាស់សួរបញ្ហាក្នុងរូបសមាបត្តិ និងអរូបសមាបត្តិទាំង ៨ តាំងពីទុតិយជ្ឈានជាដើមទៅ ព្រះគន្ថិកត្ថេរក៏មិនអាចឆ្លើយបានសូម្បីមួយបញ្ហា ។ ព្រះវិបស្សកភិក្ខុ ឆ្លើយបញ្ហានោះបានទាំងអស់ ។

គ្រានោះ ព្រះសាស្ដាត្រាស់សួរបញ្ហាក្នុងសោតាបត្តិមគ្គចំពោះព្រះគន្ថិកត្ថេរ ។ ព្រះគន្ថិកភិក្ខុក៏មិនអាចឆ្លើយបាន ។ ពេលនោះ ក៏

ទ្រង់ត្រាស់សួរបញ្ហាចំពោះព្រះខីណាសវត្ថេរ ។ ព្រះថេរៈក៏ឆ្លើយបាន ។

## ព្រះវិបស្សកភិក្ខុបានទទួលសាធុកា

ព្រះសាស្តា ទ្រង់អនុមោទនាថា "សាធុ សាធុ" ហើយត្រាស់សួរបញ្ហាសូម្បីក្នុងមគ្គដ៏សេសទាំងឡាយដោយលំដាប់ ។ ព្រះគន្ថិកត្ថេរក៏មិនអាចឆ្លើយបានសូម្បីត្រឹមតែមួយបញ្ហា ។ ចំណែកព្រះខីណាសវៈឆ្លើយបញ្ហាដែលព្រះសាស្តាទ្រង់ត្រាស់សួរហើយៗ បាន ។ ព្រះសាស្តា បានប្រទានសាធុកាដល់ព្រះខីណាស្រពនោះ ក្នុងឋានៈទាំង ៤ ។ ទេវតាទាំងអស់តាំងអំពីភុម្មទេវតា ដរាបដល់ព្រហ្មលោក និងនាគ គ្រុឌបានស្តាប់សាធុកានោះហើយ ក៏បានឲ្យសាធុការដែរ ពួកអន្តេវាសិក និងសទ្ធិវិហារិករបស់គន្ថិកភិក្ខុ បានស្តាប់សាធុកានោះហើយ ក៏លើកទោសចំពោះព្រះសាស្តាថា "ព្រះសាស្តាទ្រង់ធ្វើកម្មអ្វីហ្នឹង" ? ព្រះអង្គបានប្រទានសាធុការដល់ព្រះមហល្លកត្ថេរ ( ព្រះថេរៈកញ្ចាស់ ) អ្នកមិនដឹងនូវអ្វីៗ ក្នុងឋានៈទាំង ៤, ចំណែកលោកអាចារ្យរបស់យើង អ្នកទ្រទ្រង់ព្រះបរិយត្តិធម៌ទុកបានទាំងអស់ ជា

ប្រធានភិក្ខុប្រមាណ ៥០០ អង្គ ព្រះអង្គមិនបានទ្រង់ធ្វើសួម្បីត្រឹមតែការសរសើរ" ។

## និយាយច្រើនតែមិនបដិបត្តិក៏ឥតប្រយោជន៍

គ្រានោះ ព្រះសាស្តា ត្រាស់សួរភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយពោលនូវពាក្យអ្វីហ្នឹង"? កាលភិក្ខុទាំងនោះក្រាបទូលសេចក្តីនោះហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អាចារ្យរបស់ពួកអ្នកទាំងឡាយ ដូចអ្នករក្សាគោទាំងឡាយដើម្បីថ្លៃឈ្នួលក្នុងសាសនារបស់តថាគត, ចំណែកបុត្ររបស់តថាគត ដូចជនជាម្ចាស់អ្នកបរិភោគនូវបញ្ចគោរសតាមសេចក្តីគាប់ចិត្ត" ដូច្នេះហើយ បានភាសិតព្រះគាថាទាំងនេះថា ៖

១៤ ពហុម្បិ ចេ សហិតំ ភាសមានោ
ន តក្ករោ ហោតិ នរោ បមត្តោ
គោបោវ គាវោ គណយំ បរេសំ
ន ភាគវា សាមញ្ញស្ស ហោតិ ។

អប្បម្បិ ចេ សហិតំ ភាសមានោ
ធម្មស្ស ហោតិ អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ
សម្មប្បជានោ សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា
ស ភាគវា សាមញ្ញស្ស ហោតិ ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍សូម្បីច្រើន តែជាអ្នកប្រមាទមិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដទៃហើយ ( ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស ) ដូចច្នោះឯង ។ បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ និងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ

មានចិត្តដកផុតអំពីសេចក្តីសៅហ្មង មិនមានសេចក្តី
ប្រកាន់មាំ ក្នុងលោកនេះ និងលោកខាងមុខ នរជននោះ
រមែងជាអ្នកបានចំណែកសាមញ្ញផល ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សហិតំ** នេះជាឈ្មោះនៃព្រះពុទ្ធ-វចនៈ គឺព្រះត្រៃបិដក, នរជនចូលទៅរកអាចារ្យទាំងឡាយ រៀនយកនូវព្រះពុទ្ធវចនៈនោះហើយ ពោល គឺប្រាប់ បានដល់ការសម្តែងនូវព្រះពុទ្ធវចនៈសូម្បីច្រើនដល់ជនពួកដទៃ (តែ) មិនជាអ្នកធ្វើកិច្ចដែលការកបុគ្គលស្តាប់ធម៌នោះហើយនឹងគប្បីធ្វើទេ, គឺមិនញុំាងការធ្វើទុកក្នុងចិត្តដោយប្រពៃឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម សូម្បីអស់កាលត្រឹមតែកិរិយាទទះស្លាបនៃមាន់, នរជននោះរមែងជាអ្នកមានចំណែកនៃផល ត្រឹមតែការធ្វើវត្តបដិវត្តន៍អំពីសំណាក់នៃអន្តេវាសិកទាំងឡាយតែប៉ុណ្ណោះ ប៉ុន្តែមិនជាអ្នកមានចំណែកនៃសាមញ្ញផលឡើយ ដូចបុគ្គលអ្នករក្សាគោទាំង-

ឡាយដើម្បីថ្ងៃឈ្នួលប្រចាំថ្ងៃ ទទួលយកគោអំពីព្រលឹម វេលាសៀលរាប់គោប្រគល់ឲ្យដល់ម្ចាស់គោទាំងឡាយហើយ ទទួលយកតែថ្ងៃឈ្នួលប្រចាំថ្ងៃប៉ុណ្ណោះ, ប៉ុន្តែមិនបានដើម្បីបរិភោគនូវបញ្ចគោរសតាមសេចក្តីគាប់ចិត្តឡើយ ដូច្នេះឯង ។

ដូចយ៉ាងថា ជនជាម្ចាស់គោមួយពួក រមែងបរិភោគនូវបញ្ចគោរសទាំងឡាយដែលនាយគោបាលប្រគល់ឲ្យហើយ យ៉ាងណាមិញ, ការកបុគ្គលទាំងឡាយស្តាប់ធម៌ដែលនរជននោះសម្តែងហើយ បដិបត្តិតាមដែលនរជននោះប្រៀនប្រដៅហើយ ក៏ដូច្នោះដែរ, ពួកខ្លះបានសម្រេចបឋមជ្ឈានជាដើម, ពួកខ្លះចម្រើនវិបស្សនាហើយ បានសម្រេចមគ្គ និងផល, ចាត់ថាជាអ្នកមានចំណែកនៃសាមញ្ញផល ដូចជនជាម្ចាស់គោរមែងជាអ្នកមានចំណែកនៃគោរសដូច្នោះ, ព្រះសាស្តាត្រាស់គាថាទី ១ ដោយអំណាចនៃភិក្ខុអ្នកសំបូណ៌ដោយសីល អ្នកមានសុត្តៈច្រើន ( តែ ) មានប្រក្រតីនៅដោយសេចក្តីប្រមាទ មិនមានយោនិសោមនសិការ គឺការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ដោយ

អំណាចនៃត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ។ មិនបានត្រាស់ដោយអំណាចនៃភិក្ខុអ្នកទ្រុស្តសីលទេ ដោយប្រការដូច្នេះ ។

ចំណែកគាថាទី ២ ព្រះអង្គទ្រង់ត្រាស់សម្តែងដោយអំណាចនៃការកបុគ្គលអ្នកមានសុត្តៈតិច ( តែ ) ធ្វើទុវកម្មដោយយោនិសោមនសិការ ។

ក្នុងបទទាំងនោះ បទថា **អប្បម្បិ ចេ** សេចក្តីថា តិចតួចគឺសូម្បី ត្រឹមតែ ១ វគ្គ ឬ ២ វគ្គ ។

បាទព្រះគាថាថា **ធម្មស្ស ហោតិ អនុធម្មចារី** ជាដើម សេចក្តីថា នរជនដឹងអត្ថដឹងធម៌ហើយ ប្រព្រឹត្តធម៌ដ៏សមគួរដល់លោកុត្តរធម៌ ៩ គឺប្រភេទនៃធម៌ មានបរិសុទ្ធិសីល ៤ ធុតង្គគុណ និងអសុភកម្មដ្ឋានជាដើម ដែលបណ្ឌិតរាប់ថា បដិបទាជាចំណែកខាងដើម រមែងឈ្មោះថា ជាអ្នកមានប្រក្រតីប្រព្រឹត្តនូវធម៌ដ៏សមគួរ គឺប្រាថ្នាការចាក់ធ្លុះថា "យើងនឹងចាក់ធ្លុះក្នុងថ្ងៃនេះ យើងនឹងចាក់ធ្លុះក្នុងថ្ងៃនេះ" ឈ្មោះថា រមែងប្រព្រឹត្តធម៌សមគួរដល់ធម៌ ។ នរជននោះ

រមែងលះបង់រាគៈ ទោសៈ និងមោហៈដោយបដិបទាដ៏ប្រពៃនេះហើយ កំណត់ដឹងធម៌ដែលគួរកំណត់ដឹងដោយប្រពៃ គឺដោយហេតុ ដោយន័យ មានចិត្តរួចផុតស្រឡះហើយដោយអំណាចនៃតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ ។ អស់ការប្រកាន់មាំក្នុងលោកនេះ និងលោកដទៃ គឺមិនចូលទៅប្រកាន់ខន្ធ អាយតនៈ និងធាតុទាំងឡាយ ដែលរាប់ថាលោកនេះ និងលោកដទៃ ឬដែលជាខាងក្នុង និងខាងក្រៅដោយឧបាទាន ៤ ឈ្មោះថា ជាមហាខីណាស្រព រមែងជាអ្នកមានចំណែកនៃសាមញ្ញផល ដែលមកហើយដោយអំណាចនៃសាមញ្ញគុណ ពោល គឺមគ្គ និងជាកងនៃអសិកធម៌ ៥[១] ។

ព្រះសាស្តាទ្រង់រួបរួមកំពូលនៃធម្មទេសនា ដោយព្រះអរហត្តដូច មេជាងកាន់យកកំពូលនៃផ្ទះ ដោយកំពូលកែវដូច្នោះ ។

---

(១) សីលក្ខន្ធ គុណគឺសីល ១ សមាធិក្ខន្ធ គុណគឺសមាធិ ១ បញ្ញាក្ខន្ធ គុណគឺបញ្ញា ១ វិមុត្តិក្ខន្ធ គុណគឺវិមុត្តិ ១ វិមុត្តិញាណទស្សនក្ខន្ធ គុណគឺវិមុត្តិញាណទស្សនៈ ១ ។

ក្នុងកាលចប់គាថា មនុស្សជាច្រើនបានជាអរិយបុគ្គល មាន សោតាបន្នជាដើម ។ ទេសនាមានប្រយោជន៍ដល់មហាជនដូច្នេះឯង ។

( រឿងភិក្ខុជាសំឡាញ់ ២ រូប ចប់ )

**យមកវគ្គវណ្ណនា និដ្ឋិតំ**

**យមកវគ្គទី ២ ចប់**